សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ 2011

# លីអាហូណា




## អំណោយនៃសេចក្ដីសុខសាន្ត និង អំណាររបស់ព្រះអង្គសង្គ្រោះ ទំព័រ 18

ចេញពីអ័ព្ទមករកពន្លឺរបស់ទ្រង់ ទំព័រ 42

របៀបដែលទីហ្វៃបានជួយឪពុកខ្ញុំ និង ខ្ញុំ ទំព័រ 56

ការចងចាំអំពីបុណ្យគ្រីស្ទម៉ាសរបស់ស៊ីស្ទើរ អុជដូហ្វ ទំព័រ 66



កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ ដោយ ហ្វីលីស ឡូច

*យើងរៀននៅក្នុងម៉ាថាយ 2:9–11ថាពួកហោរ៉ាបានថ្វាយដង្វាយដល់ព្រះយេស៊ូវគ្រីស្ទកាលទ្រង់នៅជាបុត្រតូច ហើយពួកគេត្រូវបានដឹកនាំដោយផ្កាយថ្មីដែលបានលេចចេញមកចំពេលកំណើតរបស់ទ្រង់។*

*«ផ្កាយដែល [ពួកហោរ] បានឃើញពីទិសខាងកើតនោះក៏នាំមុខគេ ដរាបដល់ចំពីលើកន្លែងដែលបុត្រតូចនៅទើបឈប់។*

*«គេមានសេចក្ដីអំណរជាខ្លាំងក្រៃដោយបានឃើញផ្កាយនោះ។*

*«ហើយក៏ចូលទៅក្នុងផ្ទះ ឃើញបុត្រតូចនៅជាមួយនឹងម៉ារាជាមាតា រួចក៏ក្រាបថ្វាយបង្គំព្រមទាំងបើកយកទ្រព្យដ៏វិសេសរបស់ខ្លួនថ្វាយដង្វាយជាមាស ជាកំញាន ជាជ័រល្វីងទេសដល់បុត្រនោះ»។*

## សារលិខិត


**4** **សារលិខិតគណៈប្រធានទីមួយ ៖ ការជ្រើសរើសដើម្បីមានការដឹងគុណ**
ដោយប្រធាន ហែនរី ប៊ី អាវរីង

**7** **សារលិខិតសួរសុខទុក្ខ ៖ ទង្វើមួយដ៏ប្រកបដោយវិសាលភាព**


## អត្ថបទពិសេសៗ


**18** **សេចក្ដីសុខសាន្ត និងសេចក្ដីអំណរមកពីការដឹងពីជីវិតរបស់ព្រះអង្គសង្គ្រោះ**
ដោយ អែលឌើរ រ័សុល អិម ណិលសុន
*ព្រះរាជបុត្រាដ៏ទេវភាពនៃព្រះដ៏មានព្រះជន្មរស់នឹងស្រឡាញ់អ្នក លើកអ្នកឡើង និងបង្ហាញអង្គទ្រង់ដល់អ្នកប្រសិនបើអ្នកស្រឡាញ់ទ្រង់ គោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់។*

**24** **វិធីទៅកាន់ព្រះវិហារបរិសុទ្ធ**
ដោយ ឆេឌ អ៊ី ហ្វាវេស
*ថ្វីត្បិតតែពួកគេដើរតាមផ្លូវផ្សេងគ្នាក្ដី ក៏ពួកបរិសុទ្ធនៅក្នុងប្រទេសអ៊ុយក្រែន កំពុងតែស្វែងរកគ្រប់ផ្លូវដែលសុចរិតទាំងអស់ ដែលនាំទៅរកព្រះវិហារបរិសុទ្ធ។*

**28** **គន្លឹះនាំទៅរកឱកាស ៖ ការប្រារព្ធពិធីលើកទី 10 នៃកម្មវិធីមូលនិធិអប់រំដែលមានជាបន្តបន្ទាប់**
ដោយ រីប៊ីកា អាតឃីន
*បានប្រកាសនៅក្នុងឆ្នាំ 2001 ថា មូលនិធិអប់រំជាបន្តបន្ទាប់ បានប្រទានពរដល់ជីវិតសមាជិកសាសនាចក្ររាប់ពាន់នាក់។*

**34** **បាត់ ហើយរកឃើញវិញ**
ដោយ អ័ដាម ស៊ី អូសុន
*របៀបដែលគូស្វាមីភរិយាមួយគូ បានភ្ជាប់ការសម្រេចចិត្តប្រចាំថ្ងៃទៅនឹងទិដ្ឋភាពនៃជោគវាសនាដ៏អស់កល្បជានិច្ចរបស់ពួកគេ។*


## ផ្នែកទាំងឡាយ


**8** **កិច្ចការតូចតាច និងងាយ**

**11** **គេហដ្ឋាន និងក្រុមគ្រួសាររបស់យើង ពុំមានភ្លេងប៉ុន្ដែពោរពេញដោយភាពសប្បាយរីករាយ**
ដោយ ចាទាល ប៊ី ហ្វ្រីមែន


**លើគម្រប**
ខាងមុខ ៖ រូបថតដែលបានថតនៅក្នុងឈុត *សញ្ញានៃហ្វូងចៀមមួយ និង អ្នកគង្វាលមួយ* ។
ខាងក្រោយ ៖ *ការមកដល់របស់អ្នកគង្វាល* ដោយ ហែនរី លឺរ៉ូល ច្បាប់ដើមនៅក្នុងគំនូរ ម៉ូអ៊ី ដេ ប៊ឺអូ ខាកាសូនី ប្រទេសបារាំង ប្រើដោយមានការអនុមតិ ហាមថតចម្លង ។


**12** **ការបម្រើក្នុងសាសនាចក្រ ការបម្រើរបស់ខ្ញុំក្នុងនាមជាសមាជិកតែម្នាក់ឯង**
ដោយ ជូលី ប៊ើរឌែតទ៍

**14** **យើងនិយាយអំពីព្រះគ្រីស្ទ ចម្លើយចំពោះរាល់សំនួរ «តើអ្វីនឹងកើតឡើងប្រសិនបើ?»**
ដោយ ម៉ៃខល ឌី រូចប៊ើរី

**16** **ដំណឹងល្អពីបុរាណ មេរៀនមកពីលោកចៅហ្វាយ**
ដោយអែលឌើរ ម៉ាវីន ជេ អាស្តុន

**38** **សម្លេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**74** **ព័ត៌មានអំពីសាសនាចក្រ**

**79** **គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ**

**80** **លុះត្រាជួបទៀតពន្លឺនៃព្រះរាជបុត្រា**
ដោយ ជែហ្វ អេស ម៉ាក់អិនតុស




*ព្រះវិហារបរិសុទ្ធ គីអ៊ីវ អ៊ុយក្រែន* 24

## មជ្ឈិមវ័យវ័យក្មេង





42 **ពួកគេបាននិយាយមកកាន់យើង ចូរយើងនាំគ្នាចូលមកថ្វាយបង្គំទ្រង់**
ដោយអែលឌើរ ផាទ្រិក ខេរ៉ុន




*ចាំមើលថាតើអ្នកអាចរកឃើញរូបលីអាហូណា ដែលលាក់នៅក្នុងលេខនេះបានដែរឬទេ។ តម្រុយ ៖ អំណោយមួយនៅក្រោមដើមឈើ។*




## យុវវ័យ


46 **សំណួរ និងចម្លើយ**
*តើខ្ញុំអាចរក្សាអាកប្បកិរិយាវិជ្ជមានអំពីអនាគតបានយ៉ាងដូចម្ដេច?*

48 **ប័ណ្ណប្រកាស**
**អ្នកពុំមែនរស់នៅម្នាក់ឯងនោះទេ**

49 **របៀបដែលខ្ញុំដឹង**
**ព្រះអម្ចាស់បានចាក់ស្រោចពរជ័យ**
ដោយ គីម គង់

50 **សាក្សីដ៏ខ្ជាប់ខ្ជួន**
ដោយអែលឌើរ ខាល បី ប្រាត្ត
*តើការសន្យារបស់មូរ៉ូណៃអនុវត្តចំពោះអ្នកដែរឬទេ?*

52 **ហើយនេះជាទីសម្គាល់ដល់អ្នករាល់គ្នា**
ដោយ វីតនី ហ៊ីងគ្លី
*ការព្យាករណ៍អំពីកំណើតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានបំពេញប្រកបដោយអព្ភូតហេតុដោយរបៀបណា។*

55 **អំណោយប្រកបដោយការចេះគិតគូរ**
*អត្ថន័យពីខាងក្រោយមាស ផាកំញាណ និងជ័រល្វីងទេស ដែលបានថ្វាយដល់ព្រះគ្រីស្ទកុមារ។*

56 ***ពួកគេគួរតែផ្លាស់ប្ដូរ***
ដោយ ហ្វ្រែនស៊ីស្កូ ហាវីអ៊ែរ ឡារាហ៊ីណាន់ដែស
*ខ្ញុំគឺជាសមាជិកតែម្នាក់គត់នៅក្នុងគ្រួសាររបស់ខ្ញុំដែលបានទទួលយកដំណឹងល្អ។ ឥឡូវខ្ញុំត្រូវតែស្វែងរកវិធី ដើម្បីឆ្លើយតប នៅពេលដែលជីវិតរស់នៅរបស់ពួកគាត់ មិនសមស្របគ្នានឹងគោលការណ៍នៃដំណឹងល្អ។*

58 **ជួបបងប្រុសយ៉ូសែប**
*នេះគឺជារឿងមួយចំនួនតូចផ្សេងទៀត ដែលអ្នកប្រហែលជានឹងពុំបានដឹងអំពីព្យាការីយ៉ូសែប។*


## កុមារ





59 **សាក្សីពិសេស**
**តើខ្ញុំអាចធ្វើតាមព្រះអង្គសង្គ្រោះបានយ៉ាងដូចម្ដេច?**
ដោយអែលឌើរ ឃ្វីនធិន អិល យុក

60 ***ពាក្យទាំងនោះ***
ដោយ អាន់ជី ប៊ើរស្ត្រុម មីលលើរ
*តើហ្សេលប៊ីអាចធ្វើអ្វីខ្លះ នៅពេលនាងបានស្ដាប់ឮមិត្តរបស់នាងដែរ?*

62 **ទំព័ររបស់យើង**

63 **ខិតប័ណ្ណព្រះវិហារបរិសុទ្ធ**

64 **ការបង្រៀនមេរៀនថ្នាក់កុមារក្នុងលំនៅដ្ឋាន ព្រះគម្ពីរទាំងឡាយ បង្រៀនខ្ញុំអំពីការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ និងការយាងមកជាលើកទីពីររបស់ទ្រង់**
ដោយ ជែនទីហ្វើ ម៉ាឌី

66 **ដើមបុណ្យគ្រីស្ទម៉ាស**
ដោយ ហែរីត អរ អុជដូហ្វ
*ការចងចាំអំពីបុណ្យគ្រីស្ទម៉ាស់ពីកុមារភាពរបស់ខ្ញុំនៅក្នុងប្រទេសអាល្លឺម៉ង់។*

68 **មូលនិធិបេសកកម្មរបស់ខ្ញុំ**
ដោយ ស្ពែនស៊ើ អេស.
*អ្នកអាចចាប់ផ្ដើមការសន្សំប្រាក់សម្រាប់បេសកកម្មរបស់អ្នកនៅថ្ងៃនេះ។*

69 **មាត្រានៃសេចក្ដីជំនឿ**
*ជំនឿដ៏សំខាន់ទាំងដប់បីរបស់យើង។*

70 **សម្រាប់កុមារតូចៗ**

**ខែ ធ្នូ ឆ្នាំ 2011 វ៉ុល 11 លេខទី 6**
**លីអាហូណា 09692 258**

ទស្សនាវដ្តីអន្តរជាតិជាផ្លូវការនៃសាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយៈ** ថូម៉ាស អេស ម៉នសុន, ហិនរី ប៊ី អាវរិង, ឌៀថើរ អេស្វ អុជដូហ្វ

**ក្រុមនៃពួកសាវក 12 នាក់ៈ** បិយដ៍ ឃេ ផាកកឺ, អិល ថម ភែរី, រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម រ័សុល បាឡឺដ, រីឆាដ ជេ ស្កុត, របឺត ឌី ហេ៊ល, ជែហ្វ្រី អរ៍ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិលឃុក, ឌី ថត គ្រីស្វហ្វឺសិន, និង នែល អិល អាន់ឌើរសិន

**អ្នកបោះពុម្ពផ្សាយៈ** ផល ប៊ី ភីបភ័រ
**អ្នកណែនាំៈ** ស្ទេនលី ជី អឺលលីស, គ្រីស្វហ្វឺល ហ្គោលដិន ជុញ៉រ យ៉ូស៊ីហ្វីកូ គីគូកឃី

**នាយកផ្នែកចាត់ការៈ** ដេវីត អិល ហ្វ្រីចទីច
**អគ្គនាយកផ្នែកបោះពុម្ពផ្សាយៈ** វិនសិន អេ វ៉ន
**នាយកផ្នែកក្រាភិចៈ** អាល់លែន អ័រ ឡយប៊ិត

**អ្នកចាត់ការបោះពុម្ពផ្សាយៈ** អ័រ វ៉ាល ចនសុន
**ជំនួយការអ្នកចាត់ការបោះពុម្ពផ្សាយៈ** ជេនីហ្វ៊ អែល គ្រីនវូឌ, អ័ដាម សេ អូសុន
**សហការីអ្នកបោះពុម្ពផ្សាយៈ** រ៉ាយអិន ខា
**ជំនួយការអ្នកបោះពុម្ពផ្សាយៈ** សូសាន បារីត
**បុគ្គលិកបោះពុម្ពផ្សាយៈ** Brittany Beattie, ដេវីឌ អេ អេឌវីឌ, ម៉ាថាយ ឌី ហ្វលីតុន, ឡារីន ផ័ទី ហ្គូន, ឡារី ហ្សេលលី, ការី កាស្ទីន, ជេនទីហ្វ៊ ម៉ាឌី, លៃ ម៉ាក់ឡាណាហាន, ម៉ែលីស្សា ម៉ើរីល, ម៉ៃគល អ័រ ម៉ូរីស, សាលី ជេ អូឌីគីត, យ៉ូស្វេ ជេ ភើកឃី, ជេឌ អឺ ហ្វាស, ជេន ភីនប្ឫហ្វ, រីឆាត អិម រ៉មនី, ដូន អិល សៀ, ជេនីត ថូម៉ាស, ផល វេឌីបេវហ្គិ, ជូលី វីដែលលេខាធិការជាន់ខ្ពស់, ឡូវែល ធូស្ទើរ, ម៉ារីស្សា អេ វីតឌីសុន, ម៉ាលីស្សា ហ្សេនទីណូ

**នាយកចាត់ចែងផ្នែកសិល្បៈ** ជេ ស្កុត នូតសុិន
**នាយកផ្នែកសិល្បៈ** ស្កុត វេន ឃេមផេន
**អ្នកគ្រប់គ្រងផលិតកម្មៈ** ជេន អាន ផេតធី
**អ្នករៀបចំប្លង់ជាន់ខ្ពស់ៈ** ស៊ី គីមបល ប៊ុត, ថូម៉ាស អេស ឆាល, ឃូលលីន ឃីងហ្គឺរ, អ៊ិច ភី ចនសិន, ស្កុត អឹម ម៉ោយ
**បុគ្គលផលិតកម្មៈ** ខាលី អរ អារូយ៉ូ, ឃូលីតទី ណាបាឃីរ អុណឺ, ហាវ៉ូដ ជី ប្រោន, ជូលី បិរដីទ, វីហ្គីណោល ជេ គ្រីស៊ីនសិន, គីម ហ្វីនស្ទរមេឃើរ, កាតលីន ហាវ៉ូដ, ឌីនទីស ឃីរប៊ី, ជីនទី ជេ ណីលសិន
**អ្នកបោះពុម្ពៈ** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ពៈ** គ្រីជ ឃេ ស៊ីជរីគន
**នាយកផ្នែកការចែកចាយៈ** អ៊ីវ៉ានឡាស៊ិន

**សំរាប់ជំនាវ និងតម្លៃខាងក្រៅសហរដ្ឋអាមេរិក និងកាណាដា សូមទាក់ទងមជ្ឈមណ្ឌលចែកចាយនៃសាសនាចក្រក្នុងមូលដ្ឋាន ឬអ្នកដឹកនាំវួដ ឬសាខា។ ផ្ញើការបោះពុម្ព ឬសំណួរទាំងឡាយតាមអ៊ិនធើរណិត liahona.lds.org, តាម *Liahona*, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA។**

*លីអាហូណា* (ព្រះគម្ពីរមរមនមានន័យថា «ត្រីវិស័យ» ឬ «វត្ថុនាំផ្លូវ») ត្រូវបាន បោះពុម្ពជាភាសា អាល់ប៊េនី, អាមេនី, ប៊ីស្លាម្បេ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហៃទី, ហិនឌី, ហុងហ្គារី, អាយឡែនឌិច, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាកាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, ណរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស៊ីនហាឡា, ស្លូវ៉ានី, អេស្ប៉ាញ, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, តាមីល, តេលូហ្គូ, ថៃ, តុងហ្គា, អ៊ុយក្រែន អ៊ើឌូ និងវៀតណាម។ (ភាពញឹកញាប់ប្រែប្រួលតាមភាសា)។

© 2011 ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅក្នុងសហរដ្ឋអាមេរិក។

អត្ថបទ និងរូបភាពផ្សេងៗនៅក្នុងទស្សនាវដ្តី លីអាហូណា អាចថតចម្លងបាន ដើម្បីប្រើប្រាស់នៅតាមគេហដ្ឋាន មិននៅក្នុងសាសនាចក្រ តែមិនមែនសំរាប់ធ្វើអាជីវកម្ម។ រូបភាពមួយចំនួនមិនអាចថតចម្លងបានទេ ចំពោះរូបភាពមួយចំនួនដែលត្រូវបានហាមឃាត់។ បើមានសំណួរ លោកអ្នកអាចទាក់ទងជាមួយ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org.

**For Readers in the United States and Canada:**
December 2011 Vol. 11 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address *must* be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (Visa, MasterCard, American Express) may be taken by phone. (Canada Poste Information: Publication Agreement #40017431)

POSTMASTER: Send address changes to Salt Lake Distribution Center, Church Magazines, PO Box 26368, Salt Lake City, UT 84126-0368.

# រឿងជាច្រើនទៀតនៅលើអ៊ិនធើរណែត

Liahona.lds.org







## ជាភាសារបស់អ្នក

*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសា សូមចូលទៅកាន់ www.languages.lds.org។

### សម្រាប់មជ្ឈឹមវ័យ

**មូលនិធិដែលមានជាបន្តបន្ទាប់** ត្រូវបានរីកចម្រើនឡើងចាប់តាំងពីប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានប្រកាសកាលពី 10 ឆ្នាំមុន (សូមមើល ទំព័រ 28)។ ដើម្បីដឹងពីរឿងរ៉ាវជោគជ័យច្រើនទៀត រៀនពីរបៀបដើម្បីទទួលបានប្រាក់កម្ចី ភី.អ៊ី.អេហ្វ ឬបរិច្ចាគមូលនិធិ សូមចូលទៅកាន pef.lds.org។

### សម្រាប់យុវវ័យ

សូមអានពីរបៀបដែលព្រះវិហារបរិសុទ្ធ គីអ៊ីវ អ៊ុយក្រែន បានពង្រឹងដល់ក្រុមគ្រួសារទាំងឡាយ (សូមមើល ទំព័រ24) និងមើលពីរបៀបដែលការប្រារព្ធកម្មវិធីវប្បធម៌របស់**យុវវ័យ**ដែលបានធ្វើឡើងពីមុនព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងបានពង្រឹងដល់ទីបន្ទាល់របស់ពួកក្មេងជំទង់ដែលបានចូលរួម។ សូមមើលវីដេអូដែលពោរពេញដោយការបំផុសគំនិតនៅ youth.lds.org (សូមស្រាវជ្រាវរកមើលពាក្យថា “Kyiv Ukraine Temple”)។

### សម្រាប់កុមារតូចៗ

សូមរីករាយជាមួយនឹងរឿងបុណ្យគ្រីស្ទម៉ាស់នៅទំព័រ 64, 66, និង 70។ បន្ទាប់មក**សូមមើលវីដេអូអំពីបុណ្យគ្រីស្ទម៉ាស់លើកដំបូង**ដោយផ្អែកទៅលើលូកា 2។ សូមចូលទៅកាន់ lds.org/new-testament-videos។

## ប្រធានបទនៅក្នុងទស្សនាវដ្ដីច្បាប់នេះ

*លេខតំណាងឱ្យទំព័រទីមួយនៃអត្ថបទ។*

*ការធ្វើឱ្យសកម្មឡើងវិញ 34*
*ដង្វាយធួន 4, 14*
*អាកប្បកិរិយា 46*
*ពរជ័យទាំងឡាយ 4*
*ការហៅ 12*
*បុណ្យគ្រីស្ទម៉ាស់ 4, 9, 12, 18, 38, 39, 40, 41, 42, 52, 55, 66, 70, 72, 73*
*ប្រវត្តិសាស្ត្រសាសនាចក្រ 8*
*ការផ្លាស់ប្រែចិត្តជឿ 49, 50, 56*
*ការអប់រំ 28*
*គំរូ 7, 11, 60*
*សេចក្តីជំនឿ 69*
*គ្រួសារ 11, 34, 56*
*ការដឹងគុណ 4*
*ការព្យាបាល 14*
*ព្រះវិញ្ញាណបរិសុទ្ធ 50*
*សេចក្តីសង្ឃឹម 42, 46*
*ព្រះយេស៊ូវគ្រីស្ទ 4, 14, 16, 18, 42, 48, 52, 55, 59, 64, 70, 80*
*កិច្ចការផ្សព្វផ្សាយសាសនា 39, 49, 50, 56, 68*
*តន្ត្រី 11*
*មូលនិធិដែលមានជាបន្តបន្ទាប់ 28*
*ពួកព្យាការី 52, 58*
*សមាគមសង្គ្រោះ 7*
*ការប្រែចិត្ត 24, 34, 42*
*ការបម្រើ 28, 38, 39, 40, 41, 68*
*យ៉ូសែប ស៊្មីធ 58*
*ឡូរែនសូ ស្ណូ 10*
*ស៊័ន្ទរកថា 60*
*បទដ្ឋាន 60*
*ការបង្រៀន 11, 16*
*កិច្ចការព្រះវិហារបរិសុទ្ធ 24, 63*
*ទីបន្ទាល់ 50*

**ដោយប្រធាន**
**ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ



# ការជ្រើសរើសដើម្បីមាន ការដឹងគុណ

ព្រះវរបិតារបស់យើងដែលគង់នៅឯស្ថានសួគ៌ បញ្ជាយើងឱ្យអរព្រះគុណក្នុងគ្រប់ការណ៍ទាំងអស់ (សូមមើល ថែស្សាឡូនីចទី1 5:18)ហើយទ្រង់តម្រូវឱ្យយើងផ្តល់នូវការដឹងគុណសម្រាប់រាល់ពរជ័យទាំងឡាយដែលយើងទទួល (សូមមើល គ. និង.ស 46:32)។ យើងដឹងថារាល់ព្រះបញ្ញត្តិទាំងអស់របស់ទ្រង់ គឺមានបំណងធ្វើឱ្យយើងសប្បាយរីករាយ ហើយយើងក៏ដឹងផងដែរថា ការពុំគោរពតាមព្រះបញ្ញត្តិនាំទៅរកទុក្ខវេទនា។

ដូច្នេះដើម្បីមានសេចក្តីរីករាយ និងចៀសផុតពីទុក្ខវេទនា យើងត្រូវតែមានដួងចិត្តដែលពោរពេញទៅដោយអំណរគុណ។ យើងបានឃើញនៅក្នុងជីវិតរបស់យើងពីទំនាក់ទំនងរវាងការដឹងគុណ និងសុភមង្គល។ យើងទាំងអស់គ្នាចង់មាននូវអារម្មណ៍ដឹងគុណ ប៉ុន្តែវាពុំមែនជាការងាយស្រួលទេដើម្បីមាននូវអំណរគុណដ៏ខ្ជាប់ខ្ជួននៅក្នុងគ្រប់កិច្ចការទាំងអស់នៅក្នុងការសាកល្បងនៃជីវិត។ ជម្ងឺ ការបាក់ទឹកចិត្ត និងការបាត់បង់មនុស្សដែលយើងស្រឡាញ់កើតឡើងនៅក្នុងជីវិតរបស់យើង។ ទុក្ខព្រួយទាំងឡាយរបស់យើងអាចធ្វើឱ្យពិបាកក្នុងការមើលឃើញពីពរជ័យទាំងឡាយរបស់យើង ហើយមាននូវអំណរគុណចំពោះពរជ័យទាំងឡាយដែលព្រះរៀបចំសម្រាប់យើងនាពេលអនាគត។

វាគឺជាឧបសគ្គមួយដើម្បីរាប់ពរជ័យទាំងឡាយរបស់យើងដោយសារយើងមានទំនោរចង់បានអ្វីដែលល្អដោយពុំសូវឱ្យតម្លៃ។ នៅពេលដែលយើងបាត់បង់ជំរុកជ្រកកោន គ្មានអាហារទទួលទាន ឬគ្មានភាពកក់ក្តៅពីមិត្តភ័ក្តិ និងក្រុមគ្រួសារ នោះទើបយើងភ្ញាក់ខ្លួនថា យើងគួរតែមានការដឹងគុណខណៈពេលដែលយើងមានអ្វីទាំងអស់នោះ។

អ្វីដែលសំខាន់បំផុត មានពេលខ្លះវាពិបាកសម្រាប់យើងក្នុងការមាននូវអំណរគុណគ្រប់គ្រាន់ចំពោះអំណោយដ៏អស្ចារ្យបំផុតដែលយើងទទួលដូចជា ៖ កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ ដង្វាយធួនរបស់ទ្រង់ ការសន្យាពីការរស់ឡើងវិញ ឱកាសដើម្បីរីករាយនឹងជីវិតដ៏នៅអស់កល្បជានិច្ចជាមួយនឹងក្រុមគ្រួសាររបស់យើង ការស្តារឡើងវិញនៃដំណឹងល្អព្រមជាមួយនិងបព្វជិតភាព និងកូនសោរបស់វា។ មានតែតាមរយៈជំនួយពីព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះដែលអាចធ្វើឱ្យយើងចាប់ផ្តើមគិតពីអត្ថន័យនៃពរជ័យទាំងនោះចំពោះយើង និងចំពោះអ្នកទាំងឡាយដែលយើងស្រឡាញ់។ មានតែតាមរយៈការណ៍ទាំងនោះទេដែលអាចធ្វើឱ្យយើងសង្ឃឹមដើម្បីមានអំណរគុណក្នុងគ្រប់កិច្ចការទាំងអស់ និងចៀសផុតពីការមិនសព្វព្រះហឫទ័យពីព្រះដោយការពុំចេះដឹងគុណ។

យើងត្រូវតែអធិស្ឋានសុំដល់ព្រះថា ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នឹងជួយយើងឱ្យឃើញនូវពរជ័យទាំងឡាយយ៉ាងច្បាស់ទោះបីជាស្ថិតនៅក្នុងការសាកល្បងរបស់យើងក៏ដោយ។ ទ្រង់អាចជួយយើងបានតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណឱ្យស្គាល់ និងមាននូវអំណរគុណចំពោះពរជ័យទាំងឡាយដែលយើងយកដោយពុំសូវឱ្យតម្លៃ។ អ្វីដែលបានជួយខ្ញុំខ្លាំងបំផុតគឺទូលសុំដល់ព្រះក្នុងការអធិស្ឋាន «សូមព្រះអង្គដឹកនាំទូលបង្គំទៅរកនរណាម្នាក់ដែលទូលបង្គំអាចជួយដល់ទ្រង់បាន?» វាគឺជាការជួយដល់ព្រះប្រទានពរដល់អ្នកដទៃទើបធ្វើឱ្យខ្ញុំបានឃើញពរជ័យទាំងឡាយផ្ទាល់ខ្លួនរបស់ខ្ញុំបានច្បាស់ជាង។

ពេលមួយការអធិស្ឋានរបស់ខ្ញុំត្រូវបានឆ្លើយតប នៅពេលដែលមានស្វាមីភរិយាមួយគូរដែលខ្ញុំពុំដែលស្គាល់ពីមុនបានអញ្ជើញខ្ញុំទៅកាន់មន្ទីរពេទ្យ។ នៅទីនោះខ្ញុំបានឃើញទារិកាដ៏តូចមួយដែលល្មមនឹងដៃរបស់ខ្ញុំ។ ទារិកាតូចនោះបានឆ្លងកាត់ការវះកាត់ជាច្រើនដង នៅក្នុងអាយុតែពីរបីសប្តាហ៍ប៉ុណ្ណោះ។ ពួកវេជ្ជបណ្ឌិតបានប្រាប់ដល់ឪពុកម្តាយថា នៅមានការវះកាត់បេះដូង និងសួតពិបាកៗផ្សេងទៀតដើម្បីជួយជីវិតទារកតូចនោះរបស់ព្រះ។

ខ្ញុំបានផ្តល់ពរជ័យបព្វជិតភាពដល់ទារិកានោះ តាមសំណើសុំរបស់ឪពុកម្តាយ។ ក្នុងពរជ័យនោះរួមមានទាំងការសន្យាពីការពន្យារជីវិត។ លើសពីការផ្តល់នូវពរជ័យ ខ្ញុំបានទទួលពរជ័យសម្រាប់ខ្លួនខ្ញុំផ្ទាល់គឺដួងចិត្តកាន់តែពោរពេញទៅដោយអំណរគុណ។

ដោយមានជំនួយពីព្រះវរបិតារបស់យើង យើងទាំងអស់គ្នាអាចជ្រើសរើសដើម្បីទទួលអារម្មណ៍ដឹងគុណកាន់តែខ្លាំងជាង។ យើងអាចទូលសុំដល់ទ្រង់ឱ្យជួយយើងមើលឃើញពរជ័យទាំងឡាយរបស់យើងកាន់តែច្បាស់ ទោះបីជាយើងស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ ចំពោះខ្ញុំថ្ងៃនោះ ខ្ញុំបានមាននូវសេចក្តីអំណរដែលខ្ញុំពុំធ្លាប់មានពីមុនមក ជាអព្ភូតហេតុនៃបេះដូង និងសួតរបស់ខ្ញុំផ្ទាល់កំពុងធ្វើចលនា។ នៅតាមផ្លូវត្រឡប់មកផ្ទះវិញ ខ្ញុំបានថ្លែងអំណរគុណចំពោះពរជ័យទាំងឡាយដល់កូនៗរបស់ខ្ញុំដែលខ្ញុំអាចមើលឃើញយ៉ាងច្បាស់ថាជាអព្ភូតហេតុនៃសេចក្តីមេត្តាករុណាមកពីព្រះ និងពីមនុស្សល្អដែលនៅជុំវិញពួកគេ។

អ្វីដែលអស្ចារ្យបំផុត ខ្ញុំបានទទួលអារម្មណ៍ដឹងគុណចំពោះភស្តុតាងនៃដង្វាយធួន



*ព្រះដែលជាព្រះវរបិតាបានប្រទានដល់យើងនូវព្រះរាជបុត្រារបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទប្រទានដល់យើងនូវដង្វាយធួន ដែលជាអំណោយទានដ៏មហិមាបំផុតលើអំណោយទានទាំងអស់ ព្រមទាំងការប្រទានឱ្យទាំងអស់។*

ដែលកំពុងជួយនៅក្នុងជីវិតរបស់ឪពុកម្ដាយទាំងឡាយដែលខ្វល់ខ្វាយ និងក្នុងជីវិតខ្ញុំ។ ខ្ញុំបានឃើញសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធរបស់ព្រះគ្រីស្ទកំពុងរះនៅលើផ្ទៃមុខរបស់ពួកគេ សូម្បីតែកំពុងតែស្ថិតនៅក្នុងការសាកល្បងដ៏ជូរចត់របស់ពួកគេក៏ដោយ។ ហើយខ្ញុំបានទទួលអារម្មណ៍ជាក់ស្ដែងថាអ្នកក៏អាចទទួលបានដែរប្រសិនបើអ្នកទូលសុំដល់ព្រះឱ្យបើកសម្ដែងដល់អ្នកថាដង្វាយធួនអាចអនុញ្ញាតឱ្យអ្នកទទួលនូវអារម្មណ៍នៃសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់បាន។

យើងទាំងអស់គ្នាអាចធ្វើការជ្រើសរើសដើម្បីថ្លែងអំណរគុណនៅក្នុងការអធិស្ឋាន និងទូលសុំដល់ព្រះ ឱ្យដឹកនាំទៅរកការបម្រើដល់អ្នកដទៃជំនួសទ្រង់—ជាពិសេសក្នុងអំឡុងពេលនេះនៃឆ្នាំជាពេលដែលយើងប្រារព្ធកំណើតរបស់ព្រះអង្គសង្គ្រោះ។ ព្រះដែលជាព្រះវរបិតាបានប្រទានដល់យើងនូវព្រះរាជបុត្រារបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទបានប្រទានដល់យើងនូវដង្វាយធួន ដែលជាអំណោយទានដ៏មហិមាបំផុតលើអំណោយទានទាំងអស់ ព្រមទាំងការប្រទានឱ្យទាំងអស់ (សូមមើលគ. និង. ស14:7)។

ការថ្លែងអំណរគុណនៅក្នុងការអធិស្ឋានអាចអនុញ្ញាតឱ្យយើងមើលឃើញពីទំហំនៃពរជ័យទាំងនេះ និងពរជ័យដទៃទៀតទាំងអស់របស់យើង ហើយការធ្វើដូច្នោះនឹងទទួលបាននូវដួងចិត្តដែលពោរពេញដោយអំណរគុណច្រើនជាង។ ■

### ការបង្រៀនដកស្រង់ចេញពីសាលិខិតនេះ

ការកត់ត្រាទុកពរជ័យ និងបទពិសោធន៍ទាំងឡាយរបស់យើង អាចជួយយើងឱ្យចងចាំពីវា និងផ្ដល់ឱ្យយើងនូវអ្វីមួយដែលទាក់ទងទៅនឹងការណ៍ទាំងនោះ។ ចូរពិចារណាពីការសុំឱ្យអ្នកទាំងឡាយដែលអ្នកបង្រៀនឱ្យសរសេរនូវអ្វីដែលពួកគេមានអំណរគុណចំពោះ—ដើម្បីជួយពួកគេឱ្យចងចាំពីពរជ័យទាំងឡាយដែលពួកគេបានទទួល ឱ្យដឹងពីពរជ័យទាំងឡាយនាពេលបច្ចុប្បន្ន និងសម្លឹងឆ្ពោះទៅមុខសម្រាប់ពរជ័យទាំងឡាយនាពេលអនាគត។

អ្នកក៏អាចលើកទឹកចិត្តអ្នកទាំងឡាយដែលអ្នកបង្រៀនឱ្យធ្វើតាមគំរូរបស់ប្រធាន អាវរិងនៅក្នុងការទូលសុំដល់ព្រះវរបិតាសួគ៌ឱ្យដឹកនាំពួកគេទៅកាន់នរណាម្នាក់ដែលពួកគេអាចជួយ ឬបម្រើបាន។

## យុវវ័យ

# ចូរទទួលសេចក្តីល្បងដោយដឹងគុណ

ដោយចន ហ៊ីលថុន ទី III និងអាថូរី ស្ម៊ីត

ចូរកុំគ្រាន់តែនិយាយពីការរាប់ពរជ័យទាំងឡាយរបស់យើង—ចូរធ្វើវា! សូមសរសេរតារាងអំពីកិច្ចការ 100 ចំណុចដែលអ្នកមានអំណរគុណចំពោះ។ ប្រសិនបើវាហាក់ដូចជាច្រើនពេក សូមសាកល្បងតាមរបៀបនេះ ៖

1. សូមសរសេរ 10 ចំណុចអំពីសមត្ថភាពខាងរាងកាយដែលអ្នកមានអំណរគុណចំពោះ។
2. សូមសរសេរ10 ចំណុចអំពីសម្ភារផ្ទាល់ខ្លួនដែលអ្នកមានអំណរគុណចំពោះ។
3. សូមសរសេរពីមនុស្សដែលនៅរស់ចំនួន 10នាក់ដែលអ្នកមានអំណរចំពោះ។
4. សូមសរសេរអំពីមនុស្សស្លាប់ចំនួន 10នាក់ដែលអ្នកមានអំណរគុណចំពោះ។
5. សូមសរសេរ10 ចំណុចអំពីធម្មជាតិដែលអ្នកមានអំណរគុណចំពោះ។
6. សូមសរសេរ10 ចំណុចអំពីថ្ងៃនេះដែលអ្នកមានអំណរចំពោះ។
7. សូមសរសេរអំពីទីកន្លែងចំនួន 10ដែលអ្នកមានអំណរចំពោះ។
8. សូមសរសេរអំពីការច្នៃប្រឌិតទាសម័យទំនើបចំនួន 10ដែលអ្នកមានអំណរចំពោះ។
9. សូមសរសេរអំពីម្ហូបអាហារចំនួន 10មុខដែលអ្នកមានអំណរគុណចំពោះ។
10. សូមសរសេរ10 ចំណុចអំពីដំណឹងល្អដែលអ្នកមានអំណរចំពោះ។

កាលណាយើងធ្វើបញ្ជីមួយដូចនេះឡើង យើងរកឃើញថាបញ្ជីដែលមានកិច្ចការ 100 ចំណុចគឺគ្រាន់តែជាការចាប់ផ្តើមនៃកិច្ចការគ្រប់យ៉ាងដែលព្រះបានប្រទានដល់យើងតែប៉ុណ្ណោះ។

## កុមារ

# សូមជួយខ្ញុំឱ្យមើលឃើញពរជ័យទាំងឡាយរបស់ខ្ញុំ

ហ្វិលីពកំពុងតែទូលសុំព្រះវរបិតាសួគ៌ឱ្យជួយគាត់មើលឃើញពរជ័យទាំងឡាយនៅក្នុងជីវិតរបស់គាត់។ សូមជួយដល់គាត់ឱ្យរកឃើញពរជ័យទាំងឡាយដែលគាត់អាចមានអំណរគុណចំពោះដោយការគូសរង្វង់លើពរជ័យទាំងនោះ។ ចូរប្រាកដថាអ្នកពុំភ្លេចវត្ថុទាំងនេះដែលបានលាក់នៅក្នុងរូបភាពនេះ ៖ ផ្ទះ, ចេក, ផ្កែ, ព្រះវិហារ, សាលារៀន, សម្លៀកបំពាក់, កង់, ហ្គីតា, បាល់, និងផ្កា។

សូមពិចារណាពីការធ្វើបញ្ជីមួយអំពីការណ៍នានាដែលអ្នកមានអំណរគុណចំពោះ ហើយចែកចាយវាជាមួយនឹងក្រុមគ្រួសាររបស់អ្នក។



# ទង្វើមួយដ៏ប្រកបដោយវិសាលភាព

*សូមសិក្សាឯកសារនេះ ហើយបើអាចធ្វើទៅបាន សូមពិភាក្សាវាជាមួយនឹងបងប្អូនស្រីដែលអ្នករាល់គ្នាចុះទៅសួរសុខទុក្ខ។ សូមប្រើសំណួរដើម្បីជួយអ្នកពង្រឹងដល់បងប្អូនស្រីរបស់អ្នក និងធ្វើឱ្យសមាគម សង្គ្រោះ ក្លាយទៅជាផ្នែកមួយដ៏សំខាន់នៅក្នុងជីវិតផ្ទាល់របស់អ្នក។*

**សេចក្ដីជំនឿ • ក្រុមគ្រួសារ • ការសង្គ្រោះ**

ព្រះអម្ចាស់, សាសនាចក្ររបស់ទ្រង់, ក្រុមគ្រួសារ និងសហគមន៍ទាំងឡាយត្រូវការឥទ្ធិពលរបស់ពួកស្ត្រីសុចរិត។ តាមពិត អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា «រាល់បងប្អូនស្រីទាំងអស់នៅក្នុងសាសនាចក្រនេះដែលបានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់មានទូវសិទ្ធិអំណាចដ៏ទេវភាពក្នុងការជួយសង្គ្រោះព្រលឹងទាំងឡាយ ក្នុងការដឹកនាំស្ត្រីនៃពិភពលោក ក្នុងការពង្រឹងគេហដ្ឋាននៃស៊ីយ៉ូន និងក្នុងការស្ថាបនានគររបស់ព្រះ»។[1]

បងប្អូនស្រីមួយចំនួនអាចមានចម្ងល់ប្រសិនបើពួកគាត់អាចសម្រេចនូវគោលដៅដ៏ខ្ពស់ដូច្នេះបាន។ ប៉ុន្តែនៅពេលដែល អ៊ីឡៃស្សា អរ ស្នូ (1804–87) ប្រធានសមាគមសង្គ្រោះទូទៅទីពីរ បានពន្យល់ថា «ពុំមានបងប្អូនស្រីណាដែលទុកឱ្យនៅតែម្នាក់ឯង និងឥទ្ធិពលរបស់គាត់មានកំណត់ដែលធ្វើឱ្យគាត់ពុំអាចធ្វើអ្វីបានច្រើនដើម្បីឆ្ពោះទៅរកការបង្កើតនគររបស់ព្រះនៅលើផែនដីបាននោះទេ»។[2] ស៊ីស្ទើរ ស្នូក៏បានបង្រៀនផងដែរថាសមាគមសង្គ្រោះត្រូវបានរៀបចំឡើង «សម្រាប់ភាពជោគជ័យនៃរាល់កិច្ចការល្អ និងថ្លៃថ្លា»។[3]

ការចូលរួមនៅក្នុងសមាគមសង្គ្រោះពង្រីកសមត្ថភាពរបស់យើងដោយការផ្ដល់ឱ្យបងប្អូនស្រីម្នាក់ៗនូវឱកាសដើម្បីស្ថាបនាសេចក្ដីជំនឿ ដើម្បីពង្រឹងក្រុមគ្រួសារ និងគេហដ្ឋាន ព្រមទាំងផ្ដល់នូវការបម្រើទាំងនៅគេហដ្ឋាន និងនៅទូទាំងពិភពលោក។ ហើយដោយសំណាងល្អ កិច្ចខិតខំរបស់យើងជាបុគ្គល និងជាសមាគមសង្គ្រោះពុំចាំបាច់ធំ និងលើសលប់នោះទេ ប៉ុន្តែវាគួរតែរួបរួម និងខ្ជាប់ខ្ជួន។ ការរស់នៅដោយសុចរិតដូចជាការអធិស្ឋានជាក្រុមគ្រួសារ និងដោយផ្ទាល់ខ្លួនជារៀងរាល់ថ្ងៃ ការសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ និងការលើកដំកើងការហៅបម្រើនឹងជួយពង្រីកសេចក្ដីជំនឿ និងស្ថាបនានគររបស់ព្រះអម្ចាស់។

ចំពោះបងប្អូនស្រីទាំងឡាយណាដែលមានចម្ងល់ថាប្រសិនបើការរួមចំណែកដែលមើលទៅហាក់ដូចជាស្ងប់ស្ងាត់ទាំងនេះធ្វើឱ្យមានភាពខុសគ្នា អែលឌើរ បាឡឺដ បញ្ជាក់ថា ៖ «គ្រប់បងប្អូនស្រីដែលឈរដើម្បីសេចក្ដីពិត និងសេចក្ដីសុចរិតធ្វើឱ្យឥទ្ធិពលរបស់អារក្សអន់ថយ។ គ្រប់បងប្អូនស្រីដែលពង្រឹង និងការពារដល់ក្រុមគ្រួសាររបស់គាត់គឺកំពុងតែធ្វើកិច្ចការរបស់ព្រះ។ គ្រប់បងប្អូនស្រីដែលរស់នៅក្នុងនាមជាស្ត្រីម្នាក់របស់ព្រះក្លាយទៅជាភ្លើងនាំផ្លូវសម្រាប់អ្នកដទៃឱ្យដើរតាម និងដាំគ្រាប់នៃឥទ្ធិពលសុចរិតដែលនឹងត្រូវបានប្រមូលផលជាច្រើនទសវត្សរ៍នាពេលអនាគត»។[4]

## តើខ្ញុំអាចធ្វើអ្វីបាន?

1. តើខ្ញុំអាចជួយបងប្អូនស្រីដែលខ្ញុំចុះសួរសុខទុក្ខឱ្យស្គាល់ និងរស់នៅតាមសមត្ថភាពរបស់ពួកគេដើម្បីធ្វើជាឥទ្ធិពលដ៏សុចរិតបានដោយរបៀបណា?

2. តើខ្ញុំអាចប្រើអំណោយទាន និងទេពកោសល្យដ៏ពិសេសរបស់ខ្ញុំដើម្បីប្រទានពរដល់អ្នកដទៃបានដោយរបៀបណា?

## ចេញពីព្រះគម្ពីរ

កូរិនថូសទី1 12:4–18
ធីម៉ូថេទី1 6:18–19
ម៉ូសាយ 4:27 មាត្រានៃសេចក្ដីជំនឿ1:13

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ www.reliefsociety.lds.org។

## ចេញពីប្រវត្តិសាស្ត្ររបស់យើង

អ៊ីឡៃស្សា អរ ស្នូ ដែលបានបម្រើជាលេខានៅពេលដែលសមាគមសង្គ្រោះត្រូវបានរៀបចំឡើងនៅ ទីក្រុង ណៅវូ ត្រូវបានហៅដោយប្រធាន ព្រិកហាំ យ៉ង់ (1801–77) ឱ្យធ្វើដំណើរទូទាំងសាសនាចក្រ ក្នុងការជួយដល់ប៊ីស្សពទាំងឡាយរៀបចំសមាគមសង្គ្រោះនៅក្នុងវួដទាំងឡាយរបស់ពួកគេ។

ស៊ីស្ទើរ ស្នូ បានបង្រៀនថា ៖ «ប្រសិនបើកូនស្រី និងម្ដាយទាំងឡាយក្នុងវង្សអ៊ីស្រាអែលកំពុងតែមានអារម្មណ៍ថាស្ថិតនៅក្នុងភាពមានកំណត់នៅក្នុងសកម្មភាពរបស់ពួកគេ នោះពួកគេនឹងរកឃើញនូវសមត្ថភាពដ៏លើសលប់សម្រាប់គ្រប់ទាំងអំណាច និងព្រះចេស្ដាដើម្បីធ្វើកិច្ចការល្អដែលពួកគេមានយ៉ាងបរិបូរណ៍។ … ប្រធាន យ៉ង់បានបើកឱកាសសម្រាប់ទង្វើដ៏ប្រកបដោយវិសាលភាព និងមានសារៈប្រយោជន៍»។[5]

**កំណត់ចំណាំ**

1. អិម រ័សុល បាឡឺដ «ស្ត្រីនៃសេចក្ដីសុចរិត» *Liahona* ខែ ធ្នូ ឆ្នាំ 2002 ទំព័រ 39។
2. អ៊ីឡៃសា អរ ស្នូ «An Address» *Woman's Exponent* ថ្ងៃទី 15 ខែ កញ្ញា ឆ្នាំ 1873 ទំព័រ 62។
3. អ៊ីឡៃសា អរ ស្នូ «Female Relief Society» *Deseret News,* ថ្ងៃទី 22 ខែ មេសា ឆ្នាំ 1868 ទំព័រ 81។
4. អិម រ័សុល បាឡឺដ *លីអាហូណា* ខែ ធ្នូ ឆ្នាំ 2002 ទំព័រ 39។
5. អ៊ីឡៃសា អរ ស្នូ *Deseret News,* ថ្ងៃទី 22 ខែ មេសា ឆ្នាំ 1868 ទំព័រ 81។



# កិច្ចការតូចតាច និងងាយ

*«ដោយកិច្ចការតូចតាច និងងាយទើបនាំឱ្យកើតកិច្ចការដ៏ធំៗបាន» (អាលម៉ា 37:6)។*





## ម៉ិកស៊ិក

ពួកអ្នកផ្សព្វផ្សាយសាសនាពួកបរិសុទ្ធថ្ងៃចុងក្រោយដំបូងគេបង្អស់បានមកដល់ប្រទេសម៉ិកស៊ិកនៅឆ្នាំ 1875។ ពួកគេបានចែកចេញជាពីរក្រុម ៖ មួយក្រុមបានផ្ញើភាគនៃព្រះគម្ពីរមរមនជាភាសាអេស្ប៉ាញដល់ពួកអ្នកដឹកនាំដែលប្រកបដោយឥទ្ធិពល នៅទូទាំងប្រទេស និងបានបង្រៀនមនុស្សជាច្រើននាក់ ប៉ុន្តែពួកគេពុំមានពួកអ្នកផ្លាស់ប្រែចិត្តជឿទេ។ ក្រុមមួយទៀតបានធ្វើបុណ្យជ្រមុជទឹកឱ្យសមាជិកសាសនាចក្រជនជាតិម៉ិកស៊ិកដំបូងគេនៅហឺម៉ូស៊ីឡូ សូណូរ៉ា។ បួនឆ្នាំក្រោយមក អ្នកដឹកនាំម្នាក់ដែលបានទទួលការបង្រៀនរបស់សាសនាចក្រនៅក្នុងឆ្នាំ 1875 នៅ ផ្លូទីណូ ស៊ី រ៉ូដាកាណាទីនៃក្រុងមិកស៊ីកូស៊ីធី បានស្នើរសុំនូវបុណ្យជ្រមុជទឹកសម្រាបខ្លួនគាត់ និងពួកអ្នកឯទៀត។ ការបកប្រែរព្រះគម្ពីរមរមនជាភាសារអេស្ប៉ាញត្រូវបានបញ្ចប់នៅឆ្នាំ 1885។

ប្រទេសនេះបានប្រឈមមុខនឹងភាពតានតឹងខាងនយោបាយជាច្រើនឆ្នាំ ប៉ុន្តែសមាជិកជំនាន់មុន នៅតែមានភាពស្មោះត្រង់។ ស្តេកម៉ិកស៊ិកូជាស្តេកប្រើប្រាស់ភាសាអេស្ប៉ាញដំបូងគេនៅក្នុងសាសនាចក្រ ត្រូវបានរៀបចំឡើងនៅ ថ្ងៃទី3, ខែ ធ្នូ ឆ្នាំ1961។ សាសនាចក្របានបើកសាលារៀនជាច្រើនកន្លែង រួមមានសាលារៀន បេនេមែរីតូ ដេ ឡាស អាមេរីកាស នៅក្នុងទីក្រុងម៉ិកស៊ីកូតាំងពីឆ្នាំ 1963 ដែលនៅតែមានដំណើការ។

ព្រះវិហារបរិសុទ្ធដំបូងគេដែលបានសង់នៅក្នុងប្រទេសម៉ិកស៊ិក គឺស្ថិតនៅក្នុងទីក្រុងម៉ិកស៊ីកូបានឧទ្ទិសឆ្លង ក្នុងឆ្នាំ 1983។ នៅក្នុងឆ្នាំ 2000 ព្រះវិហារបរិសុទ្ធចំនួនប្រាំបីត្រូវបានឧទ្ទិសឆ្លងនៅក្នុងប្រទេសម៉ិកស៊ិក។

នៅក្នុងឆ្នាំ 2004 ប្រទេសម៉ិកស៊ិក បានក្លាយទៅជាប្រទេសទីមួយ នៅខាងក្រៅសហរដ្ឋអាមេរិក ដែលមានសមាជិកចំនួនមួយលាននាក់។



*ពួកអ្នកដឹកនាំនៃសាសនាចក្រចូលរួមនៅក្នុងពិធីបញ្ចុះធម្មសិលា សម្រាប់ព្រះវិហារបរិសុទ្ធ បេនេមែរីតូ ដេ ឡាស អាមេរីកាស នៅថ្ងៃទី 4 ខែ វិច្ឆការ ឆ្នាំ 1963។*

| សាសនាចក្រនៅក្នុងប្រទេសម៉ិកស៊ិក | |
|---|---|
| សមាជិកភាព | 1,234,545 |
| បេសកកម្ម | 23 |
| ស្តេក | 221 |
| វួដ និងសាខា | 2,009 |
| ព្រះវិហារបរិសុទ្ធ | ព្រះវិហារបរិសុទ្ធចំនួន12<br>កំពុងដំណើរការ 1 បានប្រកាសសាងសង់ |




រូបភាពនៃព្រះវិហារបរិសុទ្ធ ហ៊ើម៉ូស៊ីឡូ សូណូរ៉ា ម៉ិកស៊ិក ដោយ ស្ទីវេន បុណ្ណេល រូបព្រះអាទិត្យលិច© CORBIS IMAGES
ផែនទីដោយ ថូម៉ាស ឆែល និង រូបភាពនៃការបញ្ចុះបង្គោលធម្មសិលាដោយប្រវត្តិសាស្ត្រសាសនាចក្រ រូបភាពដោយ ជូឃ ម៉ាន់

# បុណ្យគ្រីស្ទម៉ាស់សម្រាប់ពួកអ្នកត្រួសត្រាយផ្លូវមុនដំបូង

ខែរដូវរងាដ៏កាចសាហាវបានធ្វើឱ្យមានការពិបាកដល់ពួកអ្នកត្រួសត្រាយផ្លូវស្ទើរគ្រប់គ្នា និងធនធានសម្រាប់អំណោយនាបុណ្យគ្រីស្ទម៉ាស់ ហើយជាញឹកញាប់កម្រមានការប្រារព្ធពិធីណាស់។ ប៉ុន្តែការទាំងនោះពុំបានធ្វើឱ្យពួកអ្នកត្រួសត្រាយផ្លូវជំនាន់មុនមានការរុញរាពីការបង្កើតនូវអនុស្សាវរីយ៍ដ៏ពិសេសក្នុងរដូវកាលឈប់សម្រាកនោះឡើយ។ នេះគឺជាកំណត់ត្រាមួយចំនួនអំពីរបៀបដែលបុណ្យគ្រីស្ទម៉ាស់ត្រូវបានប្រារព្ធនាអំឡុងពេលត្រួសត្រាយផ្លូវ ៖

## បុណ្យគ្រីស្ទម៉ាស់ដ៏សប្បាយបំផុតរបស់ខ្ញុំ

«បុណ្យគ្រីស្ទម៉ាស់ដំបូងរបស់ខ្ញុំនៅជ្រលងភ្នំ [សលត៍លេក ] បានប្រារព្ធឡើងចំថ្ងៃសៅរ៍។ យើងបានប្រារព្ធពិធីនៅក្នុងថ្ងៃបរិសុទ្ធ។ យើងទាំងអស់គ្នាបានមកជួបជុំគ្នានៅជុំវិញដងទង់ជាតិនៅកណ្ដាលបន្ទាយ។ យើងមានប្រជុំមួយនៅទីនោះ។ វាគឺជាការប្រជុំដ៏អស្ចារ្យ។ យើងបានច្រៀងសរសើរដំកើងដល់ព្រះ។ យើងបានចូលរួមនៅក្នុងការអធិស្ឋានបើក និងខ្ញុំតែងតែចងចាំអ្នកនិយាយ ឡើងនិយាយនៅថ្ងៃនោះជានិច្ច។ វាបានពោរពេញទៅដោយពាក្យថ្លែងអំណរគុណ និងសេចក្ដីសប្បាយរីករាយ ដោយពុំមានពាក្យទុទ្ទិដ្ឋិនិយមមួយម៉ាត់ណាត្រូវបានបន្លឺឡើងឡើយ។ ហ្វូងមនុស្សបានពោរពេញដោយសេចក្ដីសង្ឃឹម និងសេចក្ដីក្លៀវក្លា ដោយសារតែសេចក្ដីជំនឿរបស់ពួកគេនាពេលអនាគត។ បន្ទាប់ពីការប្រជុំទីនោះបានពោរពេញដោយការចាប់ដៃគ្រប់ៗគ្នា។ អ្នកខ្លះបានយំដោយសេចក្ដីអំណរ។ កុមារតូចៗបានរត់លេងនៅក្នុងបរិវេណ និងជុំវិញពំនូកភ្លើងនាយប់នោះ។ យើងបានជួបជុំគ្នា និងច្រៀង ‹ មកមកពួកបរិសុទ្ធ កុំខ្លាចឡើយណា តែខិតខំដោយសាទរ។ យើងមានទទ្យាយស្ងោ និងនំប៉័ងបន្តិចបន្តួចសម្រាប់ជាអាហារពេលល្ងាច។ យើងទាំងអស់គ្នាបានញ៉ាំឆ្អែត និងបានពោរពេញដោយវិញ្ញាណនៃសេចក្ដីសុខសាន្ត និងសេចក្ដីល្អដ៏ឥតខ្ចោះ។ ខ្ញុំពុំដែលមានបុណ្យគ្រីស្ទម៉ាស់ណាដែលសប្បាយជាងនោះទេនៅក្នុងជីវិតរបស់ខ្ញុំ»។

**ពុំស្គាល់អ្នកនិពន្ធ បានដកស្រង់ដោយ ប្រាយអិន អែស ហ៊ិង្គ្លី នៅក្នុង Kate B. Carter, comp., *Our Pioneer Heritage,* វ៉ុល 20។ (ឆ្នាំ 1958–77), 14:198។**

## ឱ!លោកអើយ! ពេលវេលាដើរលឿនម្ល៉េះ!

«យប់មួយនៅពេលដែលខ្ញុំទើបតែមានអាយុដប់ប្រាំមួយឆ្នាំ ឪពុកបានធ្វើនូវពិធីបុណ្យគ្រីស្ទម៉ាស់មួយសម្រាប់កូនៗរបស់គាត់ផ្ទាល់ និងក្រុមគ្រួសារ ព្រមទាំងអ្នកជិតខាងដែលជិតបំផុតរបស់ពួកគាត់។ យើងបានរាំ។ បងប្អូនប្រុសរបស់ខ្ញុំជាអ្នកលេងភ្លេង។ យើងបានដឹងហើយថាវាជាគោលបំណងរបស់ឪពុកក្នុងការបញ្ចប់កម្មវិធីនៅត្រឹមម៉ោងដប់ ហើយគាត់ពិតជាបានបញ្ចប់នៅម៉ោងដប់មែនដោយបញ្ជារពួកអ្នកលេងភ្លេងឱ្យឈប់ពីកណ្ដាលវង់រាំ។ ប៉ុន្តែលោកឪពុកពុំបានដឹងទេថាបងប្អូនប្រុសរបស់ខ្ញុំបានលើកខ្ញុំឡើងជាច្រើនដងដើម្បីបង្វិលទ្រនិចនាឡិកានាយប់នោះ។ គ្រប់ពេលខ្ញុំបានបង្វិលត្រឡប់ថយក្រោយសាមសិបនាទី។ នៅពេលកម្មវិធីបញ្ចប់ វាបានរំលងអធ្រាត្រទៅហើយ»។

**ចេញពីកំណត់ត្រាគ្រួសារ គ្រីស្ទាន អុលសុន នៅ *Our Pioneer Heritage,* 15:199។**

## ពេលដ៏សប្បាយក្អាកក្អាយ

«នៅពេលដែលកូនៗបានក្រោកពីគេងនៅព្រឹកបុណ្យគ្រីស្ទម៉ាស់ក្នុងឆ្នាំ 1849 ពុំមានកូនក្រមុំជ័រ ស្ករគ្រាប់មួយដើម ឬប៉មមួយផ្លែនៅក្នុងខ្ទមឡើយ។ ប៉ុន្តែកូនៗ និងឪពុកម្ដាយរបស់ពួកគេនៅតែសប្បាយរីករាយទោះបីជាពុំមានរបស់ទាំងទាំងនោះក្ដី។ ពួកគេបានរីករាយដែលពួកគេនៅតែមានម្ហូបបន្តិចបន្តួចដើម្បីញ៉ាំ ហើយអ្វីដែលពួកគេបានរំពឹងទុកនៅក្នុងផ្ទះថ្មីរបស់ពួកគេកំពុងតែត្រូវបានរីកត្រចះត្រចង់ឡើងជារៀងរាល់ថ្ងៃ។ ប៉ុន្តែ ប្រសិនបើពុំមានកូនក្រមុំជ័រ ឬតុក្កតាសម្រាប់កូនៗទេ នោះឪពុក និងម្ដាយពុំអាចភ្លេចបុណ្យគ្រីស្ទម៉ាស់ និងមួយថ្ងៃមុនបញ្ចប់បុណ្យគ្រីស្ទម៉ាស់ពួកគេទាំងអស់គ្នាបានមានពេលយ៉ាងសប្បាយក្អាកក្អាយ។

«នៅពេលល្ងាចពួកគេបានជួបជុំគ្នានៅឯខ្ទមរបស់ ចន រូបើរី។ នេះគឺជាផ្ទះដែលការប្រជុំលើកដំបូងត្រូវបានធ្វើឡើង។ នៅទីនោះពួកគេបានរាំជាប្រពៃណីមួយដើម្បីបញ្ចប់កម្មវិធី ហើយវាគឺជាហ្វូងមនុស្សដែលសប្បាយរីករាយបំផុត ដែលធ្លាប់បានជួបជុំគ្នានៅក្នុងការជួបជុំបុណ្យគ្រីស្ទម៉ាស់។ … ប៉ុន្តែចំណុចខ្សោយដ៏ធំនោះគឺផ្នែកដន្ត្រី។ ដោយពុំមានឧបករណ៍ដន្ត្រីប្រភេទណាមួយឡើយ។ សៃរឹស ខល គឺជាអ្នកពូកែហួចណាស់ ហើយគាត់បានហួចជាបទភ្លេងក្នុងខណៈពេលដែលពួកអ្នកត្រួសត្រាយផ្លូវរាំយ៉ាងរីករាយ»។

**សារ៉ា ផុលម៉ាន នៅ Kate B. Carter, comp., Kate B. Carter, comp., *Treasures of Pioneer Heritage,* វ៉ុល 6។ (1952–57), 4:197–98។**



ជីវិតដែលអស្ចារ្យត្រូវបានគេចងចាំ

# ប្រធាន ឡូរែនសូ ស្នូ (1814–1901)



ទោះបីជាក្រោយមកគាត់បានក្លាយទៅជាប្រធានទីប្រាំនៃសាសនាចក្រក៏ដោយ ឡូរែនសូ ស្នូ មានចំណាប់អារម្មណ៍តិចតួចណាស់ ក្នុងការទទួលបុណ្យជ្រមុជទឹករហូតដល់បងស្រីរបស់លោក អេលីហ្សា បានអញ្ជើញលោកឱ្យចូលរួមថ្នាក់ហេព្រើរនៅឯសាលារបស់ពួកព្យាការីនៅក្នុង ទីក្រុងខឺតឡង់ រដ្ឋអូហៃអូ។ អ្នកដែលបានចូលរួមក្នុងសាលានោះមានព្យាការី យ៉ូសែប ស្ម៊ីធ និងពួកអ្នកដឹកនាំសាសនាចក្រជាច្រើននាក់ឯទៀតផងដែរ។ ឡូរែនសូ ស្នូបានចាប់ផ្ដើមចាប់អារម្មណ៍ក្នុងដំណឹងល្អ និងបានចូលរួមក្នុងសាសនាចក្រនៅថ្ងៃ ទី 19 ខែ មិថុនា ឆ្នាំ 1836។ ក្រោយមកអែលឌើរ ស្នូ បានចេញបម្រើបេសកកម្មទៅប្រទេស អ៊ីតាលី, សេនវិច អាយឡែន (រដ្ឋហាវៃបច្ចុប្បន្ន) និងចក្រភពអង់គ្លេស ជាកន្លែងដែលលោកឱ្យព្រះគម្ពីរមរមនមួយច្បាប់ដល់ម្ចាស់ក្សត្រី វិចទ័ររា។



អែលឌើរ ស្នូ បានមាននូវអំណោយទានដ៏អស្ចារ្យ ដែលលោកបានប្រើដើម្បីបម្រើព្រះអម្ចាស់។ នៅក្នុងពរជ័យអយ្យកោរបស់លោក លោកត្រូវបានសន្យាថាទោះបីជាលោកនឹងរស់នៅរហូតដល់ចាស់ជរាក៏ដោយ ក៏លោកនឹងពុំមានអារម្មណ៍ថារងឥទ្ធិពលមកពីភាពចាស់ជរានោះឡើយ។ ភាពក្លៀវក្លារបស់លោកនៅតែបន្តធ្វើឱ្យសកម្មក្នុងអំឡុងជាច្រើនឆ្នាំក្រោយរបស់លោក ក្នុងនាមជាសាវក និងព្យាការី។ លោកក៏បានប្រើបព្វជិតភាពដើម្បីប្រោសមនុស្សជាច្រើនឱ្យរួចពីស្លាប់ផងដែរ។

ក្នុងអំឡុងពេលប្រធាន ស្នូ ធ្វើជាព្យាការី ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅរដ្ឋយូថាហ៍ប៉ែកខាងត្បូងបានទទួលរងការឈឺចាប់ដោយសារតែគ្រោះរាំងស្ងួត។ ក្នុងខណៈពេលដែលកំពុងតែនិយាយនៅក្នុងសន្និសីទនៅក្នុងទីក្រុងសេនចចប៉ែកខាងត្បូង នៃរដ្ឋយូថាហ៍ ប្រធានស្នូ ត្រូវបានទទួលការបំផុសឱ្យធ្វើការសន្យាដល់ពួកបរិសុទ្ធថា វានឹងមានភ្លៀងធ្លាក់ ហើយពួកគេនឹងរីករាយជាមួយនឹងផលដ៏បរិបូរណ៍ ប្រសិនបើពួកគេនឹងបង់ដង្វាយមួយភាគក្នុងដប់។ ទោះបីជាសមាជិកទាំងឡាយបានបង់ដង្វាយមួយភាគក្នុងដប់របស់ពួកគេក៏ដោយ អស់រយៈពេលជាច្រើនខែនៅតែពុំមានទឹកភ្លៀង។ ប្រធាន ស្នូបានទូលអង្វរសុំដល់ព្រះវរបិតាសួគ៌ឱ្យបញ្ជូនទឹកភ្លៀងមក។ ក្រោយមកលោកបានទទួលសេចក្ដីប្រកាសតាមទូរលេខថា «មានភ្លៀងធ្លាក់នៅ សេន ចច»។

*ចំពោះព័ត៌មានបន្ថែម សូមមើល Francis M. Gibbons,* Lorenzo Snow: Spiritual Giant, Prophet of God *(ឆ្នាំ 1982)។*



*ខាងលើ ៖ រូបភាពរបស់ ឡូរែនសូ ស្នូ ប្រហែលជាឆ្នាំ 1865។ កណ្ដាល ៖ ប្រធាន ស្នូ (កណ្ដាល) ជាមួយនឹងទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ ចច យ្យូ ខានុន (ខាងឆ្វេង) និងយ៉ូសែប អេហ្វ ស្ម៊ីធ (នៅខាងស្ដាំ) ក្នុងឆ្នាំ 1900។ ខាងក្រោម ៖ ពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានប្រទានពរដោយមានភ្លៀងធ្លាក់សម្រាប់កសិផលរបស់ពួកគេបន្ទាប់ពីស្ដាប់តាមការប្រឹក្សារបស់ប្រធាន ស្នូពីការបង់ដង្វាយមួយភាគក្នុងដប់។*



# ពុំមានភ្លេងប៉ុន្តែ **ពោរពេញដោយភាពសប្បាយរីករាយ**

**ដោយ ចានាល ប៊ី ហ្វ្រីមែន**

ឪពុករបស់ខ្ញុំច្រៀងគោកតែម្នាក់ឯង—ដោយពុំមានសម្លេងធំ ពុំមានសម្លេងទាប ប៉ុន្តែទាំងពីរនេះដូចជាមាននៅគ្រប់ទីកន្លែង។ ទោះបីជាគាត់ពុំស្គាល់ពីភាពខុសគ្នារវាងណោតភ្លេង C កណ្ដាល ចេញពី ណោតភ្លេង A ខ្មៅ ក៏ដោយ ក៏ប៉ាបានច្រៀងយ៉ាងឮ ហើយខ្លាំង។

ខ្ញុំពុំដែលចងចាំពីភាពអាម៉ាស់ដោយសារតែការច្រៀងរបស់ឪពុកខ្ញុំនោះទេ ប៉ុន្តែខ្ញុំចាំពីភាពអស់សំណើច និងរីករាយដោយសារតែសម្លេងដែលពោរពេញដោយភាពរីករាយរបស់គាត់។ តើគាត់ពុំបានដឹងទេថា មនុស្សដទៃកំពុងតែស្ដាប់គាត់?

ប៉ារបស់ខ្ញុំចូលចិត្តទំនុកដំកើងដំណឹងល្អ ហើយគាត់ពុំបានអនុញ្ញាតឱ្យការខ្វះខាតទេពកោសល្យរំខានដល់ការថ្វាយបង្គំរបស់គាត់តាមរយៈដន្ត្រីឡើយ។ គាត់បានច្រៀងដោយសេចក្ដីអំណរ សេចក្ដីរំភើប និងរំជួលចិត្ត។ ខ្ញុំចូលចិត្តពីរប្បៀបដែលគាត់ច្រៀងទំនុកដំកើងដូចជា «ព្រះវិញ្ញាណនៃព្រះ» ដោយកម្លាំង និងភាពជឿជាក់ ហើយពីរបីនាទីក្រោយមកច្រៀងទំនុកដំកើងសាក្រាម៉ង់ដោយដោយភាពទន់ភ្លន់ និងការគោរព។

មានរសៀលមួយឪពុករបស់ខ្ញុំបានបង្រៀនខ្ញុំនូវមេរៀនមួយប្រកបដោយព្រះចេស្ដា តាមរយៈទំនុកដំកើង។ ខ្ញុំបានកំពុងលេងព្យាណូដូចដែលខ្ញុំធ្លាប់ធ្វើជាញឹកញាប់ដើម្បីសម្រាកនៅថ្ងៃសម្រាកពីការសិក្សានៅវិទ្យាល័យ។ ឪពុករបស់ខ្ញុំ តែងតែព្យាយាមស្វែងរកឱកាសដើម្បីចំណាយពេល តែពីរនាក់ខ្ញុំ វាគឺជាទម្លាប់ដដែលៗដែលខ្ញុំធ្លាប់ធ្វើ ៖ គាត់នឹងបើកសៀវភៅចម្រៀង ស្វែងរកបទចម្រៀង និងឱ្យខ្ញុំលេងព្យាណូក្នុងខណៈពេលដែលគាត់ច្រៀង។

នៅថ្ងៃដ៏ពិសេសនេះ ប៉ាបានទាញសៀវភៅចម្រៀងមក និងបានបើកទំនុកដំកើង។

«នេះជាបទដ៏ពីរោះ។ ដោយដាក់សៀវភៅនៅលើព្យាណូ គាត់បាននិយាយថា បទមួយក្នុងចំណោមបទជាទីពេញចិត្តរបស់ប៉ា»។ វាគឺជាបទ “A Poor Wayfaring Man of Grief.” លោកប៉ាបានប្រាប់ថា វាគឺជាបទជាទីពេញចិត្តរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ហើយយ៉ូសែបបានសុំឱ្យយ៉ូហាន ថេលើរច្រៀងបទនោះនៅក្នុងគុកកាតធេចក្នុងរយៈពេលដ៏ខ្លីពីមុនយ៉ូសែប និងហៃរុមត្រូវបានគេសម្លាប់។

ហើយលោកប៉ាបានច្រៀងទាំងប្រាំពីរវគ្គ ក្នុងខណៈពេលដែលខ្ញុំបានលេងព្យាណូអមគាត់។ នៅរំពេចនោះមានរឿងដ៏អស្ចារ្យពីរបានកើតឡើង។ រឿងអស្ចារ្យទីមួយគឺឪពុករបស់ខ្ញុំបានច្រៀងដល់ចប់ដោយពុំមានភ្លេចណោតភ្លេងខ្ពង់ណាមួយឡើយ។ សម្លេង A ខ្មៅរបស់គាត់គឺត្រឹមត្រូវជា A ខ្មៅ! សម្លេងរបស់ប៉ាមានលក្ខណៈធម្មជាតិ និងសាមញ្ញ ហើយចំពោះខ្ញុំវាពីរោះណាស់។ រឿងអស្ចារ្យទីពីរ គឺលែងសូវភ្ញាក់ផ្អើលប៉ុន្តែមានសារៈសំខាន់ខ្លាំងជាងមុន។ នៅពេលដែលឪពុករបស់ខ្ញុំច្រៀង ខ្ញុំដឹងថាគាត់ស្រឡាញ់យ៉ូសែប ស្ម៊ីធ និងមាននូវទីបន្ទាល់អំពីការហៅដែលបានព្យាករណ៍ទុករបស់លោក។ ព្រះវិញ្ញាណបានឈរជាសាក្សីដល់ខ្ញុំថាយ៉ូសែប ស្ម៊ីធគឺជាព្យាការីម្នាក់។

ឪពុករបស់ខ្ញុំបានទទួលមរណភាពនៅពីរបីឆ្នាំក្រោយ ហើយជាញឹកញាប់ខ្ញុំគិតពីថ្ងៃនោះ និងឥទ្ធិពលដែលវាបានមានមកលើខ្ញុំ។ ផ្នែកមួយដ៏សំខាន់នៃទីបន្ទាល់របស់ខ្ញុំអំពីដំណឹងល្អ គឺមានភាពខ្ជាប់ខ្ជួនដោយសារតែឪពុកមួយរូបដែល «ពុំអាចច្រៀងបានពីរោះ» តែជ្រើសរើសដើម្បីច្រៀងដោយអស់ពីដួងចិត្តរបស់គាត់។ ■



**ចូរទទួលយកឱកាសដើម្បីបង្រៀន**

«ក្រៅពីការបង្ហាញដល់យុវវ័យតាមរយៈគំរូ យើងដឹកនាំពួកគេដោយការយល់ពីដួងចិត្តរបស់ពួកគេ និងដើរទន្ទឹមនឹងពួកគេនៅលើផ្លូវដំណឹងល្អ។ ដើម្បីឱ្យយល់ពីដួងចិត្តរបស់ពួកគេយ៉ាងពិតប្រាកដ យើងត្រូវតែធ្វើកិច្ចការឱ្យបានច្រើន ជាជាងគ្រាន់តែនៅក្នុងបន្ទប់ ឬចូលរួមសកម្មភាពសាសនាចក្រ និងក្រុមគ្រួសារដដែលៗនោះទេ។ យើងត្រូវតែដាក់ផែនការ និងឆ្លៀតឱកាសគ្រប់វិនាទីដើម្បីបង្រៀនដែលនឹងធ្វើឱ្យមានការចាប់អារម្មណ៍ដ៏ជ្រាលជ្រៅ និងគ្មានទីបញ្ចប់នៅក្នុងគំនិត និងដួងចិត្តរបស់ពួកគេ។ ...

«ខ្ញុំសង្ឃឹមថាយើងនឹងមានឱកាសដើម្បីថ្លែងទីបន្ទាល់របស់យើង ដែលយើងដឹងថាព្រះមានព្រះជន្មរស់ ហើយថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ។ ខ្ញុំសង្ឃឹមថាយើងនឹងថ្លែងទីបន្ទាល់របស់យើង ដើម្បីឱ្យកូនៗរបស់យើងនឹងដឹងថាដួងចិត្តរបស់យើងស្ថិតនៅទីណា និងដឹងថាយើងស្រឡាញ់ពួកគេ។ សេចក្ដីស្រឡាញ់ និងការបង្រៀនដ៏មហិមាគួរតែស្ថិតនៅក្នុងគេហដ្ឋានរបស់យើង»។

**អែលឌើរ រ៉ូប៊ីត ឌី ហែលនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ «កាតព្វកិច្ចរបស់យើងចំពោះព្រះ ៖ បេសកកម្មរបស់ឪពុកម្ដាយ និងពួកអ្នកដឹកនាំដល់ជំនាន់កំពុងពេញវ័យ»** *លីអាហូណា* ខែឧសភា ឆ្នាំ 2010 ទំព័រ 95, 98។

រូបថតដោយ ខាយអ៊ែ បេខ៊ែ



# ការបម្រើរបស់ខ្ញុំ ក្នុងនាមជាសមាជិកតែម្នាក់ឯង

**ដោយ ជូលី ប៊ើរឌែតទ៍**
ទស្សនាវដ្ដីសាសនាចក្រ

*ខ្ញុំស្រឡាំងកាំង នៅពេលដែលខ្ញុំបានទទួលការហៅថ្មីមួយ។ «តើខ្ញុំអាចធ្វើបានឬទេ?» ខ្ញុំបានសួរខ្លួនឯង។*

ប្រហែលជាប្រាំពីរឆ្នាំកន្លងផុតទៅហើយ នៅពេលដែលខ្ញុំមានអាយុ 29 ឆ្នាំ ខ្ញុំបានប្ដូរពីរដ្ឋ អ័រហ្គិនទៅនៅរដ្ឋយូថាហ៍ សហរដ្ឋអាមេរិក។ បន្ទាប់ពីថ្លឹងថ្លែងពីគំនិតរបស់ខ្ញុំ ពីការគិតថាខ្ញុំត្រូវផ្លាស់ប្ដូរចេញពីវួដនៅលីវដែលខ្ញុំបានចូលរួម ខ្ញុំបានសម្រេចចិត្តចូលរួមនៅក្នុងវួដប្រចាំមូលដ្ឋានក្រុមគ្រួសាររបស់ខ្ញុំ។

ឪពុកម្ដាយរបស់ខ្ញុំបានចិញ្ចឹមបីបាច់ខ្ញុំឱ្យតែងតែទទួលយកការហៅនៅក្នុងសាសនាចក្រជានិច្ច ដូច្នេះខ្ញុំបានណាត់ជួបជាមួយនឹងប៊ីស្សព ដើម្បីបង្ហាញខ្លួនខ្ញុំថាជាមនុស្សម្នាក់ដែលចង់ធ្វើការបម្រើ។ វាពុំយូរប៉ុន្មានពីមុនខ្ញុំរកឃើញថាខ្លួនរបស់ខ្ញុំកំពុងតែបង្រៀនកុមារអាយុប្រាំឆ្នាំនៅក្នុងថ្នាក់កុមារ ដែលខ្ញុំបានមានភាពរីករាយ។ ប្រាំខែក្រោយមកប៊ីស្សពបានហៅខ្ញុំឱ្យធ្វើជាប្រធានថ្នាក់កុមារ។ ខ្ញុំបានស្រឡាំងកាំង។ «តើខ្ញុំអាចធ្វើបានឬទេ?» ខ្ញុំបានសួរខ្លួនឯង។

ដោយភាពនៅលីវ និងពុំមានកូនបានធ្វើឱ្យឆ្ងល់ប្រសិនបើខ្ញុំមានគុណសម្បត្តិដើម្បីបម្រើនៅក្នុងតួនាទីនោះ។ តាមរយៈបទពិសោធន៍ជាមួយនឹងវួដក្រុមគ្រួសារ ប្រធានកុមារ គឺជាម្នាក់ដែលបានរៀបការប្រកបដោយសុភមង្គល មានភាពជោគជ័យ និងជាម្ដាយទាំងឡាយដែលមានភាពលះបង់។ ទោះបីជាយ៉ាងណាក៏ដោយ ដោយចងចាំនូវអ្វី ដែលឪពុកម្ដាយរបស់ខ្ញុំបានបង្រៀនខ្ញុំ នោះខ្ញុំបានទទួលយកការចាត់តាំងថ្មីនេះ។ ប៊ីស្សព បានទទួលយកយ៉ាងហ្មត់ចត់ដើម្បីប្រឹក្សាថាប៊ីស្សពគួរតែ «ស្វែងរកការហៅបម្រើណាមួយដែលប្រកបដោយអត្ថន័យសម្រាប់ពួកមជ្ឈិមវ័យនៅលីវទាំងអស់»។[1] ការហៅនោះអាចត្រូវបានមានន័យលើសពីអ្វីដែលខ្ញុំបានរំពឹងទុកបន្តិច ប៉ុន្តែខ្ញុំបានមានអំណរគុណចំពោះការហៅនោះ។

នៅពេលដែលខ្ញុំបានបម្រើនៅក្នុងការហៅថ្មីរបស់ខ្ញុំ ខ្ញុំបានទទួលបទពិសោធន៍ដ៏ផ្អែមល្ហែម សប្បាយរីករាយ និងវិនាទីដែលពោរពេញដោយ ការបំផុសជាច្រើនជាមួយនឹងកុមារ។ ឆ្នាំមួយ ក្នុងអំឡុងពេលបុណ្យគ្រីស្ទម៉ាស់ យើងបានរំឮកដល់កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ សម្រាប់ពេលវេលាចែកចាយដ៏ពិសេស។ យើងបានច្រៀងបទចម្រៀងទាំងឡាយ។ យើងបានចាត់ឱ្យរក្សរូប និងកន្សែងជូតក្បាលសម្រាប់ពួកអ្នកគង្វាលចៀម និងយ៉ូសែប។ យើងមានកម្រងផ្កាយតូចៗសម្រាប់ពាក់ក្បាលទេវតា។ យើងយកក្រដាសឡាំង និងក្រដាសផ្លេកធ្វើជាមកុដសម្រាប់ពួកហោរ។

នៅពេលដែលយើងបានរំឮកដល់ដំណើររឿងបុណ្យគ្រីស្ទម៉ាស់ និងច្រៀងចម្រៀងដ៏ពិសិដ្ឋទាំងឡាយនៃរដូវកាលនោះ ខ្ញុំកត់សម្គាល់ដល់យុវនារីដ៏ស្រស់ស្អាតដែលដើរតួជានាងម៉ារា។ គំរូរបស់នាងពីការគោរពភាព និងភាពទន់ភ្លន់ដែលនាងបានលត់ជង្គង់ កាន់តុក្កតាជ័រដែលតំណាងឱ្យទារកតូចព្រះយេស៊ូវដ៏ស្ងៀមស្ងាត់ បានដក់ជាប់ក្នុងដួងចិត្តរបស់ខ្ញុំ។ វិញ្ញាណនៃវិនាទីនោះបានធ្វើឱ្យខ្ញុំពោរពេញដោយអំណរគុណដល់ព្រះវរបិតាសួគ៌



ជាទីស្រឡាញ់ចំពោះព្រះអង្គសង្គ្រោះរបស់យើង និងបានជួយពង្រឹងដល់ទីបន្ទាល់របស់ខ្ញុំអំពីបេសកកម្មដែលពោរពេញដោយសេចក្តីស្រឡាញ់ និងមហិមារបស់ទ្រង់។ វាក៏បានធ្វើឱ្យខ្ញុំពោរពេញដោយអំណរគុណចំពោះពរជ័យដ៏មហិមាដែលខ្ញុំបានទទួលនៅក្នុងការហៅឱ្យបម្រើ និងចំពោះប៊ីស្សពដែលពោរពេញដោយការបំផុសដែលបានជួយឱ្យការបម្រើអាចធ្វើទៅបាន។

នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា យើងអាន «ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាមានបំណងចង់បម្រើដល់ព្រះ នោះអ្នករាល់គ្នាបានហៅឱ្យធ្វើកិច្ចការនោះហើយ (គ. និង. ស 4:3)។ ទោះបីជាខនេះជាធម្មតាទាក់ទងជាមួយតែកិច្ចការផ្សព្វផ្សាយសាសនាក៏ដោយ ក៏ខ្ញុំគិតថាវាអាចទាក់ទងទៅនឹងគ្រប់ទម្រង់ទាំងអស់នៃការបម្រើ ដែលផ្អែកលើដំណឹងល្អ។

ពុំថាឡើយយើងនៅលីវ ឬរៀបការហើយ អ្វីដែលសំខាន់បំផុតគឺយើងជាបុត្រាបុត្រីជាទីស្រឡាញ់ម្នាក់របស់ព្រះវរបិតាសួគ៌ ដែលសព្វព្រះទ័យឱ្យយើងរីកចម្រើន ស្ថិតនៅលើផ្លូវត្រូវ អភិវឌ្ឍទេពកោសល្យបម្រើគ្នាទៅវិញទៅមក និងជួយគ្នាទៅវិញទៅមកឱ្យត្រឡប់ទៅឯទ្រង់វិញ។

ការទទួលយក និងសេចក្តីស្រឡាញ់ដែលខ្ញុំបានទទួលនៅក្នុងវួដនោះគឺខ្ជាប់ខ្ជួន និងនៅតែមាននៅក្នុងដួងចិត្តរបស់ខ្ញុំរហូតដល់សព្វថ្ងៃនេះ។ បំណងរបស់ខ្ញុំដើម្បីបម្រើត្រូវបានទទួលស្គាល់ និងមានសារប្រយោជន៍មនុស្សជាច្រើនបានស្វាគមន៍ខ្ញុំ ហើយព្រះវរបិតាសួគ៌ពិតជាបានប្រទានពរជ័យដល់ខ្ញុំ។ ដោយសារតែមានពួកអ្នកដឹកនាំដែលប្រកបដោយការយកចិត្តទុកដាក់ និងចិត្តល្អ ទើបធ្វើឱ្យខ្ញុំបានទទួលពរជ័យដើម្បីបង្រៀន និងរៀនពីកូនដ៏អស្ចារ្យមួយចំនួនរបស់ទ្រង់។ ■

**កំណត់ចំណាំ**

1. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* (ឆ្នាំ 2010) វគ្គ 16.3.3។



**ការយកចិត្តទុកដាក់ប្រកបដោយសេចក្តីស្រឡាញ់**

«ទោះបីជាមានពួកសមាជិកពេញវ័យនៅលីវជាច្រើនត្រូវបានសម្របខ្លួនទៅនឹងជីវិត និងបញ្ហាទាំងឡាយរបស់គេក៏ដោយ ក៏ពួកគេនៅតែត្រូវការការយកចិត្តទុកដាក់ប្រកបដោយសេចក្តីស្រឡាញ់ពីសាសនាចក្រ និងពួកសមាជិកសាសនាចក្រដើម្បីបញ្ជាក់សាជាថ្មីពីសារប្រយោជន៍របស់ពួកគេ និងសេចក្តីស្រឡាញ់ដែលព្រះមានចំពោះពួកគេម្នាក់ៗ»។

**ប្រធាន ជែមស៍ អ៊ី ហ្វោស្ត (1920–2007) ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ «Welcoming Every Single One,» *លីអាហូណា* ខែ សីហា ឆ្នាំ 2007, 4។**

រូបភាពដោយ រ៉ូប៊ឺត បារ៉េត

# ចម្លើយចំពោះរាល់សំនួរដែល «តើអ្វីនឹងកើតឡើងប្រសិនបើ?»

*«ហើយ [ព្រះយេស៊ូវគ្រីស្ទ] នឹងយាងទៅដោយរងការឈឺចាប់ និងទុក្ខវេទនា និងការល្បួងគ្រប់បែបយ៉ាង ហើយទ្រង់ធ្វើយ៉ាងនេះគឺដើម្បីឱ្យបានបំពេញនូវពាក្យទាំងឡាយដែលបានថែងមកថា ទ្រង់នឹងលើកដាក់លើខ្លួនទ្រង់នូវការឈឺចាប់ និងជម្ងឺទាំងឡាយរបស់រាស្ត្រទ្រង់» (អាលម៉ា 7:11)។*

**ដោយ ម៉ៃខល ឌី រូចប៊ើរី**

ជាច្រើនឆ្នាំកន្លងមកហើយ ម៉ូតូកូនទារបស់ខ្ញុំបានរអិលដួលខ្ទាតខ្ញុំចេញ ហើយខ្ញុំបានខ្ទាតធ្លាក់ទៅចំកណ្ដាលផ្លូវ។ រំពេចនោះខ្ញុំត្រូវឡានមួយទៀតបុក—ឡានមួយដ៏ធំ—ហើយបានទាញអូសធ្លាក់ពីផ្លូវ។ មនុស្សទាំងឡាយដែលបានឃើញហេតុការណ៍នោះថាខ្ញុំបានស្លាប់ហើយ។

នៅពេលដែលពួកអ្នកជំនួយការវេជ្ជបណ្ឌិតបានឃើញថាខ្ញុំនៅមានជីវិត នោះពួកគេបានប្រញាប់ប្រញាល់យកខ្ញុំទៅកាន់មន្ទីរពេទ្យ អំឡុងពេលច្រើនថ្ងៃក្រោយមកខ្ញុំបានឆ្លងកាត់ការវះកាត់សង្គ្រោះបន្ទាន់មួយចំនួន។ នៅពេលដែលខ្ញុំស្ថិតនៅក្នុងការជួយទ្រទ្រង់ជីវិតពីម៉ាស៊ីន និងសន្លប់ពុំដឹងខ្លួន ឪពុករបស់ខ្ញុំនិងអ្នកផ្សេងទៀតបានដាក់ដៃរបស់ពួកគេនៅលើក្បាលរបស់ខ្ញុំ និងបានប្រសិទ្ធពរដល់ខ្ញុំ តាមរយៈអំណាចបព្វជិតភាព។ ចាប់តាំងពីពេលនោះមក ដំណើរការនៃព្យាបាលគឺប្រកបដោយអព្ភូតហេតុ។ ប៉ុន្តែអ្វីដែលអស្ចារ្យជាងរឿងដែលបានកើតឡើងរូបកាយនោះ គឺជាអ្វីដែលបានកើតឡើងខាងវិញ្ញាណ។

បទពិសោធន៍នេះបានបើកដួងចិត្តរបស់ខ្ញុំទៅរកឥទ្ធិពលរបស់ព្រះអង្គសង្គ្រោះ។ មួយសប្ដាហ៍ក្រោយគ្រោះថ្នាក់ ទើបខ្ញុំដឹងខ្លួនឡើងវិញ និងបានដឹងនូវអ្វីដែលបានកើតឡើង។ ខ្ញុំបានដឹងថាព្រះអម្ចាស់បានការពារខ្ញុំ និងបានអនុញ្ញាតឱ្យខ្ញុំបន្តរស់នៅជាមួយនឹងភរិយា និងកូនរបស់ខ្ញុំនៅលើផែនដី។ ខ្ញុំបានឃើញថា ខ្លួនរបស់ខ្ញុំត្រូវបានលួងលោមដោយព្រះ ទ្រង់ពុំបានបោះបង់ខ្ញុំចោលឡើយ។ ជាជាងការមានអារម្មណ៍តក់ស្លុតអស្ចារ្យក្រៃលែង និងពិបាកទ្រាំដោយសារដំណើរការព្យាបាលដែលនៅពីមុខខ្ញុំនោះ គឺខ្ញុំបានមានអារម្មណ៍សុខសាន្ត។

បន្ទាប់ពីពេលនោះមក សេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានស៊ីជម្រៅកាន់តែខ្លាំង ហើយចំណង់របស់ខ្ញុំដើម្បីបន្តស្មោះត្រង់អស់មួយជីវិតរបស់ខ្ញុំមានកាន់តែខ្លាំងឡើង។ ខ្ញុំបានឃើញសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ តាមរយៈមនុស្សល្អដែលខ្ញុំបានជួបប្រទះ។ ហើយខ្ញុំបានឃើញថា ព្រះវរបិតាសួគ៌បានឮ និងឆ្លើយតបរាល់ការអធិស្ឋាននានា និងការតមអាហាររបស់អស់អ្នកដែលមានសេចក្ដីជំនឿដ៏មហិមាជំនួសខ្ញុំ។

ដូចដែលខ្ញុំបានចែកចាយរឿងនេះជាមួយនឹងអ្នកដទៃពី «អ្វីនឹងកើតឡើងប្រសិនបើ?» សំណួរពុំមានទីបញ្ចប់។ «តើអ្វីនឹងកើតប្រសិនបើអ្នកបានស្លាប់?» «តើអ្វីនឹងកើតឡើងប្រសិនបើអ្នកនៅរស់ដោយពុំអាចដើរបាន?» «តើអ្វី



**អំណាចនៃការព្យាបាលរបស់ដង្វាយធួន**

«[ព្រះយេស៊ូវគ្រីស្ទ] ជ្រាបពីទុក្ខលំបាករបស់យើង ហើយទ្រង់គង់នៅទីនោះដើម្បីជួយយើង។ ដូចជាសាសន៍សាម៉ារីដ៏ល្អនៅក្នុងរឿងប្រៀបធៀបរបស់ទ្រង់ នៅពេលដែលទ្រង់បានទតឃើញយើងមានរបួសនៅតាមផ្លូវ នោះទ្រង់រុំរបួសរបស់យើង និងថែទាំយើង (សូមមើលលូកា 10:34)។ បងប្អូនប្រុសស្រីទាំងឡាយ អំណាចនៃការព្យាបាលនៃដង្វាយធួនរបស់ទ្រង់គឺសម្រាប់អ្នក សម្រាប់យើង សម្រាប់មនុស្សទាំងអស់គ្នា»។

**អែលឌើរ ដាល្លិន អេក អូកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ «He Heals the Heavy Laden,» *លីអាហូណា*, ខែវិច្ឆិកា ឆ្នាំ 2006 ទំព័រ 7។**



នឹងកើតឡើង ប្រសិនបើអ្នកត្រូវតែស៊ូទ្រាំ នឹងការឈឺចាប់ដ៏ធ្ងន់ធ្ងរអស់មួយជីវិតរបស់អ្នក? ផ្នែកមួយដ៏អស្ចារ្យចំពោះខ្ញុំ គឺថាដង្វាយធួនផ្ដល់នូវចម្លើយមួយ ចំពោះរាល់សំណួរដែលថា «តើអ្វីនឹងកើតឡើងប្រសិនបើ?»

ដោយសារតែដង្វាយធួន ខ្ញុំនឹងត្រូវបានរស់ឡើងវិញ និងរាល់ទុកវេទនាខាងរូបកាយ ឬការឈឺចាប់ណាមួយនឹងត្រូវបានសម្អាតចេញ។ ភរិយារបស់ខ្ញុំ កូនរបស់ខ្ញុំ និងខ្ញុំត្រូវបានផ្សារភ្ជាប់ជាក្រុមគ្រួសារដ៏អស់កល្បជានិច្ច។ ដង្វាយធួនបានធ្វើឱ្យការណ៍នោះអាចទៅរួចផងដែរ។ ប្រសិនបើយើងឆ្ពោះទៅមុខដោយសេចក្ដីជំនឿនៅក្នុងព្រះអង្គសង្គ្រោះរបស់យើង នៅពេលដែលយើងឆ្លងកាត់ការសាកល្បងទាំងឡាយនៃជីវិត និងស៊ូទ្រាំដល់ទីបញ្ចប់ នោះដង្វាយធួននឹងផ្ដល់នូវផ្លូវមួយដែលយើងត្រូវការដើម្បីធ្វើតាម ភ្ជាប់ជាមួយនឹងការសន្យាដ៏រុងរឿងពីជីវិតដ៏អស់កល្បជានិច្ចកំពុងរង់ចាំយើងនៅទីបញ្ចប់។ ■

ចំពោះសេចក្ដីបន្ថែមទៀតពីអត្ថបទនេះ សូមមើលម៉ាថាយ 11:28–30 នីហ្វៃទី 3 17:7–9 និង Bruce C. Hafen, "Beauty for Ashes: The Atonement of Jesus Christ," លីអាហូណា ខែ មេសា ឆ្នាំ 1997 ទំព័រ 39។

***«ហើយទ្រង់នឹងយកដាក់លើរូបអង្គទ្រង់នូវសេចក្ដីស្លាប់ ដើម្បីទ្រង់អាចស្រាយចំណងទាំងឡាយនៃសេចក្ដីស្លាប់ដែលចងរាស្ត្រទ្រង់ ហើយទ្រង់នឹងដាក់លើរូបអង្គទ្រង់ នូវជម្ងឺឈឺចាប់របស់ពួកគេ ដើម្បីឱ្យព្រះហឫទ័យទ្រង់បាន ពោរពេញទៅដោយសេចក្ដីមេត្តាករុណាស្របតាមសាច់ឈាមដើម្បីទ្រង់អាចដឹងស្របតាមសាច់ឈាមថាតើត្រូវជួយរាស្ត្រទ្រង់បែបណាតាមជម្ងឺរបស់គេ» (អាលម៉ា 7:12)។***

**តើព្រះអម្ចាស់ពង្រឹងយើងដោយរបៀបណា?**

អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ជួយឆ្លើយនូវសំណួរនេះនៅក្នុងសុន្ទរកថាសន្និសីទទូទៅ «In the Strength of the Lord» (*លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2004 ទំព័រ 76–78) ៖

- «នៅក្នុងកម្លាំងរបស់ព្រះអម្ចាស់យើងអាចសម្រេច និងស៊ូទ្រាំ និងឈ្នះលើគ្រប់កិច្ចការទាំងអស់»។
- «ទ្រង់ទ្រាយនៃការពង្រឹង និងការផ្ដល់ឱ្យពីដង្វាយធួនជួយយើងឱ្យឃើញ និងធ្វើ និងក្លាយទៅជាសេចក្ដីល្អនៅក្នុងគ្រប់មធ្យោបាយដែលយើងពុំដែលដឹង ឬសម្រេចបានដោយសមត្ថភាពខាងសាច់ ឈាមដែលមានកំហិតរបស់យើង»។
- «នៅក្នុងកម្លាំងរបស់ព្រះអម្ចាស់ និងតាមរយៈព្រះគុណរបស់ទ្រង់ ខ្ញុំដឹងថាអ្នក និងខ្ញុំអាចត្រូវបានប្រទានពរដើម្បីសម្រេចកិច្ចការគ្រប់យ៉ាងបាន»។

ចូរពិចារណាពីការចែកចាយទីបន្ទាល់របស់អ្នកតាមរបៀបផ្សេងទៀតអំពីពរជ័យទាំងឡាយ ដែលបានមកតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។

# មេរៀនមកពីលោក ចៅហ្វាយ



**ដោយអែលឌើរ ម៉ាវីន ជេ អាស្តុន**
**(ឆ្នាំ 1915–94)**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*ម៉ាវីន ជេ អាស្តុនត្រូវតែងតាំងជាសាវកនៅថ្ងៃទី 2 ខែ ធ្នូ ឆ្នាំ 1971។ អត្ថបទនៅខាងក្រោមនេះ គឺជាការដកស្រង់ចេញពីសន្ទរកថាក្នុងការប្រជុំធម្មទិដ្ឋានសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ដែលលោកបានថ្លែងនៅថ្ងៃទី 5 ខែ មិថុនា ឆ្នាំ 1988។*

តាមខ្ញុំនៅចាំបានថា ខ្ញុំធ្លាប់បានមានសេចក្ដីស្រឡាញ់ដ៏ពិសេសចំពោះព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំត្រូវបានបង្រៀនថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះដែលមានព្រះជន្មរស់។ ខ្ញុំត្រូវបានបង្រៀនថាទ្រង់គឺជាមិត្តភ័ក្តិ ជាគ្រូ និងជាកម្លាំងរបស់ខ្ញុំ។ ជាច្រើនឆ្នាំកន្លងផុតទៅ នៅពេលដែលការហៅ និងការទទួលខុសត្រូវ ព្រមទាំងកិត្តិយសនៃការឈរជាសាក្សីពិសេសរបស់ទ្រង់បានចូលមកក្នុងជីវិតរបស់ខ្ញុំ ខ្ញុំបានខិតខំអនុវត្តតាមគំរូនៃជីវិតរបស់ទ្រង់ និងមាគ៌ារបស់ទ្រង់។ ពិតណាស់ ទ្រង់គឺជាលោកគ្រូចៅហ្វាយ។ ដើម្បីជួយខ្ញុំក្នុងការបម្រើ និងការតាំងចិត្តរបស់ខ្ញុំ ខ្ញុំបានរកឃើញថាខ្លួនខ្ញុំផ្ទាល់បានអាននៅក្នុងយ៉ូហានជំពូកទីប្រាំបី នៅក្នុងព្រះគម្ពីរសញ្ញាថ្មីជាញឹកញាប់សម្រាប់ជាកម្លាំង សម្រាប់ជាការណែនាំ និងជាសម្រាប់គំរូ។ ប្រសិនបើអ្នកចង់ ចូរយើងអានខមួយចំនួនដើម្បីពង្រឹងដល់ជីវិតរបស់យើង និងទំនាក់ទំនងរបស់យើងជាមួយនឹងព្រះយេស៊ូវ។ ព្រះបន្ទូល និងជួរបន្ទាត់ទាំងនេះជួយខ្ញុំឱ្យយល់ពីទ្រង់កាន់តែប្រសើរឡើង និងផ្ដល់ឱ្យខ្ញុំនូវចំណង់ដើម្បីធ្វើ និងក្លាយកាន់តែដូចទ្រង់។ ...

[ពួកអាចារ្យ និងពួកផារ៉ាស៊ី] នាំស្ត្រីម្នាក់ដែលទាន់នៅដំណេកមកឯទ្រង់។ ពួកសត្រូវទាំងនេះ ... បានព្យាយាមបោកបញ្ឆោតទ្រង់។ ពួកគេបានឱ្យនាងអង្គុយនៅចំកណ្ដាល ដើម្បីបង្ហាញថាជាអ្នកមានបាប ជាមនុស្សម្នាក់ដែលពុំបរិសុទ្ធ។ ទ្រង់ពុំបានចាកចោលនាងឡើយ។ ... នាងបានប្រព្រឹត្តអំពើកំផិត—ពិតជាត្រូវគេចាប់បានពិត។ ពុំមានការសង្ស័យទេអំពីកំហុសរបស់នាង។ ពួកគេបានដាក់ទ្រង់ទៅក្នុងស្ថានភាពមួយដែលមើលទៅហាក់ដូចជាពុំអាចដោះស្រាយបាន។ ក្រិត្យវិន័យរបស់ម៉ូសេថាត្រូវចោលនាងនឹងថ្ម។ «ដូច្នេះតើលោកគិតដូចម្ដេច?» [យ៉ូហាន 8:5] គេទូលដូច្នោះ ល្បងទ្រង់ ដាក់អន្ទាក់ទ្រង់—ដាក់ទ្រង់ទៅក្នុងស្ថានភាពមួយដែលពុំអាចឈ្នះ។

ទោះជាទ្រង់មានព្រះបន្ទូលយ៉ាងម៉េចក៏ដោយ ក៏ទ្រង់នឹងត្រូវបានមូលបង្កាច់ ជំនុំជម្រះដោយអយុត្តិធម៌។ ពួកគេបានកំពុងល្បងទ្រង់ប្រសិនបើពួកគេអាចធ្វើឱ្យទ្រង់បាត់បង់ភាពអត់ធ្មត់របស់ទ្រង់ និងភ្លេចថាទ្រង់ជានរណា។ ការចោលនាងនឹងថ្ម វាសាហាវណាស់។ ដោយពុំអើពើពីការប្រព្រឹត្តខុសរបស់នាង ... ទ្រង់ឱនទៅសរសេរនៅដីហាក់ដូចជាទ្រង់ពុំបានឮពួកគេ (ដោយទទួលបានការយកចិត្តទុកដាក់របស់ពួកគេ និងការរៀបចំពួកគេឱ្យត្រៀបស្ដាប់ដើម្បីបង្រៀន)។ ... ក្នុងខណៈដែលមានភាពស្ងៀមស្ងាត់ ពួកគេបានបន្តសួរ។ ខ្ញុំអាចឮសំនួរទាំងឡាយផ្ដេសផ្ដាស ៖ «សូមឆ្លើយសំណួរមក។ យើងចាប់អ្នកបានហើយ។ តើអ្នកពុំហានឆ្លើយឬ?» ប៉ុន្តែព្រះយេស៊ូវ គឺជាអ្នកជំនុំជម្រះ។ ...

ព្រះយេស៊ូវបានងើបឡើង នៅក្នុងការបន្ទាបខ្លួន និងភាពទន់ទាប ហើយក៏មានបន្ទូលថា ៖ «អ្នកណាដែលគ្មានបាបសោះ ចូរឱ្យអ្នកនោះចោលនាងនឹងថ្មជាមុនគេចុះ» [យ៉ូហាន8:7]។ ចម្លើយដ៏ឥតខ្ចោះមកពីមនុស្សដ៏ឥតខ្ចោះ។

សព្វថ្ងៃនេះនៅក្នុងការទទួលខុសត្រូវ ស្ថានភាព និងការហៅនានារបស់យើង យើងត្រូវបានរំឮកពីរឿងនេះម្ដងហើយម្ដងទៀត។ នៅក្នុងទំនាក់ទំនងរបស់យើងជាមួយនឹងមនុស្សទូទៅ ចូរឱ្យអ្នកណាដែលពុំមានបាបសោះ រិះគន់ ឬស្វែងរកកំហុស ឬមើលងាយគេមុនគេ។ ... រួចទ្រង់ក៏ឱនសរសេរនៅដីម្ដងទៀត។ ពួកគេបានឮអ្វីដែលទ្រង់បានមានបន្ទូល។ ពួកគេបានដក់អារម្មណ៍ពីភាពស្ងៀមស្ងាត់របស់ទ្រង់ក្នុងខណៈពេលដែលទ្រង់ពុំបានមានបន្ទូលអ្វីទាំងអស់។

សតិសម្បជញ្ញៈរបស់ពួកគេ បានដាក់ទោសលើខ្លួនគេ ដែលធ្វើឱ្យខ្លួនពួកគេដើរចេញដោយខ្លួនឯង ដោយពុំចាំបាច់បណ្តេញគេចេញឡើយ។ នោះពួកគេក៏ថយចេញទៅម្នាក់ម្តងៗ—ដោយពុំស្វែងរកថ្មទេ ប៉ុន្តែចេញទៅដើម្បីថែទាំរបួសខាងវិញ្ញាណរបស់ពួកគេ។

ទ្រង់នៅតែម្នាក់ឯងជាមួយនឹងស្ត្រីនោះ។ ខ្ញុំមានអំណរដែលហេតុការណ៍នេះ ត្រូវបានកត់ត្រាទុក។ ពួកយើងមួយចំនួនព្យាយាមគេចចេញពីអ្នកទាំងឡាយដែលបានប្រព្រឹត្តខុស។ ... ទ្រង់បានមានព្រះបន្ទូលថា «ពួកដែលចោទប្រកាន់នាងតើនៅឯណា? គ្មានអ្នកណាកាត់ទោសនាងទេឬអី?» យ៉ូហាន 8:12 ... ព្រះយេស៊ូវចំណាយពេលដើម្បីសួរ និងស្តាប់។ ខ្ញុំប្រាថ្នាថាយើងអាចធ្វើកិច្ចការដូច្នោះបានច្រើនថែមទៀត! ចម្លើយរបស់យើងនឹងងាយស្រួល បានរីកចម្រើនជាច្រើន។ ...

ស្ត្រីដែលត្រូវគេចាប់បានក្នុងបទកំផិតបានឆ្លើយនឹងសំណួររបស់ព្រះអម្ចាស់ទាក់ទងទៅនឹងពួកអ្នកចោទប្រកាន់នាងថា «គ្មានទេ លោកម្ចាស់»។ ហើយក្រោយមកការប្រកាសដ៏ប្រកបដោយព្រះចេស្តានេះថា ៖ «ទៅចុះតែកុំធ្វើបាបទៀតឡើយ» [យ៉ូហាន 8:11]។ លោកចៅហ្វាយបានបង្រៀននៅថ្ងៃនោះ និងកំពុងបង្រៀននៅពេលនេះ។ សារលិខិតដ៏មហិមារបស់ទ្រង់ ៖ ស្អប់អំពើបាប តែត្រូវស្រឡាញ់អ្នកមានបាប។ ខ្ញុំសង្ឃឹមថាវាអាចផ្តល់ដល់យើងនូវកម្លាំង និងទំនុកចិត្ត ព្រមទាំងទំនាក់ទំនងមួយដ៏ជិតស្និទ្ធជាមួយនឹងព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវពុំលើកលែងឱ្យអំពើកំផិតឡើយ។ ទ្រង់បានប្រទានដល់ស្ត្រីនោះនូវសេចក្តីស្រឡាញ់ពីដំបូន្មានដែលប្រកបដោយសិទ្ធិអំណាច។ នាងនិងពួកអ្នកចោទប្រកាន់ត្រូវការមេរៀនសេចក្តីស្រឡាញ់។ ស្ថានភាពអំពាវនាវរកសេចក្តីមេត្តាករុណា និងសេចក្តីអាណិតអាសូរ។ តើវាជារង្វាន់អស្ចារ្យប៉ុណ្ណាក្នុងការដឹងថាព្រះយេស៊ូវជឿថា មនុស្សគឺមានតម្លៃមហិមាជាងអំពើបាបទាំងអស់របស់គេ។ តើនេះពុំអស្ចារ្យទេឬដែលទ្រង់ត្រូវរាប់ទុកថាជា «អ្នកគង្វាលល្អ?» ទ្រង់ស្រឡាញ់ចៀមទាំងអស់របស់ទ្រង់ទោះបីជាពួកវាវង្វេង ស្រេកឃ្លាន, ពុំមានជំនួយ, រងា ឬវង្វេង។

នៅទីបញ្ចប់នៃបទពិសោធន៍នៃការបង្រៀនដ៏មហិមានេះ មេរៀននៃសេចក្តីស្រឡាញ់នេះ និងសេចក្តីមេត្តាករុណា គឺជាខមួយដ៏សំខាន់។

«ព្រះយេស៊ូវទ្រង់មានបន្ទូលទៅគេម្តងទៀតថា ខ្ញុំជាពន្លឺលោកិយ ៖ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្តីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ» (យ៉ូហាន8:12)។

ចូរយើងដើរតាមពន្លឺរបស់ទ្រង់។ ចូរយើងធ្វើតាមព្រះបន្ទូលទាំងនេះជាញឹកញាប់។ ខ្ញុំសូមថ្លែងទីបន្ទាល់ដល់អ្នកថា ព្រះបន្ទូលទាំងនោះត្រូវបានរក្សាទុកសម្រាប់សេចក្តីល្អដល់យើងទាំងអស់គ្នា។ ■



*ការប្រកប ការដាក់វណ្ណយុត្តិ និង អក្សរធំ ត្រូវបានអនុលោមតាមសម័យទំនើប។ ចំពោះអត្ថបទដ៏ពេញលេញពីសុន្ទរកថានេះជាភាសាអង់គ្លេស សូមចូលទៅកាន់ speeches.byu.edu។*

ស្ត្រីដែលបានប្រព្រឹត្តអំពើកំផិត ដោយ HARRY ANDERSON © SEVENTH-DAY ADVENTIST CHURCH ហាមថតចម្លង



## សេចក្តីសុខសាន្ត និងសេចក្តីអំណរពីការដឹងថា

# ព្រះអង្គសង្គ្រោះមាន ព្រះជន្មរស់



*ក្នុងនាមជាសាក្សីពិសេសនៃព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ខ្ញុំសូមថ្លែងទីបន្ទាល់ថាព្រះយេស៊ូវជាព្រះគ្រីស្ទជាព្រះរាជបុត្រាដ៏ទេវភាពនៃព្រះដែលមានព្រះជន្មរស់។*



**ដោយ អែលឌើរ រ័សុល អិម ណិលសុន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

ក្នុងនាមជាសាវកមួយរូបក្នុងចំណោមពួកសាវកដប់ពីរនាក់ ខ្ញុំអាចនិយាយថាសមាជិកនៃពួកដប់ពីរនាក់ រីករាយនឹងអភ័យឯកសិទ្ធិដើម្បីបង្រៀន និងថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង។ យើងរីករាយនឹងចែកចាយនូវទីបន្ទាល់របស់យើងអំពីជីវិតរបស់ទ្រង់ ការបម្រើរបស់ទ្រង់ និងបេសកកម្មរបស់ទ្រង់ក្នុងអំឡុងជីវិតរមែងស្លាប់។

យើងរំឭកចាំអំពីកំណើតដ៏រាបទាបរបស់ព្រះអង្គសង្គ្រោះ នៅពេលនេះក្នុងអំឡុងឆ្នាំនេះទោះបីជាយើងបានដឹងថាវាពុំបានកើតឡើងនៅក្នុងខែធ្នូក៏ដោយ។ ជាការពិតណាស់ ព្រះអម្ចាស់ត្រូវបានប្រសូត្រនៅក្នុងខែមេសា។ ទាំងប្រវត្តិសាស្ត្រ និងព្រះគម្ពីរផ្តល់ភស្តុតាងថា ចំនិទាឃរដូវនៃឆ្នាំ ជិតដល់ថ្ងៃបុណ្យរំលងរបស់ពួកយូដា (សូមមើល គ. និង. ស 20:1)។

ព្រះគម្ពីរប្រកាសថាម្តាយរបស់ទ្រង់ ម៉ារា ជាគូដណ្តឹងរបស់យ៉ូសែប (សូមមើលម៉ាថាយ1:18 លូកា1:27)។ ភាពជាគូដណ្តឹងរបស់ពួកគេប្រហែលជាដូចជាការភ្ជាប់ពាក្យនាសម័យទំនើបនេះផងដែរ ដែលក្រោយមកត្រូវបានរៀបអាពាហ៍ពិពាហ៍ពិតប្រាកដ។

សាច់រឿងនៅក្នុងលូកាការលេចមករបស់ទេវតា កាព្រីយ៉ែលដល់ម៉ារានៅពេលដែលនាងបានដឹងពីបេសកកម្មនៅលើផែនដីរបស់នាង ៖

«ទេវតាក៏ចូលមកឯនាងពោលថា ជម្រាបសួរនាង ឱនាងដែលប្រកបដោយព្រះគុណអើយ ព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងនាងក្នុងចំណោមពួកស្រីៗនាងជាស្ត្រីមានពរពិត។ ...

«តែទេវតានិយាយថាកុំខ្លាចអី ម៉ារាអើយ ៖ ត្បិតព្រះបានប្រោសមេត្តាដល់នាងហើយ។

«មើលនាងនឹងមានគភ៌ប្រសូតបានបុត្រាមួយដែលនាងត្រូវថ្វាយព្រះនាមថាយេស៊ូវ។

«បុត្រនោះនឹងបានជាធំឧត្តមហើយគេនឹងហៅទ្រង់ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត» (លូកា1:28, 30–32)។

ព្រះវរបិតាសួគ៌របស់យើងគឺ*ខ្ពស់បំផុត*។ ព្រះយេស៊ូវ គឺជា*ព្រះរាជបុត្រារបស់ព្រះដ៏ខ្ពស់បំផុត*។

«តែម៉ារាសួរទេវតាថា ខ្ញុំមិនស្គាល់ប្រុសណាផង ដូច្នេះតើធ្វើដូចម្តេចនឹងឱ្យការនេះសម្រេចបាន?

«ទេវតាឆ្លើយថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង ហើយព្រះចេស្តានៃព្រះដ៏ខ្ពស់បំផុត នឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូច្នេះបុត្របរិសុទ្ធដែលនឹងប្រសូតមកនោះត្រូវហៅថាព្រះរាជបុត្រានៃព្រះ» (លូកា1:34–35)។

មុននឹងយ៉ូសែប និងម៉ារាបានរៀបការ នាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ។ យ៉ូសែបមានបំណងការពារ ម៉ារា (សូមមើលម៉ាថាយ1:18–19) ដោយរំពឹងគិតថានឹងជួយនាងឱ្យផុត

សេចក្តីលម្អិតមកពី*ព្រះគ្រីស្ទ និងអ្នកមានវ័យក្មេង* ដោយ ហ៊ែនរិច ហូហ្វមាន់ រូបភាពនៃ C. HARRISON CONROY CO. *ទេសភាពបេថ្លេហិម ឆ្នាំ 1857* ដោយនីកាណោ ហ្គ្រីហ្គ័រ អ៊ីរិច ដើណែតសូវ សារៈមន្ទីរ ពុស្សគីន ម៉ូស្គូវ ប្រទេស រ៉ុស្ស៊ី បណ្ណាល័យសិល្បៈអន្តរជាតិ ប្រិចមិន

ពីទារុណកម្មដល់ស្ត្រីដែលមានផ្ទៃពោះដោយពុំបានរៀបការស្របច្បាប់។ កាលដែលគាត់កំពុងតែគិតពីការណ៍នោះ ស្រាប់តែទេវតា កាព្រីយ៉ែលបានលេចមកឯយ៉ូសែប ដោយប្រាប់គាត់ថា ៖

«យ៉ូសែបពូជហ្លួងដាវីឌអើយ កុំឱ្យខ្លាចនឹងយកនាងម៉ារាជាប្រពន្ធអ្នកឡើយ ៖ ត្បិតបុត្រដែលមកចាប់ទំផ្ទៃនាងនោះកើតពីព្រះវិញ្ញាណបរិសុទ្ធ។

«នាងនឹងប្រសូតបុត្រាមួយ ហើយអ្នកត្រូវថ្វាយព្រះនាមថាយេស៊ូវ ៖ ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឱ្យរួចពីបាប» (ម៉ាថាយ 1:20–21)។

ម៉ារា និងយ៉ូសែបពុំចាំបាច់បង្រៀនពីសារៈសំខាន់ដ៏ស៊ីជម្រៅនៃព្រះនាម *យេស៊ូវឡើយ។* ពាក្យឫសនៅក្នុងភាសាហេព្រើរវាចេញមកពីពាក្យ *យេហូស្សួរ៉ា* ឬ *យេហូស្វា*ដែលមានន័យថា «យេហូវ៉ាគឺការសង្គ្រោះ»។[1] ដូច្នេះកិច្ចការរបស់ព្រះអម្ចាស់ព្រះយេហូវ៉ា ក្រោមមកត្រូវបានដាក់ឈ្មោះថាព្រះយេស៊ូវ គឺការសង្គ្រោះ។ ទ្រង់បានក្លាយទៅជាព្រះអង្គសង្គ្រោះនៃពិភពលោក។

នៅក្នុងព្រះគម្ពីរមរមនយើងអានការសន្ទនារបស់នីហ្វៃជាមួយនឹងទេវតាដែលបានសួរថា «តើអ្នកយល់ពីការយាងចុះមកនៃព្រះឬទេ?»

នីហ្វៃបានទូលទៅទេវតាថា «ខ្ញុំដឹងថាព្រះអង្គទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់ ប៉ុន្តែទោះជាយ៉ាងណា ក៏ដោយគង់តែខ្ញុំមិនយល់ន័យនៃរឿងទាំងអស់នោះទេ។

«ហើយទេវតាមានបន្ទូលមកខ្ញុំថា ៖ មើលចុះនាងព្រហ្មចារីដែលអ្នកឃើញនោះ គឺជាមាតានៃព្រះរាជបុត្រានៃព្រះស្របតាមខាងឯសាច់ឈាម។

«... ខ្ញុំបានឃើញថានាងត្រូវបាននាំទៅដោយព្រះវិញ្ញាណ ហើយបន្ទាប់ពីនាងត្រូវបាននាំទៅដោយព្រះវិញ្ញាណអស់មួយរយៈហើយនោះទេវតាក៏មានបន្ទូលមកខ្ញុំថា ៖ មើលន៍!

«ហើយខ្ញុំក៏មើល ហើយបានឃើញនាងព្រហ្មចារីម្ដងទៀត នាងកំពុងតែបីព្រះឱរសក្នុងដៃរបស់នាង។

«ហើយទេវតាមានបន្ទូលមកខ្ញុំថា ៖ មើលន៍កូនចៀមនៃព្រះ មែនហើយគឺជាព្រះរាជបុត្រានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ច!» (នីហ្វៃទី 1 11:16–21)។

## ភាពស៊ីជម្រៅពីលូកា

ភាពស៊ីជម្រៅដ៏មានតម្លៃ ត្រូវបានបន្ថែមចំពោះសាច់រឿងដ៏ផ្អែមល្ហែម និងជំនិតដែលយើងរៀបរាប់ឡើងវិញនៅពេលបុណ្យគ្រីស្ទម៉ាស់ ដូចដែលបានកត់ត្រានៅក្នុងលូកា ជំពូកទី 2៖ «នៅគ្រានោះសេសារ អូគូស្ទ បានចេញព្រះរាជក្រមមួយច្បាប់ឱ្យមនុស្សទាំងអស់ ដែលនៅផែនដីបានចុះបញ្ជី» (លូកា 2:1)។

នេះពិតជាការបង់ពន្ធអាករ ជំរឿន និងការចុះបញ្ជី—ជាសញ្ញាតិនៃចក្រភពរ៉ូម។



ស្ដេចហេរ៉ូឌ បានណែនាំប្រជាជនថា ត្រូវរាប់បញ្ចូលទៅក្នុងដែនដីនៃដូនតារបស់ពួកគេ។ ពេលនោះ ម៉ារី និងយ៉ូសែបដែលរស់នៅណាសារ៉ែត ត្រូវធ្វើដំណើរដ៏ឆ្ងាយទៅកាន់ទីក្រុងដាវីឌដែលនៅភាគខាងត្បូង មានចម្ងាយប្រហែល 90 ម៉ាយល៍ (145 គីឡូម៉ែត្រ)។ ពួកគេប្រហែលជាបានធ្វើដំណើរឆ្ងាយជាង ប្រសិនបើពួកគេត្រូវធ្វើដំណើរជុំវិញតំបន់ដ៏ជាសត្រូវដែលជាប់នឹងខេត្តនៃទីក្រុងសាម៉ារី។

ប្រាកដណាស់ពួកគេ បានធ្វើដំណើរជាមួយនឹងសាច់ញាតិ ដែលត្រូវបានកោះហៅឱ្យទៅដែនដីនៃដូនតារបស់ពួកគេផងដែរ។ ការធ្វើដំណើរដ៏លំបាកនេះពិតជា ត្រូវធ្វើដំណើរជាមួយនឹងសត្វពាហនៈរបស់ពួកគេ ដូចជាឆ្កែ និងលាទាំងឡាយរបស់ពួកគេ។



*សាលាសំណាក់ ដែលម៉ារី និងយ៉ូសែបបានស្នាក់នៅ មានរាងជាម៉ុមកែង ដោយមានទីធ្លានៅកណ្ដាល សម្រាប់សត្វ ព័ទ្ធជុំវិញដោយជញ្ជាំងបន្ទប់ជាកន្លែងមនុស្សស្នាក់នៅ។*

ពួកគេត្រូវបោះជំរំអស់ជាច្រើនយប់ ដោយសារតែការធ្វើដំណើររបស់ពួកគេ ត្រូវចំណាយពេលបីទៅបួនថ្ងៃ។ នៅពេលដែលពួកគេទៅដល់ភូមបេថ្លេហិម ដល់ពេលដែលបុត្រដ៏បរិសុទ្ធត្រូវប្រសូត។

«ហើយនាងបានប្រសូត បានបុត្រាជាចម្បងមក រួចរុំនឹងសំពត់ផ្ដេកក្នុងស្នូកពីព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងណានៅទេ» (លូកា2:7)។

ខនេះពោរពេញដោយអត្ថន័យ បានពង្រីក ដោយការស្គាល់ពាក្យមួយចេញពីអត្ថបទដើមនៃព្រះគម្ពីរសញ្ញាថ្មីជាភាសាក្រិក និងយល់ពីទំនៀមទម្លាប់នៃពេលវេលា និងកន្លែងនោះ។ អត្ថន័យចេញមកពីពាក្យ «inn» ត្រូវបានបកប្រែជា *kataluma*។[2] ពាក្យនាំមុខក្នុងភាសាក្រិក *kata* (ឬ *cata*) មានន័យថា «ចុះ» ជាពេលវេលា ឬទីកន្លែង។ នៅពេលដែល *kata* ចូលរួមជាមួយនឹង *luma* ពាក្យបញ្ជាក់ពីទីកន្លែងដែលមនុស្សបែកគ្នា ឬ សម្រាកពីការធ្វើដំណើររបស់ពួកគេ។ នៅក្នុងសញ្ញាថ្មីជាភាសាក្រិក ពាក្យ *kataluma* មានអត្ថន័យតែនៅក្នុងឃ្លាពីរផ្សេងទៀតតែប៉ុណ្ណោះ បានបកប្រែទៅតាមន័យនីមួយៗពុំដូចជា «inn» ទេប៉ុន្តែជា «guestchamber» (ម៉ាកុស 14:14 លូកា 22:11)។

នៅសម័យ និងទីកន្លែងនោះ សណ្ឋាគារអាស៊ី ពុំដូចជាសណ្ឋាគារហូលីដេ ឬបេថ្លេហិម ម៉ារីយុត្តនោះទេ។ ផ្ទះសំណាក់នៅសម័យនោះបានផ្ដល់នូវម្ហូបអាហារ និងទីស្នាក់នៅសម្រាប់អ្នកធ្វើដំណើរផ្លូវឆ្ងាយ រួមមានមនុស្ស និងសត្វពាហនៈរបស់ពួកគេ។ អ្នកធ្វើដំណើរបានស្នាក់នៅកន្លែងមួយដែលនៅសម័យនោះ ត្រូវបានស្គាល់ថា (នឹងនៅតែត្រូវបានស្គាល់ថា) ជា *caravansary* ឬជា *khan*។ វចនានុក្រមពន្យល់អត្ថន័យទាំងនេះថាជា សណ្ឋាគារដែលមានទីលានព័ទ្ធជុំវិញនៅប្រទេសលោកខាងកើត (ឬអាស៊ី) ដែលអ្នកធ្វើដំណើរសម្រាកនៅពេលយប់។[3]

អគារទាំងនោះជាទូទៅមានម៉ុមកែង មានទាំងទីធ្លានៅកណ្ដាលសម្រាប់សត្វពាហនៈ ព័ទ្ធជុំវិញដោយបន្ទប់ជញ្ជាំងតូចៗជាទីដែលកន្លែងមនុស្សស្នាក់នៅ។ បន្ទប់ទាំងនេះអនុញ្ញាតឱ្យភ្ញៀវនៅខ្ពស់ជាងសត្វពាហនៈរបស់ពួកគេ ព្រមទាំងមានទ្វាបើកចំហដើម្បីម្ចាស់ទាំងឡាយ អាចមើលឃើញសត្វពាហនៈរបស់ពួកគេ។ ការបកប្រែរបស់យ៉ូសែប ស្ម៊ីធពីលូកា 2:7 បង្ហាញថាពុំមានបន្ទប់សម្រាប់ពួកគេទេនៅក្នុង «សណ្ឋាគារទាំងឡាយ» ដោយបង្ហាញថាបន្ទប់ទាំងអស់នៃសាលាសំណាក់ត្រូវបានពេញអស់ហើយ។

គំនិតដែលថា អ្នកថែរក្សាសណ្ឋាគារមិនពេញចិត្ត នឹងឱ្យស្នាក់នៅ ឬស្អប់នោះពុំត្រឹមត្រូវទេ។ ដោយពុំសង្ស័យទេ មនុស្សនៅជំនាន់នោះ ពុំមាន—ភាពស្អប់ខ្ពើមខ្លាំងដូចជាមនុស្សសម័យនេះទេ។ ជាធម្មតា តើនេះជាការពិតទេ នៅពេលដែលអត្រាប្រជាជនធម្មតានៃយេរូសាឡឹម និងបេថ្លេហិមដែលនៅជិតនោះត្រូវបានពេញដោយសាច់ញាតិរបស់ប្រជាជនដែលរស់នៅក្នុងតំបន់។ នៅឯសាលាសំណាក់របស់ប្រជាជនអាស៊ី សត្វពាហនៈត្រូវបានការពារនៅពេលយប់នៅជ្រុងទីធ្លាសាលាសំណាក់។ នៅទីធ្លានោះមានលា, ឆ្កែ, ចៀម, អាចមានគោ និងអូដ្ឋ រួមទាំងក្លិនស្អុយនៃសត្វពាហនៈទាំងនោះ។

ដោយសារតែទីសំណាក់ទទួលភ្ញៀវនៅជុំវិញទីធ្លាត្រូវបានពេញ ទើបយ៉ូសែបបានសម្រេចចិត្តដើម្បីថែទាំការឆ្លងទន្លេរបស់ម៉ារានៅកណ្ដាលទីធ្លានៃសាលាសំណាក់ រួមជាមួយនឹងសត្វ។ វាពិតជាអាចធ្វើទៅបានដែលថានៅក្នុងកាលៈទេសៈដ៏រៀបទាបកូនចៀមនៃព្រះត្រូវបានប្រសូតមក។

ពីរដងនៅក្នុងលូកាទី 2 សេចក្ដីយោងត្រូវបានធ្វើឡើងដោយការរុំនឹងសំពត់។ តើឃ្លាថា «រុំទ្រង់នឹងសំពត់» មានអត្ថន័យដូចម្ដេច លូកា2:7)? ខ្ញុំយល់ពីភាពអស្ចារ្យលើសពីការប្រើកន្ទបធម្មតា ឬការទទួលយកភ្ជួយ។ ជំនួសពាក្យទាំងប្រាំនោះដែលប្រើនៅក្នុងអត្ថបទភាសាអង់គ្លេស ពាក្យតែមួយគត់ដែលត្រូវបានប្រើនៅក្នុងអត្ថបទភាសាក្រិកនៃសញ្ញាថ្មី។ ពាក្យនោះគឺ *sparganoo* ជាកិរិយាសព្ទមានន័យថា រុំទារកទើបតែកើតជាមួយនឹងក្រណាត់ដ៏ពិសេស ត្រូវបានដកយកមករុំពីជាយម្ខាងទៅជាយម្ខាង។[4] ក្រណាត់សំពត់ប្រាកដជាមានសញ្ញាសម្គាល់ដែលតំណាងឱ្យក្រុមគ្រួសារ។ របៀបនោះត្រូវបានអនុវត្តជាពិសេសដល់កំណើតកូនប្រុសដំបូង។

ទេវតាបានប្រកាសថា «ហើយនេះជាទីសម្គាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរសមួយរុំនឹងសំពត់ផ្ដេកនៅក្នុងស្នូក» (លូកា2:12)។ សាច់ក្រណាត់ដែលរុំទ្រង់ប្រាកដណាស់ថា ជាសញ្ញាដែលអាចទទួលស្គាល់បាន។

ចុះស្នូកវិញ? អ្នកនិយាយភាសាបារាំងនឹងស្គាល់ថា *manger* មានន័យថា «ញាំ។» ស្នូក គឺជាស្នូកដាក់ចំណីសត្វ ឬប្រអប់ចំហដែលរចនាឱ្យឈរបាន ដើម្បីផ្ទុកចំណីសម្រាប់សត្វ។ ខ្ពស់ផុតពីដី ផុតពីទីធ្លាដ៏ក្រខ្វក់ ស្នូកប្រហែលជាទីកន្លែងដ៏ស្អាតបំផុត។ ស្នូកដាក់ចំណីសត្វប្រភេទនោះបានក្លាយទៅជាអង្រឹងសម្រាប់ព្រះអម្ចាស់របស់យើង!

## ខ្សែស្រឡាយដ៏អស្ចារ្យរបស់ព្រះអង្គសង្គ្រោះ

អ្វីដែលសំខាន់ជាង ការប្រសូតមករបស់ព្រះអង្គសង្គ្រោះ នៅទីដែលរាបទាបនោះ គឺខ្សែស្រឡាយដ៏អស្ចារ្យរបស់ទ្រង់។ បទគម្ពីរជាច្រើនចោទសួរថា «តើនរណានឹងប្រកាសបាប់នៅសម័យជំនាន់របស់ទ្រង់?» អេសាយ 53:8 កិច្ចការ 8:33 ម៉ូសាយ 14:8 15:10)។ នេះមានន័យថា «តើនរណានឹងប្រកាសពីពង្សប្រវត្តិរបស់ទ្រង់?» ឥឡូវនេះ ពីរសហវត្សក្រោយមក យើងប្រកាសថា ព្រះយេស៊ូវជាព្រះគ្រីស្ទត្រូវបានប្រសូតមកពីបិតាអមតភាព និងពីម្ដាយមតភាព។ មកពីព្រះវរបិតារបស់ទ្រង់ ព្រះយេស៊ូវបានទទួលនូវអំណាចដើម្បីរស់នៅជារាងរហូត។ មកពីម្ដាយមតៈភាពរបស់ទ្រង់ ទ្រង់បានទទួលនូវសេចក្ដីស្លាប់ខាងរូបកាយ។

ព្រះយេស៊ូវទទួលស្គាល់នូវភាពពិតទាំងនេះនៅពេលដែលវាបានជះឥទ្ធិពលដល់ជីវិតរបស់ទ្រង់ ៖ ទ្រង់បានមានព្រះបន្ទូលថា «គ្មានអ្នកណាដកយកជីវិតពីខ្ញុំបានទេ» «គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ។ ខ្ញុំអាចនឹងដាក់ជីវិតនេះចុះ ហើយក៏អាចនឹងយកមកវិញបានដែរ។ ខ្ញុំបានទទួលអំណាចនេះពីព្រះវរបិតាខ្ញុំមក» (យ៉ូហាន 10:18)។

លក្ខណៈដ៏អស្ចារ្យនៃខ្សែស្រឡាយទាំងនោះរបស់ទ្រង់គឺមានសារៈសំខាន់សម្រាប់បេសកកម្មរបស់ទ្រង់ដើម្បីធ្វើឱ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក។ ហេតុដូច្នេះហើយ ព្រះយេស៊ូវដ៏ជាព្រះគ្រីស្ទត្រូវបានប្រសូតមកដើម្បីសុគត និងរស់ឡើងវិញដើម្បីជីវិតដ៏អស់កល្បជានិច្ច (សូមមើលនីហ្វៃទី 3 27:13–15)។ ទ្រង់សុគតដើម្បីឱ្យយើងអាចបានរស់ម្ដងទៀត។ ទ្រង់ប្រសូតមកដើម្បីឱ្យមនុស្សទាំងអស់ អាចរួចពីចំណងនៃសេចក្ដីស្លាប់ និងឈ្នះសេចក្ដីស្លាប់ (សូមមើល កូរិនថូសទី 1 15:55 ម៉ូសាយ 16:7–8 អាលម៉ា 22:14 មរមន 7:5)។

ដង្វាយធួនរបស់ទ្រង់ត្រូវបានមកនៅក្នុងសួនគែតសេម៉ានី ជាកន្លែងដែលទ្រង់ហូរលោហិតចេញពីគ្រប់រន្ធញើស (សូមមើល លូកា 22:44) និងនៅគាល់កូថា (ឬកាវ៉ារីយ៉ូ) ជាកន្លែងដែលរូបកាយរបស់ទ្រង់ត្រូវបានលើកឡើងលើឈើឆ្កាង «លើភ្នំរលាក្បាល» ដែលតំណាងឱ្យសេចក្ដីស្លាប់ (ម៉ាកុស 15:22 ម៉ាថាយ 27:33សូមមើលផងដែរនីហ្វៃទី 3 27:14)។ ដង្វាយធួនដែលគ្មានទីបញ្ចប់នេះ នឹងរំដោះមនុស្សពីសេចក្ដីស្លាប់ដែលមិនចេះចប់ (សូមមើល នីហ្វៃទី 2 9:7)។ ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះបានធ្វើឱ្យការរស់ឡើងវិញជាការពិតមួយ និងជីវិតដ៏អស់កល្បជានិច្ចអាចមានដល់មនុស្សទាំងអស់។ ដង្វាយធួនទ្រង់បានក្លាយទៅជាកិច្ចការដ៏សំខាន់ចំពោះប្រវត្តិសាស្ត្រនៃមនុស្សលោកទាំងអស់។

ចំណុចសំខាន់របស់វាគឺត្រូវបានបញ្ជាក់ដោយ ព្យាការី យ៉ូសែប ស្ម៊ីធ ដែលលោកបានមានប្រសាសន៍ថា «គោលការណ៍ដ៏សំខាន់នៃសាសនាចក្ររបស់យើង គឺជា *ទីបន្ទាល់* នៃពួកសាវក និងពួកព្យាការី អំពីព្រះយេស៊ូវគ្រីស្ទ ថាទ្រង់បានសុគត ត្រូវបានគេកប់ ហើយបានរស់ឡើងវិញនៅថ្ងៃទីបី ហើយបានយាងឡើងទៅស្ថានសួគ៌ ហើយរឿងផ្សេងទៀតដែលទាក់ទងនឹងសាសនារបស់យើង គឺជារឿងបន្ទាប់បន្សំប៉ុណ្ណោះ»។[5]

ការប្រកាសនេះគឺជាការបំផុសដ៏មុតមាំដែលបានដឹកនាំគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្នុងអំឡុងប៉ុន្មានឆ្នាំមុន នៅពេលដែលយើងកំពុងតែពិភាក្សាពីខួបលើកទី 2,000 ឆ្នាំនៃកំណើតរបស់ព្រះអង្គសង្គ្រោះ។ យើងជាបុរសទាំង 15 នាក់ ដែលមានកូនសោទាំងឡាយនៃនគរ បានរៀបចំទីបន្ទាល់ជាលាយលក្ខណ៍អក្សររបស់យើង។ យើងបានដាក់ចំណងជើងថា «ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក»។[6] សាវកម្នាក់ៗនៃសាវក 15 នាក់បានរស់នៅដោយស្មោះតាមទីបន្ទាល់ដែលពួកគាត់បានចុះហត្ថលេខា។

ដោយសេចក្ដីជំនឿ បុគ្គលម្នាក់ៗដែលមានទីបន្ទាល់អំពីព្រះអម្ចាស់មានអភ័យឯកសិទ្ធិ ដើម្បីដឹងពីខ្សែស្រឡាយដ៏ទេវភាពរបស់ទ្រង់ និងដើម្បីថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះដែលមានព្រះជន្មរស់។ ទីបន្ទាល់ដ៏ពិតរួមមានទាំងសេចក្ដីពិតដែលព្រះវរបិតា និងព្រះរាជបុត្រាបានបង្ហាញដល់ យ៉ូសែប ស្ម៊ីធ ដែលកំណើតរបស់ទ្រង់យើងធ្វើការរំឭកចងចាំនៅថ្ងៃទី 23 ខែ ធ្នូ។ ទីបន្ទាល់នោះរួមមានទាំងសេចក្ដីពិតដែលថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាពិត ហើយត្រូវបានដឹកនាំដោយព្រះអម្ចាស់ដែលមានព្រះជន្មរស់តាមរយការព្យាករណ៍ និងវិវរណៈតាមរយៈពួកអ្នកបម្រើដែលមានសិទ្ធអំណាចដែលទទួល និងអនុវត្តតាមការណែនាំមកពីទ្រង់។

ទោះបីជាស្ថិតក្នុងពេលវេលាដ៏ច្របូកច្របល់នៃជីវិតនាសម័យទំនើបនេះ ចំណេះដឹងនេះនាំឱ្យយើងមានសេចក្ដីអំណរ និងសេចក្ដីសុខសាន្ត។ លោកចៅហ្វាយបានមានបន្ទូលថា «ចូរសង្ឃឹមឡើង» «ហើយចូរកុំខ្លាចឡើយ ត្បិតយើងជាព្រះអម្ចាស់គង់នៅជាមួយនឹងអ្នក ហើយនឹងឈរនៅក្បែរអ្នក ហើយអ្នកនឹងថ្លែងទីបន្ទាល់អំពីយើង គឺព្រះយេស៊ូវគ្រីស្ទ ថាយើងជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ ថាយើងគង់នៅតាំងពីដើម ហើយយើងនៅឥឡូវនេះ ហើយថាយើងត្រូវយាងមកទៀត»



*ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះបានធ្វើឱ្យការរស់ឡើងវិញជាការពិតមួយ និងជីវិតដ៏អស់កល្បជានិច្ចអាចមានដល់មនុស្សទាំងអស់។ ដង្វាយធួនរបស់ទ្រង់បានក្លាយទៅជាកិច្ចការដ៏សំខាន់ចំពោះប្រវត្តិសាស្ត្រនៃមនុស្សលោកទាំងអស់។*

ព្រះគ្រីស្ទនៅក្នុងសួនច្បារគែតសេម៉ានី ដោយហែនរិច ហូហ្វម៉ាន រូបភាពនៃសាសនាចក្រ

(គ. និង. ស 68:6)។ យើងតោងជាប់ទៅនឹងសេចក្ដីសន្យាដ៏បរិសុទ្ធរបស់ទ្រង់ ដោយសេចក្ដីស្រឡាញ់។

**អំណោយរបស់យើងដល់ទ្រង់**

ថ្ងៃដ៏ពិបាកនៅខាងមុខ អំពើបាបកំពុងតែរីកចម្រើនឡើង។ ប៉ុលបានព្យាករណ៍ថាសមាជិកទាំងឡាយនៃសាសនាចក្រនឹងស៊ូទ្រាំនូវការបៀតបៀន (សូមមើលធីម៉ូថេទី 2 3:1–13 គ. និង. ស 112:24–26)។ ពេត្រុសបានប្រឹក្សាថា «តែបើរងទុក្ខដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរដំកើងដល់ព្រះដោយព្រោះនាមនោះវិញ» (ពេត្រុសទី 1 4:16)។ ដូចដែលព្រះយេស៊ូវគ្រីស្ទបានបន្ទាបចុះក្រោមអ្វីទាំងអស់ ដើម្បីបានក្រោកឡើងខ្ពស់ជាងអ្វីទាំងអស់ នោះទ្រង់រំពឹងឱ្យយើងធ្វើតាមគំរូរបស់ទ្រង់។ ចូរទឹមជាមួយនឹងទ្រង់ យើងម្នាក់ៗអាចងើបខ្ពស់ជាងរាល់ឧបសគ្គទាំងអស់របស់យើងបាន ពុំថាឧបសគ្គទាំងនោះពិបាកយ៉ាងណានោះទេ (សូមមើលម៉ាថាយ11:29–30)។

សូមពិចារណាពីអ្វីៗទាំងអស់ដែលព្រះអង្គសង្គ្រោះបានធ្វើ—ហើយនៅតែបន្ត—ធ្វើសម្រាប់យើង តើយើងអាចធ្វើអ្វីបានខ្លះសម្រាប់ទ្រង់? អំណោយទានដ៏អស្ចារ្យបំផុតដែលយើងអាចថ្វាយដល់ព្រះអម្ចាស់នៅរដូវបុណ្យគ្រីស្ទម៉ាស់ ឬនៅពេលណាក៏បាន គឺការថែរក្សាខ្លួនរបស់យើងឱ្យបានស្អាតពីលោកិយ ដោយមានភាពសក្ដិសមដើម្បីចូលរួមក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់។ ហើយអំណោយរបស់ទ្រង់ដល់យើងនោះគឺជាសេចក្ដីសុខសាន្តពីការដឹងថា យើងត្រូវបានរៀបចំដើម្បីជួបទ្រង់នៅពេលដែលពេលវេលាមកដល់។

ភាពពោរពេញនៃការបម្រើរបស់លោកចៅហ្វាយមាននៅពេលអនាគត។ ការព្យាករណ៍អំពីការយាងមកជាលើកទីពីររបស់ទ្រង់ពុំទាន់បានបំពេញនៅឡើយទេ។ ជាការពិតណាស់ យើងផ្ដោតសំខាន់ទៅលើកំណើតរបស់ទ្រង់ នៅរដូវគ្រីស្ទម៉ាស់។ ហើយទ្រង់នឹងយាងមកកាន់លោកិយនេះម្ដងទៀត។ នៅការយាងមកជាលើកទីមួយរបស់ទ្រង់ ព្រះយេស៊ូវស្ទើរតែបានយាងមកដោយសេចក្ដីអាថ៌កំបាំង។ មានមនុស្សមតះភាពតែពីរបីនាក់តែប៉ុណ្ណោះដែលបានដឹងពីកំណើតរបស់ទ្រង់។ នៅការយាងមកជាលើកទីពីររបស់ទ្រង់ មនុស្សលោកទាំងអស់នឹងដឹងពីការត្រឡប់មកវិញរបស់ទ្រង់។ ហើយទ្រង់នឹងយាងមក ពុំដូចជា «បុរសដែលធ្វើដំណើរនៅលើផែនដីឡើយ» (គ. និង. ស 49:22)។ ប៉ុន្តែ «នោះសិរីល្អនៃព្រះយេហូវ៉ានឹងសម្ដែងមក គ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា» (អេសាយ 40:5 សូមមើលផងដែរ គ. និង. ស 101:23)។

ក្នុងនាមជាសាក្សីពិសេសនៃព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាដ៏ទេវភាពនៃព្រះដែលមានព្រះជន្មរស់។ ទ្រង់នឹងស្រឡាញ់អ្នក លើកអ្នកឡើង និងបង្ហាញអង្គទ្រង់ដល់អ្នកប្រសិនបើអ្នកស្រឡាញ់ទ្រង់ គោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ (សូមមើលយ៉ូហាន 14:21)។ តាមពិតពួកហោរ៉ា និងស្រ្ដីទាំងឡាយនៅតែបន្តគោរពថ្វាយបង្គំទ្រង់។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានផ្ដល់នៅក្នុងការប្រជុំធម្មនិដ្ឋាននៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ថ្ងៃទី10 ខែ ធ្នូ ឆ្នាំ 2002។ ចំពោះអត្ថបទដ៏ពេញលេញជាភាសាអង់គ្លេស សូមចូលទៅកាន់ speeches.byu.edu។*

**កំណត់ចំណាំ**

1. សូមមើល Eric D. Huntsman, "Glad Tidings of Great Joy," *Ensign,* ខែ ធ្នូ ឆ្នាំ 2010 ទំព័រ 54។
2. សូមមើលពាក្យលេខ 2,596 និង 2,646 នៅក្នុង James Strong, "Greek Dictionary of the New Testament," *Strong's Exhaustive Concordance of the Bible* (ឆ្នាំ 1890), ទំព័រ 39, 40។
3. សូមមើល *Merriam-Webster's Collegiate Dictionary,* លើកទី11។ (ឆ្នាំ 2003), "caravansary" និង "khan."
4. សូមមើលពាក្យលេខ 4,683 នៅក្នុង "Greek Dictionary of the New Testament," ទំព័រ 66។
5. *Teachings of Presidents of the Church: Joseph Smith* (ឆ្នាំ 2007) ទំព័រ 49 បញ្ជាក់បន្ថែម។
6. សូមមើល «ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក» *លីអាហូណា* ខែមេសា ឆ្នាំ 2000 ទំព័រ 2–3។



# ផ្លូវទៅកាន់ព្រះ
# វិហារបរិសុទ្ធ

*ទោះបីជាសមាជិកទាំងឡាយបានជ្រើសរើសយកផ្លូវខុសៗគ្នាក្តី ក៏ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេស អ៊ុយក្រែន កំពុងតែស្វែងរកនូវផ្លូវនៃសេចក្តីសុចរិតទាំងអស់ដើម្បីទៅកាន់ព្រះវិហារបរិសុទ្ធដែរ។*

**ដោយ ឆាដ អ៊ី ហ្វែស**
ទស្សនាវដ្តីសាសនាចក្រ

នៅព្រឹកព្រលឹមស្រាងៗអ្នកធ្វើដំណើរបាននាំគ្នាធ្វើដំណើរតាមផ្លូវគីលស្គីវ៉ា ក្នុងក្រុងឃេយីវ ប្រទេសអ៊ុយក្រែន ដែលមានអ្នកធ្វើដំណើរនៅលើផ្លូវយ៉ាងស្ងប់ស្ងាត់បំផុតទៅកាន់ព្រះវិហារបរិសុទ្ធគីលស្គីវ៉ា ប្រទេសអ៊ុយក្រែន។ មានតែពន្លឺភ្លើងហ្វាពីរបីប៉ុណ្ណោះដែលបំភ្លឺនៅក្នុងអ័ព្ទពេលព្រឹក ខណៈដែលយានយន្តបើកលើក្រឡុកតូចៗ។

ពន្លឺសន្ទៅនៃព្រះវិហារបរិសុទ្ធនៅឯខាងមុខគឺបង្ហាញជាភ្លើងសញ្ញា ដែលជាពន្លឺនាំផ្លូវដែលបង្ហាញដល់ពួកអ្នកធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធដឹងថា តើពួកគេត្រូវទៅទីកន្លែងណាយ៉ាងច្បាស់។

ខណៈដែលមនុស្សមួយចំនួនត្រូវបានប្រទានពរជ័យ ដើម្បីធ្វើដំណើរតាមផ្លូវដ៏ស្ងប់ស្ងាត់នេះទៅកាន់ព្រះវិហារបរិសុទ្ធ ចាប់តាំងពីព្រះវិហារបរិសុទ្ធនេះត្រូវបានឧទិស្សឆ្លងកាលពីខែ សីហា ឆ្នាំ 2010 មកម្ល៉េះ នោះអ្នកដទៃទៀតអាចប្រកាសថាផ្លូវរបស់ពួកគេទៅព្រះវិហារបរិសុទ្ធមិនស្ងប់ស្ងាត់ដូចនេះទេ។

នៅពេលដែលព្រឹកព្រលឹមចូលមកដល់ ហើយព្រះអាទិត្យ រះនៅឯជើងមេឃ នោះមានយានជំនិះ និងឡានក្រុងជាច្រើនបើកបរនៅលើផ្លូវ គីលស្គីវ៉ា។ ឥឡូវនេះ យានជំនិះកកកុញ ហើយវិធីដ៏ស្ងប់ស្ងាត់នេះក្លាយទៅជាចំណតឡានដ៏អ៊ូរអរ។

ដោយដឹងហើយថាចរាចរណ៍គឺជាផ្នែកមួយនៃការបើកបរ នោះមានអ្នកទៅព្រះវិហារបរិសុទ្ធជាច្រើនបន្តនៅលើផ្លូវនេះ ដោយឆ្ពោះទៅមុខពីរបីជំហានម្តង មុនបន្តទៅចំណតខាងមុខទៀត។ ព្រះវិហារបរិសុទ្ធគឺនៅតែជាទិសដៅ ប៉ុន្តែការបើកបរមានសភាពយឺតៗ។

អ្នកដទៃទៀតបានជ្រើសរើសបើកតាមវិថីផ្សេងៗ។ នៅខាងក្រោយព្រះវិហារបរិសុទ្ធគឺមានផ្លូវលំ និងផ្លូវជនបទជាច្រើន។ ផ្លូវនោះពុំបានគូសសម្គាល់បានច្បាស់លាស់ឡើយ ហើយពួកអ្នកបើកបរក៏អាចបត់ចុះឡើងបានតាមចិត្តយ៉ាងងាយស្រួល។ ទោះជាយ៉ាងណាក្តី ប្រសិនបើពួកអ្នកបើកបរងាកមើលទៅលើ នោះគាត់អាចមើលឃើញកំពូលព្រះវិហារបរិសុទ្ធ ជាថ្មីម្តងទៀត កំពូលនេះបម្រើការដឹកនាំ ដោយអញ្ជើញមនុស្សទាំងអស់ឱ្យមកកាន់ព្រះវិហារបរិសុទ្ធ។

ផ្លូវខាងវិញ្ញាណដែលសមាជិកនៅប្រទេសអ៊ុយក្រែន បានជ្រើសរើស ទៅកាន់ដំណាក់របស់ព្រះអម្ចាស់គឺមិនដូចជាផ្លូវដែលនៅជុំវិញព្រះវិហារបរិសុទ្ធនោះទេ។

ខណៈពេលដែលសមាជិកវ័យក្មេងជាច្រើនបានទទួលពរជ័យដោយធំឡើងនៅក្នុងសាសនាចក្រ ហើយឥឡូវនេះអាចចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធ ឃេយីវ ប្រទេសអ៊ុយក្រែន ដើម្បីទទួលកិច្ចការនៃពិធីបរិសុទ្ធរបស់ពួកគេផ្ទាល់ នោះមានមនុស្សជាច្រើនទៀត បានធ្វើដំណើរឆ្លងកាត់ចរាចរណ៍ខាងវិញ្ញាណដ៏ច្រើនរបស់ពួកគេដើម្បីទៅព្រះវិហារបរិសុទ្ធ។

ព្រះវិហារបរិសុទ្ធនេះបានត្រូវប្រកាសសាងសង់នៅក្នុងឆ្នាំ 1998 ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី (ឆ្នាំ1910–2008) ត្រូវ

ថតរូបដោយ ម៉ារីណា លូតាង







*ខាងលើ ៖ អាស៊ីយ៉ា និងនីកូឡៃ ឈីមីស្សូវ ត្រូវបានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ យេឃីវ អ៊ុយក្រែន នៅបីថ្ងៃបន្ទាប់ពីព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លង។ ភីត្រោ និងអាដាលីនា មីយេលេនកូ មានអំណរគុណណាស់ដែលចៅស្រីរបស់ពួកគាត់ ម៉ាស្ហា រង់ចាំដល់ការចូលនៅក្នុងព្រះវិហារបរិសុទ្ធនៅទឹកដីកំណើតរបស់ខ្លួន។ អេនឌ្រេ និងវ៉ាលីនធីណា ឌូឌកាបានទៅទស្សនកិច្ចនៅព្រះវិហារបរិសុទ្ធជាញឹកញាប់ចាប់តាំងពីព្រះវិហារបរិសុទ្ធបានសង់រួច។*

បាន សង់រួចនៅឆ្នាំ 2010។ នៅក្នុងអំឡុង 12 ឆ្នាំនោះ សមាជិកស្តេកយេឃីវ ប្រទេសអ៊ុយក្រែន ជាច្រើនបានបន្តដើរលើផ្លូវតូចនោះ—ទោះបីជាវាហាក់ដូចជារីកចម្រើនដ៏យឺតក្តី—ក៏រង់ចាំដោយចិត្តអំណត់ដើម្បីឱ្យការ សង់ព្រះវិហារបរិសុទ្ធរួចចប់សព្វគ្រប់ផងដែរ។ មនុស្សផ្សេងទៀតបានជ្រើសរើសយកផ្លូវខុសគ្នា ដោយបាត់បង់នូវចក្ខុវិស័យនៃគោលដៅទៅព្រះវិហារបរិសុទ្ធរបស់ពួកគេមួយរយៈ។

ទោះបីជាសមាជិករើសយកផ្លូវខាងវិញ្ញាណដើម្បីទៅព្រះវិហារបរិសុទ្ធខុសៗគ្នាក្តី ក៏សមាជិកសាសនាចក្រដ៏ស្មោះស្ម័គ្រនៅក្នុងប្រទេសអ៊ុយក្រែន គឺកំពុងស្វែងរកផ្លូវសុចរិតទាំងឡាយដែលដឹកនាំពួកគេទៅព្រះវិហារបរិសុទ្ធ។

## ផ្លូវត្រង់

សមាជិកមជ្ឈិមវ័យជាច្រើននៅអឺរ៉ុបភាគខាងកើត គឺត្រូវបានដឹកនាំទៅរកដំណឹងល្អនៅវ័យក្មេង។ ចំណេះដឹងនៃដំណឹងល្អក្នុងភាពវ័យក្មេងនេះ មិនត្រឹមតែបានផ្តល់ឱ្យពួកគេបណ្តុះនូវទីបន្ទាល់របស់ពួកគេតាំងពីវ័យក្មេងនោះទេ ប៉ុន្តែក៏ដើម្បីស្ថាបនានូវបំណងប្រាថ្នាដ៏ខ្លាំងក្លាដើម្បីរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ។

ទាំងនីកូឡៃ ឈីមីស្សូវ និងភរិយារបស់លោក អ្នកស្រីអាស៊ីស៉ា មកពីរ៉ូដ ហាគីវស្គី ត្រូវបានណែនាំឱ្យស្គាល់ពីដំណឹងល្អនៅក្នុងយុវវ័យរបស់ពួកគេ—កាលនីកូឡៃ ជាកុមារមានអាយុប្រាំបីឆ្នាំ និងអាស៊ីយ៉ាក្នុងវ័យជំទង់។

បងប្រុស ឈីមីស្សូវ មានប្រសាសន៍ថា «តាំងពីខ្ញុំបានទទួលបុណ្យជ្រមុជទឹក ខ្ញុំបានដឹងថាផែនការរបស់ព្រះវរបិតាគឺជាផ្លូវការលើកដំកើង»។ «ការបង្រៀនរបស់សាសនាចក្រអំពីបេសកកម្មដ៏ទេវភាពនៃ ក្រុមគ្រួសារតែងតែជារឿងសំខាន់សម្រាប់ខ្ញុំ»។

ស៊ីស្ទើរ ឈីមីស្សូវ៉ា ក៏ដឹងពីសារៈសំខាន់នៃគ្រួសារដ៏នៅអស់កល្បជានិច្ចតាំងពីនៅវ័យក្មេងផងដែរ។ គាត់បាននិយាយថា «នៅពេលដែលខ្ញុំចូលរួមក្នុងសាសនាចក្រកាលពីនៅជាយុវនារី ខ្ញុំត្រូវបានបង្រៀនពីសារៈសំខាន់នៃការចូលក្នុងសេចក្តីសញ្ញាដ៏ពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ»។ «ខ្ញុំតែងតែ សុបិនដល់អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ហើយខ្ញុំតែងតែព្យាយាមឱ្យមានភាពសក្តិសម ដើម្បីរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ»។

ប្តីប្រពន្ធរូបនេះបានចាប់ផ្តើមដើរលេងជាគូរជាមួយគ្នាកាលពីឆ្នាំ 2009។ នៅពេលដែលសេចក្តីស្នេហារីកឡើង ហើយការផ្តោះផ្តងស្នេហាឆ្ពោះទៅរកអាពាហ៍ពិពាហ៍ នោះបុគ្គលទាំងពីរូបនេះបានដឹងរួចហើយនូវជំហានបន្ទាប់របស់ពួកគេ។ ស៊ីស្ទើរ ឈីមីស្សូវ៉ា និយាយថា «នៅពេលដែលពួកគេបានប្រកាសថា ព្រះវិហារបរិសុទ្ធយេឃីវ នឹងត្រូវឧទ្ទិសឆ្លងនៅខែ សីហា ឆ្នាំ 2010 នោះពួកយើងបានសម្រេចចិត្តថា ពួកយើងនឹងធ្វើពិធីផ្សាភ្ជាប់នៅទីនោះ»។

បងប្រុស ឈីមីស្សូវនិយាយបន្ថែមថា «វាជាការណ៍ល្អណាស់ដែលយើងពុំចាំបាច់ត្រូវរង់ចាំយូរពេកនោះ»។

ប្តីប្រពន្ធមួយគូនេះត្រូវបានផ្សាភ្ជាប់ជាអាពាហ៍ពិពាហ៍នៅថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2010។

បងប្រុស ឈីមីស្សូវ មានប្រសាសន៍ថា «កាលនោះវាគឺជាថ្ងៃដ៏អស្ចារ្យបំផុតសម្រាប់ជីវិតរបស់ខ្ញុំ»។ «ខ្ញុំបានមានអារម្មណ៍ថា វាគឺជាពរជ័យដែលខ្ញុំបានកាន់ដៃអាស៊ីស៉ាជាទីស្រឡាញ់របស់ខ្ញុំ ហើយយកនាងទៅដំណាក់នៃព្រះអម្ចាស់។ វាមានសុវត្ថិភាពណាស់ដើម្បីនិយាយថា នៅថ្ងៃនោះសុបិនរបស់ខ្ញុំបានក្លាយជាការពិត—សុបិននៃការបង្កើតក្រុមគ្រួសារដ៏អស់កល្បមួយ»។

## ផ្លូវដ៏វែងឆ្ងាយ

ទោះបីជាផ្លូវទៅកាន់អាពាហ៍ពិពាហ៍ដ៏អកល្បជានិច្ចគឺត្រង់សម្រាប់សមាជិករ៉ូដ ភីត្រោ និងអាដាលីនា មីយេលេនកូក្នុងតំបន់ វីនូរាដាស្គី ក្តី ក៏ផ្លូវនោះនៅតែវែងឆ្ងាយ ដែរ។ ក្រុមគ្រួសាររបស់ មីយេលេនកូ គថិត

ខាងលើ ៖ រូបថតរបស់ក្រុមគ្រួសារឈីមីស្សូវ រូបថតផ្សេងទៀតដោយ ចាង អ៊ី. ផារីស

ក្នុងចំណោមក្រុមគ្រួសារដំបូងមួយដែលចូលរួមនៅក្នុងសាសនាចក្រ នៅប្រទេសអ៊ុយក្រែន ដែលបានទទួលបុណ្យជ្រមុជទឹកកាលពីឆ្នាំ 1993—ត្រឹមតែពីរឆ្នាំក្រោយពីសាខាដំបូងត្រូវបានបង្កើតឡើងនៅក្នុងក្រុងយេយីវ។

ថ្វីបើរស់នៅឆ្ងាយ ពីព្រះវិហារបរិសុទ្ធ និងកត្តាផ្សេងៗទៀតដែលបានបង្ខាំងប្ដីប្រពន្ធមួយគូនេះ មិនបានផ្សារភ្ជាប់សម្រាប់ពេលជាច្រើនឆ្នាំក្ដី។ ដោយពុំរុញរា ពួកគាត់នៅតែបន្តប្ដេជ្ញាចិត្តចំពោះគ្នាទៅវិញទៅមក និងចំពោះក្ដីសុបិនរបស់ពួកគាត់ទៅលើអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច។

បងប្រុស មីយេលេនកូ មានប្រសាសន៍ថា «ខ្ញុំបានរង់ចាំព្រះវិហារបរិសុទ្ធដោយមានចិត្តអំណត់»។ «ខ្ញុំពុំដែលមានគំនិតដើម្បីចាកចេញពីសាសនាចក្រ ទេ។ ផ្លូវតែងតែ ច្បាស់លាស់ជានិច្ច»។

បន្ទាប់ពីប្រធាន ថូម៉ាស អេស ម៉នសុន បានធ្វើការឧទ្ទិស្ឋឆ្លងព្រះវិហារបរិសុទ្ធនៅខែ សីហា ឆ្នាំ 2010 បំណងប្រាថ្នាដ៏ខ្លាំងក្លារបស់គូស្វាមីភរិយាមួយគូនេះគឺមិនអាចបញ្ឈប់បានឡើយ។ ស៊ីស្ទើរ មីយេលេនកូនិយាយថា «យើងបានមកដល់លឿននៅថ្ងៃដែលយើងត្រូវបានផ្សារភ្ជាប់ ដែលព្រះវិហារបរិសុទ្ធពុំទាន់បានបើកទ្វារនៅឡើយទេ»។

គូស្វាមីភរិយារូបនោះពុំនៅម្នាក់ឯងនោះទេ។ សមាជិករួមជាច្រើនបានមកកាន់ព្រះវិហារបរិសុទ្ធនៅថ្ងៃនោះផងដែរ ដោយមានចិត្តរំភើបដើម្បី ចូលរួមចំណែកនឹងសេចក្ដីអំណររបស់ មីយេលេនកូ។

ស៊ីស្ទើរ មីយេលេនកូ និយាយថា «ពិធីផ្សារភ្ជាប់គឺអស្ចារ្យណាស់»។ «នៅពេលនោះមានអារម្មណ៍មួយកើតឡើង ដូចជាអ្នកមិនដែលបានស្រឡាញ់បរបស់អ្នក ដូចដែលអ្នកស្រឡាញ់គាត់នៅក្នុងគ្រានោះឡើយ»។

អារម្មណ៍នៃសេចក្ដីស្រឡាញ់មាននៅស្ថិតស្ថេរតាំងពីថ្ងៃនោះមក។ បងប្រុស មីយេលេនកូ មានប្រសាសន៍ថា «មានទំនាក់ទំនងដ៏ខុសប្លែកមួយនៅក្នុងពួកយើង»។ «យើងបានរៀបការអស់រយៈពេលយ៉ាងយូរ ប៉ុន្ដែពេលនេះយើងបែរជាមានអារម្មណ៍ខុសប្លែក។ យើងចង់ធ្វើអ្វីៗជាច្រើនសម្រាប់គ្នាទៅវិញទៅមក ហើយយើងធ្វើដោយមានសេចក្ដីស្រឡាញ់កាន់តែច្រើន»។

> *ព្រះវិហារបរិសុទ្ធ យេយីវ អ៊ុយក្រែន គឺជាព្រះវិហារបរិសុទ្ធដែលកំពុងប្រតិបត្តិការណ៍ទី 134 ដោយបម្រើដល់សមាជិកមកពីប្រទេសចំនួនប្រាំបួន។*

## ត្រឡប់ទៅលើផ្លូវវិញ

អេនទ្រេ្យ និង វ៉ាលីនធីណា ខូឧកា មកពីរ៉ូដ វីណូរាដាស្គី ត្រូវបានណែនាំឱ្យស្គាល់ដំណឹងល្អដោយអ្នកជិតខាងរបស់ខ្លួននៅឆ្នាំ 2003។ បន្ទាប់ពីការជួបជុំគ្នាជាច្រើនសប្ដាហ៍ជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនាមក គូស្វាមីភរិយារូបនេះបានសម្រេចចិត្តដើម្បីចូលរួមនៅក្នុងសាសនាចក្រ។

ទោះបីជា ក្រុមគ្រួសាររបស់ខូឧកាស មានចិត្តរំភើបរីករាយដើម្បីរៀនពីសេចក្ដីពិតដំណឹងល្អ ដែលជាតម្រូវការសម្រាប់ទៅព្រះវិហារបរិសុទ្ធនៅថ្ងៃចុងក្រោយ ហើយសក្ដានុពលនៃការមានក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច នោះបានដឹកនាំទៅរកការមានសកម្មភាពបន្តិចម្ដងៗ។ ស៊ិស្ទើរ ខូឧកា មានប្រសាសន៍ថា «យើងទើបតែរកឃើញមូលហេតុដែលយើងមិនទៅព្រះវិហារ»។ «យើងបណ្ដោយឱ្យមានរឿង—ដូចជាយើងអស់កម្លាំងខ្លាំងពេក ឬមានកម្មវិធីសំដែងតាមទូរទស្សន៍ដែលយើងចង់មើលវិញនោះ»។

ក្រុមគ្រួសាររបស់ ខូឧកាស បានខ្វះធ្វើនូវសកម្មភាពដែលវាបានធ្វើឱ្យប៉ះពាល់ដល់សុភមង្គលរបស់ពួកគេ។ បងប្រុសខូដ មានប្រសាសន៍ថា «យើងចាប់ផ្ដើមមើលឃើញពីភាពខុសគ្នាពិតប្រាកដរវាងជីវិតនៅក្នុងសាសនាចក្រ និងជីវិតនៅខាងលោកិយ បន្ទាប់ពីយើងបានចាកចេញពីសាសនាចក្រ»។ «យើងមិនសប្បាយនោះទេ»។

ប្រហែលជាបួនខែដែលមិនបានចូលរួមនៅក្នុងសាសនាចក្រនោះ ស៊ិស្ទើរ ខូឧកា បានឈានដល់ចំនុចបែកបាក់របស់គាត់។ គាត់បាននិយាយថា «នៅថ្ងៃអាទិត្យបានមកដល់ហើយខ្ញុំបាននិយាយថា «ប្រសិនបើខ្ញុំមិនទៅនៅថ្ងៃនេះទេ ខ្ញុំមិនអាចរស់បានទេ»។ «ខ្ញុំហាក់ដូចជាមនុស្សរស់នៅដោយគ្មានទឹកអស់ជាច្រើនថ្ងៃ។ ខ្ញុំត្រូវការទឹកនោះ»។ បន្ទាប់ពីការត្រឡប់ទៅរកសកម្មភាពវិញ ស៊ិស្ទើរ ខូឧកាបានអធិស្ឋានដោយមានចិត្តអំណត់ ហើយបានលើកទឹកចិត្តឱ្យស្វាមីរបស់គាត់ត្រឡប់មកព្រះវិហារជាមួយគាត់វិញ។ ប្រហែលជាមួយឆ្នាំកន្លះក្រោយមក គាត់បានត្រឡប់មកព្រះវិហារវិញ ហើយស្វាមីរបស់គាត់ដូចគ្នាដែរ។

បងប្រុស ខូឧកា និយាយថា «ការអធិស្ឋានរបស់ភរិយាខ្ញុំ បានជះឥទ្ធិពលដល់ខ្ញុំ»។ «ខ្ញុំបានចាប់ផ្ដើមដឹងថា ក្នុងនាមជាអ្នកកាន់បព្វជិតភាពមិលគីស្សាដែកម្នាក់ ខ្ញុំមានទំនួលខុសត្រូវដើម្បីធ្វើជាសមាជិកសកម្ម។ ខ្ញុំបានចាប់ផ្ដើមដឹងថា បើគ្មានព្រះទេ នោះខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់»។

បន្ទាប់ពីក្រុមគ្រួសាររបស់ ខូឧកាស បានត្រឡប់មកសាសនាចក្រវិញ គំនិតរបស់ពួកគាត់បានគិតទៅដល់ពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធ។ គូស្វាមីភរិយា នេះបានចូលជាមួយនឹងពួកបរិសុទ្ធថ្ងៃចុងក្រោយជាជាតិអ៊ុយក្រែនដទៃទៀត នៅក្នុងការរីករាយនឹងពិធីសម្ពោធនៃព្រះវិហារបរិសុទ្ធក្នុងឆ្នាំ 2007។

បងប្រុស ខូឧកា មានប្រសាសន៍ថា «បន្ទាប់ពីពួកគេបានចាប់ផ្ដើមសាងសង់ព្រះវិហារបរិសុទ្ធ យើងបានមកមើលជាញឹកញាប់ ហើយមើលការធ្វើការ សង់នោះ»។

ស៊ីស្ទើរខូឧកា បានបន្ថែមថា «ខ្ញុំបានលោតយ៉ាងខ្ពស់ នៅពេលដែលខ្ញុំបានឃើញពួកគេរៀបថ្មដំបូងឡើង»។

នៅពេលដែលរូបភាពរបស់ទេវតាម៉ូរ៉ូណៃ ត្រូវបានដំឡើងនៅលើកំពូលព្រះវិហារបរិសុទ្ធ គឺមាននូវការឱប និងទឹកភ្នែកនៅក្នុងចំណោមពួកបរិសុទ្ធជាច្រើន ជាពិសេសគឺនៅក្នុងក្រុមគ្រួសាររបស់ខូឧកាស។

បងប្រុស ខូឧកាមានប្រសាសន៍ថា «នៅពេលដែលពួកគេបានសង់ព្រះវិហារបរិសុទ្ធរួច យើងមានអារម្មណ៍ធូរស្រាលណាស់ នៅពេលដែលដឹងថាយើងមានភាពសក្តិសមដើម្បីចូលក្នុងព្រះវិហារបរិសុទ្ធ»។

ក្រុមគ្រួសារ ខូឧកាស និយាយថា ការត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ បានធ្វើឱ្យពួកគេកាន់តែរឹងមាំផ្អែកជីវិតដ៏នៅអស់កល្បជានិច្ចខាងមុខ។ ស៊ិស្ទើរ ខូឧកា មានប្រសាសន៍ថា «អ្នកចាប់ផ្ដើមយល់ថា ក្រុមគ្រួសាររបស់អ្នកមិនមានតែអ្នក និងស្វាមីរបស់អ្នកប៉ុណ្ណោះនោះទេ—ឥឡូវនេះព្រះអម្ចាស់គឺជាផ្នែកមួយរបស់អ្នក»។ «ឥឡូវនេះយើងសម្លឹងមើលគ្នាទៅវិញទៅមកដោយកែវភ្នែកដ៏នៅអស់កល្បជានិច្ច»។ ■

## ការប្រារព្ធពិធីលើកទី 10 នៃកម្មវិធីមូលនិធិអប់រំដែលមានជាបន្តបន្ទាប់

# គន្លឹះនាំទៅរកឱកាស



*រយៈពេលមួយទសវត្សរ៍ ក្រោយពីប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានប្រកាសពីមូលធិអប់រំដែលមានជាបន្តបន្ទាប់ ទាំងអ្នកផ្ដើមគំនិត និងអ្នកកម្ចីមូលនិធិល្ងូតលាស់ទៅមុខ។*

**ដោយ រីប៊ីកា អាតឃីន**
ទស្សនាវដ្ដីសាសនាចក្រ

នៅឆ្នាំ 1850 គឺនៅបីឆ្នាំក្រោយពីការមកដល់ជ្រលងភ្នំ សលត៍លេក ប្រធាន ព្រិកហាំ យ៉ង់ (ឆ្នាំ 1801–77) បានចាប់ផ្ដើមរៀបចំវិទ្យាល័យ និងសាកលវិទ្យាល័យដើម្បីផ្ដល់ការអប់រំដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ។ រាល់ព្យាការីនៃសម័យកាន់កាប់ត្រួតត្រានេះ បានលើកទឹកចិត្តសមាជិកសាសនាចក្រឱ្យមានការអប់រំ។

នៅក្នុងចំណោមព្យាការីទាំងនេះគឺមានប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី (ឆ្នាំ 1910–2008) ដែលលោកបានបង្កើតឡើងនូវមូលនិធិអប់រំដែលមានជាបន្តបន្ទាប់ (PEF) ដោយតាមគំនិតរបស់ប្រធាន ព្រិកហាំ យ៉ង់ នៅសតវត្សរ៍ទី 19 ដែលមានឈ្មោះថា មូលិធិអប់រំដែលមានជាបន្តបន្ទាប់។ ប្រធាន ថូម៉ាស អេស ម៉នសុន មានប្រសាសន៍ថា មូលនិធិអប់រំថ្មីនេះនឹងក្លាយជាសញ្ញាសម្គាល់មួយនៃការដឹកនាំរបស់ប្រធាន ហ៊ិងគ្លី។ [1] ប្រធាន ហ៊ិងគ្លី បានមើលឃើញនូវភាពក្រីក្រ និងកង្វះខាតនៃការអប់រំ និងការបណ្ដុះបណ្ដាល ដែលបានបង្ខាំងមជ្ឈឹមវ័យវ័យក្មេងជាច្រើននៅក្នុងសាសនាចក្រពីការសម្រេចបាននូវសក្ដានុពលរបស់ខ្លួន។ លោកបានស្វែងរកចម្លើយពីព្រះអម្ចាស់។

នៅក្នុងសន្និសីទទូទៅកាលពី ថ្ងៃទី 31 ខែ មិនា ឆ្នាំ 2001 ប្រធាន ហ៊ិងគ្លី បានប្រកាសពីចក្ខុវិស័យរបស់លោកពីកម្មវិធីនេះ។ លោកបានគិតថាវាគឺជា «ការផ្ដួចផ្ដើមគំនិតដ៏ក្លាហាន» មួយ ប៉ុន្តែបានធ្វើឡើងដោយ «ការអប់រំគឺជាគន្លឹះនាំទៅរកឱកាស»។[2] ប្រធាន ហ៊ិងគ្លី បានអញ្ជើញដល់អស់អ្នកទាំងឡាយណាដែលចង់បរិច្ចាគដល់មូលិធិនិ ហើយកម្មវិធីនេះត្រូវបានចាប់ផ្ដើមឡើង។

ឥឡូវនេះ 10 ឆ្នាំក្រោយមក ការបរិច្ចាគតិចឬច្រើនមកពីអ្នកបរិច្ចាគទូទាំងពិភពលោក បានធ្វើឱ្យអ្នកដែលមានគំនិតផ្ដួចផ្ដើម—និងអ្នកទទួលប្រាក់កម្ចី—បានរីកចម្រើន។ អែលឌើរ ចន ឃេ ខាម៉ាក ដែលជាអតីតសមាជិកនៃពួកចិតសិបនាក់ និងជានាយកប្រតិបត្តិ ភី. អ៊ី. អែហ្វ មានប្រសាសន៍ថា មូលនិធិនេះគឺ «កំពុងសង្គ្រោះពួកបរិសុទ្ធពីដំណើរនៃភាពក្រីក្រ»។ រេក អាល់ឡេន ជានាយកស្ម័គ្រចិត្តនៃការបំពាក់បំប៉ន និងទំនាក់ទំនង ភី. អ៊ី. អែហ្វ. មានប្រសាសន៍ថា មូលនិធិនេះបានទទួលជោគជ័យនៅក្នុងការសង្គ្រោះនោះ ពីព្រោះមូលនិធិគឺត្រូវបានបង្កើតឡើងនៅលើគោលការណ៍ដ៏នៅអស់កល្បជានិច្ច និងបង្កើតឡើងដោយមានសេចក្ដីសន្យារបស់ព្យាការីថាមាន «ឥទ្ធិពលច្រើនលើសពីអ្វីដែលយើងអាចយល់បាន»។

ថតរូបដោយ ព្រាយអិន រីលខូក្ស ; រូបភាពដោយប្រីន គ្រូស្តុន




*អស់ជាច្រើនទសវត្សរ៍ចាប់តាំងពីកម្មវិធីនេះនេះ ចាប់ផ្ដើម មូលនិធិអប់រំដែលមានជាបន្ដបន្ទាប់បាន អភិវឌ្ឍឡើងបានជួយធ្វើឱ្យជីវិតអ្នកទទួលប្រាក់កម្ចី ជាង 50,000 នាក់ នៅក្នុងប្រទេសជាង 51 ប្រទេសបានប្រសើរឡើង ជាក់ស្ដែងដូចជា ខេវីន ម៉រ មកពីប្រទេសឥណ្ឌាភាគខាងលិច និងអ្នកទទួលប្រាក់កម្ចីមកពីប្រទេសពេរ៉ូ (ខាងឆ្វេង)។ ម៉ារៀម អ័រខ្សីស្សា ជាអ្នកត្រឡប់ពីផ្សព្វផ្សាយ*

## ការផ្តួចផ្តើមគំនិតដ៏ក្លាហាន

នៅពេលដែលប្រធាន ហ៊ិងគ្លី បានពន្យល់នៅឆ្នាំ 2001 នោះ មូលនិធិនេះបានបង្កើតឡើងដោយមានថវិកាមកពីការបរិច្ចាគផ្សេងៗ ហើយចំណាប់អារម្មណ៍នេះបានទាក់ទាញនូវថវិកាបរិច្ចាគនេះដើម្បីផ្តល់ប្រាក់កម្ចីដល់និស្សិតនាពេលអនាគត។

ពួកមជ្ឈិមវ័យនៅលីវដែលចាប់អារម្មណ៍នៅក្នុងការទទួលប្រាក់កម្ចី អាចទៅជួបនឹងពួកអ្នកដឹកនាំបព្វជិតភាព និងនាយកថ្នាក់វិទ្យាស្ថាននៅក្នុងតំបន់។ ដោយមានការអនុញ្ញាតរបស់ពួកលោកនោះ «យុវជន និងយុវនារីដែលមានមហិច្ឆតា» ដែលពួកគេភាគច្រើនគឺជាពួកអ្នកត្រឡប់ពីបេសកកម្មវិញ បានទទួលប្រាក់កម្ចីដើម្បីទៅសាលារៀននៅក្នុងសហគមន៍របស់ខ្លួន។[3] ខណៈកំពុងរៀននៅសាលាបណ្តើរ ពួកគេចាប់ផ្តើមបង់សងប្រាក់កម្ចីបណ្តើរ ដែលធ្វើឱ្យពួកនិសិត្សដទៃទៀតអាចប្រើប្រាស់មូលនិធិនេះផងដែរ។

អស់ជាច្រើនទសវត្សរ៍មកហើយ ចាប់តាំងគំនិតអំពីកម្មវិធីនេះផ្តើមឡើង កម្មវិធីនេះបានជួយកែលំអដល់ជីវិតមនុស្សជាង 50,000 នៅក្នុងប្រទេសចំនួន 51 ប្រទេស ដោយការជួយពួកគេឱ្យ «ក្រោកឡើងពីភាពក្រីក្រ ដែលពួកគេ និងសាច់ញ្ញាតិដែលបានរស់នៅពីមុនពួកគេបានជួបប្រទះ» ដូចដែលប្រធានហ៊ិងគ្លី មានប្រសាសន៍ថាកម្មវិធីនេះនឹងជួយដល់ពួកគេ។[4]

បងប្រុស អាលលីន បានពិពណ៌នាពី ភី. អ៊ី. អែហ្វ. តាមវិធីនេះថា ៖ «នៅថ្ងៃនោះព្យាការីបានធ្វើកិច្ចការមួយដ៏អស្ចារ្យ។ ជាយូរមកហើយ ម៉ូសេ បាននាំប្រជាជនរបស់គាត់ឆ្លងសមុទ្រក្រហម ហើយបានបំបែកទឹកចេញពីគ្នា។ ប្រធាន ហ៊ិងគ្លី បានបង្ហាញនូវសេចក្តីជំនឿដូចគ្នានេះ នៅពេលដែលលោកធ្វើកិច្ចការជាព្យាការីរបស់លោកយ៉ាងពិតប្រាកដ ដើម្បីបំភ្លឺលើសមុទ្រងងឹតនៃភាពក្រីក្រ និងផ្តួចផ្តើមគំនិតជា ភី. អ៊ី. អែហ្វ. ឡើង។

## គោលការណ៍ទាំងឡាយ

មូលនិធិអប់រំដែលមានជាបន្តបន្ទាប់ បានស្ថាបនាឡើងនៅលើគ្រឹះនៃគោលការណ៍ទាំងឡាយនៃដំណឹងល្អ—សេចក្តីជំនឿ និងសេចក្តីសង្ឃឹមលើព្រះយេស៊ូវគ្រីស្ទ ការអប់រំ ការងារ ការពលិកម្ម ខ្លួនទីពឹងខ្លួន សេចក្តីថ្លៃថ្នូ និងការបម្រើ។ អ្នកទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ. និងអ្នកដែលបានបញ្ចប់ការសិក្សាទូទាំងពិភពលោក គឺកំពុងតែប្រតិបត្តិតាមគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ។

ខារ៉ូលីណា តែឡូ វ៉ាហ្គាស ជាអ្នកបញ្ចប់ការសិក្សាម្នាក់មកពីប្រទេស កូឡុំប៊ី និយាយថា ភី. អ៊ី. អែហ្វ. គឺជា «កាំរស្មីនៃសេចក្តីសង្ឃឹម» និងជាភស្តុតាងនៃជំនួយរបស់ព្រះវរបិតាសួគ៌ ដែលជា «អង្គដឹកនាំដល់[នាង] និងបើកផ្លូវសម្រាប់ការរីកចម្រើន»។

គាត់យល់ពីសារៈសំខាន់នៃការអប់រំ និងការងារ ហើយនិងការពលិកម្មដែលត្រូវធ្វើឡើង។ ពីមុនគាត់បានចូលរួមនៅក្នុងភី. អ៊ី. អែហ្វ. ខារ៉ូលីណា បានធ្វើការពីរបីមុខ ហើយបានលក់គ្រឿងអលង្ការរបស់គាត់ទាំងអស់ ដើម្បីគាត់អាចសិក្សាជំនាញច្បាប់។ ក្រុមគ្រួសាររបស់គាត់បានធ្វើការពលិកម្មជាច្រើនផងដែរ។

ខារ៉ូលីណា ពន្យល់ថា «ខ្ញុំបានដឹងថា ដើម្បីទទួលការសិក្សាត្រូវតែមានការពលិកម្ម»។ «ខ្ញុំស្ម័គ្រចិត្តដើម្បីធ្វើដូច្នោះ ដើម្បីខ្ញុំអាចមានឱកាសការងារល្អនៅពេលអនាគត»។

ប៉ុន្តែនៅពេលនោះស្ថានភាពក្រុមគ្រួសាររបស់នាងបានផ្លាស់ប្តូរនៅក្នុងឆ្នាំចុងក្រោយរបស់នាងនៅសាលារៀន ហើយនាងមិនមានលទ្ធភាពដើម្បីបង់ថ្លៃសាលាឡើយ។ នាងបានទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ. ហើយបានប្រើប្រាស់ប្រាក់កម្ចីដើម្បីបង់បញ្ចប់បរិញ្ញាបត្ររបស់ប្រកបដោយជោគជ័យ។

ឈើលី អិមវីលីស មកពីអាហ្វ្រិចខាងត្បូងក៏មានបទពិសោធន៍នៃគោលការណ៍ទាំងនេះផងដែរ។ នាងបានប្រើប្រាស់ប្រាក់កម្ចីភី. អ៊ី. អែហ្វ. ដើម្បីបញ្ចប់វគ្គសិក្សាផ្នែកកុំព្យូទ័ររបស់នាង ហើយបន្ទាប់មកក៏បានទទួលការងារមួយនៅក្រុមហ៊ុនធានារ៉ាប់រង រួចក៏បានបង់សងប្រាក់កម្ចីរបស់នាងដែលនៅសេសសល់ទាំងអស់ វាបានជួយនាងឱ្យមានអារម្មណ៍ «អាចពឹងពាក់បាន និងមានភាពសក្តិសម»។

ឈើលី ពន្យល់ថា «ការទទួលបានការងារល្អមានន័យថាការមានគុណភាពជីវិតល្អ» វាមានន័យថាខ្ញុំអាចជួយដល់ឪពុកម្តាយ និងក្រុមគ្រួសាររបស់ខ្ញុំ ហើយជំនាញ និងការដុះខាត់ដែលខ្ញុំមានតាមរយៈការធ្វើការងារបានជួយខ្ញុំប្រែក្លាយជាអ្នកផ្តល់សេវាកម្មដ៏ប្រសើរចំពោះមុខងារហៅបម្រើរបស់ខ្ញុំទាំងអស់ក្នុងសាសនាចក្រ»។

ការធ្វើការជាអ្នករៀបចំកម្មវិធីកុំព្យូទ័រ នាងបានសម្រេចបាននូវអ្វីៗជាច្រើន។ នាងនិយាយថា «ខ្ញុំមានអារម្មណ៍ថា ប្រសិនបើមិនដោយសារការសិក្សា និងការចូលរួមនៅក្នុងព្រះវិហារជាញឹកញាប់នោះទេ ខ្ញុំមិនអាចមានការងារ ឬក៏មិនអាចសម្រេចបាននូវអ្វីៗដែលល្អជាច្រើនដូចនេះនោះទេ»។

## កាសន្យានិងពរជ័យទាំងឡាយ

នៅពេលដែលប្រធានហ៊ិងគ្លី បានប្រកាសពីមូលនិធិអប់រំដែលមានជាបន្តបន្ទាប់ លោកបានសន្យាថាមូលនិធិនេះនឹងនាំមកនូវពរជ័យដល់បុគ្គលម្នាក់ៗ ចំពោះក្រុមគ្រួសារ និងសហគមន៍របស់



**ចំនួនអ្នកទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ.**

មូលនិធិអប់រំដែលមានជាបន្តបន្ទាប់បានប្រសិទ្ធិពរជ័យដល់ជីវិតអ្នកទទួលប្រាក់កម្ចីជាង 50,000 នាក់នៅក្នុងប្រទេសចំនួន 51 ប្រទេសនៅ 10 ឆ្នាំកន្លងមកនេះ។ ខាងក្រោមនេះគឺជាស្ថិតិអំពីមជ្ឈិមវ័យវ័យក្មេងទាំងនេះ ៖

- ចំនួន 51 ភាគរយគឺជាបុរស និងចំនួន 53 ភាគរយគឺជាស្ត្រី។
- 34 ភាគរយគឺជាអ្នកបានរៀបការរួច។
- 80 ភាគរយកគឺជាបុរសដែលបានត្រឡប់ពីបេសកកម្មវិញ។
- 82 ភាគរយកំពុងធ្វើការខណៈកំពុងតែសិក្សាបណ្តើរ។
- មធ្យមភាគគឺ 24.5។
- ពួកគេត្រូវចំណាយរយៈពេលមធ្យមភាគចំនួន 2.6 ឆ្នាំ ដើម្បីបញ្ចប់ការអប់រំរបស់ពួកគេ។
- ពួកគេទទួលបានប្រាក់ចំណូលច្រើនជាងបីទៅបួនដងបន្ទាប់ពីពួកគេទទួលបានការអប់រំ។




### ផលផ្លែទាំង 10 ដំបូង បន្ទាប់ពីរយៈពេល 10 ឆ្នាំដំបូង

អែលឌើរ ចន យេ. ខាម៉ាក ជានាយកប្រតិបត្តិរបស់ភី. អ៊ី. អែហ្វ. មានប្រសាសន៍ថាមូលនិធិនេះបានបង្កើតផលផ្លែទាំងនេះ។

1. បង្កើតឱ្យមានការពឹងពាក់ខ្លួនឯង និងសេចក្ដីថ្លៃថ្នូរ ៖ ការបំពេញកាតព្វកិច្ច និងជួយដល់ក្រុមគ្រួសារ។
2. ដំណើរការរីកចម្រើនដ៏អស់កល្បទៅពេលខាងមុខ ៖ ការទទួលយកនូវបញ្ញានៅក្នុងជីវិតនេះនឹងបានទៅជាអត្ថប្រយោជន៍នៅក្នុងជីវិតបន្ទាប់ (សូមមើល គ. និង ស. 130:18–19)។
3. ការស្ថាបនាពួកអ្នកដឹកនាំដែលមានសមត្ថភាព ៖ ស្វែងរកការងារល្អដែលអនុញ្ញាតឱ្យមានពេលវេលាបម្រើសាសនាចក្រ។
4. ការបើកឱកាសតាមរយៈការអប់រំ ៖ ការមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការងារដែលតម្រូវឱ្យមានការបណ្ដុះបណ្ដាល និងជំនាញច្បាស់លាស់មួយចំនួន។
5. ការធ្វើឱ្យជីវិតមានការរីកចម្រើន ៖ ការពង្រីកការយល់ដឹងឱ្យធំទូលាយ និងការបើកគំនិត។
6. ការលើកទឹកចិត្តឱ្យមានអារម្មណ៍នៃច្បាប់ឧទ្ទិសកម្ម ៖ ការអញ្ជើញមនុស្សទាំងអស់ឱ្យមានការលះបង់ ចូរមករួមគ្នាតែមួយ (សូមមើល គ. និង ស. 38:27)។
7. ជួយថែរក្សាដល់ជនក្រីក្រ ៖ បំពេញកូនសោនៃកាតព្វកិច្ចនៃសាសនាចក្រ (សូមមើល គ. និង ស. 81:5; 83:6)។
8. ការស្ថាបនាក្រុមគ្រួសារឱ្យកាន់តែរឹងមាំ ៖ បំបែកចេញនូវវដ្តនៃភាពក្រីក្រ។
9. ការស្ថាបនាទំនៀមទម្លាប់នៃភាពឥតខ្ចោះ ៖ អនុវត្តតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ។
10. ការធ្វើតាមគំរូនៃការពលិកម្មរបស់ព្រះអង្គសង្គ្រោះ ៖ លះបង់អ្វីដែលយើងត្រូវលះបង់ដើម្បីជួយដល់អ្នកដទៃ។

ពួកគេ និងចំពោះសាសនាចក្រទាំងមូល តាមរយៈឱកាសដើម្បីធ្វើការរ ការបម្រើ និងភាពជាអ្នកដឹកនាំ។

ប្រធានហ៊ិងគ្លី បានសន្យាដល់អ្នកទទួលប្រាក់កម្ចីថា «នឹងអាចទទួលបាននូវការសិក្សាល្អដែលនឹងលើកពួកគេឡើងចេញពីសំណាកនៃភាពក្រីក្រ។ «ពួកគេនឹងរៀបការ ហើយឈានជើងទៅមុខជាមួយនឹងជំនាញទាំងឡាយ ដែលនឹងធ្វើឱ្យពួកគេមានគុណសម្បត្តិដើម្បីរកប្រាក់ចំណូលបានល្អ និងមានកន្លែងខ្លួននៅក្នុងសង្គមជាកន្លែងដែលពួកគេអាចធ្វើការបរិច្ចាគប្រកបដោយអត្ថន័យ»។[5]

សេចក្ដីសន្យានេះបានបំពេញដល់អ្នកទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ. រាប់ពាន់នាក់ ដោយរួមទាំងបាប្លូ ប៊ីនីធីស្ស មកពីយ៉ូរ៉ាហ្គាយ។ បាប្លូ ធ្វើការងារ 12 ម៉ោងក្នុងមួយថ្ងៃនៅឯហាងលក់ឥវ៉ាន់ ដោយរកចំណូលស្មើរតែគ្រប់គ្រាន់សម្រាប់ការរស់នៅបាននៅពេលដែលគាត់សម្រេចចិត្តដើម្បីធ្វើការផ្លាស់ប្ដូរជីវិតរបស់គាត់។ គាត់ចាប់ផ្ដើមចូលរៀននៅសាលា ប៉ុន្តែនៅពេលដែលតម្លៃសាលាកាន់តែមានតម្លៃថ្លៃឡើង គាត់បានដឹងខ្លួនថា គាត់ពុំមានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបង់ថ្លៃលើការអប់រំរបស់គាត់តែឯងនោះទេ។

តាមរយៈភី. អ៊ី. អែហ្វ. គាត់អាចបញ្ចប់បរិញ្ញាបត្ររបស់គាត់ផ្នែករាងកាយ។ ជាលទ្ធផល គាត់បានទទួលការងារជាច្រើននៅប៉ុន្មានឆ្នាំនោះ ការងារនីមួយៗបានបង្កើនដល់ប្រាក់ចំណូលរបស់

*សាសនានៅប្រទេសពីលីពីន បានត្រូវទទួលឱ្យធ្វើការក្នុងក្រុមហ៊ុនទេសចរណ៍មួយ ម៉ោងធ្វើការរបស់នាងបានអនុញ្ញាតឱ្យនាងបម្រើជាប្រធានយុវនារី និងជាគ្រូបង្រៀនថ្នាក់វិទ្យាស្ថាន។*




## របៀបដើម្បីចូលរួម

ភី. អ៊ី. អែហ្វ. មានដំណើរការប្រាំជំហាន សម្រាប់ជនទាំងឡាយណាដែលរស់នៅក្នុងតំបន់ដែលត្រូវបានអនុញ្ញាតឱ្យដើម្បីចូលរួមនៅក្នុងកម្មវិធីនោះ។ ចំពោះព័ត៌មានបន្ថែមស្ដីអំពីដំណើរការ ឬគុណសម្បត្តិដើម្បីចូលរួម សូមចូលទៅកាន់ pef.lds.org។ ដើម្បីចាប់ផ្ដើម សូមនិយាយជាមួយនឹងពួកអ្នកដឹកនាំបព្វជិតភាព ឬអ្នកដឹកនាំថ្នាក់វិទ្យាស្ថាននៅក្នុងតំបន់របស់អ្នក។

**ជំហានទី 1 ៖ ក្ដីសុបិន**—សូមរៀនអំពីកម្មវិធីភី. អ៊ី. អែហ្វ. និងអ្វីដែលមានជាប់ទាក់ទងនៅក្នុងតំបន់របស់អ្នក និងចូលរួមនៅក្នុងការប្រជុំពិសេសស្ដីពីការអប់រំនៅក្នុងស្តេករបស់អ្នក។

**ជំហានទី 2 ៖ ដាក់ផែនការ និងធ្វើឱ្យមានគុណសម្បត្តិ**—ចូលរៀនសិក្ខាសាលាស្ដីពីការដាក់ផែនការដើម្បីទទួលជោគជ័យនៅក្នុងថ្នាក់វិទ្យាស្ថានរបស់អ្នក ហើយសូមស្វែងរកការអនុញ្ញាត និងការប្រឹក្សាពីពួកអ្នកដឹកនាំបព្វជិតភាពទាំងឡាយរបស់អ្នក។

**ជំហានទី 3 ៖ ដាក់ពាក្យ**—សូមបំពេញបែបបទភី. អ៊ី. អែហ្វ. នៅតាមអ៊ិនធើរណែត ផ្អែកលើអ្វីដែលអ្នករៀននៅក្នុងសិក្ខាសាលាស្ដីការដាក់ផែនការដើម្បីទទួលជោគជ័យ។

**ជំហានទី 4 ៖ ការប្ដេជ្ញាចិត្ត**—ប្រសិនបើត្រូវបានអនុមតិ នោះសូមចូលសម្ភាសន៍នៅក្នុងការទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ. ដែលអ្នកនឹងត្រូវយល់ព្រមដើម្បីបំពេញការតាំងចិត្តរបស់អ្នក។

**ជំហានទី 5 ៖ សិក្សា បញ្ចប់ការសិក្សា រកការងារល្អធ្វើ និងបង់សងប្រាក់កម្ចីវិញ**—សូមអនុវត្តសេចក្ដីជំនឿរបស់អ្នក និងបង្ហាញឱ្យឃើញនូវការខិតខំសេចក្ដីថ្លៃថ្នូរ ការប្ដេជ្ញាចិត្ត និងការពឹងពាក់លើខ្លួនឯងខិតខំធ្វើការ ដើម្បីបំពេញនូវក្ដីសុបិនរបស់អ្នក។

គាត់។ គាត់ថែមទាំងរាយការណ៍ថា «ជាញឹកញាប់ខ្ញុំទទួលបានការងារដែលតម្រូវធ្វើពេញម៉ោង ឬធ្វើការជំនួសអ្នកដទៃទៀត ដែលខ្ញុំមិនអាចទទួលយកបាន ពីព្រោះខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់។ ហើយអ្វីៗទាំងអស់នេះគឺជាអំណរគុណដល់ភី. អ៊ី. អែហ្វ និងចំពោះឱកាសទាំងឡាយដែលបើកផ្លូវសម្រាប់ខ្ញុំ ពីព្រោះតែការសិក្សារបស់ខ្ញុំ។

ដោយសារតែឱកាសដែលបានទទួលតាមរយៈការអប់រំ នោះបាប្លូ អាចជួយឧបត្ថម្ភដល់ក្រុមគ្រួសាររបស់គាត់ ខណៈដែលកំពុងតែបម្រើ និងស្ថាបនាសហគមន៍របស់គាត់ក្នុងនាមជាគ្រូបង្រៀនមួយរូប។

បងប្រុស អាលលីន មានប្រសាសន៍ថា ការធ្វើការជាច្រើនម៉ោងតែស្ទើរតែរកចំណូលមិនគ្រប់លើការបង់ថ្លៃចំណាយក្នុងជីវភាពរស់នៅ និងដង្វាយមួយភាគក្នុងដប់អាចធ្វើឱ្យការបម្រើនៅក្នុងសាសនាចក្រជួបប្រទះនឹងឧបសគ្គដ៏ធំ។ នេះគឺជាការស្មុគស្មាញចំពោះសមាជិកជាច្រើននៅទូទាំងពិភពលោក ប៉ុន្តែប្រធាន ហ៊ិងគ្លីបានធ្វើឱ្យសេចក្ដីសន្យានេះដល់អ្នកទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ. ថា «ពួកគេនឹងក្លាយជាអ្នកដឹកនាំនៅក្នុងកិច្ចការដ៏ធំនេះ នៅលើទឹកដីរបស់ពួកគេ។ ពួកគេនឹងបង់ដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងៗរបស់ពួកគេ ដែលនឹងធ្វើឱ្យសាសនាចក្រអាចពង្រីកការងាររបស់ខ្លួនដល់ទូទាំងពិភពលោក»។[6]

*វេនឌើល លីរ៉ា មកពីប្រទេសប្រេស៊ីល បានបម្រើជាប្រធានសាខាអស់រយៈពេលប្រាំមួយឆ្នាំ ខណៈពេលដែលធ្វើការជាកម្មករ។ បន្ទាប់ពីគាត់បានបន្តការអប់រំបន្ថែម ដោយមានអំណរគុណចំពោះប្រាក់កម្ចីភី. អ៊ី. អែហ្វ. គាត់បានទទួលការងារថ្មីដែលមានប្រាក់ខែច្រើនជាងមុន។ ប្រធានស្តេករបស់គាត់បានហៅគាត់ថាជា «បុរសម្នាក់ដែលមានសក្ដានុពលដ៏អស្ចារ្យ ដោយ សារតែ ឱកាសហុចឱ្យ»។*

រូបថតរបស់ប្រធាន ម៉នសុន ដោយ ដាវីឌ ទូមេន

អ្នកទទួលប្រាក់កម្ចីជាច្រើនកំពុងតែយល់ឃើញថា ការអប់រំដែលទទួលបានតាមរយៈភី. អ៊ី. អែហ្វ. នាំទៅរកការងារល្អដោយមានពេលវេលាគ្រប់គ្រាន់ សម្រាប់ពួកគេដើម្បីបម្រើនៅក្នុងសាសនាចក្រ។ ម៉ារៀម អៀគ្វីស្សា ជាអ្នកត្រឡប់មកពីបេសកកម្មនៅប្រទេសពីលីពីន បានរៀនចប់រយៈពេលពីរឆ្នាំផ្នែកកម្មវិធីរចនាបទ និងតាមរយៈ «ការអធិស្ឋានដ៏ខ្លាំងក្លា» បានទទួលការងារនៅផ្នែកភ្នាក់ងារធ្វើដំណើរ។ ការងារមួយនេះបានអនុញ្ញាតឱ្យនាង ជួយឧបត្ថម្ភដល់ក្រុមគ្រួសាររបស់នាង និងមានពេលវេលាដើម្បីបម្រើជាប្រធានយុវនារី និងជាគ្រូបង្រៀនថ្នាក់វិទ្យាស្ថាន។

វេនឌើលៃ លីរ៉ា មកពីប្រទេសប្រេស៊ីល បានបម្រើជាប្រធានសាខាអស់រយៈពេលប្រាំមួយឆ្នាំ ដោយជួយឱ្យសាខារបស់លោកមានការរីកចម្រើនពីសមាជិកសកម្មចំនួន 18 នាក់ទៅ 110 នាក់ ខណៈដែលធ្វើការជាកម្មករ ពីព្រោះតែគាត់ខ្វះការអប់រំ។ នៅពេលដែលមូលនិធិ ភី. អ៊ី. អែហ្វ. ត្រូវបានប្រកាសឡើង គាត់អាចទទួលបាននូវការសិក្សាអាជីពមួយ ដោយសុវត្ថិភាព និងរកការងារថ្មីធ្វើ ដែលបានជួយបង្កើនប្រាក់ខែគាត់ រួចបង់សងប្រាក់កម្ចីរបស់គាត់វិញភ្លាម។ គាត់នៅបន្តដើម្បីបម្រើសាសនាចក្រនៅសព្វថ្ងៃនេះ។ ប្រធានស្តេករបស់គាត់ពិពណ៌នាពីគាត់ថា ជាអ្នកដឹកនាំ និងជាឪពុកដ៏អស្ចារ្យមួយរូប «ជាយក្សមានសេរីភាពដោយសារឱកាស»។

ប្រធាន ហ៊ិងគ្លី បានប្រាប់សមាជិកទាំងឡាយនៃសាសនាចក្រថា កម្មវិធីនេះនឹងទទួលបានជោគជ័យពីព្រោះតែសាសនាចក្រមាននូវ «អង្គការ ... និងពួកអ្នកបម្រើរបស់ព្រះអម្ចាស់ដែលមានការពលិកម្ម» ដែលចាំបាច់សម្រាប់ការទទួលជោគជ័យ។[7] ជាការពិតណាស់ មូលនិធិអប់រំដែលមានជាបន្តបន្ទាប់គឺកំពុងតែទទួលបានជោគជ័យពីព្រោះតែមូលនិធិនេះមាននូវការចូលរួមចំណែកពីអ្នកទទួលប្រាក់កម្ចី និងពួកអ្នកដឹកនាំនៅក្នុងមូលដ្ឋាន នៅក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងពួកអ្នកដឹកនាំទូទៅដទៃទៀតនៅក្នុងសាសនាចក្រ។ មជ្ឈមណ្ឌលធនធានការងាររបស់សាសនាចក្រ និងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានក៏បានចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចខិតខំនេះផងដែរ។

ប្រសិទ្ធភាពនៃមូលនិធិនេះមានជាបន្តបន្ទាប់ពុំមែនតែខាងហិរញ្ញវត្ថុ ដូចជាប្រាក់ត្រូវបានបង់សង រួចហើយយកទៅឱ្យសិស្សដ៏ទៃទៀតខ្ចីតែម្យ៉ាងប៉ុណ្ណោះនោះទេ ប៉ុន្តែវាក៏មានជាបន្តបន្ទាប់ខាងវិញ្ញាណ និងខាងសង្គមផងដែរ នៅពេលពួកអ្នកខ្ចី អ្នកបរិច្ចាគ ពួកអ្នករដ្ឋបាល និងមនុស្សដទៃទៀតរាប់មិនអស់ត្រូវបានទទួលពរជ័យដោយផ្ទាល់នោះ។ បងប្រុសអាឡេនបាននិយាយថា «ការអប់រំគឺជាកូនសោដើម្បីបើកទ្វាចូលទៅក្នុងជញ្ជាំងមួយដ៏រឹងមាំ ពុំមែនគ្រាន់តែសម្រាប់បុគ្គលប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ក្រុមគ្រួសារ និងសហគមន៍ផងដែរ»។

អស់រយៈពេល10ដប់ឆ្នាំកន្លងទៅនេះ បច្ចេកវិជ្ជា និងបទពិសោធន៍បានជួយជុសខាត់នូវដំណើរការសម្រាប់ពួកអ្នកខ្ចី និងពួកសម្របសម្រួល ប៉ុន្តែមូលនិធិអប់រំជាបន្តបន្ទាប់នៅតែស្វែងរកដើម្បីបំពេញទស្សនៈនៃការព្យាករណ៍ដែលបានស្ថាបនាសម្រាប់មូលនិធិនេះ។ «គំនិតផ្តួចផ្តើមដ៏ក្លាហាន»នេះនឹងនៅតែជាការព្យាយាមមួយដែលបានព្យាករ។ ប្រធានម៉នសុន បន្តកិច្ចការនៃមូលនិធិនេះដែលលោកបានមានប្រសាសន៍ ថា «វាឈានជើងយ៉ាងឆ្ងាយទៅក្នុង ថ្ងៃអនាគត»។[8] ■



### អនាគតមួយដ៏ភ្លឺត្រចះត្រចង់

«មូលនិធិអប់រំជាបន្តបន្ទាប់ ... បំបែកនូវចំណងនៃភាពក្រីក្រសម្រាប់សមាជិកយើងនៅក្នុងតំបន់ជាច្រើននៃពិភពលោកនេះ ហើយផ្តល់ជាជំនាញ និងការបំពាក់បំប៉នដែលធ្វើយុវជន និងយុវនារីមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការងារយដ៏ប្រសើរ។ ផែនការដ៏បំផុសគំនិតនេះបានបង្កឱ្យមានពន្លឺនៃសេចក្តីសង្ឃឹមនៅក្នុងកែវភ្នែកនៃអស់អ្នកដែលមានអារម្មណ៍ អស់សង្ឃឹមដោយសារតែភាពក្រីក្រ ប៉ុន្តែឥឡូវនេះជាអ្នកដែលមានឱកាសមួយសម្រាប់អនាគតមួយដ៏ត្រចះត្រចង់»។

ប្រធាន ថូម៉ាស អេស ម៉នសុន «They Marked the Path to Follow» *Liahona* ខែ តុលា ឆ្នាំ 2007 ទំព័រ 6។

### របៀបដើម្បីបរិច្ចាគ

មូលនិធិដែលទទួលបានផ្អែកទៅលើសប្បុរសធម៌ដ៏ធំ និងជំនួយពីសមាជិកទាំងឡាយ ព្រមទាំងពួកអ្នកស្ម័គ្រចិត្តទូទាំងពិភពលោក។ ខាងក្រោមនេះគឺជាវិធីមួយចំនួនដែលអ្នកអាចជួយបាន ៖

- ស្ម័គ្រចិត្តធ្វើការក្រៅម៉ោងនៅសេវាកម្មមជ្ឈមណ្ឌល ភី. អ៊ី. អែហ្វ.។
- ជាមួយប្តីប្រពន្ធរបស់អ្នក បម្រើពេញម៉ោងជាអ្នកផ្សព្វផ្សាយសាសនានៅក្នុងកម្មវិធីភី. អ៊ី. អែហ្វ.។
- បរិច្ចាគដល់មូលនិធិអប់រំដែលមានជាបន្តបន្ទាប់។


**កំណត់ចំណាំ**

1. សូមមើល «16th President Fields Questions from Media» *Church News* ថ្ងៃទី 9 ខែ កុម្ភៈ ឆ្នាំ 2008 ទំព័រ 15។
2. ហ្គរដុន ប៊ី ហ៊ីងគ្លី «The Perpetual Education Fund» *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 62, 67។
3. ហ្គរដុន ប៊ី ហ៊ីងគ្លី *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 62។
4. ហ្គរដុន ប៊ី ហ៊ីងគ្លី *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 62។
5. ហ្គរដុន ប៊ី ហ៊ីងគ្លី «The Church Goes Forward» *Liahona* ខែ កក្កដា ឆ្នាំ 2002 ទំព័រ 6។
6. ហ្គរដុន ប៊ី ហ៊ីងគ្លី «Reaching Down to Lift Another» *Liahona* ខែ មករា ឆ្នាំ 2002 ទំព័រ 62។
7. ហ្គរដុន ប៊ី ហ៊ីងគ្លី *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 67។
8. ថូម៉ាស អេស ម៉នសុន នៅក្នុង «16th President Fields Questions from Media» *Church News* ថ្ងៃទី 9 ខែ កុម្ភៈ ឆ្នាំ 2008 ទំព័រ 15។


*សូមចូលទៅកាន់ **pef.lds.org** ដើម្បីអានបន្ថែមទៀតនូវដំណើររឿងពីអ្នកទទួលប្រាក់កម្ចីភី. អ៊ី. អែហ្វ. និងដើម្បីរៀននូវរបៀបដើម្បីចូលរួមចំណែក។*



# បាត់ & រកឃើញវិញ

*ការវង្វេងផ្លូវរបស់យើងគឺងាយស្រួលណាស់ ប្រសិនបើ ការសម្រេចចិត្តប្រចាំថ្ងៃរបស់យើងមិនភ្ជាប់ទៅនឹង ជោគវាសនាដ៏នៅអស់កល្បជានិច្ចរបស់យើងនោះទេ។*



ថតរូបដោយ អ័ដាម ស៊ី. អូលសិន

**ដោយ អ័ដាម ស៊ី. អូលសិន**

ទស្សនាវដ្ដីសាសនាចក្រ

មិនយូរប៉ុន្មានពីមុនឈានដល់អាយុ 30 ឆ្នាំ រ៉ូប៊ីតា ធូលីម៉ូ បានដឹងថាគាត់មិនសប្បាយចិត្តទេ។ គាត់មានកូនដ៏ស្រស់ស្អាតបីនាក់ ហើយគាត់ស្រឡាញ់ដានីយ៉ែល ទីប៉ា ដែលជាឪពុករបស់កូនគាត់ខ្លាំងណាស់ ប៉ុន្តែ រ៉ូប៊ីតា និងដានីយ៉ែល មិនបានរៀបការទេ។ ដានីយ៉ែល ពុំមែនជាសមាជិកនៃសាសនាចក្រទេ ដោយយូរមកហើយដែល រ៉ូប៊ីតា ចូលរួមក្នុងសាសនាចក្រទៀងទាត់នោះ។

គាត់រស់នៅឆ្ងាយពីអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ដែលគាត់មានក្តីសុបិនតាំងពីនៅក្មេង ដែលគាត់តែងតែទៅព្រះវិហារជារៀងរាល់សប្តាហ៍ជាមួយនឹងឪពុកម្តាយរបស់គាត់នៅ អ៊ុកលែន ប្រទេសញូសាឡែន។ ប៉ុន្តែការបង្វែរគាត់ឱ្យត្រឡប់ទៅរកគោលដៅដ៏នៅអស់កល្បជានិច្ចរបស់គាត់គឺមិនមែនជារឿងសម្រេចចិត្តម្តងនោះទេ វាគឺជាការត្រឡប់មកវិញបន្តិចម្តងៗតាមរយៈការសម្រេចចិត្តដ៏តូចៗរបស់គាត់ជារៀងរាល់ថ្ងៃ។

«យើងនឹងស្វែងរកសត្វណាដែលវង្វេងបាត់ ហើយនាំសត្វណាដែលប្រដេញឱ្យមកវិញ សត្វណាដែលបាក់ជើង នោះយើងនឹងរុំអបឱ្យ ហើយយើងនឹងចម្រើនកម្លាំងដល់សត្វណាដែលឈឺ» (អេសេគាល 34:16)។

## ការសម្រេចចិត្តទាំងឡាយបានផ្ដាច់

ដោយសារតែការសម្រេចចិត្តរបស់ រ៉ូប៊ីតា នៅគ្រានោះបង្ហាញយ៉ាងច្បាស់ពេលដែលគាត់សម្រេចចិត្តឈានជើងចេញពីផ្លូវនៃដំណឹងល្អ ក៏មានការជ្រើសរើសមួយចំនួនដែលបានទាញធ្វើឱ្យគាត់ធ្លាក់ដល់ចំណុចនេះ។ កាលពីនៅក្មេង រ៉ូប៊ីតា បានគេចអត់ទៅព្រះវិហារពីរបីសប្ដាហ៍ដើម្បីធ្វើកិច្ចការសាលា។ គាត់បាននិយាយថា «វាជារឿងគួរឱ្យចាប់អារម្មណ៍ណាស់ដែលវាអាចចាប់ផ្ដើមជាមួយនឹងកិច្ចការដែលហាក់បីដូចជាតូចតាចនៅគ្រានោះ»។

បន្ទាប់ពីខានទៅពីរបីសប្ដាហ៍ វាជារឿងងាយស្រួលណាស់ដល់គាត់ដើម្បីមិនទៅសប្ដាហ៍ក្រោយ។ ការមិនទៅចូលរួមប៉ុន្មានសប្ដាហ៍ក្លាយទៅជាការមិនចូលរួមរាប់ខែ។ បន្ទាប់ពីគាត់ចូលវ័យអាយុ 18 ឆ្នាំ នោះមិត្តរបស់គាត់បានបបួលគាត់ឱ្យចូលក្លឹបដល់យប់ជ្រៅនៅថ្ងៃសៅរ៍ខ្លះ ដែលធ្វើឱ្យកាន់តែមានការលំបាកទៅព្រះវិហារនៅថ្ងៃអាទិត្យ។ វាក៏បានដឹកនាំគាត់ចាប់ផ្ដើមផឹកសុរាផងដែរ។

គាត់បាននិយាយថា «ខ្ញុំបានដឹងថា វាពុំមែនជារឿងត្រឹមត្រូវនោះទេ ប៉ុន្តែខ្ញុំបានគិតថាខ្ញុំអាចបញ្ឈប់វាភ្លាមប្រសិនបើខ្ញុំចង់ធ្វើ»។ «ខ្ញុំបានព្យាយាមនិយាយដោះសារចំពោះការសម្រេចចិត្តរបស់ខ្ញុំ»។

នាងបានរស់នៅតាមរចនាបថជីវិតមួយដែលមិនសក្តិសមនឹងការចូលក្នុងព្រះវិហារបរិសុទ្ធ ប៉ុន្តែក្រោយពីបានជួបនឹងដានីយ៉ែលមក នាងបាននាំគាត់ទៅលេងទៅបរិវេណព្រះវិហារបរិសុទ្ធហាមិតុនន្ទូវហ្សីឡង់ ហើយបានប្រាប់គាត់ថានាងចង់រៀបការនៅទីនោះ។

នាងបាននិយាយថា «ខ្ញុំបានដឹងថា នោះគឺជាកន្លែងដែលខ្ញុំចង់ទៅ»។ ប៉ុន្តែការសម្រេចចិត្តខុសនីមួយៗហាក់ដូចជាធ្វើឱ្យមានការសម្រេចខុសបន្ទាប់ទៀតដោយងាយ—ដោយដឹកនាំនាងចេញឆ្ងាយពីទិសដៅដែលនាងបានប៉ងប្រាថ្នា។ មិនយូរប៉ុន្មាន រ៉ូប៊ីតា និងដានីយ៉ែលបានរួមរស់នឹងគ្នា។

នាងបាននិយាយថា «មានការឃ្លាតចេញឆ្ងាយមួយរវាងអ្វីដែលចង់បាន—ដែលជាអ្វីដែលខ្ញុំដឹងថាត្រឹមត្រូវ—និងការសម្រេចចិត្តដែលខ្ញុំបានធ្វើ»។ «ខ្ញុំស្ថិតនៅក្នុងពេលបច្ចុប្បន្ន។ ខ្ញុំមិនបានភ្ជាប់ទៅនឹងការសម្រេចបច្ចុប្បន្នជាមួយនឹងកន្លែងដែលវានឹងដឹកនាំខ្ញុំទៅនោះឡើយ»។

## ព្រះអម្ចាស់ស្វែងរកអ្នកដែលវង្វេងផ្លូវ

ទោះបីជានាងឃ្លាតឆ្ងាយពីកន្លែងដែលនាងចង់ទៅក៏ពិតមែន ប៉ុន្តែរ៉ូប៊ីតាមិនត្រូវបានព្រះអម្ចាស់បំភ្លេចចោលឡើយ។ ប៉ុន្តែដានីយ៉ែល និងរ៉ូប៊ីតាមិនបានដឹងទេថានៅពេលនោះអ្នកគង្វាលដ៏ល្អ បានមក «ដើម្បីនឹងរក ហើយជួយសង្គ្រោះមនុស្សបាត់បង់» (លូកា 19:10) បានស្វែងរកដល់ពួកគេជារៀងរហូតមកនោះទេ។

ព្រះវិញ្ញាណបានបំផុសដល់ដានីយ៉ែល ដូចជានៅពេលដែលរ៉ូប៊ីតា បាននាំគាត់ទៅកាន់បរិវេណព្រះវិហារបរិសុទ្ធ ហើយនៅពេលដែលឪពុករបស់រ៉ូប៊ីតា បានប្រសិទ្ធពរដល់កូនៗរបស់ពួកគេ ជាដើម។ ទោះបីជាពួកគេបានផ្លាស់លំនៅជាច្រើនដងក្តី ជារៀងរាល់ការផ្លាស់លំនៅ ពួកគេតែងតែជួប—និងសិក្សាជាមួយ—ពួកអ្នកផ្សព្វផ្សាយសាសនាជានិច្ច។

បន្ទាប់មក ក្រោយពីការផ្លាស់ប្ដូរលំនៅសារជាថ្មីទៀតនៅក្នុងឆ្នាំ 2006 ពួកគេបានជួបនឹងមិត្តរួមថ្នាក់ចាស់មួយចំនួន ដែលមានឈ្មោះថា ដាន និងលីស្សា ណាថាន់ ដែលជាសមាជិកសកម្មនៅក្នុងសាសនាចក្រ។ ដានីយ៉ែល និងរ៉ូប៊ីតា ទើបតែផ្លាស់លំនៅទៅក្នុងព្រំដែនវួដរបស់ ណាថាន់។

អស់រយៈពេលបីសប្ដាហ៍ រ៉ូប៊ីតា បានទទួលយកការអញ្ជើញរបស់ លីស្សា ព្រមទៅព្រះវិហារជាមួយនឹងនាង។ គាត់និយាយថា «ខ្ញុំមិនចង់ពន្យល់ពីស្ថានភាពរបស់ខ្ញុំនោះទេ»។ «ប៉ុន្តែខ្ញុំបានសម្រេចចិត្តថា ខ្ញុំចង់ឱ្យកូនៗរបស់ខ្ញុំចូលថ្នាក់កុមារ»។

មិនយូរប៉ុន្មាន ដានីយ៉ែល និងរ៉ូប៊ីតា បានជួបជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនាម្ដងទៀត។ ដានីយ៉ែល បានចាប់ផ្ដើមចូលរួមក្នុងព្រះវិហារ ដោយមានគ្រូបង្រៀនថ្នាក់គោលការណ៍ល្អម្នាក់បានធ្វើឱ្យមានការផ្លាស់ប្ដូរ។ គ្រូបង្រៀនការសួរសុខទុក្ខបានទៅសួរសុខទុកជារៀងរាល់ខែ។ ប្ដីប្រពន្ធរូបនេះ ថែមទាំងបានជួបជាមួយនឹងអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅអំឡុងការប្រជុំធម្មនិដ្ឋានពិសេសមួយ។

រ៉ូប៊ីតា មើលឃើញពីភស្តុតាងដែលព្រះវរបិតាសួគ៌បានរៀបចំពួកគេ តាមរយៈបទពិសោធន៍របស់ពួកគេថា «ក្រុមមនុស្សដ៏ល្អៗមួយក្រុមបានជួយដល់យើង»។

## សូមពិចារណាពីផ្លូវទាំងឡាយរបស់អ្នក

តាមរយៈបទពិសោធន៍ផ្សេងៗ និងមនុស្សទាំងឡាយ ព្រះវរបិតាសួគ៌បានប្រទានឱកាសដល់ដានីយ៉ែល និងរ៉ូប៊ីតា ឱ្យ «ពិចារណាពីផ្លូវប្រព្រឹត្ត [របស់ពួកគេ]ចុះ» (ហាកាយ 1:7). ប៉ុន្តែពួកគេត្រូវតែ «ទុកដាក់ផ្លូវ[របស់ពួកគេ] និងព្រះយេហូវ៉ាចុះ» ទំនុកដំកើង មុននិងពួកគេអាចរីកចំរើន។

រ៉ូប៊ីតា និយាយថា «ខ្ញុំដឹងថាផ្លូវរបស់ខ្ញុំគឺមិនមែនជាផ្លូវរបស់ទ្រង់ទេ» (សូមមើល អេសាយ 55:8–9) «ប៉ុន្តែខ្ញុំពុំដឹងអំពីរបៀបដើម្បីភ្ជាប់ផ្លូវទាំងពីរនោះទេ»។



រូបថតព្រះវិហារបរិសុទ្ធ ហាមីលតុន ដោយ ម៉ៃឃល ម៉ាក់ខនឃី© IRI

ផ្ទុយទៅវិញ នៅពេលដែលពួកអ្នកផ្សព្វផ្សាយសាសនាបាននិយាយដោយវិញ្ញាណសួរដល់ដានីយ៉ែល និងរ៉ូប៊ីតា ឱ្យធ្វើការសម្រេចចិត្ត ថាតើផ្លូវណាដែលពួកគេចង់ដើរ និងអ្វីដែលពួកគេត្រូវតែធ្វើដើម្បីទៅដល់ទីនោះ។

គាត់និយាយថា «នៅពេលដែលយើងសម្រេចចិត្តនៅទីបញ្ចប់នូវអ្វីដែលយើងចង់ធ្វើ គឺធ្វើអ្វីដែលទ្រង់ដឹកនាំផ្លូវ។ យើងចាប់ផ្តើមសម្លឹងមើលអ្វីដែលត្រូវធ្វើដើម្បីធ្វើតាមផ្លូវរបស់ទ្រង់នៅទីនោះ»។

នៅប៉ុន្មានខែក្រោយមក រ៉ូប៊ីតា ចាប់ផ្តើមងាកចេញពីការសម្រេចចិត្តខុសរបស់គាត់កាលពីអតីត និងត្រឡប់ទៅកាន់ផ្លូវដែលគាត់បានបោះបង់ចោលអស់មួយទសវត្សរ៍មុន។ គឺដូចនឹងអ្វីដែលគាត់បានបែរចេញពីផ្លូវនៃដំណឹងល្អកាលពីគាត់នៅវ័យជំទង់ ដែលបានចាប់ផ្តើមដោយការជ្រើសរើសតូចៗ នោះការត្រឡប់ជាថ្មីរបស់រ៉ូប៊ីតា ទៅកាន់ផ្លូវដែលបានចាប់ផ្តើមដោយការធ្វើនូវអ្វីៗដែលតូចតាចជារៀងរាល់ថ្ងៃ។

រ៉ូប៊ីតា និយាយថា «នៅពេលដែលខ្ញុំព្យាយាមធ្វើនូវកិច្ចការធម្មតាៗជារៀងរាល់ថ្ងៃ—ការអធិស្ឋានជាផ្ទាល់ខ្លួន និងជាក្រុមគ្រួសារ ដោយការអានបទគម្ពីរ និងនាំកូនៗទៅកាន់ព្រះវិហារដោយការជួយអ្នកដទៃនៅពេលខ្ញុំអាចធ្វើបាន—ខ្ញុំអាចទទួលអារម្មណ៍ថាព្រះវរបិតាសួគ៌មើលខុសត្រូវលើយើង និងស្តាប់ការអធិស្ឋានរបស់យើង»។ «ក្រុមគ្រួសាររបស់យើងសប្បាយជាងមុន»។

ការសម្រេចចិត្តតូចៗទាំងនោះបានជួយពង្រឹងដានីយ៉ែល និងរ៉ូប៊ីតា នៅពេលដែលវាដល់ពេលដើម្បីធ្វើការសម្រេចចិត្តធំៗ។ ពួកគេសម្រេចចិត្តដើម្បីរៀបការ។ បន្ទាប់មក ប្រហែលជាជិតមួយឆ្នាំក្រោយពីដានីយ៉ែល និងរ៉ូប៊ីតា បានចាប់ផ្តើមជួបជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា នោះបំណងប្រាថ្នារបស់ពួកគេដើម្បីរស់នៅជាមួយនឹងក្រុមគ្រួសាររបស់ពួកគេដ៏នៅអស់កល្បជានិច្ច បានដឹកនាំដានីយ៉ែល ឱ្យទទួលបុណ្យជ្រមុជទឹក។

នៅទីបំផុត បន្ទាប់ពីរយៈពេលពីរឆ្នាំនៃការព្យាយាមធ្វើអ្វីឱ្យត្រូវនឹងអ្វីដែលពួកគេបានធ្វើជារៀងរាល់ថ្ងៃ នឹងអ្វីដែលពួកគេចង់បាននៅអនាគត ដានីយ៉ែល និងរ៉ូប៊ីតា បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ—បំពេញក្តីសុបិនរបស់រ៉ូប៊ីតា កាលពីនៅក្មេង។

## រស់នៅក្នុងថ្ងៃនេះសម្រាប់ភាពដ៏អស់កល្បជានិច្ច

ដោយសារជាផ្នែកមួយនៃផែនការរបស់ព្រះវរបិតាសួគ៌ ដានីយ៉ែល និងរ៉ូប៊ីតា បានមានឱកាសដើម្បីធ្វើការសម្រេចចិត្តជារៀងរាល់ថ្ងៃថាតើផ្លូវណាមួយដែលពួកគេនឹងជ្រើសរើស—ផ្លូវរបស់ពួកគេ ឬផ្លូវរបស់ទ្រង់។ ប្តីប្រពន្ធរូបនេះ ឥឡូវកាន់តែយកចិត្តទុកដាក់ចំពោះទិសដៅដែលការជ្រើសរើសប្រចាំថ្ងៃរបស់ពួកគេនឹងហុចផលឱ្យពួកគេ។

ដោយសារតែបទពិសោធន៍ផ្ទាល់ខ្លួននេះ ពួកគេយល់ថាតើវាងាយស្រួលយ៉ាងណាក្នុងការវង្វេងផ្លូវ នៅពេលដែលការសម្រេចចិត្តជាប្រចាំថ្ងៃត្រូវបានធ្វើឡើងដោយគ្មានការពិចារណាដល់លទ្ធផលដែលជះឥទ្ធិពលដល់ជោគវាសនាដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ។ ប៉ុន្តែពួកគេតែងតែមានអំណរគុណដែលបានរៀននូវតាំងពីដំបូងថា គឺមានផ្លូវដើម្បីត្រឡប់មកវិញ។

រ៉ូប៊ីតា និយាយថា «ខ្ញុំដឹងថាព្រះអម្ចាស់ស្រឡាញ់ខ្ញុំ ហើយចង់ឱ្យខ្ញុំត្រឡប់ទៅវិញ ពីព្រោះទ្រង់បានប្រទានពរជ័យដល់ជីវិតរបស់យើងជាមួយនឹងមនុស្សដែលយើងបានជួបនៅក្នុងជីវិតរបស់យើងដែលបានជួយយើងឱ្យត្រឡប់មកវិញ»។ «ទ្រង់មិនដែលបំភ្លេចខ្ញុំនៅអំឡុងពេលដែលខ្ញុំបានឃ្លាតឆ្ងាយពីសាសនាចក្រនោះទេ»។

សូមអរគុណចំពោះសេចក្តីស្រឡាញ់—និងការពលិកម្មដ៏ធួន—នៃអ្នកគង្វាលល្អ «ត្រូវឱ្យមនុស្ស អាក្រក់[អាច]បោះបង់ផ្លូវរបស់ខ្លួន រួចត្រលប់មករកព្រះយេហូវ៉ាវិញ នោះទ្រង់នឹងអាណិតមេត្តាដល់គេ … , ត្បិតទ្រង់នឹងអត់ទោសឱ្យជាបរិបូរ” (អេសាយ 55:7).

ឥឡូវនេះ ក្រុមគ្រួសារ ទីប៉ាស គឺកំពុងតែព្យាយាមដើម្បីបន្តផ្តោតយកចិត្តទុកដាក់ចំពោះទីកន្លែងដែលពួកគេចង់ទៅ។ ដានីយ៉ែល និយាយថា «នៅពេលដែលអ្នកដឹងខ្លួនថា មានអ្វីៗជាច្រើនសម្រាប់ជីវិតនេះ ជាងអ្វីៗដែលមាន*ឥឡូវនេះ* នោះវានឹងផ្លាស់ប្តូរការជ្រើសរើសរបស់អ្នក»។ ■



**ការសម្រេចចិត្តកំណត់ដល់ជោគវាសនាប្រធាន**

«ជាច្រើនឆ្នាំទៅហើយ មានមនុស្សនិយាយថា ប្រវត្តិសាស្ត្រផ្លាស់ប្តូរដូចជាត្រចៀកទ្វារតូចមួយ ហើយជីវិតមនុស្សក៏ដូច្នោះដែរ។ ជីវិតរបស់យើងពឹងផ្អែកទៅលើការសម្រេចចិត្តដែលយើងធ្វើ—ត្បិតការសម្រេចចិត្តកំណត់នូវជោគវាសនា»។

**ប្រធាន ថូម៉ាស អេស ម៉នសុន «ការសម្រេចចិត្តកំណត់នូវជោគវាសនា» *New Era* ខែ វិច្ឆិកា ឆ្នាំ1979 ទំព័រ 4។**

# ដូចដែលព្រះគ្រីស្ទបានលួងលោមយើង

គឺវាជាថ្ងៃបុណ្យគ្រីស្ទម៉ាសដំបូងនៅលើកោះញូសាឡែនភាគខាងជើង—ទឹកដីដ៏ស្រស់ស្អាត និងគួរឱ្យទាក់ទាញ។ ប៉ុន្តែក្រៅពីពន្លឺព្រះអាទិត្យដ៏ត្រចះត្រចង់ និងសេចក្ដីល្អរបស់សមាជិកនៃសាសនាចក្រ ខ្ញុំបានមានអារម្មណ៍ថាទទួលការឈឺចាប់ពីភាពឯកកោរយ៉ាងខ្លាំងចំពោះឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំ។ យើងបានប្ដូរទីលំនៅពីសហរដ្ឋអាមេរិកកាលពីដើមឆ្នាំនោះ ហើយមានអារម្មណ៍ថានឹកផ្ទះ។

នៅក្នុងតំបន់ថ្មីរបស់យើងនោះ ស្វាមីខ្ញុំ និងខ្ញុំបានក្លាយជាមិត្តភក្ដិជាមួយនឹងក្រុមគ្រួសារវិលសុន ជាក្រុមគ្រួសារក្មេងខ្ចីមួយមកពីប្រទេសអៀរឡង់ ដែលជឿលើសាសនាគ្រីស្ទផ្សេងទៀត ដែលទើបតែមករស់នៅប្រទេសញូសាឡែនថ្មីថ្មោង។ ទូលីន វិលសុន គឺជាមិត្តភក្ដិធ្វើការជាមួយខ្ញុំ ហើយយើងបានក្លាយជាមិត្តល្អនឹងគ្នាភ្លាមៗ ដោយការចែកចាយពីបទពិសោធន៍នៃការធ្វើអន្តោប្រវេសន៍ និងសេចក្ដីស្រឡាញ់ចំពោះផ្ទះថ្មីរបស់យើង។ ខណៈដែលចំណងមិត្តភាពរបស់យើងបានរីកលូតលាស់ឡើង ខ្ញុំបានចាប់ផ្ដើមដឹងថា ក្រុមគ្រួសាររបស់ពួកគេកំពុងជួបប្រទះនឹងរឿងស្មុគស្មាញនៃភាពឯកកោរផងដែរ ដែលជាអារម្មណ៍នៃការព្រួយបារម្ភ។ ពួកគេមានកូនតូចៗបីនាក់ នៅកំពុងពរពោះកូនទីបួន។

នៅល្ងាចមួយពេលដែលខ្ញុំកំពុងមានអារម្មណ៍ឯកោរយ៉ាងខ្លាំង និងសោកស្ដាយចំពោះខ្លួនឯង ខ្ញុំបានទទួលអារម្មណ៍ថា វិធីដ៏ប្រសើរបំផុតដើម្បីយកឈ្នះភាពឯកកោរគឺបម្រើគ្នាទៅវិញទៅមក—ជាពិសេសក្រុមគ្រួសារវិលសុន។ នៅយប់នោះ ខ្ញុំ និងស្វាមីបានសម្រេចចិត្តប្រារព្ធពិធីបុណ្យគ្រីស្ទម៉ាសក់ចំនួន 12 ថ្ងៃ ជាមួយនឹងក្រុមគ្រួសារវិលសុន ដោយការផ្ញើសារ និងអំណោយតូចៗនៅលើកាំជណ្ដើរមាត់ទ្វាររបស់ពួកគេ ដោយពុំឱ្យពួកគេដឹងថាវាមកពីយើងឡើយ។ ជារៀងរាល់យប់ភាពឯកោររបស់ខ្ញុំបានត្រូវផ្លាស់ប្ដូរដោយភាពរំភើប និងសេចក្ដីសង្ឃឹម នៅពេលដែលយើងលួចចូលទៅក្នុងផ្ទះរបស់ពួកគេ ដើម្បីទុកសារលិខិត និងអំណោយឱ្យ ដោយគោះទ្វាររបស់ពួកគេ ហើយរត់ចេញក្រៅដោយស្នាមញញឹមនៅលើផ្ទៃមុខរបស់យើង។

ជារៀងរាល់ថ្ងៃនៅកន្លែងធ្វើការទូលីន ប្រាប់ខ្ញុំពីរឿងអាថ៌កំបាំងពី «ពួកទេវតាក្នុងបុណ្យគ្រីស្ទម៉ាស» ដែលបានទៅលេងកាលពីយប់មុន។ គាត់នឹងនិយាយប្រាប់ពីដំណើររឿងពីការដែលកូនៗរបស់គាត់ចូលចិត្តដល់អ្នកដែលទុកអំណោយទាំងនោះ ដែលធ្វើឱ្យបុណ្យគ្រីស្ទម៉ាសនៅក្នុងក្រុមគ្រួសាររបស់ពួកគេមានភាពសប្បាយរីករាយ។ មានប៉ុន្មានយប់នោះពួកយុវជនយុវនារីនៅក្នុងវួដបានចូលរួមធ្វើជាមួយយើង។

នៅយប់ចុងក្រោយក្នុងយប់មុនចូលដល់បុណ្យគ្រីស្ទម៉ាស ក្រុមគ្រួសារវិលសុន បានទុកសារលិខិត និងនំឃុកឃីនៅលើកាំជណ្ដើរមាត់ទ្វាររបស់ពួកគេ ដោយសុំជួបនឹងពួកទេវតា។ នៅពេលដែលយើងបានទៅច្រៀងសរសើរទុកជាអំណោយចុងក្រោយរបស់យើងជាមួយនឹងពួកយុវជនយុវនារី កូនៗរបស់ពួកគេបានមានអារម្មណ៍រីករាយ ហើយមិត្តភក្ដិរបស់យើងបានឱបយើង និងស្រក់ទឹកភ្នែកនៃអំណរគុណ។ ភាពឯកកោរនៅក្នុងដួងចិត្តរបស់ខ្ញុំគឺត្រូវបានផ្លាស់ប្ដូរដោយសេចក្ដីស្រឡាញ់ និងភាពរីករាយ និងចំណងមិត្តភាពរវាងក្រុមគ្រួសាររបស់យើងត្រូវបានពង្រឹង។

បន្ទាប់មកយើងបានទទួលអ៊ីម៉ែលមកពីបុរសម្នាក់នៅក្នុងព្រះវិហាររបស់វិលសុន ដែលគាត់បាននិយាយថាគាត់មានអារម្មណ៍ក្ដុកក្ដួលណាស់ ដោយសារតែអ្វីដែលយើងបានធ្វើចំពោះក្រុមគ្រួសារនេះ ដែលធ្វើឱ្យគាត់បានសួរពីសាសនាចក្ររបស់យើង និងអំពីការបម្រើដែលយើងបានធ្វើចំពោះអ្នកដទៃ។ ក្រុមជំនុំនោះពុំដែលបានឮពីការប្រារព្ធបុណ្យគ្រីស្ទម៉ាស 12 ថ្ងៃដូច្នេះពីមុនមកទេ ហើយឥឡូវនេះ ទទួលយកទំនៀមទម្លាប់នេះពីពួកបរិសុទ្ធថ្ងៃចុងក្រោយ។

ខ្ញុំនឹងមិនបំភ្លេចបុណ្យគ្រីស្ទម៉ាសដំបូងនៅក្នុងទឹកដីញូសាឡែន ឡើយ ជាកន្លែងដែលខ្ញុំបានរៀននូវវិធីដែលមិនបានរំពឹងទុកជាមុននូវការបំភ្លេចខ្លួនរបស់ខ្ញុំ ទៅធ្វើការ និង «កម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការកំសាន្តទុក» (ម៉ូសាយ 18:9)—គឺដូចជាព្រះយេស៊ូវគ្រីស្ទលួងលោមដល់យើងនៅក្នុងគ្រាដែលយើងលំបាក និងឯកោរដូច្នោះដែរ។ ■

**អេនជីឡា ហ្វាលីនធីន មកពីប្រទេស ញូសាឡែន**



***នៅពេលដែលយើងបានទៅច្រៀងសរសើរទុកជាអំណោយចុងក្រោយរបស់យើងជាមួយនឹងពួកយុវជនយុវនារី កូនៗរបស់ពួកគេបានមានអារម្មណ៍រីករាយ ហើយមិត្តភក្ដិរបស់យើងបានឱបយើង។***

# ប័ណ្ណគ្រីស្ទម៉ាសរបស់ខ្ញុំ មកពី អ្វូប្រីហ្គូន



*បន្ទាប់ពីបុណ្យគ្រីស្ទម៉ាសខ្ញុំរៀបនឹងបោះប័ណ្ណនោះចោលទៅហើយ តែខ្ញុំបានទទួលអារម្មណ៍ថា រក្សាប័ណ្ណនោះទុក។*

ខណៈដែលខ្ញុំកំពុងបម្រើបេសកកម្មរបស់ខ្ញុំនៅក្នុងប្រទេសម៉ិចស៊ិក្កូ ខ្ញុំ និងដៃគូបានជួបនឹងបុរសម្នាក់មកពី អ្វូប្រីហ្គុន ជាទីក្រុងមួយនៅទិសពាយព្យនៃប្រទេសម៉ិចស៊ិក្កូ នៅជិតឈូងសមុទ្រនៃរដ្ឋកាលីហ្វ័ញ៉ា។ គាត់បានចាប់អារម្មណ៍ចំពោះសារលិខិតរបស់យើងអំពីការស្ដារដំណឹងល្អឡើងវិញ ប៉ុន្តែគាត់មានពេលតែ 10 នាទីប៉ុណ្ណោះដើម្បីនិយាយ ពីព្រោះគាត់ត្រូវតែទៅឱ្យទាន់ជើងរថភ្លើង។ យើងបានបង្រៀនគាត់នូវអ្វីដែលយើងអាចបង្រៀននៅក្នុងរយៈពេលខ្លីនោះ ហើយបានជូនដល់គាត់នូវព្រះគម្ពីរមរមន និងប័ណ្ណដែលយើងមាន។ នៅពេលនោះ បេសកកម្មរបស់យើងពុំមានអ្នកផ្សព្វផ្សាយសាសនានៅក្នុងទីក្រុង អ្វូប្រីហ្គុននោះទេ។

ពីរបីខែក្រោយមក ខ្ញុំបានទទួលប័ណ្ណជូនពរនាបុណ្យគ្រីស្ទម៉ាសមកពីមនុស្សម្នាក់នៅក្នុងទីក្រុង អ្វូប្រីហ្គុន។ ខ្ញុំបានមើលប័ណ្ណនោះ ហើយបានឆ្ងល់ថាតើនរណាជាអ្នកផ្ញើប័ណ្ណនេះមក។ បន្ទាប់មកខ្ញុំបានដឹងថា ប័ណ្ណនេះត្រូវបានផ្ញើមកដោយបុរសម្នាក់ដែលយើងបាននិយាយជាមួយក្នុងរយៈពេល 10 នាទីនោះ។ ខ្ញុំបានដាក់ព្យួរប័ណ្ណនោះនៅក្នុងបន្ទប់ជួលជាមួយនឹងប័ណ្ណគ្រីស្ទម៉ាសដែលពួកអែលឌើរផ្សេងទៀត និងដែលខ្ញុំបានទទួល

បន្ទាប់ពីបុណ្យគ្រីស្ទម៉ាសខ្ញុំរៀបនឹងបោះប័ណ្ណនោះចោលទៅហើយ តែខ្ញុំបានទទួលអារម្មណ៍ថា រក្សាប័ណ្ណនោះទុក។ អារម្មណ៍ពុំមែនជាសម្លេងដែលស្ដាប់ឮនោះទេ ប៉ុន្តែជាអារម្មណ៍នៅក្នុងចិត្ត។ ជំនួសពីការបោះប័ណ្ណនោះចោល ខ្ញុំបានទុកវានោះក្នុងវ៉ាលីរបស់ខ្ញុំ។

ពីរបីខែក្រោយមក នៅពេលដែលខ្ញុំបានកំពុងអានសំបុត្រមកពីផ្ទះបេសកកម្ម ខ្ញុំបានសម្គាល់ឃើញថាមានសេចក្ដីប្រកាសថាកិច្ចការផ្សព្វផ្សាយសាសនានឹងត្រូវបើកនៅក្នុងក្រុងអ្វូប្រីហ្គុន។ ជាថ្មីម្ដងទៀតខ្ញុំបានគិតថា «តើទីក្រុងនោះមានទំនាក់ទំនងអ្វីជាមួយនឹងខ្ញុំ?»។ បន្ទាប់មក ខ្ញុំបានចងចាំជាថ្មីទៀតនូវបុរសដែលយើងបានជួបមកពីទីក្រុងនោះ។ ខ្ញុំបានរើវ៉ាលីរបស់ខ្ញុំ ហើយបានឃើញប័ណ្ណគ្រីស្ទម៉ាសនោះ។ ខ្ញុំបានសរសេរនៅលើកាតនោះថា «ពួកអែលឌើរទាំងនេះគឺជាមិត្តភក្ដិរបស់ខ្ញុំ ហើយខ្ញុំបញ្ជូនពួកគាត់ឱ្យទៅបង្រៀនលោកថែមទៀតអំពីដំណឹងល្អ»។ បន្ទាប់មកខ្ញុំបានផ្ញើប័ណ្ណនោះទៅពួកអែលឌើរដែលត្រូវបានចាត់តាំងឱ្យបម្រើនៅក្នុងក្រុងអ្វូប្រីហ្គុន ហើយបានប្រាប់ពួកគេឱ្យយកទៅជាមួយពួកគេ ហើយទៅលេងបុរសនោះ។

មិនយូរប៉ុន្មាន ខ្ញុំបានទទួលសំបុត្រមួយមកពីពួកអែលឌើរនៅក្នុងក្រុង អ្វូប្រីហ្គុន។ សំបុត្រសរសេរថា ៖ «ជូនចំពោះអែលឌើរ វ៉ាម៉ូស កិច្ចការនៅទីនេះមានការលំបាកណាស់ ដែលប្រធានបេសកកម្មបានរៀបចំផែនការដើម្បីដកយើងចេញពីតំបន់នេះរហូតដល់ពួកយើងបានទទួលប័ណ្ណរបស់អ្នក។ យើងបានទៅជួបនឹងបងប្រុសរូបនេះ ហើយគាត់បានសប្បាយចិត្តអំពីសារលិខិតរបស់យើងណាស់ ដែលគាត់បាននាំយើងទាំងអស់គ្នាទៅជួបក្រុមគ្រួសារ និងមិត្តភក្ដិរបស់គាត់។ ពីព្រោះតែបងប្រុសរូបនេះ យើងបានបង្កើតជាសាខាមួយ»។

ជាច្រើនឆ្នាំបានកន្លងទៅ ហើយឥឡូវនេះមានស្តេកចំនួនបីត្រូវបានរៀបចំឡើងនៅក្នុងទីក្រុង អ្វូប្រីហ្គុន។ ខ្ញុំមានចិត្តរាបសារដោយដឹងថាពីព្រោះតែខ្ញុំបានស្ដាប់តាមការបំផុសមកពីព្រះវិញ្ញាណ ខ្ញុំបានត្រូវប្រទានពរដើម្បីដើរតួជាផ្នែកតូចមួយនៅក្នុងការជួយបងប្អូនប្រុសស្រីរបស់ខ្ញុំនៅទីក្រុង អ្វូប្រីហ្គុន ឱ្យទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ ■

**រ៉ូបឺត វ៉ាម៉ូស មកពីអ្វូរីហ្គូន សហរដ្ឋអាមេរិក**

# យើងគ្មានអ្វីដើម្បីបរិភោគទេ

ខ្ញុំបានក្រោកពីព្រលឹមនៅមុនថ្ងៃចូលបុណ្យគ្រីស្ទម៉ាស បានព្រួយបារម្ភដោយសារតែយើងពុំមានអ្វីសោះដើម្បីធ្វើអាហារពេលល្ងាចសម្រាប់បុណ្យគ្រីស្ទម៉ាសរបស់យើង ឬក៏លុយដើម្បីទិញអាហារអ្វីក៏គ្មានដែរ។ នៅពេលនោះខ្ញុំបានរស់នៅជាមួយបងស្រីរបស់ខ្ញុំឈ្មោះអ៊ុឌីកតា នៅក្នុងក្រុងម៉ារ៉ាសៃប៊ូ វ៉េនេហ្ស៊ូអេឡា។

នៅពេលខ្ញុំក្រោកពីដេក ខ្ញុំបានលុតជង្គង់ចុះ ហើយចាប់ផ្ដើមធ្វើការអធិស្ឋាន។ ខ្ញុំបានបួងសួងឱ្យព្រះវរបិតាសួគ៌របស់ខ្ញុំឱ្យចងចាំពួកយើង។ ខ្ញុំបានទូលដល់ទ្រង់ឱ្យប្រទានពរដល់យើង យ៉ាងហោចណាស់នូវអាហារខ្លះៗសម្រាប់ថ្ងៃដ៏ពិសេសនោះ *la Noche Buena* (មុនថ្ងៃចូលបុណ្យគ្រីស្ទម៉ាស)។

នៅពេលដែលខ្ញុំបានអធិស្ឋាន ខ្ញុំបានពោរពេញដោយសេចក្ដីសុខសាន្ត។ ខ្ញុំហាក់ដូចជាបានឮសម្លេងដ៏ទន់ភ្លន់មានបន្ទូលមកកាន់ខ្ញុំថា «អ្វីៗទាំងអស់នឹងមិនថ្វីទេ។ កុំប្រារព្ធឡើយ»។ នៅពេលខ្ញុំបានអធិស្ឋានរួច ខ្ញុំបានដឹងថានឹងមានអ្វីមួយល្អកើតឡើងនៅក្នុងថ្ងៃនោះ។

បន្ទាប់ពីបានដាស់បងស្រីរបស់ខ្ញុំក្រោកពីដេក ខ្ញុំបានទៅជូតរានហាលមុខផ្ទះ។ អ្នកជិតខាងដែលនៅទល់មុខនោះបានឃើញខ្ញុំ ហើយបានមកផ្ទះរបស់ខ្ញុំ ដើម្បីឱ្យខ្ញុំ 1,000 bolívares ដែលគាត់បានជំពាក់ថ្លៃ កម្រាលតុដែលខ្ញុំបានប៉ាក់ និងការតុបតែងឱ្យគាត់។ ខ្ញុំបានភ្ញាក់ផ្អើលដោយសារតែខ្ញុំមិនបានចងចាំថា គាត់បានជំពាក់ប្រាក់ខ្ញុំឡើយ។

ខ្ញុំបានរត់ទៅជួបបងស្រីរបស់ខ្ញុំ ហើយបានបង្ហាញដល់គាត់នូវប្រាក់ដែលខ្ញុំបានទទួល។ ដោយការភ្ញាក់ផ្អើលគាត់បានសួរខ្ញុំថាតើខ្ញុំបានប្រាក់នោះពីណា។ ខ្ញុំបានឆ្លើយថា «តែព្រះ ទ្រង់អាចនឹងធ្វើកើតទាំងអស់» (ម៉ាថាយ 19:26)។

ពីរបីនាទីក្រោយមក យើងបានឮនរណាម្នាក់នៅខាងក្រៅស្រែកហៅបងស្រីរបស់ខ្ញុំ។ នៅពេលដែលយើងចាប់ផ្ដើមដឹងថា គឺជាអ្នកជិតខាងដដែលរូបនោះ យើងបានចេញទៅនិយាយជាមួយគាត់។ បន្ទាប់មកគាត់បានបង់ប្រាក់ឱ្យបងស្រីរបស់ខ្ញុំ 1,000 bolívares ដែលគាត់បានជំពាក់បងស្រីខ្ញុំថ្លៃដេរមួយចំនួន។ បងស្រីខ្ញុំនិងខ្ញុំបានមានចិត្តសប្បាយរីករាយណាស់ ពីព្រោះឥឡូវនេះយើងអាចទិញអាហារពេលព្រឹក អាហារថ្ងៃត្រង់ *និង* អាហារពេលល្ងាចបាន។

បន្ទាប់ពីយើងបានត្រឡប់មកពីការដើរទិញគ្រឿងទេសវិញ យើងបានជួបមិត្តភក្តិរបស់យើងកំពុងរង់ចាំយើង។ គាត់បានសួរប្រសិនបើគាត់អាចចំណាយពេល *la Noche Buena* ជាមួយយើង ពីព្រោះគាត់ពុំចង់ចំណាយពេលបុណ្យគ្រីស្ទម៉ាសតែម្នាក់ឯងឡើយ។ យើងបានពន្យល់ថា យើងគ្រាន់តែមានអាហារពេលល្ងាចនៅផ្ទះតែបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែគាត់ត្រូវបានស្វាគមន៍ឱ្យចូលរួម។ គាត់បានបរិច្ចាគ 2,000 bolívares ទៀតដើម្បីជួយចំណាយលើថ្លៃអាហារ។ យើងមិនអាចជឿថាតើព្រះបានកំពុងប្រទានពរជ័យដល់យើងប៉ុណ្ណានោះទេ។

ក្រោយមក ក្មួយរបស់ខ្ញុំបានទូរស័ព្ទហៅយើងថានាងនឹងមកដល់នៅយប់នោះ ហើយនឹងយកសាច់ប្រឡាក់ 33 ផោន (15 kg) មកជាមួយដែរ។ ហើយនៅពេលថ្ងៃត្រង់ក្មួយប្រុសរបស់ខ្ញុំបានមកជាមួយនឹងភរិយារបស់គាត់ និងកូនៗរបស់ពួកគេ។ ពួកគេបានសួរប្រសិនបើពួកគេអាចត្រឡប់មកវិញនៅពេលល្ងាចនោះដោយនាំមកនូវអាហារមួយចំនួន និងការប្រារព្ធយប់មុនចូលបុណ្យគ្រីស្ទម៉ាសជាមួយយើង។

យើងបានឆ្លើយថា «យើងនឹងពុំមានអាហារពេលល្ងាចច្រើននោះទេ ប៉ុន្តែយើងនឹងមានអាហារសម្រាប់មនុស្សគ្រប់គ្នា»។

នៅយប់នោះ អ៊ែឌីកតា និងខ្ញុំបានដុតមាន់ ធ្វើសាឡាត់ដំឡូង បង្អែមធ្វើពីក្រូច និង *majarete* ជាបង្អែមសង់ខ្យាធ្វើពីដូងតាមប្រពៃណី ដែលទាំងយើងនិងភ្ញៀវទាំងឡាយហូបយ៉ាងរីករាយជាមួយគ្នា។ ប៉ុន្តែដំបូងគេយើងថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ចំពោះពរជ័យដ៏មហិមាដែលទ្រង់បានប្រទានដល់យើង។

នៅថ្ងៃនោះយើងត្រូវបានរំលឹកថា ប្រសិនបើយើងមានសេចក្ដីជំនឿ និងពុំមានការសង្ស័យ នោះទ្រង់នឹងប្រទានពរជ័យដល់យើង នៅពេលដែលយើងសុំជំនួយពីទ្រង់។ ■

**អែស្ទីលីតា ឆាស៊ីន ហាត មកពីរដ្ឋយូថា សហរដ្ឋអាមេរិក**



*នៅពេលខ្ញុំក្រោកពីដេក ខ្ញុំបានលុតជង្គង់ចុះ ហើយចាប់ផ្ដើមធ្វើការអធិស្ឋាន។ ខ្ញុំបានបួងសួងឱ្យព្រះវរបិតាសួគ៌របស់ខ្ញុំឱ្យចងចាំពួកយើង។*

# បុណ្យគ្រីស្ទម៉ាស ចុងក្រោយរបស់លីនដា



*លីនដា បានមកចូលរួមពិធីបុណ្យគ្រីស្ទម៉ាសនៅក្នុងវួដ នៅអំឡុងពេលដែលមានសមាជិកពីរបីនាក់ក្នុងវួដបានទៅផ្ទះរបស់គាត់យកអាហារទៅដាក់នៅលើធ្នើរ និងទូរទឹកកករបស់គាត់។*

នៅអំឡុងឆ្នាំទីពីរក្នុងសាកលវិទ្យាល័យព្រិកហ្គាំ យ៉ង់ គណៈប៊ីស្សពក្នុងវួដរបស់យើងបានចាត់តាំងឱ្យមានកម្មវិធីសាន់តាខ្លោះឡើង តាមរយៈអ្វីដែលយើងអាចជូនអំណោយទាំងឡាយនៃបុណ្យគ្រីស្ទម៉ាសដល់ក្រុមគ្រួសារដែលកំពុងខ្វះខាត។

ទោះជាយ៉ាងណាក្ដី ឈ្មោះវួដរបស់យើងតែងតែរំលងភ្នែករបស់ពួកអ្នកស្ម័គ្រចិត្តទាំងឡាយ។ នៅពេលដែលបុណ្យគ្រីស្ទម៉ាសជិតចូលមកដល់ យើងនៅតែគ្មានក្រុមគ្រួសារដើម្បីជួយ។ បន្ទាប់មកទីប្រឹក្សាម្នាក់របស់ប៊ីស្សពបានប្រាប់យើងពីក្រុមគ្រួសារមួយដែលអាចត្រូវការជំនួយរបស់យើង។ នៅពេលដែលយើងបានដឹងអំពីក្រុមគ្រួសារនេះ យើងទាំងអស់គ្នាបានមានអារម្មណ៍ជឿជាក់ថា យើងគួរតែផ្ដោតយកចិត្តទុកដាក់ចំពោះពួកគេ។

លីនដា (ឈ្មោះត្រូវបានផ្លាស់ប្ដូរ) ដែលគាត់មានកូនប្រុសពីរបីនាក់មានអាយុពី 9 ទៅ 15 ឆ្នាំ បានរកឃើញថាមានជម្ងឺមហារីកដោះ។ នៅអំឡុងពេលដ៏លំបាកនៃការឈឺចាប់ ស្វាមីរបស់គាត់បានចាកចេញពីគាត់។ គាត់ទើបតែផ្លាស់ប្ដូរលំនៅមកពីរដ្ឋផ្សេងទៀតដើម្បីធ្វើការនៅក្រុងប្រូវ៉ូ រដ្ឋយូថាហ៍ ប៉ុន្តែពុំមានការងារធ្វើ គាត់គ្មានប្រាក់ចំណូលអ្វីសោះ។

នៅពេលដែលយើងបានជួបនឹងលីនដា យើងបានមានក្ដីស្រឡាញ់ចំពោះគាត់ភ្លាមៗ។ យើងបានមានពរណាស់ដែលបានជួបនឹងគាត់តាមរបៀបដែលព្រះអង្គសង្គ្រោះបានធ្វើ—ជាវិញ្ញាណដ៏អស្ចារ្យ និងថ្លៃថ្នូរ ដែលគាត់បានយកឈ្នះលើឧបសគ្គលំបាកៗជាច្រើន។ គាត់ពុំមែនជា*អ្នកដទៃ* ចំពោះយើងទេ ផ្ទុយទៅវិញ គាត់គឺជាមិត្តដ៏នៅអស់កល្បជានិច្ច។ សមាជិកគ្រប់រូបនៅក្នុងវួដបានបរិច្ចាគអ្វី មួយដែលជួយដល់គាត់ និងកូនៗរបស់គាត់។ យើងទាំងអស់គ្នាគឺជានិស្សិតក្មេងខ្ចីនៅមហាវិទ្យាល័យ និងគ្មានសិទ្ធិដើម្បីធ្វើអ្វីច្រើនឡើយ ប៉ុន្តែយើងបានផ្ដល់ឱ្យដោយរីករាយដោយសារតែយើងស្រឡាញ់គាត់។

លីនដា បានមកចូលរួមពិធីបុណ្យគ្រីស្ទម៉ាសនៅក្នុងវួដ នៅអំឡុងពេលដែលមានសមាជិកពីរបីនាក់ក្នុងវួដបានទៅផ្ទះរបស់គាត់យកអាហារទៅដាក់នៅលើធ្នើរ និងទូរទឹកកករបស់គាត់។ ពួកគេបានតុបតែងដើមបុណ្យគ្រីស្ទម៉ាស និងបានដាក់តាំងកាដូពាសពេញសម្រាប់ក្រុមគ្រួសារទាំងមូល។ ពួកគេក៏បានទុកកង់រថយន្តថ្មីចំនួនបួនឱ្យគាត់ និងបង់ថ្លៃជលអគារពីរបីខែឱ្យគាត់។ ខ្ញុំមិនប្រាកដថាតើស្ត្រីដ៏តូចម្នាក់នេះអាចធ្វើអ្វីៗទាំងអស់បានដោយរបៀបណានោះទេ ប៉ុន្តែខ្ញុំបានដឹងថាព្រះវរបិតាសួគ៌បានប្រើប្រាស់យើងដើម្បីប្រទានពរជ័យដល់គាត់។

មួយឆ្នាំក្រោយមក ខ្ញុំបានទៅវួដរបស់និសិត្សផ្សេងទៀត ប៉ុន្តែខ្ញុំបានត្រឡប់មកលេង នឹងគណៈប៊ីស្សពចាស់របស់ខ្ញុំនៅបុណ្យគ្រីស្ទម៉ាស។ ខ្ញុំបានទទួលព័ត៌មានថាស្វាមីលីនដា បានត្រឡប់ទៅកាន់ក្រុមគ្រួសារវិញ ហើយថាបញ្ហាហិរញ្ញវត្ថុរបស់ពួកគេបានមានលំនឹងវិញ។ ប៉ុន្តែបន្ទាប់មក ជម្ងឺមហារីករបស់គាត់បានត្រឡប់មកវិញ ហើយបានទាញជីវិតគាត់ទៅ។ ខ្ញុំបានដឹងថា យើងបានជួយផ្ដល់ឱ្យលីនដា នូវបុណ្យគ្រីស្ទម៉ាសចុងក្រោយរបស់គាត់។

នៅក្នុងការទទួលអារម្មណ៍នៃ «សេចក្ដីស្រឡាញ់ដ៏សុទ្ធសាធរបស់ព្រះគ្រីស្ទ» (ម៉ូរ៉ូណៃ 7:47) យ៉ាងខ្លាំងតាមរយៈបទពិសោធន៍នោះ ខ្ញុំបានរៀនថាសេចក្ដីសប្បុរសពិតប្រាកដគឺជាអំណោយទានដែលមានតម្លៃកាត់ថ្លៃមិនបានខាងវិញ្ញាណ ដែលជំរុញយើងឱ្យដើរតួជាព្រះអង្គសង្គ្រោះ។ ■

**ជេ. អូឌ្រី ហាំមើរ មកពីរដ្ឋយូថាហ៍ សហរដ្ឋអាមេរិក**



**ដោយអែលឌើរ**
**ផាទ្រីក ខៀរ៉ុន**
នៃពួកចិតសិបនាក់

# ចូរយើងនាំគ្នា ចូលមកថ្វាយបង្គំទ្រង់

កាលពីបុណ្យគ្រីស្ទម៉ាសឆ្នាំទៅ ខណៈដែលកំពុងបម្រើនៅឯទីស្នាក់ការកណ្ដាលសាសនាចក្រក្នុងទីក្រុងសលលេក រដ្ឋយូថាហ៍ សហរដ្ឋអាមេរិក ខ្ញុំបានប្រឈមមុខស្ថានភាពធាតុអាកាសមួយក្នុងមូលដ្ឋានដែលហៅថា ការបញ្ច្រាស។ ការបញ្ច្រាសគឺជាស្ថានភាពមួយដែលខ្យល់នៅជិតនឹងដីមានភាពត្រជាក់ជាងខ្យល់ដែលនៅខ្ពស់ពីដី ជាការផ្ទុយ—ការបញ្ច្រាស—ពីស្ថានភាពធម្មតា។ ការបញ្ច្រាសនានាគឺពុំមានជារឿងចម្លែកចំពោះទីក្រុងសលលេកឡើយ ប៉ុន្តែវាមានការជះឥទ្ធិពលយ៉ាងខ្លាំង ពីព្រោះទីក្រុងនេះមានទីតាំងស្ថិតនៅក្នុងជ្រលងភ្នំមួយដែលហ៊ុមព័ទ្ធដោយភ្នំធំៗ។ ការណ៍នេះបានធ្វើទីក្រុងនេះពាសពេញទៅដោយអ័ព្ទនៅតាមចង្កេះភ្នំ ដោយធ្វើឱ្យមានដុំពពកដ៏ខ្មៅងងឹត ហើយត្រជាក់គ្របដណ្ដប់ទីក្រុងនេះ និងតំបន់ជុំវិញ។ អ័ព្ទនោះគឺបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពនៃអស់អ្នកដែលមានបញ្ហាខាងផ្លូវដង្ហើម ហើយជះឥទ្ធិពលដល់ការជឿជាក់របស់មនុស្សជាច្រើននាក់ផ្សេងទៀត ខណៈដែលខ្យល់នេះបង្កឱ្យមានមេឃស្រអាប់ ហើយមើលពុំឃើញព្រះអាទិត្យអស់រយៈពេលជាច្រើនថ្ងៃ ហើយក៏អាចរហូតដល់សប្ដាហ៍ផងដែរ។

ប៉ុន្តែការធ្វើដំណើរដ៏ខ្លីមួយទៅកាន់ភ្នំទាំងនោះបានបង្ហាញឱ្យឃើញថា អ័ព្ទនោះមានកម្រាស់ប្រមាណជាពីរបីរយហ្វីតប៉ុណ្ណោះ។ ក្នុងរយៈពីរទៅបីនាទី អ្នកអាចស្ថិតនៅក្នុងពន្លឺព្រះអាទិត្យដ៏ភ្លឺ ដោយស្រូបនូវខ្យល់ស្រស់ថ្លា ហើយសម្លឹងមើលភ្នំដ៏ស្រស់ស្អាត។ ភាពខុសគ្នាជាមួយជ្រលងភ្នំខាងក្រោមនោះគឺគ្មានភាពទទេរស្អាតឡើយ។ នៅពេលអ្នកឡើងលើភ្នំបន្តិចទៀត ហើយអ្នកសម្លឹងមើលចុះមកអ័ព្ទនោះ នោះអ្នកមើលមិនឃើញជ្រលងភ្នំនោះឡើយ វាហាក់ដូចជាដុំពពកដ៏កខ្វក់នៅក្រោមផ្ទៃមេឃពណ៌ខៀវដ៏ស្រស់បំព្រង។

មានពេលខ្លះនៅក្នុងជីវិតរបស់យើង ដែលយើងរកឃើញថាខ្លួនឯងជាប់នៅក្នុងជ្រលងភ្នំនោះ ស្ថិតនៅក្រោមភាពងងឹតនៃអ័ព្ទដ៏

*យើងត្រូវតែស្គាល់ថា យើងមានអំណាច និងសមត្ថភាពដើម្បីនាំខ្លួនយើងចេញពីខ្យល់ដ៏កខ្វក់នៃជ្រលងភ្នំនោះបាន ហើយចូលទៅក្នុងពន្លឺព្រះអាទិត្យដ៏ភ្លឺនៃសេចក្ដីសុខសាន្ត និងសេចក្ដីសង្ឃឹមដែលមានតែតាមរយៈការមករកព្រះអង្គសង្គ្រោះប៉ុណ្ណោះ។*



ក្រាស់នោះ។ ដោយសារតែការជ្រើសរើសមិនត្រឹមត្រូវដែលយើងបានធ្វើ ឥរិយាបថទាំងឡាយដែលបំពានដល់ព្រះវិញ្ញាណ ឬការសម្រេចចិត្តដ៏ឈឺចាប់ ហើយធំ និងការលំបាកជាទូទៅសម្រាប់ជីវិតរមែងស្លាប់ នោះយើងទទួលអារម្មណ៍ថាផុងនៅក្នុងអ័ព្ទដ៏ក្រាស់ណែននោះ។ យើងមិនអាចមើលឃើញច្បាស់ យើងមានការភាន់ច្រឡំ ហើយមានអារម្មណ៍ថាយើងបានរំកិលខ្លួនឆ្ងាយពីពន្លឺ និងភាពកក់ក្ដៅនៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌យើង។ យើងភ្លេចថា ពន្លឺដ៏បរិសុទ្ធនៃព្រះអម្ចាស់កំពុងរង់ចាំយើង ហើយវាគ្រាន់តែជាការបោះជំហាននៃសេចក្ដីជំនឿប៉ុន្មានជំហានទៀតប៉ុណ្ណោះ។ យើងត្រូវតែស្គាល់ថា យើងមានអំណាច និងសមត្ថភាពដើម្បីនាំខ្លួនយើងចេញពីខ្យល់ដ៏កខ្វក់នៃជ្រលងភ្នំនោះបាន ហើយចូលទៅក្នុងពន្លឺព្រះអាទិត្យដ៏ភ្លឺនៃសេចក្ដីសុខសាន្ត និងសេចក្ដីសង្ឃឹមដែលមានតែតាមរយៈការមករកព្រះអង្គសង្គ្រោះប៉ុណ្ណោះ។

នៅបុណ្យគ្រីស្ទម៉ាសនេះ យើងរីករាយនៅក្នុងការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ ជាពន្លឺនៃលោកិយ ជាអង្គដែលបានអញ្ជើញយើងទាំងអស់គ្នាឱ្យមករកទ្រង់ និងចូលមកក្នុងពន្លឺនេះ។ យើងអាចអាននៅក្នុងព្រះគម្ពីរអំពីបុរស និងស្ត្រីដែលត្រូវបានប្រទានពរឱ្យដើម្បីមករកទ្រង់នៅគ្រានៃការប្រសូត្រ។ មានមួយចំនួនបានមកពីទីឆ្ងាយ ខណៈដែលអ្នកផ្សេងទៀតនៅជិតបង្កើយ។ មានមួយចំនួនបានជួបនឹងទេវតា ហើយអ្នកផ្សេងទៀតបានធ្វើតាមវិវរណៈផ្ទាល់ខ្លួន។ ប៉ុន្តែពួកគេម្នាក់ៗបានទទួលយកការអញ្ជើញឱ្យមករកទ្រង់។

តើយើងអាចរៀនអ្វីខ្លះពីពួកគង្វាល ស៊ីម្មូន អាណា និងពួកហោរា ជាមនុស្សដែលបានមករក ហើយបានឃើញព្រះឱរសដ៏ជាព្រះគ្រីស្ទដោយផ្ទាល់ភ្នែកនោះ? នៅពេលយើងពិចារណាពីចម្លើយដ៏ស្មោះត្រង់របស់យើងចំពោះការអញ្ជើញឱ្យមករកព្រះគ្រីស្ទ នោះ យើងអាចរៀនដើម្បីលើកខ្លួនយើងឱ្យកាន់តែមានប្រសិទ្ធភាពចេញពីការបញ្ច្រាសរបស់យើងផ្ទាល់ និងចេញពីរាល់ភាពងងឹត និងការភាន់ច្រឡំដែលយើងអាចនឹងជួប ហើយនាំខ្លួន



រូបថតដោយ ថម ស្មាត *DESERET NEWS;* ព័ត៌មានលំអិតដកស្រង់ចេញពី *THE BIRTH OF JESUS,* ដោយ ខាល ហេនរីឆ ប្លូច់ បានប្រើដោយការអនុញ្ញាតមកពីសារៈមន្ទីរប្រវត្តិសាស្ត្រជាតិនៅឯហ្វ្រេឌឺរីស្បឺក ក្នុងហីលឡឺរ៉ូដ ប្រទេសដាណាម៉ាក



យើងចូលទៅក្នុងសេចក្តីសង្ឃឹមដ៏ច្បាស់បរិសុទ្ធដែលផ្តល់ឱ្យដោយពន្លឺនៃពិភពលោកនេះ។ វានៅទីនោះ ជាមួយនឹងទ្រង់ ដែលអាចដឹងថាតើយើងជានរណាឱ្យប្រាកដ ហើយពីទីកន្លែងដែលយើងនឹងត្រូវរស់នៅក្នុងទិដ្ឋភាពដ៏នៅអស់កល្បជានិច្ចនោះ។ ការបញ្ញាសរបស់យើងត្រូវច្រាសមកវិញ ហើយកត្តាដ៏ត្រឹមត្រូវត្រូវបានស្តារឡើងវិញ។

**ពួកអ្នកគង្វាល**

នៅក្នុងខគម្ពីរដ៏មានប្រជាប្រិយភាពមួយនៅក្នុងលូកា 2 យើងបានរៀនពីកត្តាដ៏ចាំបាច់អំពីអស់អ្នកដែលធ្វើជាសាក្សីដំបូងនៃការប្រសូតរបស់ព្រះគ្រីស្ទ ដូចជា ពួកអ្នកគង្វាលនៅក្នុងវាលជិតបេថ្លេហិម។ នៅពេល «ទេវតានៃព្រះអម្ចាស់មកឈរជិតគេ ... គេមានសេចក្តីភ័យខ្លាចជាខ្លាំង» (ខ 9)។ ប៉ុន្តែពួកគេបានឮ «ដំណឹងល្អពីសេចក្តីអំណរយ៉ាងអស្ចារ្យ» ដែលបានប្រាប់ទុកជាមុនជាយូរមកហើយពីព្រះអង្គសង្គ្រោះ ព្រះមេស៊ី ព្រះគ្រីស្ទ បានប្រសូតមក (ខ 10)។ ពួកគេបានស្តាប់ដើម្បីស្គាល់ពីសញ្ញាដែលពួកគេអាចស្គាល់ពីព្រះអង្គសង្គ្រោះ ថាទ្រង់នឹងត្រូវ «រុំនឹងសំពត់ផ្តេកនៅក្នុងស្នូក» (ខ 12)។ នៅពេលទេវតាពីស្ថានសួគ៌បានបញ្ចប់ការប្រកាសដ៏រីករាយរបស់ខ្លួន នោះពួកអ្នកគង្វាលបានឆ្លើយតបភ្លាមដោយនិយាយថា «ចូរយើងទៅឯបេថ្លេហិម មើលការដែលបានកើតមកនោះ» (ខ 15)។ ពួកគេក៏ទៅ «ប្រញាប់» (ខ 16) ហើយបានឃើញព្រះឱរសជាព្រះគ្រីស្ទ ដូចដែលទេវតាបានមានបន្ទូល រួចហើយពួកគេ «ក៏វិលត្រឡប់ទៅវិញទាំងសរសើរដំកើងដល់ព្រះ» (ខ 20)។ ដោយចង់ចែកចាយនូវដំណឹងដ៏រុងរឿងអំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ «គេក៏បានរ៉ាយរ៉ាប់រឿង [នោះ ]» (ខ 17)

*ភាពជាសិស្សរបស់យើងមិនតម្រូវឱ្យយើងទុកចោលចៀមរបស់យើងនៅក្នុងទីវាល ឬឆ្លងកាត់វាលខ្សាច់នោះឡើយ។ ដំណើររបស់យើងទៅកាន់ព្រះអង្គសង្គ្រោះ ពុំមែនជារឿងខាងសាច់ឈាមនោះទេ វាគឺជារឿងខាងវិញ្ញាណ និងឥរិយាបថ។ វាទាក់ទងនឹងការទទួលយក និងការឱបក្រសោបនូវដង្វាយធួនរបស់ទ្រង់។*

ដូចជាពួកគង្វាល យើងត្រូវតែឆ្លើយតបភ្លាមៗឱ្យលឿនបំផុត

នៅពេលណាព្រះវិញ្ញាណមានព្រះបន្ទូលមកកាន់យើង។ នៅក្នុងប្រសាសន៍របស់ប្រធាន ថូម៉ាស អេស ម៉នសុន នោះយើង «មិនត្រូវ ផ្អាកចំពោះការធ្វើតាមការបំផុសគំនិតមួយនោះឡើយ»។[1] ពេលខ្លះ បន្ទាប់ពីស្ដាប់នូវការបំផុសគំនិតមួយ នោះយើងមិនអាចមើលឃើញច្បាស់ពីហេតុផលដែលយើងត្រូវបានទទួលការដឹកនាំដោយព្រះវិញ្ញាណដើម្បីធ្វើតាមរបៀបដ៏ជាក់លាក់មួយឡើយ។ ប៉ុន្តែជារឿយៗ ដូចជាពួកគង្វាលផងដែរ យើងបានឃើញអព្ភូតហេតុកើតមានឡើង ហើយការឆ្លើយតបដ៏ស្មោះត្រង់របស់យើងចំពោះការបំផុសគំនិតមួយត្រូវបានបញ្ជាក់។ បន្ទាប់មក យើងអាចយកឱកាសដើម្បីចែកចាយសេចក្ដីអំណររបស់យើង និងសាក្សីរបស់យើងជាមួយនឹងមនុស្សដទៃ។ ការធ្វើដូច្នេះអាចពង្រឹងសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមរបស់មនុស្សដទៃទៀត ហើយលើសពីនេះគឺពង្រឹងដល់ទីបន្ទាល់របស់យើងផ្ទាល់ ហើយនាំយើងឱ្យខិតជិតនឹងព្រះអង្គសង្គ្រោះ និងផ្លូវរបស់ទ្រង់។

## ស៊ីម៉ូន

សាក្សីដ៏ប្រពៃម្នាក់ទៀតអំពីព្រះឱរសដ៏ជាព្រះគ្រីស្ទគឺស៊ីម៉ូន។ គាត់ជាមនុស្ស «សុចរិត និងកោតខ្លាចដល់ព្រះ» ដែលគាត់បានទទួលទំនាក់ទំនងមកពីព្រះវិញ្ញាណបរិសុទ្ធជាប្រចាំ (លូកា 2:25)។ គាត់បានទទួលការបើកសម្ដែងថា «គាត់មិនស្លាប់ឡើយ ទាល់តែបានឃើញព្រះគ្រីស្ទនៃព្រះអម្ចាស់» (ខទី 16) ហើយគាត់បានរស់នៅក្នុងសេចក្ដីសង្ឃឹម និងទទួលយកនូវពរជ័យជាហេតុការណ៍នោះ។ ព្រះវិញ្ញាណបានបំផុសគាត់ឱ្យមកឯព្រះវិហារនៅថ្ងៃដែល ម៉ារា និងយ៉ូសែប បាននាំព្រះឱរសជាព្រះយេស៊ូវទៅកាន់ក្រុងយេរូសាឡិម «ដើម្បីថ្វាយដល់ព្រះអម្ចាស់» (ខទី 22)។ ស៊ីម៉ូនបានស្គាល់ព្រះឱរសថាជាព្រះម៉ែស៊ីដែលបានសន្យា ហើយ «ក៏ទទួលមកបី ហើយសរសើរដល់ព្រះ» (ខទី 28) ដោយបានធ្វើការព្យាករណ៍ពីជោគវាសនារបស់ព្រះឱរសដ៏បរិសុទ្ធថាជា «ពន្លឺសម្រាប់បំភ្លឺដល់សាសន៍ដទៃ ហើយជាសិរីល្អរបស់អ៊ីស្រាអែល» (ខទី 32)។

ជីវិតដ៏សុចរិត ហើយស្មោះត្រង់របស់ស៊ីម៉ូនបានជួយឱ្យគាត់មានវត្តមាននៅក្នុងព្រះវិហារបរិសុទ្ធ ដើម្បីគាត់អាចថ្លែងទីបន្ទាល់អំពីពន្លឺដែលនៅទីបំផុតគាត់បានស្វែងរកវាឃើញនោះ។ ដូចជាស៊ីម៉ូន យើងក៏អាចព្យាយាមស្វែងរកអារម្មណ៍ និងការគោរពប្រតិបត្តិដ៏ធំធេងចំពោះការខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធផងដែរ ដើម្បីឱ្យជីវិតរបស់យើងអាចដើរនៅលើផ្លូវដែលព្រះវរបិតាសួគ៌យើងបានរៀបចំសម្រាប់យើង។ ដោយសារស៊ីម៉ូនបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួននៅក្នុងស្ដាប់ឮ ហើយឆ្លើយតបចំពោះព្រះវិញ្ញាណ នោះគាត់បានស្ថិតនៅក្នុងទីកន្លែង និងពេលវេលាមួយដ៏ត្រឹមត្រូវ ហើយការសន្យារបស់ព្រះអម្ចាស់ចំពោះគាត់ត្រូវបានបំពេញនៅក្នុងរបៀបដ៏រុងរឿងបំផុត។

ឱកាសដូចគ្នានេះអាចកើតមានចំពោះយើងគ្រប់គ្នា ហើយក៏អាចអនុញ្ញាតឱ្យផែនការរបស់ព្រះអម្ចាស់លាតត្រដាងនៅក្នុងជីវិតរបស់យើងផងដែរ។ នៅពេលយើងត្រូវបានប្រឈមមុខជាមួយការសម្រេចចិត្តនៃកត្តាសំខាន់ដ៏នៅអស់កល្បជានិច្ច នៅពេលយើងស្ថិតនៅក្នុងគ្រានៃសេចក្ដីពិតក្នុងជីវិតរបស់យើង នោះយើងត្រូវការភាពច្បាស់លាស់នៃការគិត និងទស្សនៈដ៏ត្រឹមត្រូវ។ ពេលខ្លះលក្ខណៈនៃការធ្វើការសម្រេចចិត្តដ៏សំខាន់ទាំងនេះបានធ្វើឱ្យយើងមានអារម្មណ៍ថាខ្វះសុវត្ថិភាព ខ្វះភាពនឹងនរ ហើយថែមទាំងមិនអាចធ្វើសកម្មភាពបានទៀតផង ដោយធ្លាក់ចូលទៅក្នុងជ្រលងភ្នំដ៏ងងឹតក្រោមការបញ្ឆោតនោះ។ ប៉ុន្តែនៅពេលយើងបោះជំហាននៃសេចក្ដីជំនឿ ហើយធ្វើឱ្យស្របតាមគោលការណ៍ដ៏សុចរិត នោះយើងនឹងមើលឃើញផែនការរបស់ព្រះកំពុងតែរៀបចំជីវិតរបស់យើងបន្តិចម្ដងៗ ហើយយើងត្រូវបាននាំឱ្យត្រឡប់ចូលទៅក្នុងពន្លឺព្រះអាទិត្យដ៏ភ្លឺនៃសេចក្ដីស្រឡាញ់របស់ព្រះ។

## អាណា

អាណា គឺជាស្ត្រីនៃ «យុគ្គសម័យដ៏អស្ចារ្យ» ជាស្ត្រីមេម៉ាយដែលត្រូវបានដាក់ទាមឱ្យថា «ហោរា» (លូកា 2:36) ជាអ្នកដែលមានអាយុដ៏វែង និងមានជីវិតស្មោះត្រង់ ដែលត្រូវបានពិពណ៌នាដោយសេចក្ដីស្មោះត្រង់របស់គាត់នៅក្នុងការតមអាហារ និងការអធិស្ឋាន ហើយគាត់ «នៅតែក្នុងព្រះវិហារមិនដែលចេញឡើយ» (ខទី 37)។ លុះបានឃើញព្រះឱរស ជាព្រះយេស៊ូវនៅក្នុងព្រះវិហារបរិសុទ្ធរួចហើយ នោះនាង «ថ្លែងអំណរគុណ» ចំពោះព្រះគ្រីស្ទ និង «ប្រកាសប្រាប់ពីព្រះឱរសដល់អស់អ្នកដែលនៅរង់ចាំសេចក្ដីប្រោសលោះនៅក្នុងយេរូសាឡិម» (ខទី 38)។

យើងរៀនពីបទពិសោធន៍របស់អាណាថា យើងអាចរស់នៅដោយស្មោះត្រង់ដោយឆ្លងកាត់រាល់អាកាសធាតុបាន ប្រសិនបើយើងបន្តមានការតមអាហារ និងការអធិស្ឋានជាទៀងទាត់ ហើយប្រសិនបើយើងមិនឃ្លាតចេញពីព្រះវិហារបរិសុទ្ធនៅក្នុងដួងចិត្តរបស់យើងនោះ។ ប្រសិនបើយើងពុំទាន់មានឱកាសធ្វើដំណើរទៅព្រះវិហារបរិសុទ្ធ ហើយទទួលពរជ័យនៅក្នុងនោះនៅឡើយ នោះ







*ការឱ្យសញ្ញាដល់ពួកអ្នកគង្វាលចៀម* ដោយ ឌេល ផាសិន *ការអធិស្ឋានថ្លែងអំណរគុណរបស់ស៊ីម៉ូន* ដោយ រ៉ូប៊ើត ធី បារ៉េត *ធាតុនៃសេចក្ដីសង្ឃឹម* ដោយ អេលស្ពេធ យ៉ង់ ហាមថតចម្លង *ការមកដល់* ដោយ ម៉ៃខល អាល់ប្រេកសុន ហាមថតចម្លង







យើងនៅតែអាចរីករាយនឹងពរជ័យដែលហូរចូលមកក្នុងជីវិតរបស់យើង នៅពេលយើងកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធដោយសក្ដិសមបានដែរ។ ពួកព្យាការីបានអញ្ជើញយើងម្ដងហើយម្ដងទៀតហើយមាននូវប័ណ្ណចូលព្រះវិហារបរិសុទ្ធមួយ ទោះបីជាស្ថានភាពរបស់យើងមិនអនុញ្ញាតឱ្យយើងចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធក្ដី។[2] យើងអាចលើកខ្លួនយើងចេញពីគ្រាដ៏ងងឹតបាន ហើយចូលទៅក្នុងពន្លឺនៃការដឹងគុណតាមរយៈការថ្វាយបង្គំរបស់យើងនៅក្នុងព្រះវិហារបរិសុទ្ធ និងតាមរយៈការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវទៅដល់អស់អ្នកណាដែលស្វែងរកសេចក្ដីសុខសាន្ត និងសេចក្ដីសង្ឃឹម។

*ទៅពេលយើងពិចារណាពីចម្លើយដ៏ស្មោះត្រង់របស់ពួកអ្នកគង្វាលទាំងនោះ រួមមាន ស៊ីម្មាន អាណា និងពួកហោរា នោះយើងអាចរៀនដើម្បីលើកខ្លួនយើងឱ្យកាន់តែមានប្រសិទ្ធភាពចេញពីការបញ្ញាសរបស់យើងផ្ទាល់ និងចេញពីភាពងងឹត និងការភាន់ច្រឡំ ហើយនាំខ្លួនយើងទៅកាន់ពន្លឺនៃពិភពលោកនេះ។*

## ពួកហោរា

ទៅទីបំផុត នៅក្នុង ម៉ាថាយ 2 យើងអានពីពួកហោរាដែលទៅដំណើរយ៉ាងឆ្ងាយ «បានឃើញផ្កាយរបស់ទ្រង់ពីទិសខាងកើតមក» ហើយបានយល់ពីសញ្ញានេះ (ខទី 2)។ បានរៀបចំអំណោយថ្វាយនិងថ្វាយបង្គំ ពួកគេបានមកមើលទ្រង់ ដោយសួរថា «តើព្រះអង្គដែលប្រសូតមកធ្វើជាស្ដេចសាសន៍យូដាទ្រង់គង់នៅឯណា?» (ខ 2)។ នៅពេលការស្វែងរករបស់ពួកគេត្រូវបានបញ្ចប់ ហើយពួកគេបានឃើញព្រះឱរសដ៏ជាព្រះគ្រីស្ទ នោះពួកគេ «រួចក៏ក្រាបថ្វាយបង្គំ» និងថ្វាយដង្វាយរបស់ពួកគេ (ខទី 11)។ ទោះជាពួកគេបានជួបនឹងពួកក្បត់របស់ស្ដេចហេរ៉ូឌក្ដី ក៏ពួកគេត្រូវ «ទ្រង់ពន្យល់សុបិនប្រាប់ មិនឱ្យត្រឡប់ទៅឯហេរ៉ូឌវិញឡើយ» ប៉ុន្តែត្រូវតែត្រឡប់ទៅផ្ទះវិញ «តាមផ្លូវផ្សេងទៀត» (ខទី 12)។ ពួកហោរាបានធ្វើតាមវិវរណៈនេះមកពីព្រះ ហើយបានការពារគ្រួសារដ៏បរិសុទ្ធនេះពីការប៉ុនប៉ងដ៏អាក្រក់របស់ហេរ៉ូឌ។

មានរឿងជាច្រើនដែលយើងអាចរៀនពីពួកហោរា។ ដូចជាពួកគាត់ផងដែរ យើងគប្បីសិក្សាព្រះគម្ពីរ ហើយស្គាល់ពីសញ្ញាដែលត្រូវមើល នៅពេលយើងរៀបចំផែនដីនេះសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ។ រួចហើយ នៅពេលយើងរុករក និងពិចារណាបទគម្ពីរទាំងឡាយ នោះយើងនឹងមានបំណងប្រាថ្នាកាន់តែច្រើនឡើងនៅក្នុងការស្វែងរកព្រះអម្ចាស់ជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង ហើយដើម្បីជាអំណោយមួយថ្វាយដល់ទ្រង់នោះយើងនឹងលះបង់នូវភាពអាត្មានិយម សេចក្ដីឆ្មើងឆ្មៃ និងការខ្វះសេចក្ដីទៀងត្រង់របស់យើងចោល។ នៅពេលវិវរណៈផ្ទាល់ខ្លួនកើតឡើងហើយកែប្រែផែនការដែលបានរៀបចំ នោះយើងអាចគោរព ដោយមានសេចក្ដីជំនឿ និងសេចក្ដីទុកចិត្តថា ព្រះទ្រង់ជ្រាបពីអ្វីដែលល្អបំផុតសម្រាប់យើង។ ហើយដែលសំខាន់បំផុត គឺតាមរយៈជីវិតនៃភាពជាសិស្សដ៏ពិត នោះយើងត្រូវដួលចុះ ហើយថ្វាយបង្គំព្រះអង្គសង្គ្រោះដោយសេចក្ដីរាបសា និងសេចក្ដីស្រឡាញ់។

ភាពជាសិស្សនេះមិនតម្រូវឱ្យយើងចាំបាច់ត្រូវទុកចោលចៀមរបស់យើងនៅក្នុងទីវាល ឬឆ្លងកាត់វាលខ្សាច់នោះឡើយ។ ដំណើររបស់យើងទៅកាន់ទ្រង់ ពុំមែនជារឿងខាងសាច់ឈាមនោះទេ វាគឺជារឿងខាងវិញ្ញាណ និងឥរិយាបថ។ វាទាក់ទងនឹងការទទួលយក និងការឱនក្រសោបចំពោះសេចក្ដីពិតថា ដង្វាយធួនរបស់ទ្រង់គឺមានជានិរន្ត ហើយវាគ្របដណ្ដប់នូវគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើង—អំពើបាបរបស់យើង ភាពទន់ខ្សោយរបស់យើង ការឈឺចាប់របស់យើង ជំងឺ និងពិការភាពរបស់យើង (សូមមើល អាលម៉ា 7:11–13)។ វាមានន័យថា យើងអាចបំភ្លេចនូវរឿងទាំងឡាយដែលទាញយើងទម្លាក់ទៅក្នុងអំពូដ៏ងងឹតនៃការបញ្ញាសរបស់យើង ហើយរស់នៅក្នុងភាពកក់ក្ដៅ និងសេចក្ដីស្រឡាញ់នៃពន្លឺនៃលោកិយជំនួសវិញ។ ដូចដែលប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយបានបង្រៀនថា ៖ «ពាក្យថា ‹មករកព្រះគ្រីស្ទ› គឺជាការអញ្ជើញមួយ។ វាគឺជាការអញ្ជើញដ៏សំខាន់បំផុតដែលអ្នកមិនធ្លាប់ធ្វើចំពោះនរណាម្នាក់ពីមុនមក។ វាគឺជាការអញ្ជើញដ៏សំខាន់បំផុតដែលមនុស្សគ្រប់គ្នាគួរទទួលយក»។[3] ■

**កំណត់សម្គាល់**

1. ថូម៉ាស អេស ម៉ុនសុន «The Spirit Giveth Life» *Ensign* ខែ ឧសភា ឆ្នាំ 1985 ទំព័រ 70។
2. ឧទាហរណ៍ សូមមើល Howard W. Hunter «The Great Symbol of Our Membership» *Tambuli* ខែ វិច្ឆិកា ឆ្នាំ 1994 ទំព័រ 6។
3. Henry B. Eyring «Come unto Christ» *Liahona* ខែ មិនា ឆ្នាំ 2008 ទំព័រ 49។

# «តើខ្ញុំអាចរក្សាឥរិយាបថវិជ្ជមានមួយចំពោះអនាគតបានដោយរបៀបណា?»

យើងទាំងអស់គ្នាជកពិសោធន៍នូវពេលវេលាដែលវាហាក់ដូចជាមានភ្លៀងដ៏ខ្លាំងមួយនៃការបាក់ទឹកចិត្តជានិច្ច និងដំណឹងអាក្រក់នៅក្នុងកម្រិតផ្ទាល់ខ្លួនមួយ ហើយពេលខ្លះមានទាំងនៅក្នុងកម្រិតដ៏ទូលំទូលាយផងដែរ។ ប៉ុន្តែយើងត្រូវតែចងចាំថា យើងមានហេតុផលសម្រាប់សេចក្ដីសង្ឃឹម ដោយសារតែសេចក្ដីជំនឿរបស់យើងលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។

នៅក្នុងសន្និសីទទូទៅខែ មេសា ឆ្នាំ 2009 ប្រធានថូម៉ាស អេស ម៉នសុន បានរំឮកយើងអំពីព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ថា «ចូរកុំខ្លាចឡើយ» (គ. និង ស. 68:6) ហើយបានផ្ដល់ឱ្យយើងនូវពាក្យសម្ដីលើកទឹកចិត្តទាំងនេះថា ៖ «ទោះបីជាព្យុះប្រមូលផ្ដុំគ្នា ទោះបីជាភ្លៀងយ៉ាងច្រើនធ្លាក់មកលើយើង ក៏ចំណេះដឹងរបស់យើងអំពីដំណឹងល្អ និងសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌យើង និងចំពោះព្រះអង្គសង្គ្រោះរបស់យើងនឹងលួងលោមចិត្តយើង ហើយគាំទ្រយើង ព្រមទាំងនាំយកសេចក្ដីអំណរមកក្នុងដួងចិត្តរបស់យើងផងដែរ ដរាបណាយើងដើរយ៉ាងខ្ជាប់ខ្ជួន ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយនោះ។ គ្មានអ្វីនៅក្នុងពិភពលោកនេះដែលអាចរារាំងយើងបានឡើយ»។

សូម្បីតែនៅពេលរឿងទាំងឡាយលេចចេញមកមានភាពតានតឹងបំផុត ដោយគ្មានទាំងការសម្រាកណាមួយពីព្យុះសង្ឃរាយ៉ាងណាក្ដី ក៏ការយល់ដឹងរបស់យើងចំពោះដំណឹងល្អអាចជួយយើងឱ្យរក្សានូវឥរិយាបថវិជ្ជមានមួយអំពីអនាគតបានផងដែរ។ ដូចដែលប្រធាន ម៉នសុនបានមានប្រសាសន៍នៅក្នុងសុន្ទរកថាដូចគ្នានោះថា ៖ «អនាគតគឺភ្លឺត្រចះត្រចង់ដូចជាសេចក្ដីជំនឿរបស់អ្នកដែរ» («Be of Good Cheer» *Liahona* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 92)។

### អាន អធិស្ឋាន ញញឹម



កាលពីប៉ុន្មានឆ្នាំមុន គណៈប្រធានយុវនារីទូទៅបានផ្ដល់ឱ្យយើងនូវការសាកល្បង ៖ អានព្រះគម្ពីរមរមនជារៀងរាល់ថ្ងៃ អធិស្ឋានជារៀងរាល់ថ្ងៃ និងញញឹមឱ្យបាន 100 ភាគរយ។ ខ្ញុំបានគិតថា ខ្ញុំនឹងសាកល្បងវា ហើយរក្សាវាឱ្យបានតាមដែលខ្ញុំអាចធ្វើបាន។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលការលំបាកនោះបាននាំការផ្លាស់ប្ដូរដ៏ធំមួយនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំបានរីករាយ ខ្ញុំបានមានព្រះវិញ្ញាណគង់នឹងខ្ញុំ ហើយខ្ញុំបានមានឥរិយាបថវិជ្ជមានមួយ។ ទោះបីជាខ្ញុំនៅតែត្រូវប្រឈមមុខការលំបាកយ៉ាងណាក្ដី ក៏កម្លាំងនៃព្រះវិញ្ញាណបានជួយខ្ញុំឱ្យស៊ូទ្រាំដោយក្ដីរីករាយផងដែរ។

*អារីណា ជី អាយុ16 ឆ្នាំ វីជិនញា សហរដ្ឋអាមេរិក*

### មានសេចក្ដីសង្ឃឹម

ខ្ញុំគិតថារឿងដ៏សំខាន់បំផុតដែលយើងអាចធ្វើដើម្បីរក្សានូវឥរិយាបថវិជ្ជមាន គឺជាស្នាមញញឹម និងការមានសេចក្ដីសង្ឃឹម! សេចក្ដីសង្ឃឹមបានជួយខ្ញុំពេញមួយជីវិតរបស់ខ្ញុំតាមវិធីជាច្រើនរាប់មិនអស់។ យើងក៏ត្រូវតែគិតថាតើយើងមានពរជ័យធំធេងដល់ប៉ុណ្ណា ហើយក៏ដឹងថាតើព្រះវរបិតាសួគ៌យើងស្រឡាញ់យើងដល់កម្រិតណាផងដែរ។ យើងអាចងាកទៅរកទ្រង់សម្រាប់សេចក្ដីសុខសាន្តនៅគ្រប់ស្ថានភាព។ ព្រះរាជបុត្រារបស់ទ្រង់បានរងទុក្ខសម្រាប់យើង ដូច្នេះទ្រង់ដឹងពីការឈឺចាប់របស់យើង។ តាមរយៈទ្រង់យើងអាចទទួលបានសេចក្ដីសង្ឃឹម ត្រូវបានព្យាបាល រួមទាំងមានចិត្តរីករាយផងដែរ។

*ខូរី ឌី អាយុ 18 ឆ្នាំ យូថាហ៍ សហរដ្ឋអាមេរិក*

### គិតពីដង្វាយធួន

ជានិច្ចកាល ការពិចារណាពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះយើងនឹងផ្ដល់សេចក្ដីសង្ឃឹម ហើយជួយយើងឱ្យមានសុទិដ្ឋិនិយម។ យើងទាំងអស់គ្នានឹងជួបការសាកល្បងនៅក្នុងជីវិតនេះ។ ប៉ុន្តែតាមរយៈដង្វាយធួន នោះរាល់ការសាកល្បង និងបញ្ហាទាំងឡាយទាំងខាងសាច់ឈាម និងខាងវិញ្ញាណ មាននូវដំណោះស្រាយ។ ដង្វាយធួនអាចជួយយើងឱ្យមើលឃើញពីដំណោះស្រាយទាំងនេះ។ ដង្វាយធួនគឺជាការបង្ហាញដ៏ធំមួយពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះកូនចៅទ្រង់។ វាគ្មានព្រំដែនកំណត់ ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើងក៏ដូច្នោះដែរ។ ការណ៍នេះផ្ដល់សេចក្ដីក្លាហាន និងកម្លាំងដល់យើង ដើម្បីប្រឈមមុខនឹងអនាគតដោយគ្មានការភ័យខ្លាច។

*ដារីល អេ 18 អាយុ ឆ្នាំ ឡាហ្គុណា ហ្វីលីពីន*

### បន្តស្មោះត្រង់



គ្រាដ៏លំបាកទាំងនេះគឺជាផ្នែកមួយនៃផែនការរបស់ព្រះអម្ចាស់ ហើយវាត្រូវបានប្រាប់ទុកជាមុនតាំងពីជំនាន់នៃព្រះគម្ពីរសញ្ញាចាស់មកម្ល៉េះ។ នៅក្នុងព្រះគម្ពីរទាំងអស់ ព្រះអម្ចាស់សន្យាថា មនុស្សសុចរិតនឹងទទួលបានពរជ័យ ហើយរក្សាទុក។ នៅពេលអ្នកបន្តស្មោះត្រង់ នោះព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅ



*ចម្លើយទាំងឡាយគឺមានបំណងដើម្បីជួយ និងជាទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រនោះទេ។*

ទីនោះដើម្បីដឹកនាំអ្នកឆ្លងកាត់គ្រាដ៏ជ្រួលច្របល់ទាំងនេះ ដើម្បីលួងលោមដល់អ្នក និងដើម្បីរំឭកដល់អ្នកថា ព្រះអម្ចាស់ទ្រង់មានផែនការសម្រាប់អ្នក។ ប្រសិនបើអ្នកមានពរជ័យលោកអយ្យកោ សូមសិក្សាវា ដើម្បីមើលឃើញពីអ្វីដែលព្រះអម្ចាស់បានរៀបចំសម្រាប់អ្នក។

*វេ ប៊ី អាយុ 17 ឆ្នាំ វ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក*

### ពិចារណាអំពីពរជ័យរបស់អ្នក



រឿងមួយដែលធ្វើឲ្យខ្ញុំមានសេចក្ដីអំណរ និងសេចក្ដីសង្ឃឹម នៅក្នុងគ្រាដ៏លំបាកទាំងនេះ គឺការឈប់មួយភ្លែត ហើយពិចារណាពីពរជ័យរបស់ខ្ញុំ និងពីចំណេះដឹងរបស់ខ្ញុំអំពីដំណឹងល្អ។ រឿងដ៏សាមញ្ញមួយដូចជាការមានមិត្តសម្លាញ់ល្អម្នាក់ ឬរឿងមួយដ៏ធំដូចជាផែនការសង្គ្រោះបានធ្វើឲ្យខ្ញុំពោរពេញដោយសេចក្ដីអំណរ ហើយវាធ្វើឲ្យខ្ញុំចង់ចែកចាយនូវសេចក្ដីអំណរនោះ។ នេះគឺជាអ្វីដែលរក្សាអាកប្បកិរិយារបស់ខ្ញុំឲ្យវិជ្ជមាន។

*អាណេត អិម 15 អាយុ ឆ្នាំ មីឈីហ្គែន សហរដ្ឋអាមេរិក*

### ចងចាំពីព្រះវិហារបរិសុទ្ធ



នៅពេលខ្ញុំបាក់ទឹកចិត្ត ខ្ញុំសញ្ជឹងគិតពីពាក្យពេចន៍ចុងក្រោយនៃបាវចនារបស់យុវនារី ៖ «យើងជឿនៅពេលយើងបានទទួលយក ហើយអនុវត្តចំពោះគុណតម្លៃទាំងនេះ នោះយើងនឹងត្រូវបានរៀបចំខ្លួនដើម្បីពង្រឹងដល់គេហដ្ឋាន និងគ្រួសារ ចុះ និងរក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋ ទទួលពិធីបរិសុទ្ធទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ និងរីករាយនូវពរជ័យទាំងឡាយនៃភាពតម្កើងឡើង»។ ខ្ញុំអាចស្វែងរកការលួងលោមចិត្តនៅក្នុងពាក្យពេចន៍ទាំងនេះ ហើយខ្ញុំថាវានឹងត្រូវបានបំពេញនៅក្នុងជីវិតរបស់ខ្ញុំ និងនៅក្នុងជីវិតនៃយុវនារីដ៏មានគុណធម៌ទាំងអស់។ ដោយគ្មានការសង្ស័យ ខ្ញុំមានសេចក្ដីសង្ឃឹមចំពោះពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធដ៏ពិសិដ្ឋនោះ។ ពរជ័យនៃជីវិតមួយដ៏សុចរិតគឺមានជានិរន្តរ៍ ហើយនៅពេលខ្ញុំនឹកចាំពីរឿងទាំងនេះ នោះដួងចិត្តរបស់ខ្ញុំពោរពេញដោយសេចក្ដីអំណរ សេចក្ដីសង្ឃឹម សេចក្ដីស្រឡាញ់ និងសេចក្ដីក្លាហាន។

*ណាថាលី អិម អាយុ 18 មេរីដា វេណេហ្ស៊ុយអេឡា*

### នៅក្នុងក្រុមដែលឈ្នះ

ដើម្បីរក្សាអាកប្បកិរិយាមួយវិជ្ជមាន អ្នកត្រូវដឹងពីសេចក្ដីពិតដ៏សាមញ្ញ នេះថា ៖ ក្រុមរបស់ព្រះអម្ចាស់គឺជាអ្នកឈ្នះនៅចុងបញ្ចប់។ នោះគឺវាងាយស្រួលណាស់។ សាតាំងគ្មានអំណាចលើព្រះឡើយ។



ដោយសារយើងដឹងពីអ្នកឈ្នះរួចហើយ នោះយើងត្រូវផ្ដោតយកចិត្តទុកដាក់លើការនៅក្នុងក្រុមរបស់ព្រះអម្ចាស់។ នៅពេលយើងរស់នៅឲ្យសក្ដិសមដើម្បីចូលព្រះវិហារបរិសុទ្ធ នោះយើងនឹងស្លៀកពាក់ឯកសណ្ឋានរបស់យើងដែលបង្ហាញដល់ព្រះអម្ចាស់ថា យើងគឺជាក្រុមរបស់ទ្រង់។ ដោយការអានព្រះគម្ពីររបស់យើង ដោយការពោលពាក្យអធិស្ឋានរបស់យើង និងដោយការបម្រើបងប្អូនប្រុសស្រីរបស់យើង នោះយើងរកឃើញនូវសុភមង្គលពិតដែលងាយធ្វើឲ្យមានអាកប្បកិរិយាវិជ្ជមានមួយ។

*ព្រាយឌិន អេហ្វ អាយុ 17 យូថាហ៍ សហរដ្ឋអាមេរិក*

### អភិវឌ្ឍអាកប្បកិរិយាដឹងគុណ

កុំផ្ដោតយកចិត្តទុកដាក់ចំពោះគ្រាដែលលំបាក។ ខ្ញុំរក្សាទុក «សៀវភៅកំណត់ហេតុអំពីការដឹងគុណ»។ ជារៀងរាល់ថ្ងៃ យ៉ាងហោចណាស់ខ្ញុំសរសេររឿងមួយដែលខ្ញុំបានថ្លែងអំណរគុណសម្រាប់ថ្ងៃនោះ។ មិនថានៅថ្ងៃនោះមានរឿងអាក្រក់បែបណានោះទេ ខ្ញុំតែងតែអាចរកឃើញនូវអ្វីមួយដើម្បីថ្លែងអំណរគុណ។ ចូររាប់ពរជ័យរបស់អ្នក។ ការអភិវឌ្ឍន៍អាកប្បកិរិយាដឹងគុណអាចជួយអ្នកឲ្យផ្ដោតយកចិត្តទុកដាក់លើរឿងវិជ្ជមាននៅក្នុងជីវិតអ្នក។

*អាល្លី អេផ អាយុ 18 អូក្លាហូម៉ា សហរដ្ឋអាមេរិក*



### អនាគតដ៏អស្ចារ្យរបស់អ្នក

«មិត្តសម្លាញ់វ័យក្មេងរបស់ខ្ញុំអើយ ព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកមានបំណងប្រាថ្នាដោយអស់ពីដួងចិត្តរបស់ ដើម្បីរក្សាបទដ្ឋានទាំងនេះ ហើយរស់នៅតាមសេចក្ដីពិតនៃដំណឹងល្អដែលមាននៅក្នុងដំណឹងល្អ។ នៅពេលអ្នកធ្វើដូច្នេះ នោះអ្នកនឹងមើលឃើញហួសពីគ្រានោះ ហើយអ្នកនឹងមើលឃើញអនាគតដ៏ភ្លឺ ហើយអស្ចារ្យរបស់អ្នកជាមួយនឹងឱកាស និងទំនួលខុសត្រូវដ៏ធំ។ អ្នកនឹងមានឆន្ទះដើម្បីខិតខំយ៉ាងខ្លាំង ហើយស៊ូទ្រាំយ៉ាងយូរ ហើយអ្នកនឹងមានទស្សនៈសុទិដ្ឋិនិយមមួយចំពោះជីវិត»។

**ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ «See the End from the Beginning» *Liahona* ខែ ឧសភា ឆ្នាំ 2006 ទំព័រ 44**

## សំណួរបន្ទាប់

«តើខ្ញុំឆ្លើយសំណួររបស់មិត្តខ្ញុំអំពីព្រះវិហារបរិសុទ្ធបានដោយរបៀបណាទៅ ពេលខ្ញុំមិនដឹងពីបញ្ហានោះច្រើនដោយខ្លួនឯងនៅឡើយ?»

សូមបញ្ជូនចម្លើយរបស់អ្នក មកត្រឹមថ្ងៃទី 15 ខែ មករា ឆ្នាំ 2012 ទៅកាន់ៈ

*Liahona*, Questions & Answers 1/12
50 North Temple St., Rm. 2420
Salt Lake City, UT 84150-0024, USA
ឬអ៊ីម៉ែលៈ **liahona@ldschurch.org**

ចម្លើយអាចនឹងធ្វើការកែសម្រួលឡើងវិញ ដោយព្រោះវែងពេក ឬដើម្បីភាពច្បាស់លាស់។

ព័ត៌មាន និងការអនុញ្ញាតខាងក្រោមត្រូវតែបញ្ចូលនៅក្នុងអ៊ីមែល ឬសំបុត្ររបស់អ្នកៈ (1) នាម និងគោត្តនាម (2) ថ្ងៃ ខែ ឆ្នាំ កំណើត (3) វួដ ឬសាខា (4) ស្តេក ឬមណ្ឌល (5) សំបុត្រអនុញ្ញាតដែលមានលាយលាក់អក្សររបស់អ្នក ហើយប្រសិនបើអ្នកអាយុក្រោម នោះត្រូវការសំបុត្រអនុញ្ញាតដែលមានលាយលាក់អក្សររបស់ឪពុកម្ដាយអ្នក (អ៊ីមែល អាចទទួលយកបាន) ដើម្បីធ្វើការបោះពុម្ពចម្លើយ និងរូបថតរបស់អ្នក។

# អ្នកពុំមែនរស់នៅម្នាក់ឯងនោះទេ



«ខ្ញុំមិនចោលអ្នករាល់គ្នាឱ្យនៅកំព្រាទេ
ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ»
(យ៉ូហាន 14:18)។

រូបភាពរបស់ព្រះគ្រីស្ទដោយ ហិនរីឆ ហូហ្វមិន ទទួលសិទ្ធិអនុញ្ញាតពីក្រុមហ៊ុនស៊ី. ហារីសុន ខុនរ៉យ។

# ព្រះអម្ចាស់ បានចាក់ស្រោច**ពរជ័យ**

*ខ្ញុំងឿងឆ្ងល់ថា «តើព្រះជានរណា? តើជាព្រះពុទ្ធ ព្រះយេស៊ូវគ្រីស្ទ ឬជាព្រះផ្សេងទៀត?»*

**ដោយ គីម គង់**

ខ្ញុំកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាកន្លែងដែលមានប្រជាជនភាគច្រើនគឺជាពុទ្ធសាសនិកជន។ បន្ទាប់ពីរបបខ្មែរក្រហម ដែលបានសម្លាប់ប្រជាជនជាច្រើននាក់មក មានប្រជាជនដែលនៅរស់រានមានជីវិតជាច្រើននាក់ មិនយល់ពីមូលហេតុ ថាបើសិនជាមានព្រះមែន ហេតុអ្វីបានជាទ្រង់បណ្ដាយឱ្យរឿងនេះកើតឡើងដល់ប្រជាជនរបស់យើងបាន។ កាលពីខ្ញុំមានអាយុ 14 ឆ្នាំ ខ្ញុំបានងឿងឆ្ងល់ពីរឿងដូចគ្នានេះដែរ។

បន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់ទៅ មានសាសនាមួយចំនួនបានចាប់ផ្ដើមមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំមានការច្របូកច្របល់ ដោយសារមានព្រះវិហារជាច្រើនបានបង្រៀននូវរឿងផ្សេងៗគ្នាជាច្រើន។ ក្រុមគ្រួសាររបស់ខ្ញុំប្រកាន់ខ្ជាប់នៅក្នុងព្រះពុទ្ធសាសនា ប៉ុន្តែខ្ញុំចង់បានចម្លើយចំពោះសំណួរទាំងឡាយនៅក្នុងព្រលឹងរបស់ខ្ញុំថា ៖ តើយើងបានមកពីណា ហេតុអ្វីបានជាយើងនៅទីនេះ ហើយតើយើងនឹងទៅកន្លែងណា បន្ទាប់ពីជីវិតនេះ?

នៅថ្ងៃមួយ ពេលខ្ញុំបានត្រឡប់មកពីសាលារៀនវិញ ម្ដាយមីងរបស់ខ្ញុំបានប្រាប់ខ្ញុំថា មានយុវជនពីរនាក់ ពាក់អាវស និងក្រវ៉ាត់ក បានមកផ្ទះរបស់គាត់ និយាយអំពីព្រះយេស៊ូវគ្រីស្ទ។ គាត់មានការភ្ញាក់ផ្អើលដោយសារពួកគេនិយាយភាសាខ្មែរបានល្អ។ ខ្ញុំចង់រៀនអំពីព្រះគ្រីស្ទ។ ខ្ញុំចង់ដឹងថានរណាបានបង្កើតយើងមក។ ខ្ញុំងឿងឆ្ងល់ថា «តើព្រះជានរណា? តើជាព្រះពុទ្ធ ព្រះយេស៊ូវគ្រីស្ទ ឬជាព្រះផ្សេងទៀត?»

ម្ដាយមីងរបស់ខ្ញុំ និង ខ្ញុំបានទទួលអ្នកផ្សព្វផ្សាយសាសនា។ អំឡុងពេលមេរៀនទីមួយ ពួកយើងបានទទួលអារម្មណ៍ពីព្រះវិញ្ញាណប្រាប់ដល់យើងនូវអ្វី ដែលពួកគេបាននិយាយ គឺជាការពិត។ ពួកគេបានជូនព្រះគម្ពីរមរមនដល់យើងម្នាក់មួយក្បាល ហើយបានសន្យាថា បើសិនជាយើងអាន ពិចារណា ហើយសួរទៅដល់ព្រះអំពីព្រះគម្ពីរនេះ ដោយដួងចិត្តស្មោះសរ ដោយមានសេចក្ដីជំនឿទៅលើទ្រង់ នោះទ្រង់នឹងបង្ហាញសេចក្ដីពិតមកដល់យើង។ វាជារឿងសមហេតុផលចំពោះខ្ញុំ។ ខ្ញុំបានទទួលយកដំណឹងល្អព្រមទាំងម្ដាយមីងរបស់ខ្ញុំ និង កូនៗរបស់គាត់ផងដែរ។ ប្រហែលជាមួយខែក្រោយមក ពួកយើងបានទទួលបុណ្យជ្រមុជទឹក និង បានទទួលពិធីបញ្ជាក់ទាំងអស់គ្នា។

ខ្ញុំបានចូលរៀនថ្នាក់សិក្ខាសាលាអស់រយៈពេលបួនឆ្នាំ និងថ្នាក់វិទ្យាស្ថានរយៈពេលមួយឆ្នាំ ហើយបានបម្រើជាគ្រូបង្រៀនថ្នាក់សិក្ខាសាលាម្នាក់។ នៅពេលខ្ញុំមានអាយុ 19 ឆ្នាំ ខ្ញុំមានអារម្មណ៍ថាខ្ញុំគួរតែចេញទៅបម្រើបេសកកម្ម។ ខ្ញុំបាននិយាយនឹងឪពុកម្ដាយរបស់ខ្ញុំ ហើយពួកគាត់បានមានប្រសាសន៍ថា នោះប្រហែលជាវាជាគំនិតល្អម្យ៉ាងដែរ ដូច្នេះខ្ញុំបានដាក់ពាក្យរបស់ខ្ញុំ។ មួយខែក្រោយមក ខ្ញុំបានទទួលការហៅឱ្យបម្រើរបស់ខ្ញុំ ឱ្យទៅបម្រើបេសកកម្មនៅរដ្ឋកាលីហ្វូញ៉ា សាក្រាម៉ង់តូ និយាយជាភាសាអង់គ្លេស និង ភាសាខ្មែរ។

ដោយសារតែខ្ញុំបានទទួលយកការហៅរបស់ខ្ញុំ ព្រះបានប្រទានពរជ័យជាច្រើនដល់រូបខ្ញុំ។ ប្អូនប្រុសរបស់ខ្ញុំពុំបានធ្វើការសម្រេចចិត្តដ៏ល្អនោះទេ។ ខ្ញុំបានតមអាហារ ហើយបានអធិស្ឋានសម្រាប់គាត់ ហើយអព្ភូតហេតុមួយបានកើតមាន មុនពេលខ្ញុំបានចេញទៅបេសកកម្មរបស់ខ្ញុំ។

ខ្ញុំបានធ្វើបុណ្យជ្រមុជទឹកឱ្យគាត់ ហើយឥឡូវនេះ គាត់នៅសកម្មក្នុងសាសនាចក្រ ព្រមទាំងចូលរៀនថ្នាក់សិក្ខាសាលា ទៀត។ គ្រួសាររបស់ខ្ញុំបានទទួលពរជ័យជាច្រើនផ្សេងទៀត ហើយព្រះអម្ចាស់ក៏បានចាក់ស្រោចពរជ័យយ៉ាងច្រើនមកលើខ្ញុំ អំឡុងពេលបេសកកម្មរបស់ខ្ញុំផងដែរ។

ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ។ ទ្រង់មានព្រះជន្មរស់នៅ។ ទ្រង់ស្រឡាញ់យើងម្នាក់ៗ ហើយស្គាល់យើងតាមឈ្មោះ។ ទ្រង់ស្គាល់ការលំបាក និងឧបសគ្គទាំងឡាយរបស់យើង ហើយខ្ញុំដឹងថា ទ្រង់នឹងប្រទានពរដល់យើង នៅពេលយើងព្យាយាមគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់។ ■




រូបថត គីម គង់

# សាក្សីពិត

ដោយអែលឌើរ
ខាល ប៊ី ប្រាត្ត
នៃពួកចិតសិបនាក់



ដោយបានកើតមកក្នុងគ្រួសារបរិសុទ្ធថ្ងៃចុងក្រោយសកម្មមួយ ខ្ញុំគិតថា ខ្ញុំបានធំឡើងដោយមានទីបន្ទាល់មួយ។ ខ្ញុំពុំដែលមានការសង្ស័យពិតប្រាកដអំពីសេចក្ដីពិតពេញលេញនៃដំណឹងល្អ ទេ។ ដូចជាយុវវ័យជាច្រើនទៀតផងដែរ ខ្ញុំមានសំណួរម្ដងម្កាល នូវរឿងមួយចំនួនក្នុងចិត្តរបស់ខ្ញុំ ប៉ុន្តែខ្ញុំពុំដែលមានអារម្មណ៍ថា សាសនាចក្រនេះមិនពិតនោះទេ។

ដោយសារសេចក្ដីជំនឿនេះហើយ ដែលបានបំផុសគំនិតដល់ខ្ញុំឱ្យបម្រើបេសកកម្ម។ ខ្ញុំបានដឹងថា ខ្ញុំចាំបាច់ត្រូវតែបម្រើ។ ប៉ុន្តែទោះបីជាខ្ញុំពុំមានការសង្ស័យពិតប្រាកដអំពីសាសនាចក្រក្ដី ក៏ខ្ញុំបានដឹងថា ខ្ញុំត្រូវតែទទួលទីបន្ទាល់មួយ ដោយខ្លួនខ្ញុំផ្ទាល់ផងដែរ។

ខ្ញុំបានចាប់ផ្ដើមបេសកកម្មរបស់ខ្ញុំ នៅក្នុងខែកុម្ភៈ ឆ្នាំ 1961 ខ្ញុំបានចេញទៅនៅខែត្រជាក់ពីទីក្រុងសលត៍លេក ទៅកាន់ប្រទេសអាហ្សង់ទីននៅរដូវក្ដៅ។ នៅជំនាន់នោះ គ្មានការបំពាក់បំប៉នភាសាដល់ពួកអ្នកផ្សព្វផ្សាយសាសនាទេ ប៉ុន្តែប្រធានបេសកកម្មរបស់ខ្ញុំ បានសន្យាដល់យើងថា យើងនឹងនិយាយភាសាអេស្ប៉ាញបានយ៉ាងស្ទាត់ជំនាញ បន្ទាប់ពីការអានព្រះគម្ពីរមរមនទាំងមូលឱ្យឮៗ។ ខ្ញុំបានរៀនភាសាអេស្ប៉ាញកាលពីនៅតូច ហើយបាននិយាយយ៉ាងស្ទាត់នៅក្នុងអំឡុងពេលពីរបីសប្ដាហ៍ដំបូង ប៉ុន្តែខ្ញុំនៅតែធ្វើតាមការណែនាំរបស់ប្រធានបេសកកម្មរបស់ខ្ញុំ។

ទីក្រុងដំបូងដែលខ្ញុំត្រូវបានចាត់ឱ្យទៅ ដៃគូរបស់ខ្ញុំ និង ខ្ញុំបានស្នាក់នៅក្នុងបន្ទប់តូចមួយខាងក្រោយហាងចាស់មួយ។ ពួកយើងពុំអាចផ្សព្វផ្សាយនៅពេលល្ងាចអំឡុងពេលប្រជាជនអាហ្សង់ទីនសម្រាកនោះទេ ដូច្នេះខ្ញុំបានប្រើពេលនោះ ដើម្បីអធិស្ឋាន និង អានព្រះគម្ពីរមរមន នៅខាងមុខច្រកចូលហាងចាស់នោះវិញ។

នៅចម្ងាយរាប់ពាន់គីឡូម៉ែតពីផ្ទះ នៅពីមុខហាងនោះ មានថ្ងៃមួយ ខ្ញុំឈប់ ដើម្បីគិតអំពីអ្វីដែលខ្ញុំកំពុងតែអាន។ នៅពេលអ្នកអធិស្ឋាន ហើយ ពិចារណាអំពីព្រះគម្ពីរមរមន នោះព្រះវិញ្ញាណអាចមានឥទ្ធិពលមកលើអ្នក។ ខ្ញុំបានពិចារណាពីអ្វីដែលព្រះគម្ពីរមរមនកំពុងបង្រៀន ខ្ញុំបានគិតអំពីយ៉ូសែប ស្ម៊ីធ បកប្រែផ្ទាំងទាំងឡាយ ហើយខ្ញុំបានទទួលអារម្មណ៍មួយមកគ្របដណ្ដប់លើខ្ញុំមួយរំពេច។ នៅគ្រានោះ ខ្ញុំបានដឹងថា អ្វីៗដែលខ្ញុំត្រូវបានបង្រៀនពេញមួយជីវិតរបស់ខ្ញុំគឺជាការពិត។ រំពេចនោះ វាបានធ្វើឱ្យខ្ញុំយល់យ៉ាងច្បាស់ថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីមួយរូប ហើយថាខ្ញុំកំពុងតែអានព្រះបន្ទូលរបស់ព្រះ។ វាគឺជាការពិតទាំងអស់។

អារម្មណ៍នៅរំពេចនោះគឺរំភើបអស្ចារ្យណាស់។ វាបានធ្វើឱ្យខ្ញុំព្រឺសម្បុរពេញទាំងរាងកាយ ចាប់ពីក្បាលរហូតដល់ចុងជើង។ វាពុំមែនជាអារម្មណ៍រងារនោះទេ ហើយវាក៏ពុំមែនជាអារម្មណ៍ឆាបឆួលនោះដែរ។ ប៉ុន្តែវា គឺជាអារម្មណ៍សាក្សីដ៏ខ្ជាប់ខ្ជួនមួយ។

ខ្ញុំពុំដែលភ្លេចថ្ងៃនោះទេ ហើយខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធជាច្រើនដងចាប់តាំងពីពេលនោះមក។ ដោយសារតែបទពិសោធន៍នោះ ខ្ញុំបានស្គាល់ព្រះវិញ្ញាណបរិសុទ្ធ នៅពេលទ្រង់ធ្វើទីបន្ទាល់មកកាន់ខ្ញុំ។ អារម្មណ៍នោះពុំដូចគ្នាទាំងអស់ជានិច្ចនោះទេ ប៉ុន្តែវាតែងតែជាអារម្មណ៍កក់ក្ដៅ និង សុវត្ថិភាព។

ទោះជាព្រះវិញ្ញាណមានព្រះបន្ទូលមកកាន់យើងរៀងៗខ្លួនដោយផ្ទាល់ក្ដី ក៏ការសន្យារបស់មរ៉ូណៃគឺមានចំពោះមនុស្សគ្រប់រូប (សូមមើល មរ៉ូណៃ 10:3–5)។ ការសន្យារបស់មរ៉ូណៃនៅក្នុងព្រះគម្ពីរមរមន គឺថា ព្រះវិញ្ញាណនឹងថ្លែងទីបន្ទាល់មកកាន់អ្នកអំពីសេចក្ដីពិតនៃព្រះគម្ពីរមរមន បើសិនជាអ្នកនឹងអាន សិក្សា ពិចារណា រួចហើយអធិស្ឋានដោយមានបំណងប្រាថ្នាពិត។ ការសន្យានោះអនុវត្តចំពោះខ្ញុំ ចំពោះអ្នក និង ចំពោះមនុស្សគ្រប់គ្នានៅក្នុងពិភពលោក។ សាក្សីដ៏ខ្ជាប់ខ្ជួននឹងមានដល់អស់អ្នកទាំងឡាយដែលស្វែងរកវា។ ■

**ខិតទៅកាន់តែជិតនឹងព្រះ**

«ខ្ញុំបានប្រាប់បងប្អូនទាំងឡាយថា ព្រះគម្ពីរមរមនគឺជាគម្ពីរដ៏ត្រឹមត្រូវបំផុតជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនារបស់យើង ហើយបុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារធ្វើតាមគោលការណ៍ទាំងឡាយនៃគម្ពីរនេះ ហើយបន្ទាប់មកគឺធ្វើតាមព្រះគម្ពីរដទៃផ្សេងទៀត»។

**យ៉ូសែប ស្ម៊ីធ នៅក្នុង *Teachings of Presidents of the Church: Joseph Smith* (ឆ្នាំ 2007), ទំព័រ 64។**



# នេះជា
# ទីសម្គាល់ដល់អ្នករាល់គ្នា

*«ព្យាការីទាំងអស់ ដែលបានព្យាករចាប់តាំងពីកំណើតលោកិយមកម្ល៉េះ—តើពួកគេពុំបាននិយាយតិច ឬច្រើន អំពីការណ៍អស់ទាំងនេះទេឬអី?» (ម៉ូសាយ 13:33)។*

**ដោយ វីតនី ហ៊ីងគ្លី**

បុណ្យគ្រីស្ទម៉ាស់ គឺជាពេលមួយដែលបានពេញទៅដោយសេចក្ដីសង្ឃឹម—ជាសេចក្ដីសង្ឃឹម នៃ អំណោយ ម្ហូបអាហារឆ្ងាញ់ៗ និង ការតុបតែងលំអរ។ ពេលខ្លះ 24 ថ្ងៃដំបូងក្នុងខែ ធ្នូ ហាក់បីដូចជាពេលដ៏យូរបំផុត ក្នុងការរង់ចាំ។ សូមស្រមៃថាបើសិនជាអ្នកត្រូវរង់ចាំរហូតដល់ 1000 ឆ្នាំវិញ!

បុណ្យគ្រីស្ទម៉ាសដំបូង—កំណើតរបស់ព្រះអង្គសង្គ្រោះ—ត្រូវបានព្យាកររយៈពេលរាប់រយឆ្នាំជាមុន ចាប់តាំងពីលោកអេសាយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ទៅដល់សាំយ៉ូអែលសាសន៍លេមិន នៅក្នុងព្រះគម្ពីរមរមន។ ព្យាការីពីបុរាណបានដឹង ហើយបានរំពឹងចាំនូវទីសម្គាល់ទាំងឡាយ នៃការយាងមករបស់ព្រះយេស៊ូវ គ្រីស្ទ ហើយពួកគេបានរង់ចាំទីសម្គាល់ទាំងនោះ ដោយអត់ធ្មត់។ ពួកគេបានព្យាករអំពីការយាងមករបស់ទ្រង់ ដើម្បីឱ្យអ្នកដទៃនឹងអាចស្គាល់នូវទីសម្គាល់ទាំងឡាយ ហើយចែកចាយសេចក្ដីអំណរ នៃការដឹងថា ទ្រង់បានយាងមក! ការបំពេញនូវការព្យាករណ៍ទាំងនោះ គឺជាទីបន្ទាល់មួយអំពីការហៅដ៏ទេវភាពរបស់ទ្រង់ ក្នុងនាមជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះ។

សូមអាននូវការព្យាករណ៍ទាំងឡាយដូចខាងក្រោម អំពីកំណើតរបស់ព្រះយេស៊ូវ គ្រីស្ទ និង កាលៈទេសៈប្រកបដោយអព្ភូតហេតុ ដែលនៅជុំវិញនោះ ហើយរៀនអំពីរបៀបដែលការព្យាករណ៍ទាំងនោះ ត្រូវបានបំពេញ។

## នឹងប្រសូត្រមកពីនាងម៉ារា ជាស្ត្រីព្រហ្មចារី

*ការព្យាករណ៍ទាំងឡាយ ៖* ម៉ារា ត្រូវបានព្យាករទុកថាត្រូវធ្វើជាមាតារបស់ព្រះគ្រីស្ទ រយៈពេលប្រាំពីររយឆ្នាំ មុនពេលនាងចាប់កំណើត។ លោកអេសាយ បានសរសេរថា «ព្រះអម្ចាស់ទ្រង់នឹងប្រទានទីសម្គាល់មួយមកអ្នករាល់គ្នាដោយព្រះអង្គទ្រង់ មើលនាងព្រហ្មចារីនឹងមានគត៌ប្រសូតបានបុត្រាមួយ ហើយនឹងឱ្យព្រះនាមថា អេម៉ាញូអែល» (អេសាយ 7:14)។

អាលម៉ាក្មេងក៏បានប្រាប់ផងដែរអំពីម៉ារាថា នាងជាមាតារបស់ព្រះអង្គសង្គ្រោះ ប្រហែលជា 80 ឆ្នាំ មុនកំណើតរបស់ព្រះយេស៊ូវ ហើយដែលមានចម្ងាយពាក់កណ្ដាលពិភពលោកពីលោកអេសាយមក ៖ «ទ្រង់នឹងប្រសូតមកពីនាងម៉ារា ... នាងជាស្ត្រីព្រហ្មចារី គឺជាប្រដាប់ដ៏ជម្រើស ហើយពិសេសមួយ ដែលនឹងត្រូវគ្របដណ្ដប់ ហើយចាប់ទំផ្ទៃដោយព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងប្រសូតបានបុត្រមួយ មែនហើយ គឺជាព្រះរាជបុត្រានៃព្រះ» (អាលម៉ា 7:10)។

*ការបំពេញ ៖* រយៈពេលប្រាំបីទស្សវត្សក្រោយមក ទេវតា កាព្រីយ៉ែល បានលេចមកជួបនឹង «ស្ត្រីដែលបានបម្រុងទុកឱ្យមនុស្សម្នាក់ឈ្មោះយ៉ូសែប ... នាងនោះឈ្មោះ ម៉ារា» (លូកា 1:27)។ ម៉ារា គឺជាមាតារបស់ព្រះយេស៊ូវ ដែលជាបុត្រារបស់ព្រះ។

## មានបុត្រមួយកើតដល់យើង

*ការព្យាករណ៍ ៖* លោកអេសាយបានព្យាករអំពីកំណើតរបស់ព្រះមេស៊ី ថា ៖ «ដ្បិតមានបុត្រមួយកើតដល់យើង ព្រះទ្រង់ប្រទានបុត្រាមួយមកយើងហើយ ឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្ដា ព្រះវរបិតាដ៏គង់នៅអស់កល្ប នឹងជាម្ចាស់នៃមេត្រីភាព» (អេសាយ 9:6)។

*ការបំពេញ ៖* ការបម្រើរបស់ព្រះអង្គសង្គ្រោះ បានបំពេញគ្រប់នូវអ្វី ដែលលោកអេសាយបានព្យាករ ប៉ុន្តែព្រះគ្រីស្ទបានប្រសូតមកនៅក្នុងស្ថានភាពដ៏រាបសារ ៖ «ត្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់។ ... អ្នករាល់គ្នានឹងឃើញព្រះឱរសមួយរុំនឹងសំពត់ផ្ដេកនៅក្នុងស្នូក» (លូកា 2:11–12)។



## ចាប់កំណើតនៅភូមិបេថ្លេហិម

*ការព្យាករណ៍ ៖* ព្យាការីមីកា បានរស់នៅប្រហែលជាក្នុងជំនាន់ដូចគ្នានឹងលោកអេសាយដែរ។ គាត់បានព្យាករអំពីព្រះអម្ចាស់ នឹងត្រូវបានប្រសូតនៅភូមិបេថ្លេហិម ថា ៖ «តែឯងឱបេថ្លេហិម អេប្រាតាអើយ ឯងដែលតូចនៅក្នុងពួកយូដាទាំងពាន់ៗ នឹងមានម្នាក់កើតចេញពីឯង មកឱ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រង លើអ៊ីស្រាអែល ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក» (មីកា 5:1)។

*ការបំពេញ ៖* រយៈពេលប្រាំពីររយឆ្នាំក្រោយមក ហេរ៉ូឌ បានបញ្ជាឱ្យពួកអាចារ្យប្រាប់ដល់ទ្រង់ ថាតើអ្នកគ្រប់គ្រងថ្មីនោះអាចរកឃើញនៅឯណា ៖ «ទ្រង់បានសាកសួរពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវប្រសូតនៅឯណា។ នោះគេក៏ទូលទ្រង់ថា នៅឯភូមិបេថ្លេហិម ក្នុងស្រុកយូដា» ( ម៉ាថាយ 2:4–5)។

## ពូជនៃហ្លួងដេវីឌ

*ការព្យាករណ៍ ៖* ព្រះអម្ចាស់ បានប្រាប់ដល់យេរេមា កាលពីប្រាំមួយសតវត្សរ៍ មុនពេលការចាប់កំណើតរបស់ព្រះគ្រីស្ទ ថា ទ្រង់នឹងប្រសូតចេញមកពីវង្សនៃហ្លួងដាវីឌ ៖ «នៅគ្រានោះ គឺនៅជាន់នោះឯង យើងនឹងធ្វើឱ្យមានលំពង់ដ៏សុចរិត ពន្លកឡើងដល់ដាវីឌ លំពង់នោះទ្រង់នឹងសម្រេចសេចក្ដីយុត្តិធម៌ នឹងសេចក្ដីសុចរិតនៅក្នុងស្រុក» (យេរេមា 33:15)។

*ការបំពេញ ៖* ម៉ាថាយ បានផ្ដល់បញ្ជីពង្សាវតារបស់ព្រះគ្រីស្ទ

ដល់យើង ដែលបង្ហាញអំពីរបៀបដែលព្រះអម្ចាស់ គឺជាប់ខ្សែលោហិតមកពីស្ដេចដាយ៉ូរលង់មកហើយ ៖ «នេះជាបញ្ជីពង្សាវតារពីព្រះគ្រីស្ទ ជាវង្សាហ្លួងដេវីឌ នឹងជាជំនួររង្សនៃលោកអ័ប្រាហាំដែរ។ ... ដូច្នេះ តាំងពីអ័ប្រាហាំ ដរាបមកដល់ហ្លួងដាវីឌ រួមទាំងអស់មាន 14 ដំណ តាំងពីហ្លួងដាវីឌ ដរាបមកដល់គ្រាដែលត្រូវនិរទេស ទៅស្រុកបាប៊ីឡូន ក៏មាន14 ដំណ ហើយតាំងពីគ្រាដែលត្រូវនិរទេសទៅស្រុកបាប៊ីឡូន ដរាបមកដល់ព្រះគ្រីស្ទ ក៏មាន14 ដំណដែរ» (ម៉ាថាយ 1:1, 17)។

## ស្ដេចបានយាងមកជួប

*ការព្យាករណ៍ ៖* ទោះជាការប្រសូតរបស់ទ្រង់ស្ថិតនៅក្នុងស្ថានភាពដ៏រាបសារក្ដី ក៏ពួកព្យាការីបានប្រកាសថា ស្ដេចទាំងប៉ុន្មាននឹងយាងមកទតមើលព្រះគ្រីស្ទ ៖ «អស់ទាំងសាសន៍នឹងមូលគ្នាមកឯពន្លឺរបស់ឯង ហើយស្ដេចទាំងប៉ុន្មាននឹងមកឯរស្មីដែលភ្លឺចេញពីឯងក្នុងកាលដែលឯងរះឡើង» (អេសាយ 60:3)។

សាំយ៉ូអែល ជាសាសន៍លេមិន បានប្រាប់សាសន៍នីហ្វៃរយៈពេលប្រាំឆ្នាំ មុនកំណើតរបស់ព្រះគ្រីស្ទ អំពីទីសម្គាល់ទាំងឡាយដែលនឹងប្រាប់ឱ្យដឹងជាមុនអំពីការយាងមករបស់ទ្រង់។ ទីសម្គាល់មួយនៃទីសម្គាល់ទាំងនេះ គឺជាផ្កាយដែលពួកហោរាបានដើរតាម ៖ «ហើយមើលចុះនឹងមានផ្កាយថ្មីមួយរះឡើង គឺជាផ្កាយមួយដែលអ្នករាល់គ្នា ពុំដែលបានឃើញសោះ ហើយនេះនឹងទៅជាទីសម្គាល់មួយដល់អ្នក» (ហេលេមិន 14:5)។

*ការបំពេញ ៖* ពួកហោរា បានដឹងថាគួរស្វែងរកមើលទីសម្គាល់ណាមួយ ដោយសារតែពួកគេត្រូវតែស្វែងរកដើម្បីបំពេញតាមការព្យាករណ៍ទាំងឡាយ។ ពួកគេបាននិយាយថា «តើព្រះអង្គដែលប្រសូតមកធ្វើជាស្ដេចសាសន៍យូដា ទ្រង់គង់នៅឯណា? ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់ពីទិសខាងកើតមកហើយយើងមកថ្វាយបង្គំទ្រង់» (ម៉ាថាយ 2:2)។

នៅក្នុងពិភពលោកថ្មី ពួកសាសន៍នីហ្វៃ ក៏បានស្គាល់ទីសម្គាល់ទាំងឡាយផងដែរ ហើយបានដឹងថាការព្យាករណ៍ទាំងឡាយត្រូវបានបំពេញ ៖ «ហើយអ្វីៗបានកើតឡើង មែនហើយ គឺអ្វីៗទាំងអស់គ្រប់ការណ៍ទាំងអស់ ស្របតាមពាក្យពេចន៍របស់ពួកព្យាការី។ ហើយហេតុការណ៍បានកើតឡើងថា ផ្កាយថ្មីមួយបានរះឡើង ស្របតាមពាក្យទំនាយ»(នីហ្វៃទី 3 1:20–21)។

ចូរគិតថាតើអ្នករីករាយយ៉ាងណា នៅទីបំផុតពេលអ្នកបានបើកអំណោយបុណ្យគ្រីស្ទម៉ាសរបស់អ្នក។ ប្រៀបធៀបមកវិញ តើវាយ៉ាងដូចម្ដេចដែរ បើសិនជាអ្នករង់ចាំទីសម្គាល់ទាំងឡាយអំពីកំណើតរបស់ព្រះគ្រីស្ទ ហើយទីបំផុតទីសម្គាល់ទាំងនោះត្រូវបានបំពេញ? ព្រះវរបិតាសួគ៌របស់យើង បានរៀបចំទីសម្គាល់ទាំងនេះទុកជាមុន ដែលពុំត្រឹមតែឱ្យពួកអ្នកស្មោះត្រង់នៅជុំវិញពិភពលោករីករាយជាមួយគ្នានៅពេលកំណើតរបស់ព្រះរាជបុត្រារបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែដើម្បីថ្លែងទីបន្ទាល់អំពីការហៅដ៏ទេវភាពរបស់ព្រះគ្រីស្ទផងដែរ។ ■



ផ្ទាំងគំនូរដោយ ហ្គូស្តាវ ដូរ៉េ

# អំណោយ ប្រកបដោយការចេះគិតគូរ

*ហេតុអ្វីបានជាពួកហោរាប្រគល់ជូនដល់ យ៉ូសែប និង ម៉ារី ជាមាស ជាកំញាណ និង ជ័រល្វីងទេស?*

មនុស្សជាច្រើនជឿថា វាគឺជាគំនិតចេះគិតគូរ នៅពេលឱ្យអំណោយ។ ប្រហែលជា នោះ ដោយសារតែមានគំនិតអ្វីបង្កប់នៅពីខាងក្រោយ ដែលធ្វើឱ្យអំណោយនោះមានន័យច្រើនជាជាងរបស់មានប្រយោជន៍ ឬក៏ជារបស់គួរឱ្យចាប់អារម្មណ៍—វាធ្វើឱ្យអំណោយនោះជានិមិត្តរូបមួយ នៃសេចក្តីស្រឡាញ់របស់អ្នកឱ្យអំណោយ ឬ ការចេះគិតគូរចំពោះអ្នកទទួលអំណោយ។ អំណោយមួយចំនួនក៏មានន័យច្រើនជាងគំនិតដែលនៅពីក្រោយអំណោយនោះផងដែរ អំណោយទាំងប្រភេទនេះ មាននិមិត្តរូបដែលទទួលយកបានយ៉ាងទូលំទូលាយ ដែលបន្ថែមឱ្យមានសារៈសំខាន់កាន់តែខ្លាំង។ នៅពេលអំណោយមួយ មាន—អត្ថប្រយោជន៍ តម្លៃផ្ទាល់ខ្លួន និង ន័យនៃនិមិត្តរូប ទាំងបីនេះ—នោះវាអាចជាអំណោយដែលមានការចេះគិត បំផុត និងជាអំណោយដែលមានការថ្លែងអំណរគុណដ៏ធំបំផុត។

ចូរគិតអំពីគំនិតដែលនៅពីខាងក្រោយ អំណោយជាមាស ជាកំញាន និង ជ័រល្វីងទេស ដែលពួកហោរាបានថ្វាយដល់ព្រះឱរស ព្រះគ្រីស្ទ (សូមមើលម៉ាថាយ 2:11)។ ព្រះគម្ពីរបរិសុទ្ធ ពុំបានប្រាប់ពីមូលហេតុដែលពួកហោរា បាននាំអំណោយជាក់លាក់ទាំងនេះ មកថ្វាយនោះទេ ប៉ុន្តែអំណោយទាំងបីនេះ មានតម្លៃពិត ហើយប្រហែលជាមានន័យជានិមិត្តរូបចំពោះព្រះរាជបុត្រារបស់ព្រះ និង មាតាបិតាខាងលោកិយរបស់ទ្រង់។

### មាស

*ការប្រើប្រាស់ជាក់ស្តែង ៖* សម្រាប់ប្តីប្រពន្ធវ័យក្មេងដែលមិនយូរប៉ុន្មានត្រូវចំណាយលើថ្លៃធ្វើដំណើរទៅប្រទេសអេស៊ីព្ទ ដើម្បីគេចចេញពីកំហឹងរបស់ស្តេចហេរ៉ូឌ នោះមាសនឹងជាអំណោយដែលមានតម្លៃហួសប្រមាណ។

*ន័យជានិមិត្តរូប ៖* មាស គឺជាអំណោយមួយបែបសម្រាប់ស្តេច (សូមមើល ពង្សាវតារក្សត្រទី 1 9:14, 28) ដោយសារតែវាមាននិមិត្តរូបនៃភាពជាស្តេច និង ជាក្សត្រ—នោះវាជាអំណោយដែលសម សម្រាប់ «ស្តេចលើសអស់ទាំងស្តេច» (ធីម៉ូថេ ទី 1 6:15)។

### កំញាន

*ការប្រើប្រាស់ជាក់ស្តែង ៖* ក្រៅពីគិតថាវាមានតម្លៃជារូបិយវត្ថុ នោះកំញាន គឺត្រូវបានប្រើជាធូបក្រអូប និង ជាទឹកអប់។

*ន័យជានិមិត្តរូប ៖* កំញាន យកចេញមកពីជ័រឈើផ្អែម ហើយត្រូវបានប្រើនៅក្នុងពិធីបរិសុទ្ធនៃបព្វជិតភាព នៅក្នុងការថ្វាយដង្វាយដុត (សូមមើល លេវីវិន័យ 2:1) និងនៅក្នុងប្រេងសម្រាប់ចាក់ប្រេងតាំងពួកសង្ឃ។ ហេតុដូច្នេះហើយ វាអាចជាតំណាងឱ្យបព្វជិតភាពរបស់ព្រះអម្ចាស់ និង តួនាទីរបស់ទ្រង់ក្នុងនាមជាកូនចៀមនៃព្រះ ដើម្បីពលិកម្មជំនួសឱ្យយើង (សូមមើល យ៉ូហាន 1:29)។

### ជ័រល្វីងទេស

*ការប្រើប្រាស់ជាក់ស្តែង ៖* ជ័រល្វីងទេស ជាប្រេងល្វីងចេញមកពីជ័រឈើ ក៏មានតម្លៃផ្នែកសេដ្ឋកិច្ចផងដែរ ប៉ុន្តែប្រហែលជាកាន់តែមានប្រយោជន៍ចំពោះម៉ារា និង យ៉ូសែប ដើម្បីប្រើជាឱសថ។

*ន័យជានិមិត្តរូប ៖* នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាធម្មតា ជ័រល្វីងទេស ជាប់ទាក់ទងទៅនឹងការអប់សព និង ការបញ្ចុះ ដោយសារ តែវាអាចរក្សាសាកសពបានល្អ (សូមមើល យ៉ូហាន 19:39–40)។ ការប្រើជ័រល្វីងទេសធ្វើជាឱសថ អាចជានិមិត្តរូបនៃតួនាទីរបស់ព្រះគ្រីស្ទ ក្នុងនាមជាចៅហ្វាយនៃអ្នកព្យាបាល ហើយប្រើវានៅក្នុងការបញ្ចុះសព ក៏អាចមាននិមិត្តរូបថា «តែវល្វីង» ដែលទ្រង់នឹងផឹក នៅពេលទ្រង់បានរងទុក្ខសម្រាប់អំពើបាបរបស់យើង (សូមមើល គ. និង ស. 19:18–19)។ ■



រចនារូបភាពដោយ ស្កត គ្រៀ

# ពួកគេ គួរតែ ផ្លាស់ប្តូរ

*នៅពេលខ្ញុំបានទទួលបុណ្យជ្រមុជទឹក គ្រួសាររបស់ខ្ញុំបានបដិសេធសាសនាចក្រ។ ឥឡូវខ្ញុំត្រូវតែស្វែងរកវិធី ដើម្បីឆ្លើយតបនៅពេលដែលជីវិតរស់នៅរបស់ពួកគាត់ មិនសមស្របគ្នានឹងគោលការណ៍នៃដំណឹងល្អ។*

**ដោយ ហ្វ្រែនស៊ីស្កូ ហារីអ៊ែរ ឡារា ហ៊ីណាន់ដេស**

នៅពេលខ្ញុំបានទទួលបុណ្យជ្រមុជទឹក ខ្ញុំគឺជាសមាជិកតែម្នាក់គត់នៃគ្រួសារខ្ញុំ ដែលបានទទួលយកដំណឹងល្អ។ ខ្ញុំមានអាយុ 19 ឆ្នាំ ហើយខ្ញុំរីករាយចំពោះពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ។ ខ្ញុំត្រូវបានទទួលស្វាគមន៍ពីសំណាក់បងប្អូនប្រុសស្រី ក្នុងសាខាផាណ្ហូកូទីមួយ នៅក្នុងទីក្រុងវើរ៉ាក្រូហ្ស ប្រទេសម៉ិកស៊ិច។ លើសពីនេះទៅទៀត ខ្ញុំបានចាប់ផ្តើមរៀបចំបម្រើបេសកកម្មពេញម៉ោង រំពេចណាដែលខ្ញុំបានក្លាយជាសមាជិកនៃសាសនាចក្របានរយៈពេលមួយឆ្នាំ។ វាគឺជាការអស្ចារ្យណាស់ ដើម្បីស្គាល់សាសនាចក្រពិត ហើយខ្ញុំចង់ចែកចាយដំណឹងល្អជាមួយអ្នកដទៃ។

ឪពុករបស់ខ្ញុំ ម្តាយចុងរបស់ខ្ញុំ (ម្តាយរបស់ខ្ញុំបានទទួលមរណភាព ពេលខ្ញុំមានអាយុ 12 ឆ្នាំ) និងបងប្អូនប្រុសបីនាក់របស់ខ្ញុំ បានបដិសេធសាសនាចក្រ នៅពេលខ្ញុំបានទទួលបុណ្យជ្រមុជទឹក។ ជាអកុសល ខ្ញុំពុំបានឆ្លើយតបបានល្អទេ។ ខ្ញុំ មិនបានគោរពចំពោះពួកគាត់។ ខ្ញុំពុំបានគិតដល់ឪពុករបស់ខ្ញុំ ឬអំពីមតិរបស់គាត់ឡើយ។ នៅពេលខ្ញុំបានប្រាប់គាត់ថា ខ្ញុំនឹងបម្រើបេសកកម្មក្នុងពេលឆាប់ៗនេះ នោះគាត់ពុំសប្បាយចិត្តទេ ពីព្រោះតែខ្ញុំនឹងឈប់ធ្វើការ ហើយជាពិសេស ព្រោះថាខ្ញុំប្រហែលជាចេញទៅឆ្ងាយ។

វាបានរំខានដល់ខ្ញុំគ្រប់ពេល នៅពេលដែលការរស់នៅរបស់គ្រួសារខ្ញុំ មិនសមស្របទៅនឹងគោលការណ៍របស់ខ្ញុំ ដូចជាពេលពួកគាត់មើលទូរទស្សន៍ ឬ ស្តាប់កម្មវិធីតន្ត្រី ដែលខ្ញុំដឹងថាពុំសមរម្យចំពោះថ្ងៃអាទិត្យ ឬ នៅពេលឪពុករបស់ខ្ញុំហៅខ្ញុំឱ្យបរិភោគអាហារថ្ងៃត្រង់នៅថ្ងៃអាទិត្យតមអាហារជាដើម។

ខ្ញុំបានកែសម្រួលអាកប្បកិរិយាអវិជ្ជមានរបស់ខ្ញុំ ចំពោះក្រុមគ្រួសារ ដោយការប្រាប់ដល់ខ្លួនខ្ញុំថា ខ្ញុំពុំបានធ្វើអ្វីខុសនោះទេ—ក្នុងនាមជាសមាជិកមួយរូបនៃសាសនាចក្រ ខ្ញុំគួរតែរស់នៅតាមគោលការណ៍ដំណឹងល្អ ទោះជានៅពេលដែលគ្រួសាររបស់ខ្ញុំរំខានដល់ខ្ញុំក្តី។ ខ្ញុំបានប្រាប់ខ្លួនឯងថា *ពួកគាត់* គឺជាអ្នកដែលគួរតែផ្លាស់ប្តូរ។ ដោយសារហេតុផលនេះ ទំនាក់ទំនងរបស់ខ្ញុំនឹងឪពុកខ្ញុំពុំល្អសោះ។ វាកាន់តែធ្ងន់ធ្ងរទៅ ដោយសារតែអាកប្បកិរិយា និង ភាពអំណួតរបស់ខ្ញុំ។ ខ្ញុំបានបន្តធ្វើតាមរបៀបនេះ—ដោយពុំគិតអំពីសុខុមាលភាពខាងវិញ្ញាណរបស់គាត់សោះឡើយ។

ថ្ងៃមួយ ពេលខ្ញុំកំពុងតែសិក្សានៅក្នុងថ្នាក់វិទ្យាស្ថានរបស់ខ្ញុំ ខ្ញុំបានបើកទៅនីហ្វៃទី 1 16 ត្រង់កន្លែងដែលនីហ្វៃ បានបាក់ធ្នូដែករបស់គាត់ ហើយធ្វើឱ្យវាមានការលំបាកក្នុងការរកម្ហូបអាហារ។ មនុស្សគ្រប់រូបបានចាប់ផ្តើមរអ៊ូរទាំមាន—លេមិន និងលេមយ្អួល តាមទម្លាប់របស់ពួកគេ ព្រមជាមួយនឹងឪពុករបស់ពួកគេ ជាព្យាការីលីហៃផងដែរ។ នីហ្វៃបានឆ្លើយតបដោយការធ្វើធ្នូ និងព្រួញពីឈើ ហើយបានសួរដល់ឪពុករបស់គាត់ ថាគាត់គួរតែទៅរកម្ហូបអាហារនៅកន្លែងណាបាន។ ឪពុករបស់គាត់បានអធិស្ឋានសុំការណែនាំ ហើយត្រូវបានព្រះអម្ចាស់ស្តីបន្ទោស ចំពោះការរអ៊ូរទាំ។ លីហៃបានឆ្លើយតបដោយការពេញចិត្ត ហើយបានទទួលយកតួនាទីរបស់គាត់ ក្នុងនាមជាអ្នកដឹកនាំគ្រួសាររបស់គាត់ និងជាព្យាការីនៃព្រះអម្ចាស់វិញ។ នីហ្វៃ ពុំបានវិនិច្ឆ័យដល់ឪពុករបស់គាត់ នៅពេលគាត់ស្ថិតក្នុងសភាពទន់ខ្សោយនោះឡើយ សូម្បីតែនៅពេលនីហ្វៃបាននិយាយជាមួយនឹងព្រះអម្ចាស់ ហើយបានទទួលនូវការនិមិត្តជាច្រើនក្តី ក៏គាត់ពុំបានគិតថា គាត់ពុំគួរតែធ្វើជាព្យាការីតទៅទៀតនោះទេ។

នៅពេលខ្ញុំអាន ហើយយល់អំពីដំណើររឿងនេះ រំពេចនោះខ្ញុំបានគិតថាខ្លួនខ្ញុំនេះមានឥរិយាបទអាក្រក់ចំពោះគ្រួសាររបស់ខ្ញុំ។ ខ្ញុំមានការខ្មាស់អៀនចំពោះអាកប្បកិរិយារបស់ខ្ញុំ—ដែលខ្ញុំមានអារម្មណ៍ថា ខ្ញុំល្អប្រសើរជាងពួកគាត់—ហើយជាពិសេសមានអារម្មណ៍ពុំល្អសោះ ដែលខ្ញុំបានប្រព្រឹត្តដោយគ្មានការគោរពដល់ឪពុក



*អាកប្បកិរិយា និង ឥរិយាបទរបស់ខ្ញុំបានផ្លាស់ប្ដូរបន្តិចម្ដងៗ។ ទោះបីជារឿយៗ ខ្ញុំពុំយល់ស្របតាមឪពុករបស់ខ្ញុំ ក៏ខ្ញុំបានព្យាយាមដើម្បីគោរពដល់មតិរបស់គាត់ជានិច្ចដែរ។*

របស់ខ្ញុំ។ ខ្ញុំសោកស្ដាយដែលពុំបានធ្វើឱ្យវាជាអាទិភាពមួយ ដើម្បីចែកចាយដំណឹងល្អជាមួយពួកគាត់។

ខ្ញុំពុំបានមើលទៅគ្រួសាររបស់ខ្ញុំ នូវអ្វីដែលពួកគាត់អាចប្រែក្លាយនោះទេ។ ខ្ញុំបានផ្ដោតតែទៅលើភាពទន់ខ្សោយរបស់ពួកគាត់ប៉ុណ្ណោះ។ ចាប់តាំងពីថ្ងៃនោះមក អាកប្បកិរិយា និង ឥរិយាបទរបស់ខ្ញុំ បានផ្លាស់ប្ដូរបន្តិចម្ដងៗ។ ខ្ញុំបានព្យាយាមដើម្បីគោរពតាមមតិរបស់ឪពុកខ្ញុំជានិច្ច ថ្វីបើខ្ញុំមិនយល់ស្របនឹងមតិជាច្រើន របស់គាត់នោះ ក៏ដោយ។ បើសិនជាគាត់ហៅខ្ញុំបរិភោគអាហារថ្ងៃត្រង់ នៅពេលខ្ញុំកំពុងតែតមអាហារ នោះខ្ញុំនិយាយថា ខ្ញុំសូមទោស ដែលខ្ញុំពុំអាចបរិភោគអាហារជាមួយនឹងគាត់បាន។ ខ្ញុំឈប់មានអារម្មណ៍រំខានដោយកម្មវិធី ឬ តន្ត្រី ដែលពួកគាត់មើល ឬស្ដាប់នៅថ្ងៃអាទិត្យទៀតហើយ ដោយខ្ញុំចាំបានថា ពួកគាត់នៅពុំទាន់បានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះវរបិតាសួគ៌របស់យើង ដូចដែលខ្ញុំបានធ្វើនោះទេ។

នៅព្រឹកមួយ ខណៈពេលដែលខ្ញុំកំពុងតែជួយរៀបចំអាហារឪពុកខ្ញុំ ខ្ញុំបានប្រាប់គាត់ថាខ្ញុំស្រឡាញ់គាត់ខ្លាំងប៉ុណ្ណា ហើយខ្ញុំសោកស្ដាយខ្លាំងណាស់ចំពោះឥរិយាបទឥតគួរសមរបស់ខ្ញុំ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមានមោទនភាពណាស់ ដែលគាត់ជាឪពុករបស់ខ្ញុំ ហើយថា ខ្ញុំចង់មានទំនាក់ទំនងសុខសាន្តជាមួយនឹងគាត់។

អ្វីៗគ្រប់យ៉ាងបានចាប់ផ្ដើមផ្លាស់ប្ដូរ។ ការឈ្លោះប្រកែកបានកាត់បន្ថយ ហើយឈប់កើតមានទៀត។ ទោះបីជាខ្ញុំគិតថា វានឹងចំណាយពេលដ៏យូរមុនពេលគ្រួសាររបស់ខ្ញុំបានចូលរួមក្នុងសាសនាចក្រក្ដី ក៏អាកប្បកិរិយារបស់ពួកគាត់ចំពោះសាសនាចក្រមានការប្រសើរជាងមុន។ នឹងគ្មានការផ្លាស់ប្ដូរទាំងនេះណាមួយកើតមានឡើងនោះទេ បើខ្ញុំពុំព្រមផ្លាស់ប្ដូរខ្លួនខ្ញុំជាមុនសិននោះ។

បន្ទាប់ពីខ្ញុំបានក្លាយជាសមាជិកសាសនាចក្របានមួយឆ្នាំ ខ្ញុំបានបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនៅក្នុងបេសកកម្មធីហារណ្ណា ប្រទេសម៉ិកស៊ិច។ រយៈពេលបីខែមុនពេលត្រឡប់មកផ្ទះវិញ ខ្ញុំបានទទួលសំបុត្រមួយច្បាប់ដែលប្រាប់ខ្ញុំថា គ្រួសាររបស់ខ្ញុំបានទទួលយកដំណឹងល្អ ហើយនឹងទទួលបុណ្យជ្រមុជទឹក។ នៅពេលខ្ញុំត្រឡប់មកដល់ផ្ទះវិញ ពួកគាត់បានក្លាយជាសមាជិកសាសនាចក្ររួចទៅហើយ។

នៅក្នុងរយៈពេល 15 ឆ្នាំនៃ ការក្លាយជាសមាជិកនៃសាសនាចក្ររបស់ខ្ញុំ មេរៀនដ៏ល្អបំផុតមួយរបស់ខ្ញុំ កើតចេញមកពីការសិក្សាព្រះគម្ពីរមរមនរបស់ខ្ញុំ និងជាមួយកូនចៅរបស់ព្រះ ដែលខ្ញុំបានជិតស្និតបំផុតគឺ ៖ គ្រួសាររបស់ខ្ញុំ។ ■



# ជួបបងប្រុសយ៉ូសែប

អ្នកដឹងថាយ៉ូសែប ស្ម៊ីធ គឺជាព្យាការីដំបូងគេនៅក្នុងថ្ងៃចុងក្រោយនេះ ប៉ុន្តែតើអ្នកដឹងថាគាត់ចូលចិត្តសើច និង ចូលចិត្តធ្វើឱ្យមនុស្សសើចដែរឬទេ? ឬតើអ្នកដឹងថា គាត់ និង ភរិយារបស់គាត់ អិមម៉ា បានយកកូនភ្លោះមកចិញ្ចឹមឬទេ? នេះគឺជារឿងមួយចំនួនតូចផ្សេងទៀត ដែលអ្នកប្រហែលជានឹងពុំបានដឹងអំពីព្យាការីយ៉ូសែប ៖

- យ៉ូសែប ស្ម៊ីធជុញ្ញ័រ។ បានកើតនៅថ្ងៃទី 23 ខែធ្នូ ឆ្នាំ 1805 នៅភូមិសារ៉ុន រដ្ឋវ៊ើរម៉ុន្ត សហរដ្ឋអាមេរិក ហើយត្រូវបានដាក់ឈ្មោះតាមឪពុករបស់គាត់។ បងប្អូនរបស់យ៉ូសែប រៀបរាប់តាមលំដាប់អាយុ គឺ អាលវិន ហៃរុម សូភ្រូនា សាម៉ូអែល ហារីសុន អេប្រាអិម វិលលាម ខាតធើរិន ដុនខាលុស និង លូស៊ី។
- នៅពេលយ៉ូសែប មានអាយុប្រាំពីរឆ្នាំ គាត់មានជម្ងឺគ្រុនសន្និ។ គាត់បានជាសះស្បើយពីគ្រុន ប៉ុន្តែត្រូវបានបន្សល់ទុកជាមួយនឹងរោគឆ្លងទៅជើងខាងឆ្វេងរបស់គាត់។ មានឆ្អឹងប្រាំបួនចំណែកត្រូវបានដកចេញដោយគ្មានចាក់ថ្នាំស្ពឹក (ថ្នាំបំបាត់ការឈឺចាប់)។ គាត់ដើរខ្វិចជើងពេញមួយជីវិតរបស់គាត់។[1]
- យ៉ូសែប មានអាយុ 14 ឆ្នាំ នៅពេលគាត់បានអធិស្ឋានឮៗដំបូង ហើយបានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ (សូមមើល យ៉ូសែប ស្ម៊ីធ —ប្រវត្តិ 1:17)។
- បងប្រុសច្បងរបស់យ៉ូសែប ឈ្មោះ អាលវិន បានស្លាប់នៅពេលយ៉ូសែប អាយុ 17 ឆ្នាំ។ ប្រហែលជា 13 ឆ្នាំ ក្រោយមក យ៉ូសែប បានមើលឃើញអាលវិន នៅក្នុងការនិមិត្តមួយ នៃនគរសេលេស្ទាល (សូមមើល គ. និង ស. 137:5–7)។
- អ៊ីសាក ហេល ត្រូវជាឪពុករបស់អិមម៉ា ពុំអនុញ្ញាតដល់យ៉ូសែបទេ ហើយមិនចង់ឱ្យពួកគេរៀបការឡើយ។ យ៉ូសែប និង អិមម៉ា បានសម្រេចចិត្តដើម្បីលួចរត់ទៅរៀបការ ហើយត្រូវបានរៀបការនៅថ្ងៃទី 18 ខែ មករា ឆ្នាំ 1827។[2]
- អិមម៉ា និង យ៉ូសែប បានរៀបការអស់រយៈពេល 17 ឆ្នាំ ហើយមានកូន 11 នាក់ ដែលកូន 6 នាក់ត្រូវបានស្លាប់ពេលនៅជាកុមារភាព។
- បន្ទាប់ពីធ្មេញរបស់គាត់ ត្រូវបានឆែប នៅពេលពួកមនុស្សកំណាចបានវាយដំលើគាត់ ក្នុងឆ្នាំ 1832 យ៉ូសែប បាននិយាយសម្លេងខ្សឹបៗ។[3]
- យ៉ូសែប ចូលចិត្តលេងល្បែងកំសាន្ត។ ល្បែងកំសាន្តទាំងនោះ មានដូចជា លេងបាល់ លេងបោកច្រវាប់ លេងគប់ដុំព្រិល ស្ទូចត្រី និង ទាញដំបង។[4]
- ពួកបរិសុទ្ធថ្ងៃចុងក្រោយជំនាន់មុនមួយរូប បានពិពណ៌នាអំពីសម្លេងរបស់យ៉ូសែប គឺដូចជា «សម្លេងផ្គរលាន់ពីស្ថានសួគ៌»។[5]
- យ៉ូសែប ជាមនុស្សមាឌមាំ ហើយខ្ពស់ មានកំពស់ប្រហែលជា 1 ម៉ែត្រ 9 តឹក ហើយ មានទម្ងន់ប្រហែលជា 91 គីឡូក្រាម។[6]
- យ៉ូសែប ពុំមែនគ្រាន់តែជាប្រធាននៃសាសនាចក្រប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់ក៏ឈរឈ្មោះជាប្រធានា ធិបតីនៃសហរដ្ឋផងដែរ។
- បន្ទាប់ពីយ៉ូសែប ត្រូវបានគេធ្វើទុក្ករកម្ម អែលឌើរ យ៉ូហាន ថេល័រ (ឆ្នាំ 1808 –87) ក្រោយមកជាកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសរសេរអំពីគាត់ថា «យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ជាអ្នកមើលឆុតរបស់ព្រះអម្ចាស់ បានសម្រេចច្រើនជាងគេ លើកលែងតែព្រះយេស៊ូវប៉ុណ្ណោះ សម្រាប់សេចក្តីសង្គ្រោះ ដល់មនុស្សក្នុងលោកនេះ ជាងមនុស្សផ្សេងទៀត ដែលធ្លាប់រស់នៅលោកនេះ» (គ. និង ស. 135:3)។ ■

**កំណត់ចំណាំ**

1. សូមមើល *ប្រធាននៃសាសនាចក្រ* (Church Educational System student manual, 2003), 3–4។
2. សូមមើល «Life of the Prophet: Joseph and Emma,» JosephSmith.net។
3. សូមមើល «Life of the Prophet: Friend of Man,» JosephSmith.net។
4. សូមមើល អាឡិចសាន់ឌើរ អិល. ប៊ូហ្វ «Joseph Smith's Athletic Nature,» នៅក្នុង *Joseph Smith: The Prophet, the Man* ត្រូវបានពិនិត្យកែសម្រួលដោយ ស៊ូស្សាន អេស្ទុន ប្លាក និង ឆាល ឌី. តាត ជុញ្ញ័រ។ (ឆ្នាំ 1993), ទំព័រ 137។
5. យ៉ូសែប អិល. រ៉ូប៊ីនសុន នៅក្នុង «Life of the Prophet: Teacher of God's Truth,» JosephSmith.net។
6. សូមមើល ប៊ូហ្វ «Joseph Smith's Athletic Nature,» 138–39។
7. សូមមើល «Life of the Prophet: Leading with Love,» JosephSmith.net។



*យ៉ូសែប ស្ម៊ីធ* ដោយ ឌី ជេ ប្ញុនិន *JOSEPH SMITH AND NAUVOO'S YOUTHS* ដោយ ដេល ផាសុន © IRI





# តើខ្ញុំអាច ធ្វើតាមព្រះអង្គសង្គ្រោះ បានយ៉ាងដូចម្ដេច?

*អែលឌើរ ឃ្វីនថិន អិល ឃុក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ចែកចាយគំនិតខ្លះៗ ទៅលើប្រធានបទនេះ។*



យើងបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះ នៅពេលយើងរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និង បម្រើកូនចៅរបស់ទ្រង់។



សាក្រាម៉ង់ អនុញ្ញាតឱ្យយើងធ្វើជាសាក្សីចំពោះព្រះថា យើងនឹងចងចាំព្រះរាជបុត្រារបស់ទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ នៅពេលយើងរំឭកដល់សេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង។





ព្រះអង្គសង្គ្រោះ បានប្រកាសថា យើងនឹងត្រូវបានរាប់ទុកជាពួកសិស្សរបស់ទ្រង់ បើសិនជាយើងមានសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក។



ធ្វើតាមព្យាការីនៅរស់របស់យើង ប្រធាន ថូម៉ាស អេស ម៉នសុន។ លោកគឺជា គំរូដ៏ល្អវិសេសម្នាក់ដែលធ្វើតាមព្រះអង្គសង្គ្រោះ។

យើងត្រូវតែទទួលដាក់មកលើយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ និង ទទួលព្រះភ័ក្ត្ររបស់ទ្រង់ នៅលើទឹកមុខរបស់យើង ដើម្បីនៅពេលទ្រង់យាងមក នោះយើងនឹងកាន់តែដូចជាទ្រង់។

ចេញមកពី «We Follow Jesus Christ» លីអាហូណា *ខែ ឧសភា ឆ្នាំ 2010, ទំព័រ 84, 86* «Live by Faith and Not by Fear» លីអាហូណា *ខែ វិច្ឆិកា ឆ្នាំ 2007, ទំព័រ 73*។

C. HARRISON CONROY CO.

# ពាក្យទាំងនោះ





**ដោយ អាន់ជី បើរស្ត្រម មីលលើរ**
ផ្អែកទៅលើដំណើររឿងពិត

*«ហើយមិនត្រូវស្បថបំពានដោយនូវឈ្មោះយើង ទាំងបង្អាប់ដល់ព្រះនាមព្រះនៃ ឯងឡើយ យើងនេះជាព្រះយេហូវ៉ា» (លេវីវិន័យ 19:12)។*

ហ្សែលប៊ី មិនចូលចិត្តស្ដាប់ពាក្យអាក្រក់ទេ ជាពិសេសនៅពេលមិត្តរបស់នាងនៅសាលា ប្រើព្រះនាមរបស់ព្រះជាអសាឥតការ។

នាងបាននិយាយទៅកាន់មិត្តរបស់នាងថា «សូមកុំនិយាយពាក្យទាំងឡាយនោះនៅជិតខ្ញុំ»។

ប៉ុន្តែពេលខ្លះ ពួកគេភ្លេច ហើយនាងត្រូវតែរំឭកដល់ពួកគេ។

នៅថ្ងៃមួយ មិត្តរបស់ហ្សែលប៊ី ឈ្មោះ បេថ បានធ្វើភ្នែកស្លឹចុះឡើង ហើយនិយាយថា «អូ មែនហើយ ខ្ញុំភ្លេច។ គ្មាននរណាម្នាក់ និយាយ *ពាក្យទាំងនោះ*នៅចំពោះមុខហ្សែលប៊ីបានទេ។ នាងកំពុងតែព្យាយាម ធ្វើឱ្យយើង*ល្អ*ដូចជានាងដែរ»។

ក្មេងស្រីដទៃទៀតសើច។

ហ្សែលប៊ី បានខ្មាស់។ នាងមានអារម្មណ៍មិនល្អ ដែលតែងតែសុំឱ្យមិត្តរបស់នាង កុំនិយាយពាក្យទាំងនោះនៅជិតនាង ជា—ពិសេសនៅពេលពួកគេគិតថាពាក្យទាំងនោះពុំអាក្រក់។

នៅពេលហ្សែលប៊ី មកផ្ទះពីសាលារៀនវិញ នាងបានផ្ដួលខ្លួនដេកលើគ្រែរបស់នាង។ ប៉ុន្មាននាទីក្រោយមក ម្ដាយនាងបានមកដល់ ហើយហ្សែលប៊ី បានប្រាប់ម្ដាយអំពីអ្វីដែលបានកើតឡើង។

ម្ដាយបាននិយាយថា «ចូរកុំខ្វល់ពីវាអី»។ «កូនគ្រាន់តែធ្វើអ្វីដែលត្រូវត្រឹមទៅបានហើយ នៅទីបំផុត មិត្តរបស់កូន នឹងពុំចង់និយាយពាក្យទាំងនោះទៀតទេ»។

«តើហេតុអ្វីបានជាវារំខានដល់កូន បើមិត្តរបស់កូននិយាយពាក្យទាំងនោះ?» ហ្សែលប៊ី បានសួរ។ «វាមិនដូចជាម៉ាក់កំពុងតែជេរឡើយ»។

ម៉ាក់បាននិយាយថា «ពួកព្យាការីបានបង្រៀនយើងថា យើងគួរតែរក្សាខ្លួនយើងឱ្យមានភាពសក្ដិសមដើម្បីមានអារម្មណ៍ពីព្រះវិញ្ញាណនៅគ្រប់ពេល។ ពាក្យអាក្រក់ ប្រមាថដល់ព្រះវិញ្ញាណ»។

ហ្សែលប៊ី បានចងចាំគ្រាដែលនាងមានអារម្មណ៍ពីព្រះវិញ្ញាណ ៖ នៅពេលរាត្រីជួបជុំក្រុមគ្រួសារ នៅពេលនាងថ្លែងទីបន្ទាល់របស់នាង និងនៅពេលនាងទទួលការប្រសិទ្ធពរមួយមកពីឪពុករបស់នាង។ ហ្សែលប៊ី ចូលចិត្តអារម្មណ៍ពីព្រះវិញ្ញាណ ហើយនាងពុំចង់ធ្វើអ្វី ដែលនឹងទាស់ដល់ភាពកក់ក្ដៅការលួងលោមដោយសុខសាន្តឡើយ។

នាងបានសម្រេចចិត្តដើម្បី បន្តធ្វើជាគំរូ ចំពោះមិត្តរបស់នាង ហើយជួយពួកគេឱ្យយល់ថា នាងពុំចង់ឮពាក្យទាំងអស់នោះទេ។

ស្អែកឡើង នាងបានឮពាក្យទាំងនោះម្ដងទៀតនៅសាលារៀន។

ហ៊ែរ្យលប៊ី បានសុំដល់បេកាថា «សូមកុំនិយាយពាក្យទាំងនោះនៅជិតខ្ញុំ»។

បេកា បានសម្លក់ដាក់ហ៊ែរ្យលប៊ី ហើយក៏ធ្វើព្រងើយដាក់នាង។ ហ៊ែរ្យលប៊ី សប្បាយចិត្ត ដែលនាងបាននិយាយអ្វីមួយ ប៉ុន្តែមានអារម្មណ៍សោកស្ដាយ ដែលមិត្តរបស់នាងមិនសប្បាយចិត្ត។

នៅពេលសម្រាក ហ៊ែរ្យលប៊ី បានឮម្នាក់ទៀតនិយាយពាក្យទាំងនោះម្ដងទៀត។ ពេលនេះ គឺជាបេថ។

ហ៊ែរ្យលប៊ី បាននិយាយថា «សូមកុំនិយាយពាក្យដូច្នោះនៅជិតខ្ញុំ»។

បេថ និយាយថា «សូមទោស» ដោយធ្វើភ្នែកស្លឹចុះឡើងដាក់នាង។

គំនូរដោយ ជេម ម៉ាឌ្សិន



ហ៊ែរ្យលប៊ី មានអារម្មណ៍ដូចជាអៀនខ្មាស់ម្ដងទៀតហើយ។

នៅពេលហាត់ សមលេងវាយកូនបាល់ បន្ទាប់ពីសាលារៀន ហ៊ែរ្យលប៊ី បានវាយកូនបាល់មួយ។ វាបានលោតទៅទីតាំងទីមួយ ហើយ ទៅដល់ទីនោះមុន ហ៊ែរ្យលប៊ី បានទៅដល់។ ហ៊ែរ្យលប៊ី បានស្ដាប់ឮ ប៊ុន្នី ដែលជាក្មេងស្រីថ្មីក្នុងក្រុម និយាយព្រះនាមរបស់ព្រះអម្ចាស់ជាអសាឥតការ។

ហ៊ែរ្យលប៊ី បានស្ទាក់ស្ទើរក្នុងចិត្ត។ នាងមានការនឿយហត់ក្នុងការសុំឱ្យគេកុំនិយាយពាក្យទាំងនោះនៅ ជិតនាង។ នាងមិនចង់ឱ្យក្មេងស្រីផ្សេងទៀត សើចចំអកដល់នាងទេ។

«សូមកុំនិយាយពាក្យទាំងនោះនៅជិតនាង»។

ហ៊ែរ្យលប៊ី បានងាករកមើល អ្នកដែលបាននិយាយពាក្យនោះ។

បេថ កំពុងតែប្រាប់ដល់ប៊ុន្នី ថា ហ៊ែរ្យលប៊ី គឺជាពួកបរិសុទ្ធថ្ងៃចុងក្រោយមួយរូប ហើយថា នាងមិននិយាយពាក្យទាំងនោះទេ ហើយក៏មានអារម្មណ៍មិនល្អដែរពេលស្ដាប់ឮពាក្យទាំងនោះ។

បន្នី បានបែរខ្នងមក មើលហ៊ែរ្យលប៊ី។ «សុំទោស ហ៊ែរ្យលប៊ី។ ខ្ញុំពុំបានដឹងទេ»។

បេថ បានញញឹមដាក់ហ៊ែរ្យលប៊ី។ បេថបាននិយាយថា «ខ្ញុំគិតថា យើងទាំងអស់គ្នាកំពុងតែប្រែក្លាយដូចជាឯងហើយ»។

ហ៊ែរ្យលប៊ី ញញឹម។ នាងសប្បាយចិត្ត ដែលនាងបានធ្វើការសម្រេចចិត្ត ដើម្បីធ្វើជាគំរូល្អ ចំពោះមិត្តរបស់នាង ហើយធ្វើតាមដំបូន្មានរបស់ព្យាការី ដើម្បីរក្សាព្រះវិញ្ញាណឱ្យគង់នៅជាមួយនាង។ ■

«ខ្ញុំនឹងប្រើព្រះនាមរបស់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ដោយមានគារវភាព។ ខ្ញុំនឹងមិនជេរ ឬប្រើពាក្យគ្រោតគ្រាតឡើយ»។

**បទដ្ឋានដំណឹងល្អរបស់ខ្ញុំ**

# ទំព័ររបស់កុមារ



អានជី ឌី អាយុ 11 ឆ្នាំ ប្រទេស ពេរូ



អារីណា អេ អាយុ 9 ឆ្នាំ ប្រទេសប្រេស៊ីល




*កំណើតរបស់ព្រះយេស៊ូវ* ដោយ អែនជល អរ អាយុ 10 ឆ្នាំ ប្រទេស បូលីវី



រេបេកា អេ អាយុ 7 ឆ្នាំ វ៉េនេហ្ស៊ុយអេឡា

*នៅថ្ងៃបុណ្យគ្រីស្ទម៉ាសមួយ ខ្ញុំបានចែកខិតប័ណ្ណដំណឹងល្អមួយចំនួនទៅឱ្យមិត្តភក្តិ និង គ្រូបង្រៀននៅសាលារៀនរបស់ខ្ញុំ។ នៅខែមករា គ្រូបង្រៀនមួយរូប ដែលខ្ញុំបានជូនខិតប័ណ្ណមួយឱ្យនោះ បានប្រាប់ខ្ញុំថា គាត់បានទូរស័ព្ទទៅលេខនៅលើខិតប័ណ្ណនោះ ហើយក៏បានទទួលឌីវីឌីបុណ្យគ្រីស្ទម៉ាសមួយបន្ទះ។ គាត់បានមើលឌីវីឌីនោះ ហើយចូលចិត្តវាខ្លាំងណាស់។ ខ្ញុំគិតថា ប័ណ្ណដំណឹងល្អ ពិសេសណាស់។ នៅពេលខ្ញុំចែកវាទៅឱ្យគេ ខ្ញុំអាចទទួលអារម្មណ៍ពីព្រះវិញ្ញាណ។ វាធ្វើឱ្យខ្ញុំសប្បាយចិត្តដើម្បីចែកចាយដំណឹងល្អ។ ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទ មានព្រះជន្មរស់ ហើយស្រឡាញ់យើងទាំងអស់គ្នា។*

រេអាន អរ អាយុ 11 ឆ្នាំ ប្រទេសប្រេស៊ីល



សូមអ៊ីម៉ែលគំនូរ រូបថត ឬ បទពិសោធន៍របស់អ្នកសម្រាប់ទំព័ររបស់យើង តាម liahona@ldschurch.org ដោយដាក់ប្រធានបទ «Our Page» ឬ ផ្ញើសំបុត្រទៅកាន់

Liahona, Our Page
50 E. North Temple St., Rm 2420
Salt Lake City, UT 84150-0024
USA

រាល់ការផ្ញើរមកត្រូវតែមានឈ្មោះពេញរបស់កុមារ ភេទ និង អាយុ (ត្រូវមានអាយុ 3 ឆ្នាំ ទៅ 12 ឆ្នាំ) ព្រមទាំងមានឈ្មោះឪពុកម្តាយ វួដ ឬ សាខា ស្តេក ឬមណ្ឌល និងការអនុមតិជាលាយលក្ខណ៍អក្សររបស់ឪពុកម្តាយ (អ៊ីម៉ែលទទួលយកបាន) ដើម្បីប្រើប្រាស់រូបថត និង ការផ្ញើឯកសាររបស់កុមារ ។ ឯកសារដែលផ្ញើរមកអាចនឹងធ្វើការ កែសម្រួលសម្រាប់ភាពច្បាស់លាស់ ឬ ប្រវែងអត្ថបទ ។

# ខិតប័ណ្ណព្រះវិហារបរិសុទ្ធ

ដើម្បីធ្វើខិតប័ណ្ណព្រះវិហារបរិសុទ្ធផ្ទាល់ខ្លួនរបស់អ្នក សូមដកទំព័រនេះមកពីទស្សនាវដ្ដី បិទវានៅលើក្រដាសរឹង ហើយកាត់ចេញជាខិតប័ណ្ណ។ អ្នកអាចបន្ថែមខិតប័ណ្ណទាំងនេះ ទៅក្នុងខិតប័ណ្ណទាំងឡាយ ដែលមាននៅក្នុងច្បាប់ទស្សនាវដ្ដីឆ្នាំ 2003 និង ខែ មេសា ឆ្នាំ 2005 និង ខែ កញ្ញា 2007។ ដើម្បីបោះពុម្ពខិតប័ណ្ណឱ្យបានកាន់តែច្រើនទៀត សូមចូលទៅ liahona.lds.org។



ព្រះវិហារបរិសុទ្ធ រ៉េចប៊ើក អៃដាហូ
បានឧទ្ទិសឆ្លងនៅថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ 2008
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធឃើរីទីប៉ា ប្រេស៊ីល
បានឧទ្ទិសឆ្លងនៅថ្ងៃទី 1 ខែ មិថុនា ឆ្នាំ 2008
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធ ផាណាម៉ា ទីក្រុងផាណាម៉ា
បានឧទ្ទិសឆ្លងនៅថ្ងៃទី 10 ខែ សីហា ឆ្នាំ 2008
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធ ធ្វីន ហ្វូល អៃដាហូ
បានឧទ្ទិសឆ្លងនៅថ្ងៃទី 24 ខែ សីហា ឆ្នាំ 2008
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធ គ្រាបតើរ យូថាហ៍
បានឧទ្ទិសឆ្លងនៅថ្ងៃទី 20 ខែ មិនា ឆ្នាំ 2009
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធ អូគ័រ ម៉ោនធិន យូថាហ៍
បានឧទ្ទិសឆ្លងនៅថ្ងៃទី 21 ខែ សីហា ឆ្នាំ 2009
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធវ៉ាន់ឃូវើរប្រ៊ីធីសកូឡុមប្បៀ
បានឧទ្ទិសឆ្លងនៅថ្ងៃទី 2 ខែ ឧសភា ឆ្នាំ 2010
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធ ហ្គីឡា វ៉ាលី អារីហ្សូណា
បានឧទ្ទិសឆ្លងនៅថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2010
ដោយប្រធាន ថូម៉ាស អេស ម៉នសុន



ព្រះវិហារបរិសុទ្ធ សេប៊ូ ហ្វីលីពិន
បានឧទ្ទិសឆ្លងនៅថ្ងៃទី 13 ខែ មិថុនា ឆ្នាំ 2010
ដោយប្រធាន ថូម៉ាស អេស ម៉នសុន

អ្នកអាចប្រើមេរៀន និងសកម្មភាពនេះដើម្បីរៀនសូត្របន្ថែម ទៀតពីបាវចនារបស់ថ្នាក់កុមារសម្រាប់ខែនេះ។

# ព្រះគម្ពីរទាំងឡាយ បង្រៀនខ្ញុំអំពី

# ការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ និងការយាងមកជាលើកទីពីររបស់ទ្រង់


គំនូរដោយ ប៉ុល ម៉ាន

**ដោយ ជែនទីហ្វើ ម៉ាឌី**
ទស្សនាវដ្ដីសាសនាចក្រ

*«ព្រោះកូនមនុស្សនឹងមក ក្នុងសិរីល្អនៃព្រះវរបិតា ជាមួយនឹងពួកទេវតារបស់លោក គ្រានោះ លោកនឹងសងដល់គ្រប់គ្នា តាមការដែលបាន ធ្វើរៀងខ្លួន» (ម៉ាយថាយ 16:27)*។

អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ពួកព្យាការី បានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ នឹងប្រសូតនៅលើផែនដី។ នៅក្នុងបទគម្ពីរ យើងអាចអាននូវអ្វីដែលពួកព្យាការីទាំងនេះ បាននិយាយ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ លោកអេសាយ បានមានប្រសាសន៍ថា ព្រះយេស៊ូវ នឹងធ្វើជាស្ដេចនៃមេត្រីភាព ហើយថាទ្រង់នឹងធ្វើជាសិរិសានៃសាសនាចក្រពិត។ នៅក្នុងព្រះគម្ពីរមរមន នីហ្វៃ បានមើលឃើញម្ដាយរបស់ព្រះយេស៊ូវ ម៉ារា នៅក្នុងការនិមិត្ត ហើយគាត់បានមើលឃើញព្រះយេស៊ូវ កំពុងតែបង្រៀនដល់មនុស្សនៅលើផែនដី។ ស្ដេចបេនយ៉ាមិន បានបង្រៀនដល់ប្រជាជនរបស់គាត់ អំពីអព្ភូតហេតុទាំងឡាយ ដែលព្រះគ្រីស្ទ នឹងធ្វើ នៅពេលទ្រង់យាងមកលើផែនដី។

រយៈពេលពីរបីឆ្នាំ មុនពេលព្រះអង្គសង្គ្រោះបានចាប់កំណើត ព្យាការីសាំយ៉ូអែល បានឈរនៅលើជញ្ជាំងថ្មមួយ ប្រកាសប្រាប់ដល់សាសន៍នីហ្វៃ អំពីទីសម្គាល់ទាំងឡាយ ដែលនឹងកើតមាន។ លោកបាននិយាយថា នៅពេលព្រះអង្គសង្គ្រោះ ចាប់កំណើតនោះនឹងមានផ្កាយមួយរះឡើងនៅលើមេឃ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងអាចអានអំពីផ្កាយដដែលនេះ—ដែលពួកហោរា បានដើរតាម ដើម្បីស្វែងរកព្រះគ្រីស្ទជាទារក។

នៅក្នុងបទគម្ពីរ ពួកព្យាការី ក៏បានបង្រៀនអំពីការយាងមកផែនដីជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទផងដែរ។ នៅក្នុងព្រះគម្ពីរមរមន ម៉ូរ៉ូណៃ ថ្លែងទីបន្ទាល់អំពីការយាងមកវិញរបស់ព្រះអង្គសង្គ្រោះ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ម៉ាឡាគី និយាយអំពីអ្វីដែលនឹងកើតឡើង នៅក្នុងថ្ងៃចុងក្រោយមុនពេលការយាងមកជាលើកទីពីរ។

បទគម្ពីរទាំងឡាយ មាននូវទីបន្ទាល់របស់ពួកព្យាការីអំពីព្រះយេស៊ូវគ្រីស្ទ មកពីជំនាន់ផ្សេងៗ គ្នាជាច្រើន នៅក្នុងប្រវត្តិសាស្ត្រ។ យើងក៏អាចអានអំពីគំរូរបស់ព្រះយេស៊ូវនៅក្នុងបទគម្ពីរទាំងឡាយផងដែរ។ យើងចាំបាច់ត្រូវធ្វើតាមគំរូរបស់ទ្រង់ នៅពេលយើងរៀបចំខ្លួន សម្រាប់ការយាងមករបស់ទ្រង់ ដើម្បីរស់នៅលើផែនដីម្ដងទៀត។

### សកម្មភាព

អ្នកអាចធ្វើសៀវភៅរូបភាពផ្ទាល់ខ្លួនរបស់អ្នកអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ។ សូមកាត់រូបភាពនៅទំព័រ 65។ ចោះរន្ធនៅលើទំព័រនីមួយៗ ត្រង់កន្លែងដែលបានប្រាប់ ហើយដាក់ទំព័រតាមលំដាប់។ ប្រើខ្សែចងទំព័រទាំងឡាយជាមួយគ្នាតាមរន្ធនោះ។ អ្នកអាចមើលក្នុងសៀវភៅនេះ ជាមួយគ្រួសាររបស់អ្នក អំឡុងពេលរាត្រីជួបជុំក្រុមគ្រួសារ ហើយពិភាក្សាអំពីជីវិតរបស់ព្រះអង្គសង្គ្រោះ។ ■


1


2


3


4


5


6


7


8


9



# ដើមបុណ្យគ្រីស្ទម៉ាស

**ដោយ ហៃរីត អរ អុជដូហ្វ**

ពេលសង្គ្រាមលោកលើកទី II ទើបតែបញ្ចប់ មនុស្សភាគច្រើននៅក្នុងប្រទេសអាល្លឺម៉ង់ មានអាហារ ឬ ប្រាក់កាសបន្តិចបន្តួច។ ថ្ងៃខួបកំណើតរបស់ខ្ញុំ នឹងមកដល់ក្នុងរយៈ ពេលពីរបីសប្ដាហ៍មុនពេលបុណ្យគ្រីស្ទម៉ាស។ ខ្ញុំមិនរំពឹងថាទទួលបានអំណោយបុណ្យគ្រីស្ទម៉ាស ឬ អំណោយថ្ងៃបុណ្យកំណើតណាមួយនោះទេ—ទោះជាខ្ញុំនៅក្មេង—ក្ដី ខ្ញុំបានដឹងយ៉ាងច្បាស់ថា ឪពុកម្ដាយរបស់យើង កំពុងតែជួបប្រទះនឹងបញ្ហាតម្រូវការចាំបាច់របស់យើង។ មានមនុស្សស្រេកឃ្លាន នៅក្នុងទីក្រុងដ៏ធំរបស់យើងជាប់ជានិច្ច។ វាគឺជាគ្រាដ៏សោកសៅ និង ងងឹតងងល់។

នៅថ្ងៃបុណ្យខួបកំណើតរបស់ខ្ញុំ ខ្ញុំមានការភ្ញាក់ផ្អើល និង រីករាយចិត្តជាខ្លាំង ដែលមានអំណោយដ៏អស្ចារ្យមួយ—សម្រាប់ខ្ញុំ—ដាក់នៅលើតុបាយ។ វាគឺជាអំណោយដ៏ល្អបំផុត ដែលខ្ញុំអាចនឹកស្មានដល់ ៖ កូនដើម *Weihnachtsbaum,* គ្រីស្ទម៉ាសដ៏តូចមួយដើម ដែលមានកម្ពស់តែ 30 សង់ទីម៉ែត្រប៉ុណ្ណោះ ព្រមទាំងបានគ្របដណ្ដប់ដោយក្រដាសសំណរតុបតែងធ្វើដោយដៃយ៉ាងប្រណិត។ ក្រដាសសំណរចាំងផ្លាតពន្លឺនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់យើង តាមរបៀបដ៏មនោរម្យ។ នៅពេលខ្ញុំពិនិត្យមើលក្រដាសសំណរដែលតុបតែងនោះ ខ្ញុំបានដឹងដោយមានភាពអស្ចារ្យថា វាមានដាក់ប្រេកពេញដោយស្កតាំងម៉ែតូចៗ។ វាគឺដូចជាអព្ភូតហេតុមួយ។ តើម្ដាយរបស់ខ្ញុំបានកូនដើមឈើតូចបៃតង ដែលរុំក្រដាសសំណរ និង ស្កុសដោយកម្រនោះមកពីណា?

មកដល់ថ្ងៃនេះ ខ្ញុំពុំដឹងថាគាត់បានធ្វើអព្ភូតហេតុនោះកើតឡើងនៅគ្រាដែលគ្មានរបស់មានតម្លៃទាំងនោះដោយរបៀបណានោះទេ។ វាស្ថិតនៅក្នុងដួងចិត្តរបស់ខ្ញុំជានិមិត្តសញ្ញាមួយអំពីសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ឪពុកម្ដាយខ្ញុំ ចំពោះខ្ញុំ ជានិមិត្តរូបមួយនៃសេចក្ដីសង្ឃឹម សេចក្ដីស្រឡាញ់ និង អត្ថន័យពិតនៃបុណ្យគ្រីស្ទម៉ាស។

អំឡុងពេលរដូវបុណ្យគ្រីស្ទម៉ាស យើងនៅតែមានដើមឈើបុណ្យគ្រីស្ទម៉ាសនោះនៅក្នុងផ្ទះរបស់យើងឥឡូវនេះ ត្រូវបានតុបតែងដោយពន្លឺភ្លើងអគ្គិសនី និង ការតុបតែងផ្សេងៗជាច្រើនទៀត។ នៅពេលយើងនៅជុំគ្នាជាមួយនឹងកូនៗ និង ចៅៗរបស់យើង នោះដើមឈើដ៏ស្រស់ស្អាតនេះ និង ពន្លឺភ្លើងបានកំដៅដល់ដួងចិត្តរបស់ខ្ញុំ ហើយបានរំឭកអំពីការចងចាំដ៏ផ្អែមល្ហែម នៃក្រុមគ្រួសារដ៏រីករាយមួយ ដែលកើតមកពីដើមឈើតូចដែលមានការតុបតែងនឹងក្រដាសសំណរភ្លឺផ្លេកៗ។ ■

*ហៃរីត អរ អុជដូហ្វ គឺជាភរិយារបស់ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ។*

*ចេញមកពី ហៃរីត អរ អុជដូហ្វ «‘Der Weihnachtsbaum’ ៖ Memories Linger of Small Tree»* Church News *ថ្ងៃទី 12 ខែ ធ្នូ ឆ្នាំ 2009 ទំព័រ 11។*



# គ្រឿងតុបតែងដោយដៃ

ចូរធ្វើឱ្យគ្រួសាររបស់អ្នកភ្ញាក់ផ្អើល តាមរយៈការឆ្នៃប្រឌិតគ្រឿងតុបតែងមួយចំនួនដោយដៃរបស់អ្នកផ្ទាល់! នេះគឺជាអ្វីដែលអ្នកត្រូវការ ៖

ពុម្ពនំសម្រាប់ធ្វើនំពិធីបុណ្យ ឬ កែវទឹកតូចមួយ
ក្រដាសរឹង ដូចជាក្រដាសកាតុង ឬ ប័ណ្ណប្រកាស
ខ្មៅដៃ
កន្ត្រៃ
ក្រដាសរុំអាលុយមីញ៉ូម (តាមជម្រើស)
ជ័រកាវពណ៌ស
ហ្វឺត (ឬ គូល័រទាន ឬ ខ្មៅដៃគូល័រ)
ខ្សែអំបោះ ខ្សែបូ ឬ ខ្សែ

1. ដានពុម្ពនំ ឬ កែវនៅលើក្រដាសរឹង។
2. សូមឱ្យឪពុកម្ដាយអ្នកជួយកាត់ចេញតាមរង្វង់។
3. ហែកក្រដាសសំណរផ្លេកមក ហើយប្រើវារុំនឹងក្រដាសដែលកាត់ចេញជារង្វង់នោះ។ បិទការនៅគែមនៃក្រដាសសំណរផ្លេកនៅពីខាងក្រោយគ្រឿងតុបតែងលំអរនោះ។ (បើអ្នកពុំប្រើក្រដាសសំណរផ្លេកទេ សូមរំលងជំហាននេះ ហើយធ្វើតាមជំហានបន្ទាប់)។
4. ដាក់ការតាមផ្នែកខាងមុខនៃគ្រឿងតុបតែងលំអរនោះ។ ចូរទុកឱ្យការស្ងួតស្រលប្លួលសិន។
5. ប្រើហ្វឺតដើម្បីផាត់ពណ៌នៅតាមចន្លោះតាមកន្លែងបិទការនោះ។ (បើសិនជាអ្នកពុំប្រើក្រដាសសំណរទេ អ្នកអាចប្រើគូល័រទៀន ឬ ខ្មៅដៃពណ៌ផងដែរ)។
6. ចូរឱ្យឪពុកម្ដាយរបស់អ្នកជួយចាក់រន្ធនៅខាងលើគ្រឿងតុបតែងលំអរនោះ។ ដាក់ខ្សែអំបោះ ខ្សែបូ ឬ ខ្សែតូចមួយ តាមរន្ធនោះ ហើយចងវានៅខាងលើ។
7. ព្យួរគ្រឿងតុបតែងលំអររបស់អ្នកនៅលើ ដើមឈើ *Weihnachtsbaum* របស់គ្រួសារអ្នក ឬ ឱ្យវាជា អំណោយដល់អ្នកដទៃ។





# មូលនិធិ បេសកកម្ម របស់ខ្ញុំ

**ដោយ ស្តែនស៊ី អេស.**

ខ្ញុំដឹងថារឿងនេះ អាចស្តាប់មើលទៅដូចជាចម្លែក ប៉ុន្តែខ្ញុំកំពុងតែសន្សំប្រាក់ ដើម្បីបង់ថ្លៃសម្រាប់បេសកកម្មរបស់ខ្ញុំ ចាប់តាំងពីមុនពេលខ្ញុំកើតមកម្ល៉េះ។ នៅពេលម្តាយខ្ញុំដឹងថា គាត់នឹងមានកូន គាត់បានយកកំប៉ុងទឹកដោះគោទទេមួយមក ចោះរន្ធមួយ ហើយដាក់ស្លាកថា «មូលនិធិបេសកកម្ម»។ ចាប់តាំងពីថ្ងៃនោះមក គ្រួសាររបស់ខ្ញុំ និងខ្ញុំបានសន្សំប្រាក់សម្រាប់បេសកកម្មរបស់ខ្ញុំ។

ការសន្សំប្រាក់សម្រាប់បេសកកម្មរបស់ខ្ញុំ គឺជាការប្រឹងប្រែងជាគ្រួសារ។ បន្ទាប់ពីខ្ញុំបានកើតមក ពូ និង មីងរបស់ខ្ញុំដែលបានមកលេង នឹងដាក់ប្រាក់ភេសូរបស់ប្រទេសហ្វីលីពីន ទៅក្នុងកំប៉ុងមូលនិធិបេសកកម្ម។ ហើយនៅពេលបុណ្យ ដូចជា បុណ្យគ្រីស្ទម៉ាស ឬ បុណ្យចូលឆ្នាំថ្មីមកដល់ សមាជិកគ្រួសារបានឱ្យប្រាក់មកខ្ញុំ ដើម្បីបន្ថែមទៅក្នុងមូលនិធិបេសកកម្មរបស់ខ្ញុំ។

ពេលខ្លះ លោកយាយលោកតារបស់ខ្ញុំផ្តល់ប្រាក់ដល់ខ្ញុំ ចំពោះការរៀនពូកែនៅសាលារៀន និង ការឈ្នះការប្រកួតប្រជែងនានា។ អំណោយទាំងនេះ ដាក់ទៅក្នុងមូលនិធិបេសកកម្មរបស់ខ្ញុំផងដែរ។ នៅពេលខ្ញុំបានទទួលមេដាយមួយចំនួន មីងរបស់ខ្ញុំបានរាប់មេដាយទាំងអស់ ដែលខ្ញុំបានទទួល ហើយបានឱ្យប្រាក់ដល់ខ្ញុំសម្រាប់មេដាយនីមួយៗ។ បន្ទាប់ពីខ្ញុំបានថ្វាយដង្វាយមួយភាគក្នុងដប់រួច ប្រាក់នេះក៏បានដាក់ទៅក្នុងមូលនិធិបេកកម្មរបស់ខ្ញុំផងដែរ។




នៅពេលខ្ញុំបានទទួលបុណ្យជ្រមុជទឹក បំណងប្រាថ្នារបស់ខ្ញុំដើម្បីបម្រើបេសកកម្មកើតមានកាន់តែខ្លាំង។ គ្រួសាររបស់ខ្ញុំបានដាក់គោលដៅសន្សំប្រាក់ឱ្យគ្រប់គ្រាន់ ដើម្បីបង់ថ្លៃបេសកកម្មរបស់ខ្ញុំពេញលេញ។ ដោយសារតែពេលឥឡូវនេះ ខ្ញុំមានបងប្អូន នោះប្រាក់ដែលយើងសន្សំក៏ត្រូវបានបន្ថែមទៅក្នុងមូលនិធិបេសកកម្មរបស់ពួកគេផងដែរ។

ឥឡូវខ្ញុំមានអាយុប្រាំបួនឆ្នាំហើយ ហើយជិតពាក់កណ្តាលនៃអាយុនេះ ខ្ញុំនឹងដល់អាយុដែលខ្ញុំបម្រើបេសកកម្មរបស់ខ្ញុំហើយ។ បំណងប្រាថ្នារបស់ខ្ញុំ ដើម្បីបម្រើបេសកកម្ម បានកើនឡើង ដោយសារតែខ្ញុំដឹងថាមានមនុស្សជាច្រើន ដែលបានបរិច្ចាគក្នុងមូលនិធិបេសកកម្មរបស់ខ្ញុំ។

ខ្ញុំនឹងបន្តសន្សំប្រាក់សម្រាប់បេសកកម្មរបស់ខ្ញុំ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ នឹងប្រទានពរដល់ខ្ញុំ ដើម្បីខ្ញុំអាចបម្រើទ្រង់ ជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ នៅថ្ងៃមួយ។ ■

រចនារូបភាពដោយ ប្រាយអិន ប៊ីន

# មាត្រានៃ សេចក្ដីជំនឿ

នៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

១ យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និង ដល់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ។

2 យើងខ្ញុំជឿថា មនុស្សទាំងអស់ នឹងត្រូវទទួលទោស ចំពោះអំពើបាបរបស់ខ្លួនផ្ទាល់ គឺមិនមែនចំពោះអំពើរំលងរបស់លោកអ័ដាមទេ។

3 យើងខ្ញុំជឿថា តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះ ដោយសារការគោរពតាមក្រឹត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ។

4 យើងខ្ញុំជឿថា គោលការណ៍ទីមួយ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អគឺៈ ទីមួយ សេចក្ដីជំនឿ ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទីពីរការប្រែចិត្ត ទីបីបុណ្យជ្រមុជទឹក ដោការពន្លិចសម្រាប់ការផ្ដាច់បាប ទីបួនការដាក់ដៃលើ សម្រាប់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ។

5 យើងខ្ញុំជឿថា មនុស្សត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍ និង ដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាច ដើម្បីនឹងផ្សាយដំណឹងល្អ ហើយប្រព្រឹត្តពិធីការទាំងឡាយនៃដំណឹងល្អ។

6 យើងខ្ញុំជឿចំពោះការរៀបចំដូចគ្នា ដូចដែលមាននៅក្នុងសាសនាចក្រពីអតីតកាល ដូចជាពួកសាវក ពួកព្យាការី ពួកគ្រូគង្វាល ពួកគ្រូ ពួកគ្រូផ្សាយដំណឹងល្អ ជាដើម។

7 យើងខ្ញុំជឿដល់អំណោយទានខាងភាសា ការព្យាករណ៍ វិវរណៈ ការនិមិត្ត ការប្រោសឱ្យជា ការបកប្រែភាសា ជាដើម។

8 យើងខ្ញុំជឿថា ព្រះគម្ពីរប៊ីប គឺជាព្រះបន្ទូលនៃព្រះ បើសិនជាបានបកប្រែត្រឹមត្រូវ យើងខ្ញុំក៏ជឿដែរថា ព្រះគម្ពីរមរមន ជាព្រះបន្ទូលនៃព្រះ។

9 យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ ដែលទ្រង់បានបើកសម្ដែងមក និង ការណ៍ទាំងអស់ ដែលទ្រង់បើកសម្ដែងនៅពេលឥឡូវនេះ ហើយយើងខ្ញុំជឿថា ទ្រង់នឹងបើកសម្ដែងនូវការណ៍ដ៏ធំ និង សំខាន់ៗជាច្រើន ដែល ទាក់ទងទៅនឹងនគរនៃព្រះ។

10 យើងខ្ញុំជឿចំពោះការប្រមូលដ៏ពិតប្រាកដ នៃសាសន៍អ៊ីស្រាអែល និងចំពោះការកសាងឡើងវិញ នូវពូជទាំង10អំបូរ ថាក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក ថាព្រះគ្រីស្ទ នឹងសោយរាជ្យនៅលើផែនដីផ្ទាល់ ហើយថាផែនដីនឹងបានផ្លាស់ប្ដូរសារជាថ្មី ហើយនឹងទទួលសិរីល្អដ៏ប្រកបដោយភាពបរមសុខ។

11 យើងខ្ញុំសូមអះអាងយកសិទ្ធិក្នុងការថ្វាយបង្គំព្រះដ៏មានមហិទ្ធិឫទ្ធិ ស្របតាមការណែនាំនៃសម្បជញ្ញៈរបស់យើងខ្ញុំ ហើយសូមបណ្ដោយឱ្យមនុស្សទាំងអស់មានសិទ្ធិដូចគ្នា ចូរឱ្យគេថ្វាយបង្គំតាមរបៀបណា នៅទីណា ឬអ្វីក៏ដោយ ដែលគេប្រាថ្នា។

12 យើងខ្ញុំជឿចំពោះការនៅក្រោមអំណាចស្ដេច ប្រធានាធិបតី អ្នកគ្រប់គ្រង និងចៅក្រមទាំងឡាយ ក្នុងការគោរពប្រតិបត្តិ និង ការគាំទ្រច្បាប់។

13 យើងខ្ញុំជឿលើការប្រព្រឹត្តដោយទៀងត្រង់ ត្រឹមត្រូវ បរិសុទ្ធ សប្បុរសគុណធម៌ ហើយលើការធ្វើល្អដល់មនុស្សទាំងអស់ ពិតមែនហើយ យើងខ្ញុំអាចនិយាយបានថា យើងខ្ញុំដើរតាមសេចក្ដីដាស់តឿនរបស់ប៉ុល—យើងជឿដល់អ្វីៗទាំងអស់ យើងខ្ញុំសង្ឃឹមដល់អ្វីៗទាំងអស់ យើងខ្ញុំបានទ្រាំទ្រអ្វីៗជាច្រើន ហើយសង្ឃឹមថានឹងអាចទ្រាំទ្រអ្វីៗទាំងអស់បានដែរ។ ហើយបើសិនជាមានអ្វីណាមួយដែលប្រកបដោយគុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬគួរឱ្យសរសើរ នោះយើងខ្ញុំស្វែងរករបស់ផងទាំងនេះហើយ។

យ៉ូសែប ស៊្មីធ។

© 2011 IRI។ រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅសហរដ្ឋអាមេរិក។ 1/11

# ដើមបុណ្យគ្រីស្ទម៉ាស់មួយប្រភេទទៀត

**ដោយ អ៊ីលីណា អូសប៊ីន**

ផ្អែកទៅលើដំណើររឿងពិត

*«ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ» (ម៉ាថាយ 11:29)។*















6. ជារៀងរាល់យប់បន្ទាប់ពីអាហារពេលល្ងាច អាវ៉ាសែលី និង ខាលូស បានធ្វើគ្រឿងតុបតែងផ្សេង ហើយដាក់ព្យួរនៅលើដើមឈើ។ ឪអីហ្គូ បានជួយដោយប្រាប់ដល់ពួកគេថា គាត់ស្រឡាញ់ព្រះយេស៊ូវ។



7. នៅពេលវាលំបាកគិតអំពីគំនិតថែមទៀត នោះពួកគេបានមើលនៅក្នុងខគម្ពីរ។ ខាលូស ពុំដឹងថា មានខជាច្រើននិយាយអំពីព្រះយេស៊ូវនោះទេ!



8. នៅយប់មុនបុណ្យគ្រីស្ទម៉ាស់ គ្រួសារទាំងមូល បានច្រៀងចម្រៀង ហើយបានអាននៅលើគ្រឿងតុបតែង ដែលពួកគេបានដាក់នៅលើដើមឈើ។ ខាលូស សប្បាយចិត្ត ដែលគាត់បានដឹងយ៉ាងច្រើនអំពីព្រះយេស៊ូវ។ គាត់បានដឹងថា គាត់បានត្រៀមខ្លួនជាស្រេចសម្រាប់បុណ្យគ្រីស្ទម៉ាស់ឆ្នាំនេះ។

## ចំណុចនៃភាពខុសប្លែក

កុមារទាំងនេះ កំពុងតែរៀនអំពីកំណើតរបស់ព្រះយេស៊ូវ គ្រីស្ទ តាមរយៈការដើរតួធ្វើជាអ្វីដែលបានកើតឡើង នៅពេលព្រះយេស៊ូវបានប្រសូតមក។ មើលបើសិនជាអ្នកអាចរកឃើញចំនុចខុសប្លែកចំនួនប្រាំបួន នៅចន្លោះគំនូរទាំងពីរនេះ។





ខាងឆ្វេង ៖ រចនារូបភាព ដោយ ភីលីស លុច



# រឿងនិទានបុណ្យគ្រីស្ទម៉ាស់



**ជំនួយសម្រាប់ឪពុកម្ដាយ**

សូមអានរឿងនៃបុណ្យគ្រីស្ទម៉ាស់ដំបូង នៅក្នុងលូកា 2។ នៅពេលអ្នកអាន សូមជួយដល់កូនរបស់អ្នកឱ្យស្ដាប់ព្រឹត្តការណ៍ដែលបានបង្ហាញនៅក្នុងរូបភាពទាំងពីរនេះ ហើយចំណាយពេលឱ្យកូនៗរបស់អ្នកផាត់ពណ៌។

ខាងស្ដាំ ៖ រចនា រូបភាព ដោយ បេស អិម វ៉ាយថេកឃើរ

© IRI

# ប្រធានបេសកកម្មថ្មីទាំងឡាយដែលបានប្រទានពរចំពោះការអនុវត្តន៍សេចក្ដីជំនឿ

**ដោយ ហ៊ីតធើរ វិតធល ហ្រ្វីត្ធី**
ទស្សនាវដ្ដីសាសនាចក្រ

កាលពីខែមិថុនា មានប្រធានបេសកកម្មថ្មីៗចំនួន 128នាក់ ព្រមទាំងភរិយារបស់ពួកលោកត្រូវបានអញ្ជើញឱ្យទៅកាន់មជ្ឈមណ្ឌលបំពាក់បំប៉ននអ្នកផ្សព្វផ្សាយសាសនានៅទីក្រុង ប្រ៉ូវ៉ូ រដ្ឋយូថាហ៍ សហរដ្ឋអាមេរិក ដើម្បីទទួលសេចក្ដីណែនាំពីមុនចាកចេញទៅកាន់ទីចាត់តាំងនានារបស់ពួកគេ ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានបើកសិក្ខាសាលារយៈពេលបួនថ្ងៃ ចាប់ពីថ្ងៃទី 22 ខែ មិថុនា ដល់ថ្ងៃទី 26 ខែ មិថុនា ឆ្នាំ 2011 ដោយមានប្រសាសន៍ថា « អ្នកទាំងអស់ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមពួកអ្នកស្មោះត្រង់បំផុតនៅក្នុងសាសនាចក្រ ហើយឥឡូវនេះអ្នកមានឱកាសដើម្បីចូលទៅក្នុងវាលច្រូតកាត់របស់ព្រះអម្ចាស់ ។ ... ខ្ញុំដឹងថាពុំមានវាលណាដែលផ្ដល់ក្លិនក្រអូប ឬផ្កាច្រើនជាងវាលបេសកកម្មដែលអ្នកត្រូវបានហៅនោះទេ » ។

គូស្វាមីភរិយាទាំងឡាយបានមកពីទូទាំងពិភពលោក—មាន 22 ប្រទេសខុសៗគ្នា—ហើយនឹងបម្រើទូទាំងពិភពលោកដែលមាន18ភាសា ។ ប្រវត្តិរូបរបស់ពួកគាត់ខុសៗគ្នា ប៉ុន្តែពួកគាត់មាននូវអ្វីមួយដែលដូចគ្នា ។

នៅពេលដែលពួកប្រធានបេសកកម្មថ្មីៗទាំងនេះ និងភរិយារបស់ពួកលោកដែលបានហៅនោះត្រូវបានធ្វើនូវការលះបង់ជាច្រើនដើម្បីរៀបចំទាំងខាងវិញ្ញាណ និងខាងសាច់ឈាម ពួកគាត់កំពុងតែឃើញនូវពរជ័យទាំងឡាយមកពីការអនុវត្តន៍សេចក្ដីជំនឿរបស់ពួកគាត់ភ្លាមៗ ។

## ការធ្វើការលះបង់ទាំងឡាយ

ការបម្រើជាប្រធានបេសកកម្ម គឺជាការចាត់តាំងដែលមានរយៈពេលបីឆ្នាំប្រកបដោយសេចក្ដីសប្បាយរីករាយខាងវិញ្ញាណ និងឧបសគ្គផងដែរ ។ នៅក្នុងការពុះពាររបស់ពួកគាត់ចំពោះការហៅនេះ មានស្វាមីភរិយាជាច្រើនគូរបានទុកវ័យចំណាស់ដ៏សំខាន់របស់ពួកគេ រួមទាំងការងារ និងក្រុមគ្រួសារទាំងឡាយរបស់ពួកគេចោលមួយអន្លើសិន ។

ការឈប់ពីការងារជំនាញអាចនាំទៅរកការខាតបង់ខាងហិរញ្ញវត្ថុ ។ ក្នុងខណៈពេលដែលសាសនាចក្រផ្ដល់ឱ្យប្រធានបេសកកម្មទាំងឡាយនូវប្រាក់ឧបត្ថម្ភសម្រាប់ការរស់នៅតិចតួច នោះជាធម្មតាគូស្វាមីភរិយាទាំងឡាយមាននូវមធ្យោបាយខាងហិរញ្ញវត្ថុផ្សេងទៀតដើម្បីបង្គ្រប់លើប្រាក់ឧបត្ថម្ភដោយខ្លួនរបស់ពួកគាត់ផ្ទាល់ ។

នៅពេលដែល ម៉ាឃើស ម៉ាទីន និងភរិយារបស់លោក ម៉ារៀន បានទទួលការហៅរបស់ពួកគាត់ទៅកាន់ បេសកកម្ម សៅ ប៉ូឡូណស្ស ប្រេស៊ីល, ឡាអ៊ីអេ ហាវ៉ៃ សហរដ្ឋអាមេរិក ចំពោះការស្នាក់នៅរបស់ពួកគាត់ត្រូវបានទទួលការប្រឹក្សាពី អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ថា ត្រូវតែមាននូវការលះបង់ ប៉ុន្តែលោកបានប្រាប់ពួកគាត់ថាកុំឱ្យលះបង់ច្រើនពេក ។

ក្រុមគ្រួសារ ម៉ាទីនបានទៅផ្ទះ ហើយអធិស្ឋានដើម្បីដឹងពីរបៀបដែលពួកគាត់អាចមានលទ្ធភាពដើម្បីទទួលយកឱកាសនេះ ។ ពួកគាត់បានលក់អ្វីៗទាំងអស់ ។ ស៊ីស្ទើរ ម៉ាទីនបាននិយាយថា « ជាពរជ័យ—យើងបានលក់អ្វីៗដាច់អស់ក្នុងរយៈពេលតែមួយថ្ងៃ ។ វាជាអព្ភូតហេតុមួយសម្រាប់យើង » ។

ពុំមែនទាំងអស់គ្នានោះទេដែលអាចលះបង់ខាងហិរញ្ញវត្ថុបាន ប៉ុន្តែគ្រប់ប្រធានបេសកកម្ម និងភរិយារបស់លោកនឹងប្រឈមមុខជាមួយនឹងការសាកល្បងខាងសេចក្ដីជំនឿឱ្យលះបង់បែបផ្សេងៗគ្នា ។

ចំពោះហ្គារី និងប៉ាមេឡា វ៉ាស្ទ័សិន មកពី ធូកសុន អារីហ្សូណា សហរដ្ឋអាមេរិក ទទួលការហៅឱ្យទៅបេសកកម្ម សេនដៃ ប្រទេសជប៉ុន ដោយត្រូវចាកចោលកូនៗទាំងប្រាំមួយនាក់ និងចៅៗទាំង 23 នាក់របស់ពួកគាត់ ។

ស៊ីស្ទើរ វ៉ាស្ទ័សិន បាននិយាយថា «ខ្ញុំដឹងថាព្រះវរបិតាសួគ៌អាចមើលថែកូនចៅបានល្អប្រសើរជាងខ្ញុំ ។ ដូច្នេះយើងរីករាយនឹងធ្វើការណ៍នេះ ហើយមានអារម្មណ៍ថាការណ៍នេះជាពរជ័យដ៏មហិមាដល់ពួកគេ » ។

មនុស្សដែលទទួលយកការហៅជាប្រធានបេសកកម្ម និងដៃគូរបស់ប្រធានបេសកកម្មបង្ហាញនូវឥរិយាបថដែលមានការលះបង់ប្រកបដោយឆន្ទៈ ។

ប្រធាន ម៉ាទីន បានមានប្រសាសន៍ថា « ពេលខ្លះខ្ញុំឆ្ងល់ថាតើអ្វីជាភាពជាក់លាក់ដែលត្រូវបានចាត់ទុកថាជាការលះបង់ ពីព្រោះអ្វីមួយដែលពិបាកខ្លាំងចំពោះបុគ្គលម្នាក់ហ្នឹង បែរជាងាយស្រួលចំពោះបុគ្គលម្នាក់ទៀត ។ ជាច្រើនដងនៅក្នុងជីវិតរបស់យើង ... យើងធ្លាប់បាននិយាយថា យើងនឹងដាក់ព្រះអម្ចាស់មុន និងថា សម្រាប់ព្រះអម្ចាស់យើងនឹងធ្វើអ្វីៗទាំងអស់ យើងនឹងទៅកន្លែងណាក៏បាន ។ ដូច្នេះយើងពុំបានគិតពីលក្ខខ័ណ្ឌនៃការលះបង់នោះទេ ។ ... វាគឺជាអភ័យឯកសិទ្ធិ វាគឺជាកិត្តិយសមួយក្នុងការលះបង់អ្វីៗគ្រប់យ៉ាង » ។



*ពួកប្រធានបេសកកម្មដែលទើបតែបានហៅទាំងឡាយចូលរួមវគ្គបំពាក់បំប៉នរយៈពេលបួនថ្ងៃនៅឯមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាក្នុងទីក្រុង ប្រូវ៉ូ រដ្ឋយូថាហ៍ សហរដ្ឋអាមេរិក ពីមុនពួកលោកចុះទៅតំបន់បេសកកម្ម ។*

## កំពុងត្រូវបានរៀបចំ

ក្នុងអំឡុងពេលពីមុនប្រធានបេសកកម្ម និងភរិយារបស់ពួកលោកចាប់ផ្ដើមការចាត់តាំងបេសកកម្មរបស់ពួកគេ មានទូវការរៀបចំខាងវិញ្ញាណនិងខាងសាច់ឈាមជាច្រើនកើតឡើង ។ ជាទូទៅប្រធានបេសកកម្មត្រូវបានហៅរយៈពេលប្រាំមួយខែមុន ប៉ុន្តែជាញឹកញាប់ពេលវេលានៃការរៀបចំនោះត្រូវបានកាត់បន្ថយ ។ ប្រែនត៍ និងអាននិ ស្កុត មកពីអេឌែនរដ្ឋយូថាហ៍ សហរដ្ឋអាមេរិក ត្រូវបានហៅឱ្យគ្រប់គ្រងបេសកកម្ម តូរ៉ុនតូប្រទេសកាណាដា ត្រឹមតែមួយសប្ដាហ៍មុនកម្មវិធីសិក្ខាសាលារបស់ប្រធានបេសកកម្ម ហើយមានតែពីខែប៉ុណ្ណោះពីមុនពួកគាត់ត្រូវចាប់ផ្ដើមការបម្រើរបស់ពួកគាត់ ។

ក្រៅពីការប្រាប់មិត្តភ័ក្តិ និងក្រុមគ្រួសារ ហើយនិងការព្យាយាមរៀបចំផ្ទះរបស់ពួកគាត់ ពួកគាត់បានសិក្សាសៀវភៅក្បួនខ្នាត ស្ដាប់ ស៊ី.ឌី ទាំងឡាយព្រមទាំងការរៀបចំខាងវិញ្ញាណផ្សេងៗទៀត ។ ប៉ុន្តែពួកគាត់បានមានប្រសាសន៍ថា ការរៀបចំដ៏អស្ចារ្យបំផុតរបស់ពួកគាត់គឺសិក្ខាសាលានៅឯអេម.ធី.ស៊ី ។

ប្រធាន ស្កុតបានមានប្រសាសន៍ថា « វាគឺជាការមុជចូលទៅក្នុងចំណេះដឹងខាងវិញ្ញាណមួយ ។ ការនៅក្នុងចំណោមក្រុមនៃមនុស្សដែលបាន [លះបង់ដើម្បីបម្រើព្រះអម្ចាស់] និងត្រូវបានបង្រៀនដោយពួកព្យាការី ពួកអ្នកមើលឆុត និងពួកអ្នកបើកសម្ដែង ... ពិតជាបទពិសោធន៍មួយដ៏អស្ចារ្យបំផុតនៃជីវិតរបស់យើង » ។

## ការរៀនទទួលប្រាជ្ញា

សិក្ខាសាលាដែលមានរយៈពេលបួនថ្ងៃនៅក្នុងខែមិថុនា ពួកប្រធានបេសកកម្ម និងភរិយារបស់ពួកលោកត្រូវបានផ្ដល់អាហារខាងវិញ្ញាណតាមរយៈសារលិខិតទាំងឡាយមកពីគណៈប្រធានទីមួយ និងសមាជិកទាំងឡាយនៃពួកកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

ស៊ីស្ទើរ ស្កុត បានមានប្រសាសន៍ថា « នៅពេលដែលយើងស្ដាប់ពួកលោក នៅពេលដែលពួកលោកបានបង្រៀនយើង [យើងមានអារម្មណ៍ថា] ព្រះអម្ចាស់គង់នៅទីនោះ ថាទ្រង់ខ្វល់ខ្វាយ ថានោះគឺជាកិច្ចការរបស់ទ្រង់ ថាពួកលោកគឺជាពួកអ្នកបម្រើរបស់ទ្រង់ ហើយថាយើងមានទូវអភ័យឯកសិទ្ធិដើម្បីចេញទៅ និងតំណាងឱ្យព្រះអង្គសង្គ្រោះរបស់យើង » ។

អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្ហាញទូវសេចក្ដីសង្ឃឹមរបស់លោកចំពោះពួកប្រធានបេសកកម្ម និងដៃគូរបស់ពួកលោកក្នុងការចេញទៅ ។

គាត់បានមានប្រសាសន៍ថា « សូមឱ្យអ្នកមានទូវសុខភាព សតិអារម្មណ៍ និងសុខភាពខាងវិញ្ញាណដ៏ល្អ [ព្រមទាំង] ជោគជ័យនៅក្នុងការរៀនសូត្របង្រៀន និងអនុវត្តតាមគោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ។ សេចក្ដីសង្ឃឹមរបស់ខ្ញុំរួមមាន សមត្ថភាពរបស់អ្នកក្នុងការប្រើអំណាចរបស់សមាជិកទាំងឡាយ ក្នុងការផ្ដោតទៅលើពិធីការនានា [និង] ធ្វើជាមនុស្សដែលនៅជាប់ជាមួយនឹងព្រះអម្ចាស់ ពួកសមាជិកនៃសាសនាចក្រ និងពួកអ្នកផ្សព្វផ្សាយសាសនាដ៏មានតម្លៃទាំងនោះ ដែលបានប្រគល់ឱ្យអ្នកថែទាំ » ។ ■

# បងប្អូនស្រីទាំងប្រាំពីរនាក់បញ្ជាំងពន្លឺរបស់ពួកគេនៅក្នុងតំបន់បេសកកម្ម

ផ្កាយកូនមាន់ ឬបងប្អូនស្រីទាំងប្រាំពីរនាក់ គឺជាក្រុមផ្កាយមួយនៃផ្កាយទាំងប្រាំពីរដែលស្ថិតនៅសែនឆ្ងាយ ដែលពន្លឺរបស់វាត្រូវការរយៈពេល 350 ឆ្នាំដើម្បីមកដល់ផែនដី ។

លំដាប់អាយុចាប់ពីម្ភៃស្តើងដល់សាមសិបក្រាស់ បងប្អូនស្រីទាំងប្រាំពីរនេះបានឱ្យពន្លឺរបស់ពួកគេរះចែងចាំងនៅក្នុងក្រុមគ្រួសាររបស់ពួកគេ និងនៅក្នុងតំបន់បេសកកម្ម នៅពេលដែលពួកគេចែកចាយដំណឹងល្អជាមួយនិងប្រជាជននៅក្នុងប្រទេសចំនួនប្រាំ ។

ម៉ារីសូល (ឈីលី អូសូរណូ), អានថូនា (អាហ្សង់ទីន វិស៊ីស្ទែនចា), ដានីអែលឡា (កូស្តារីកា សាន ចូសេ), ហ្វ្លរិនចា (ហុងឌូរ៉ា កូម៉ាយ៉ាហ្គែឡា), វេរ៉ូនីកា (ឈីលី សេនទីយ៉ាហ្គូ អ៊ុស្ទ) អាណៃ (ហ្គូតេម៉ាឡា ស៊ុ.ធី. ណាស្ស) និងបាលប៊ីណា ណាវ៉ា អាហ្គីឡា (អាហ្សង់ទីន បាហៀ ប្លែនកា) មកពីប្រទេសម៉ិកស៊ិកព្រមព្រៀងគ្នាចេញបម្រើបេសកកម្មសម្រាប់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយក្នុងពេលជាមួយគ្នា ។

ទំនាក់ទំនងដំបូងរបស់បងប្អូនស្រីទាំងនោះជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា អិល.ឌី.អេស គឺនៅពេលដែលពួកគេបានចាប់ផ្តើមចូលរៀនថ្នាក់ភាសាអង់គ្លេសដោយឥតគិតថ្លៃនៅក្នុងសាលាប្រជុំក្នុងមូលដ្ឋានមួយ ។ នៅក្នុងឆ្នាំ 2006 ពួកគេរួមជាមួយនឹងបងប្អូនប្រុសស្រីរបស់គេផ្សេងទៀត—ត្រូវបានទទួលបុណ្យជ្រមុជទឹក ។ ឪពុកម្តាយរបស់ពួកគេ អាលប៊ីណូ ណាវ៉ា និងអ៊ីស៊ីដ្រា អាហ្គីឡា ដែលបានចូលរួមក្នុងសាសនាចក្របីទសវត្សរ៍មុន បានត្រឡប់មកសកម្មវិញនៅពេលនោះ ។

ស៊ីស្ទើរ អាលហ្គីឡា បាននិយាយថា គាត់អាចមើលឃើញនូវសេចក្តីល្អដែលបានមកពីការបញ្ជូនកូនស្រីទាំងប្រាំពីរនាក់របស់គាត់ឱ្យចេញបេសកកម្ម ។

គាត់បាននិយាយថា « ពួកគេស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ធ្វើការ ប្រកាសដំណឹងល្អរបស់ទ្រង់ដើម្បីនាំព្រលឹងជាច្រើនទៀតឱ្យមកកាន់ [ទ្រង់] » ។

ហ្វ្លរិនចា បាននិយាយថា « ខ្ញុំស្រឡាញ់ដំណឹងល្អនេះ ហើយខ្ញុំដឹងថាកិច្ចការនេះផ្លាស់ប្តូរជីវិតទាំងឡាយ ។ វាបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ ហើយវានឹងផ្លាស់ប្តូរជីវិតអស់អ្នកទាំងឡាយដែលខ្ញុំបង្រៀន » ។

បងប្អូនស្រីទាំងនោះចាប់ផ្តើមត្រឡប់មកផ្ទះវិញនៅចុងឆ្នាំ 2011 ។ ■



រូបថតដោយ អារីណា ណាវ៉ា

*បងប្អូនស្រីមកពីប្រទេសម៉ិកស៊ិកទាំងប្រាំពីរនាក់នេះ កំពុងបម្រើបេសកកម្មពេញម៉ោងពេលជាមួយគ្នានៅផ្នែកខុសៗគ្នានៃពិភពលោក ។*

ពួកអ្នកមានសិទ្ធិអំណាចទូទៅសួរសុខទុក្ខសមាជិកទាំងឡាយនៃសាសនាចក្រទូទាំងពិភពលោកជាទៀងទាត់ ។ របាយការនៃការបម្រើរបស់ពួកលោកអាចរកបានតាមរយៈ news.lds.org ក៏ដូចជានៅលើ Prophets and Apostles Speak Today នៅ prophets.lds.org ជាភាសាអង់គ្លេស, បារាំង, អាល្លឺម៉ង់, អ៊ីតាលី, ព័រទុយហ្គាយ និងអេស្ប៉ាញ ។ នេះគឺជាការរៀបរាប់សង្ខេបអំពីដំណើរថ្មីៗរបស់ពួកលោក ។

- នៅថ្ងៃទី 26 ខែ ឧសភា ឆ្នាំ 2011 ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ទៅកាន់សហគមន៍ចំនួន 800 មានអ្នកជំនួញ និងពួកអ្នកដឹកនាំសាសនាជាច្រើននាក់ដែលបានចូលរួមនៅក្នុងក្រុមប្រឹក្សាកិច្ចការពិភពលោកទីក្រុង ឡូសអាន់ជើឡេស អង្គការដែលពុំមានការចូលរួមជាមួយនឹងក្រុមណានោះបានពុះពារដើម្បីបង្កើនការយល់ដឹងរវាងមនុស្ស និងមនុស្សនៅក្នុងពិភពលោក ។ ប្រធាន អុជដូហ្វ បានមានប្រសាសន៍អំពីការរីកចម្រើនរបស់សាសនាចក្រចាប់តាំងពីឆ្នាំ 1830 រហូតដល់បច្ចុប្បន្ននេះ ។ សូមស្រាវជ្រាវរក « Uchtdorf, Los Angeles » នៅ news.lds.org ។
- នៅថ្ងៃទី 5 ខែ មិថុនា ឆ្នាំ 2011 អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានរៀបចំស្តេក ម៉ូស្គូ រុស្ស៊ី ជាស្តេក—ដំបូងនៅក្នុងប្រទេសរុស្ស៊ី និងជាស្តេកទីពីរនៅក្នុងតំបន់ដែលគ្របដណ្តប់ដោយអតីតសហភាពសូវៀត ។ មានមនុស្សជាង 1,100នាក់បានចូលរួម ។ សូមស្រាវជ្រាវរក « Nelson, Moscow » នៅ news.lds.org ។
- នៅក្នុងខែឧសភា អែលឌើរ ជេហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចុះសួរសុខទុក្ខនៅក្នុងប្រទេសឥណ្ឌា ទីក្រុង ហុងកុង ( ជាកន្លែងដែលលោកមានអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចូលរួម ) និងបន្ទាប់មកគឺប្រទេស ម៉ុងហ្គោលី ។ សូមស្រាវជ្រាវរក « Holland, India » នៅ news.lds.org ។
- នៅថ្ងៃទី 15 ខែ មិថុនា ឆ្នាំ 2011 ប៊ីស្សពស្ដីទីអេក ដេវីឌ បើរតុន បានចុះសួរសុខទុក្ខ ហ៊ីហ្គាឈី ម៉ាស៊ុហ៊ីម៉ា ប្រទេស ជប៉ុន ដើម្បីវាយតម្លៃពីស្ថានភាពប្រទេស ចាប់តាំងពីការរញ្ជួយដីនៅថ្ងៃទី 11 ខែ មិនា និងព្យុះលលកសមុទ្រ និងដើម្បីពិនិត្យមើលការជួយសម្រាលរបស់សាសនាចក្រដែលបានផ្តល់ឱ្យនៅទីនោះ ។ សូមស្រាវជ្រាវរក « Burton, Japan » នៅ news.lds.org ។ ■

© IRI



*ឆាកវីដេអូថ្មីរបស់សាសនាចក្រនៅហ្គូស្សែន យូថាហ៍ នឹងត្រូវបានប្រើប្រាស់ដើម្បីថតឈុតទាំងឡាយចេញពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ ដូចដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។*

## ឆាកវីដេអូអំពីទីក្រុងយេរូសាឡិមបានឧទ្ទិសឆ្លង

ឆាកវីដេអូអំពីទីក្រុងយេរូសាឡិមបានសាងសង់ដោយសាសនាចក្រសម្រាប់ផលិតឈុតវីដេអូដំណឹងល្អនោះត្រូវបានឧទ្ទិសឆ្លង ហើយឥឡូវនេះកំពុងតែប្រើប្រាស់សម្រាប់ការថតវីដេអូ ។ មុនដំបូង វាត្រូវបានប្រើប្រាស់ដើម្បីបង្កើតគម្រោងបណ្ណាល័យព្រះគម្ពីរសញ្ញាថ្មី—ជាប្រភេទវីដេអូដែលពិពណ៌នាពីឈុតដ៏សំខាន់ៗចេញពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ និងពួកសាវក ។

ឆាកគឺស្ថិតនៅកន្លែងថតភាពយន្ត អេល.ឌី.អេស ភាគខាងត្បូង សហរដ្ឋអាមេរិក នៅក្នុងបរិវេណ ហ្គូស្សែន រដ្ឋយូថាហ៍ មានចម្ងាយតិចជាង 60 ម៉ាយល៍ ( 97 គីឡូម៉ែត្រ ) ភាគខាងត្បូងទីស្នាក់ការកណ្ដាលរបស់សាសនាចក្រក្នុងទីក្រុងសលត៍ លេក ។ វាពុំមែនជាការថតចម្លងមកពីទីក្រុងយេរូសាឡិមនោះទេ ប៉ុន្តែជាការបង្កើតជាថ្មីអំពីទីតាំងសំខាន់ៗទាំងឡាយនៅក្នុងទីក្រុង ។

ទីក្រុងហ្គូស្សែនដ៏តូចត្រូវបានជ្រើសរើសដោយសារតំបន់នៅព័ទ្ធជុំវិញស្រដៀងគ្នាទៅនឹងភូមិសាស្ត្រទីក្រុងយេរូសាឡិម—មានកូនភ្នំ, វាលទំនាប, ព្រៃដើមសេដា, ផ្កកខ្សាច់ និងអូរ ។ បឹងនៅក្បែររដ្ឋយូថាហ៍នឹងតំណាងឱ្យសមុទ្រកាលីឡេ ។

នៅក្នុងករណីខ្លះ គំនូរកុំព្យូទ័រនឹងធ្វើឱ្យរូបភាពមានលក្ខណៈលម្អិតពីឆាកដែលធ្វើឱ្យមិនត្រូវចិត្ត ។ ■

## គោលនយោបាយសម្រាប់អ្នកផ្សព្វផ្សាយសាសនាវ័យចំណាស់បានផ្លាស់ប្ដូរ

គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរទាក់បានធ្វើការអនុមតិលើការផ្លាស់ប្ដូរថ្មីៗ ស្ដីពីគោលនយោបាយដែលទាក់ទងទៅនឹងរយៈពេលនៃការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនាវ័យចំណាស់ និងអ្នកផ្សព្វផ្សាយសាសនានៅតាមផ្ទះ ដើម្បីលើកទឹកចិត្តឱ្យមានស្វាមីភរិយាច្រើនថែមទៀតចេញបម្រើបេសកកម្មពេញម៉ោង និងដើម្បីធ្វើឱ្យបទពិសោធន៍របស់ពួកគេកាន់តែប្រសើរឡើង ។

ចាប់ពីថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2011 តទៅ ស្វាមីភរិយាអាចធ្វើការបម្រើសម្រាប់រយៈពេល 6 ខែ, 12 ខែ, 18 ខែ ឬ 23 ខែបាន ។ បន្ថែមពីលើនោះ កញ្ចប់ថវិការ 1,400 ដុល្លារ (ដុល្លារអាមេរិក) ក្នុងមួយខែត្រូវបានបង្កើតឡើងសម្រាប់ថ្លៃផ្ទះ ។ គូស្វាមីភរិយាទាំងឡាយនឹងនៅតែបន្តចំណាយលើថ្លៃម្ហូបអាហារ និងការចំណាយផ្សេងៗទៀត ។

កាលពីអតីតកាល គោលនយោបាយត្រូវបានដាក់ថា គូស្វាមីភរិយាទាំងឡាយដែលបម្រើនៅខាងក្រៅប្រទេសកំណើតរបស់ពួកគេត្រូវបានហៅឱ្យបម្រើរយៈពេលយ៉ាងហោចណាស់ 18 ខែ ។ អ្នកទាំងឡាយដែលមានបំណងបម្រើនៅខាងក្រៅប្រទេសកំណើតរបស់ខ្លួនសម្រាប់រយៈពេលតិចជាង 18ខែ អាចធ្វើដូច្នោះបាននៅពេលនេះ ប្រសិនបើពួកគេបង់ថ្លៃធ្វើដំណើរទាំងទៅទាំងមកតំបន់បេសកកម្មដោយខ្លួនរបស់ពួកគេផ្ទាល់ ។

សំណួរទាំងឡាយអំពីបេសកកម្មវ័យចំណាស់អាចផ្ញើមកកាន់ seniormissionaryservices@ldschurch.org ■

## វិសាលភាពរបស់សាសនាចក្រផ្ដល់ឱ្យតាមប្រព័ន្ធអ៊ីនធឺណិតមានជាច្រើនភាសា

LDS.org កំពុងតែបង្កើនការផ្ដល់ឱ្យនូវភាសាទាំងឡាយរបស់វា ។ ថ្មីៗនេះមានគេហទំព័រភាសាថ្មីចំនួន 48 ត្រូវបានបន្ថែមលើគេហទំព័រផ្លូវការរបស់សាសនាចក្រ ។ ដោយចុចទៅលើភាសាដែលនៅខាងក្រោមបណ្ដាញភ្ជាប់ « Languages » ដែលស្ថិតនៅជ្រុងខាងស្ដាំ ផ្នែកខាងលើទំព័រណាមួយនៃ LDS.org នោះទស្សនិកជនអាចឃើញបណ្ដាញភ្ជាប់ទៅនឹងសម្ភារសាសនាចក្រដែលទើបតែមាននៅលើប្រព័ន្ធអ៊ីនធឺណិតជាភាសានោះ ។

ផ្នែកខុសៗគ្នានៃ LDS.org នឹងមានពី 10 ទៅ 15 ភាសា ។ នៅពេលនោះ ទំព័រភាសាសម្រាប់ភាសាទាំងនោះនឹងលែងប្រើ ។ (ឧទាហរណ៍ ពុំមានទំព័រជាភាសាអង់គ្លេស, បារាំង, អាល្លឺម៉ង់, អ៊ីតាលី, ព័រទុយហ្គាយ ឬអេស្ប៉ាញ ដោយសារតែភាសាទាំងនោះមានអ្វីៗជាច្រើនរួចហើយនៅក្នុង LDS.org ជាភាសារបស់វា) ។

ពួកបុគ្គលិកសាសនាចក្រក៏កំពុងតែធ្វើការបង្កើតទស្សនាវដ្ដី និងបកប្រែឯកសារផ្សេងទៀតពី LDS.org ដែលមានសម្រាប់ប្រព័ន្ធចល័ត ។ ■

# ព័ត៌មានសង្ខេបអំពីពិភពលោក

### ពិធីសម្ពោធន៍ព្រះវិហារបរិសុទ្ធ ហ្កេតហ្សាលទែនហ្គូ ពិធីឧទ្ទិសឆ្លងបានប្រកាស

ដើម្បីប្រារព្ធការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធហ្កេតហ្សាលទែនហ្គូ ប្រទេស ហ្គូតេម៉ាឡា យុវវ័យសាសនាចក្រនៅក្នុងប្រទេសនឹងចូលរួមនៅក្នុងការសម្ដែងតន្ត្រីវប្បធម៌ និងរបាំនៅថ្ងៃសៅរ៍ទី 10 ខែ ធ្នូ ឆ្នាំ 2011 ។

បន្ទាប់មកនៅថ្ងៃអាទិត្យ ទី 11 ខែ ធ្នូ ឆ្នាំ 2011 ព្រះវិហារបរិសុទ្ធនឹងត្រូវបានឧទ្ទិសឆ្លងជាបីវគ្គ ដែលនឹងត្រូវបានចាក់ផ្សាយទៅគ្រប់អង្គភាពទាំងអស់នៅក្នុងប្រទេស ហ្គូតេម៉ាឡា ។

បន្ទាប់ពីការឧទ្ទិសឆ្លង ព្រះវិហារបរិសុទ្ធនឹងបើកឱ្យធ្វើពិធីការនានានៅថ្ងៃអង្គារ ទី13 ខែ ធ្នូ ឆ្នាំ 2011 ។

### សាសនាចក្រសង្ឃឹមថានឹងបានសាងសង់ព្រះវិហារបរិសុទ្ធក្នុងប្រទេសបារាំង

ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសកាលពីខែកក្កដាថា សាសនាចក្រសង្ឃឹមថានឹងបានសាងសង់ព្រះវិហារបរិសុទ្ធដំបូងក្នុងប្រទេសបារាំងនៅលើដីមួយកន្លែងនៅជាយទីក្រុងប៉ារីស ។

សាសនាចក្របានធ្វើការជាច្រើនខែជាមួយនឹងមន្ត្រីរាជការប្រចាំមូលដ្ឋាន ។

កន្លងមកធ្លាប់ព្យាយាមស្វែងរកទីតាំងដែលសមគួរមួយកន្លែងដើម្បីសាងសង់ព្រះវិហារបរិសុទ្ធក្នុងប្រទេសបារាំង ប៉ុន្តែរកពុំដែលបាន ។ សមាជិកទាំងឡាយនៃសាសនាចក្រនៅក្នុងប្រទេសបារាំងដែលមានបំណងទៅកាន់ព្រះវិហារបរិសុទ្ធជាធម្មតាត្រូវធ្វើដំណើរទៅកាន់ប្រទេសជិតខាងនៅក្នុងទ្វីបអឺរ៉ុប ។

### ទម្រង់បែបបទថ្មីដើម្បីស្ដាប់បទគម្ពីរទាំងឡាយកំពុងបង្កើននូវភាពងាយស្រួល

សាសនាចក្របានបញ្ចេញកំណែទម្រង់ស្ដាប់ថ្មីមួយចេញពីបទដ្ឋានព្រះគម្ពីរ អិល.ឌី.អេស ដើម្បីទាញយកនៅលើ iTunes នៅក្នុង audiobook (ដែលហៅថា « enhanced audio content » នៅលើ iTunes) ឬទ្រង់ទ្រាយ MP3 ។

កំណែទម្រង់សោតទស្សន៍នៃបទដ្ឋានព្រះគម្ពីរពេញលេញមានជាភាសាអង់គ្លេស និងអេស្ប៉ាញ និងកំណែទម្រង់សោតទស្សន៍ជាភាសា ជប៉ុន, ព័រទុយហ្គាយ និងព្រះគម្ពីរទាំងបីជាភាសាកូរ៉េ ក៏មានផងដែរ ។

ដើម្បីចូលទៅកាន់ធនធានថ្មីទាំងនេះ សូមចូលទៅកាន់វគ្គបទគម្ពីររបស់ប៉ុស្ដិ៍សាសនាចក្រនៅ iTunes.lds.org ។ ■

*កំណែទម្រង់សោតទស្សន៍នៃបទដ្ឋានព្រះគម្ពីរឥឡូវនេះមានភាសាជាច្រើននៅ **iTunes.lds.org** ។*



## សេចក្ដីអធិប្បាយ

### ខ្ញុំត្រូវបានឈ្នះដោយការដឹងគុណ

សម្លេងពួកបរិសុទ្ធថ្ងៃចុងក្រោយតែងតែជាអត្ថបទមួយនៃអត្ថបទទាំងឡាយដែលខ្ញុំបើកអាននៅពេលដែលទស្សនាវដ្ដីខែនីមួយៗមកដល់ ។ ដូចជាករណីដែលខ្ញុំបានអាន « You Were the Angels » (*លីអាហូណា* ខែ ធ្នូ ឆ្នាំ 2010 ទំព័រ 38) ។ អត្ថបទនោះបានជះឥទ្ធិពលមកលើខ្ញុំ ប្រកបដោយព្រះចេស្ដាខាងវិញ្ញាណដ៏មហិមា ហើយខ្ញុំបានឈ្នះដោយការដឹងគុណចំពោះបេសកកម្មរបស់ព្រះអង្គសង្គ្រោះ និងចំពោះអ្នកទាំងឡាយដែលបម្រើដោយពុំមានភាពអាត្មានិយមនៅក្នុងព្រះនាមរបស់ទ្រង់ ។ ខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ហ៊ិឌី វិនឌិស្ស ហ្វើណេនឌេស្ស សម្រាប់ការចែកចាយបទពិសោធន៍ដ៏អស្ចារ្យរបស់នាង ។

**ឡារី ឌី ខឹម មកពី រដ្ឋវេសថ៍វើរជិនញា សហរដ្ឋអាមេរិក**

### *លីអាហូណា* ធ្វើឱ្យមានភាពខុសគ្នា

សារលិខិតមកពី *លីអាហូណា* តែងតែបានគាំទ្រខ្ញុំក្នុងនាមជាបុគ្គល, ជាឪពុក, ជាស្វាមី និងជាអ្នកដឹកនាំមួយរូប ហើយឯកសារសន្និសីទទូទៅនាំមកនូវវិញ្ញាណពិសេសមកកាន់គេហដ្ឋានរបស់យើង ។ ខ្ញុំតែងតែបញ្ជាទិញឯកសារសន្និសីទដោយឡែកពីគ្នាសម្រាប់ខ្លួនខ្ញុំ, ភរិយារបស់ខ្ញុំ និងកូនប្រុសខ្ញុំម្នាក់ៗ ដើម្បីឱ្យយើងអាចអាន និងគូសចំណាំសារលិខិតទាំងឡាយតាមដែលយើងចង់ដោយពុំចាំបាច់រង់ចាំអានទស្សនាវដ្ដីម្នាក់ម្ដង ។ នៅចុងឆ្នាំយើងផ្ដុំទស្សនាវដ្ដី និងឱ្យទស្សនាវដ្ដីដែលនៅសល់ដល់សមាជិកពុំសូវសកម្ម ឬមិត្តភ័ក្ដិដែលពុំមែនជាសមាជិក ។ ខ្ញុំសុំថ្លែងទីបន្ទាល់ថា *លីអាហូណា* ធ្វើឱ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់យើង ។

**ហ្វាប៊ីយ្យូ អាល់លេហ្រ្គេតទី គូភើរ ប្រទេសប្រេស៊ីល**

*សូមផ្ញើយោបល់កែលម្អ ឬសំណូមពររបស់អ្នកទៅកាន់ liahona@ldschurch.org ។ ការដាក់ស្នើអាចនឹងត្រូវធ្វើការកែសម្រួល ដោយព្រោះវែងពេក ឬដើម្បីភាពច្បាស់លាស់ ។* ■

## គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះគឺមានទូវអត្ថបទ និងសកម្មភាពទាំងឡាយ ដែលអាចយកមកប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន ។*

**« ការបម្រើរបស់ខ្ញុំក្នុងនាមជាសមាជិកទោល »** ទំព័រ 12 ៖ បន្ទាប់ពីអានសាច់រឿងរបស់ស៊ីស្ទើរ ប៊េីរខែត ចូរពិចារណាពីការពិភាក្សាពីពរជ័យទាំងឡាយដែលបានមកពីការបម្រើនៅក្នុងសាសនាចក្រ ។ អ្នកអាចអញ្ជើញសមាជិកក្រុមគ្រួសារឱ្យចែកចាយពីបទពិសោធន៍ដែលប្រកបដោយអត្ថន័យដែលពួកគេមានក្នុងខណៈពេលកំពុងបម្រើនៅក្នុងការហៅណាមួយ ។

**« សេចក្ដីសុខសាន្ត និងសេចក្ដីអំណរមកពីការស្គាល់ជីវិតរបស់ព្រះអង្គសង្គ្រោះ »** ទំព័រ 18 ៖ សូមពិចារណាពីការសួរសមាជិកគ្រួសារពីអ្វីដែលពួកគេអាចធ្វើបានសម្រាប់ព្រះអង្គសង្គ្រោះនៅឆ្នាំក្រោយ ។ សូមអានកថាខណ្ឌចុងក្រោយនៃអត្ថបទនៅខាងក្រោម « អំណោយរបស់យើងដល់ទ្រង់ » ។ តើអែលឌើរ ណិលសុន និយាយអ្វីដែលជាអំណោយដ៏ល្អបំផុតដែលយើងអាចថ្វាយព្រះអម្ចាស់បាន ?

**« មក ចូរយើងសរសើរដំកើងទ្រង់, »** ទំព័រ 42 ៖ ពីមុនមេរៀន សូមជ្រើសរើសវគ្គណាមួយ ឬវគ្គទាំងឡាយដែលអនុវត្តល្អបំផុតនៅក្នុងក្រុមគ្រួសាររបស់អ្នក ។ ប្រសិនបើអ្នកជ្រើសរើសវគ្គអំពីពួកអ្នកគង្វាលចៀម អ្នកអាចចែកចាយការប្រឹក្សារបស់ប្រធាន ម៉នសុន « ពុំត្រូវពន្យារពេលនៃការធ្វើតាមការបំផុសគំនិត » ហើយពិភាក្សាជាមួយនឹងក្រុមគ្រួសាររបស់អ្នកពីភាពអស្ចារ្យនៃការលើកឡើងនេះ ។ ដើម្បីចង្អុលបង្ហាញចំណុចនេះជាមួយនឹងកូនៗដែលនៅតូច ចូរខ្ទប់ដាក់ត្រចៀករបស់ពួកគេ និងលើកទឹកចិត្តពួកគេឱ្យធ្វើតាម ។



**« ជួបជាមួយបងប្រុស យ៉ូសែប »** ទំព័រ 58 ៖ សូមពិចារណាពីការបង្ហាញរូបភាពរបស់យ៉ូសែប ស្មិធនៅពេលដែលអ្នកអានតារាងនៃហេតុការណ៍ពិតទាំងឡាយរបស់គាត់ចេញពីអត្ថបទ ។ អ្នកអាចលេងល្បែងកម្សាន្តបន្ទាប់ពីមេរៀន ដើម្បីមើលពីរបៀបដែលហេតុការណ៍ពិតជាច្រើនដែលក្រុមគ្រួសាររបស់អ្នកអាចចងចាំបាន ។

**« *ពាក្យទាំងនោះ* »** ទំព័រ 60 ៖ បន្ទាប់ពីអានសាច់រឿងជាក្រុមគ្រួសារ សូមពិចារណាពីការពិភាក្សាពីអ្វីសមាជិកគ្រួសារអាចនិយាយបាន ប្រសិនបើមាននរណាម្នាក់នៅជុំវិញពួកគេប្រើភាសាពុំគប្បី ។ អ្នកក៏អាចពន្យល់ដល់កូនតូចៗពីមូលហេតុដែលយើងត្រូវបានបញ្ជារនៅក្នុង និក្ខមនំ 20:7 កុំឱ្យចេញព្រះនាមព្រះយេហូវ៉ាជាអសារឥតការឡើយ (សូមមើលផងដែរ គ. និង ស. 63:60–64) ។ ■

### ការចែកចាយការសន្ទនា និងព្រះវិញ្ញាណ

នៅពេលដែលខ្ញុំនៅក្នុងវួដមជ្ឈិមវ័យវ័យក្មេង ខ្ញុំមានរាត្រីជួបជុំក្រុមគ្រួសារជាមួយនឹងក្រុមគ្រួសារវួដរបស់ខ្ញុំ ។ រាត្រីក្រុមគ្រួសារមួយដែលខ្ញុំធ្លាប់បានចូលរួមដោយពុំអាចភ្លេចបានគឺជារាត្រីក្រុមគ្រួសារនាយប់មួយដែលដឹកនាំដោយពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។

ពួកអែលឌើរបានអញ្ជើញពួកអ្នកប្រែចិត្តជឿនៅក្នុងវួដរបស់យើងជាច្រើននាក់ឱ្យចែកចាយពីសាច់រឿងទាំងឡាយអំពីការផ្លាស់ប្រែចិត្តជឿរបស់ពួកគេ ។ នៅពេលដែលពួកអ្នកប្រែចិត្តជឿបាននិយាយ នោះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធបានគង់នៅដោយពុំអាចបដិសេធបាន ។

បន្ទាប់ពីសាច់រឿងត្រូវបានចែកចាយចប់ គំនិតរបស់ខ្ញុំបានត្រឡប់ទៅរកបទពិសោធន៍ជាអ្នកផ្សព្វផ្សាយផ្ទាល់ខ្លួនរបស់ខ្ញុំ—ក្នុងនាមជាអ្នកផ្សព្វផ្សាយពេញម៉ោង និងអំឡុងពេលរស់នៅ ។ ខ្ញុំបានវាយតម្លៃសកម្មភាពរបស់ខ្ញុំសាជាថ្មីក្នុងការចែកចាយដំណឹងល្អពីមួយថ្ងៃទៅមួយថ្ងៃ និងបានបន្ដុះបញ្ជាំងពីសកម្មនោះជាច្រើនសប្ដាហ៍ក្រោយមកទៀត ។

ក្រោយមកទៀតនៅពេលដែលខ្ញុំត្រូវបានហៅឱ្យដឹកនាំរាត្រីជួបជុំក្រុមគ្រួសារនៅក្នុងវួដ ខ្ញុំបានសម្រេចចិត្តបន្ត « សាច់រឿងអ្នកផ្លាស់ប្រែចិត្តជឿ » យូរៗម្ដងមានសកម្មភាព សុំឱ្យពួកអ្នកផ្លាស់ប្រែចិត្តជឿផ្សេងទៀតនៅក្នុងវួដឱ្យចូលរួម ។ ■

**ជែនណា ម៉ៃហ្វើសុន កាលីហ្វូញ៉ា សហរដ្ឋអាមេរិក**

# ពន្លឺនៃព្រះរាជបុត្រា



ពន្លឺជួយយើងមើលឃើញសេចក្ដីពិត—ហើយមើលឃើញវាកាន់តែច្បាស់។

រូបថតដោយ ដាវីដ ស្ទូក

**ដោយ ដេហ្វ អេស ម៉ាក់អិនតុស**

បន្ទាប់ពីធ្វើការនៅក្នុងហាងលក់សំលៀកបំពាក់បុរសដ៏ធំអស់រយៈ ពេលជាច្រើនឆ្នាំមក ខ្ញុំបានក្លាយជាអ្នកជំនាញនៅក្នុងការសម្របសម្រួលអាវ និង ក្រវ៉ាត់ក ជាមួយនឹងអាវធំដែលខ្ញុំបានលក់។ វាគឺជារង្វាន់ដើម្បីរើសយកវាដាក់ជាក្រុមដ៏ស្អាតឥតខ្ចោះ ហើយជាធម្មតា អតិថិជនរបស់ខ្ញុំ សប្បាយចិត្តជាមួយនឹងជម្រើសដែលខ្ញុំរើសបង្ហាញដល់ពួកគេ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងហាងមួយ អាវធំ ស្ថិតនៅក្នុងកន្លែងមួយ ដែលដាក់តាំងក្រោមពន្លឺភ្លើងពណ៌ស្រទន់ឆ្ងាយពីគេ ខណៈដែលអាវ និង ក្រវ៉ាត់ក បានដាក់តាំងនៅកន្លែងផ្សេងទៀត នៅក្រោមពន្លឺភ្លើងភ្លឺចិញ្ចាច។ ភាពខុសគ្នានៅក្នុងពន្លឺនេះ បានបង្ហាញជាការប្រឈមមុខ។

ជាញឹកញាប់ វាបានកើតឡើង បន្ទាប់ពីអតិថិជន បានសម្រេចចិត្តយកខោអាវធំមួយកំផ្លេ ឬពីរកំផ្លេរហើយ ខ្ញុំបានទៅជ្រើសរើសអាវ និង ក្រវ៉ាត់ក ដែលខ្ញុំគិតថានឹងត្រូវគ្នាយ៉ាងល្អ។ ប៉ុន្តែនៅពេលអាវ និង ក្រវ៉ាត់ក បានយកចេញមកពីកន្លែងនោះ ទៅកន្លែងផ្សេង ហើយបានដាក់នៅជិតនឹងអាវធំ ជាលទ្ធផលគឺគួរឱ្យភ្ញាក់ផ្អើល—ព្រោះពណ៌«បានផ្លាស់ប្ដូរ» នៅក្នុងពន្លឺភ្លើងថ្មី ហើយពុំត្រូវពណ៌គ្នាសោះ។

ពេលយកអាវធំទៅដាក់កន្លែង ដែលបានដាក់តាំងអាវ និង ក្រវ៉ាត់ក គឺត្រូវគ្នាយ៉ាងល្អ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ជាញឹកញាប់ អតិថិជនមានការភាន់ច្រឡំ ដោយកត់សម្គាល់ថា អាវធំដែលយើងកាន់នៅក្នុងដៃ មើលទៅពុំដូចជាអាវធំមួយ ដែលពួកគេទើបតែរើសនោះ។ អាវធំ ដែលមើលឃើញថា ជាពណ៌បៃតងអូលីវ នៅក្រោមពន្លឺភ្លើងពណ៌ស្រទន់ ឥឡូវបែរទៅជាពណ៌ប្រផេះ ខ្មៅងងឹត ឬពណ៌ត្នោតនៅពេលមើលនៅក្រោមពន្លឺភ្លើងចាំងច្បាស់។ អាវធំពណ៌ខ្មៅ ពណ៌ផ្សង និង ពណ៌ទឹកប៊ិចចាស់ មើលទៅមានការផ្លាស់ប្ដូរស្រដៀងគ្នានេះ។

ជាញឹកញាប់ ខ្ញុំត្រូវដោះស្រាយបញ្ហា ដោយការនាំអតិថិជនចេញទៅជិតទ្វារ ដើម្បីមើលអំពីការជ្រើសរើសរបស់ពួកគេនៅក្រោមពន្លឺថ្ងៃ។ ពេលមើលដោយពន្លឺព្រះអាទិត្យ នោះយើងអាចមើលឃើញពណ៌ពិតភ្លាម ហើយបានធ្វើការជ្រើសរើសបានត្រឹមត្រូវ។

នៅក្នុងពិភពលោកពិតខាងក្រៅហាង យើងបានប្រឈមមុខនឹងការជ្រើសរើសជារៀងរាល់ថ្ងៃ។ ពេលខ្លះ ការជ្រើសរើសទាំងនោះត្រូវបានធ្វើឱ្យសាកពណ៌ តាមរយៈគំនិតរបស់មនុស្ស។ អ្នកដទៃទៀតត្រូវបានបាំងដោយការល្បួងនៃពិភពលោកនេះ។ ជម្រើសជាច្រើនដែលបានដាក់នៅចំពោះមុខយើង អាចមើលទៅហាក់ដូចជាពុំត្រឹមត្រូវជានិច្ចនោះទេ ឬ យើងអាចនឹងភាន់ច្រឡំអំពីភាពពិត ឬ មិនពិត។ យើងអាចនឹងងឿងឆ្ងល់អំពីរបៀបដើម្បីមើលដឹងអំពីភាពពិតរបស់វា។

ខ្ញុំបានរកឃើញថា ជាដំណោះស្រាយ គឺត្រូវមើលទៅលើជម្រើសទាំងនោះជាមួយនឹងពន្លឺ ឬជាឧទាហរណ៍ ជាមួយនឹងពន្លឺនៃព្រះរាជបុត្រា ត្បិតទ្រង់បានសន្យាថា «ហើយ *យើង*ក៏នឹងទៅជា*ពន្លឺ*របស់អ្នករាល់គ្នា នៅក្នុងទីរហោស្ថានដែរ ហើយយើងនឹងរៀបចំផ្លូវសម្រាប់អ្នករាល់គ្នា បើសិនជា អ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ... ហើយអ្នករាល់គ្នា នឹងដឹងថា គឺយើងនេះហើយដែលបាននាំអ្នករាល់គ្នាទៅ» (នីហ្វៃទី 1 17:13 គូសបញ្ជាក់បន្ថែម)។

ការព្យាយាមដើម្បីជ្រើសរើសដោយពន្លឺពិត នឹងជួយយើងធ្វើការជ្រើសរើសត្រឹមត្រូវ សម្រាប់ ក្រុមគ្រួសាររបស់យើង និង ខ្លួនយើងផ្ទាល់។ ហើយតាមរយៈការមើលទៅព្រះ តាមរយៈការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ នោះយើងនឹងពុំត្រូវបានបញ្ឆោតឡើយ ប៉ុន្តែនឹងបានដឹងខុសនឹងត្រូវ (សូមមើលម៉ូរ៉ូណៃ 7:16)។

នៅពេលយើងធ្វើការជ្រើសរើសដើម្បីដើរតាមទ្រង់ នោះព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង បានសន្យាថានឹងចែកចាយពន្លឺរបស់ទ្រង់ជាមួយនឹងយើង ៖ «អ្វីដែលមកពីព្រះជាពន្លឺ ហើយអ្នកណាដែលទទួលពន្លឺ ហើយនៅជាប់ក្នុងព្រះ នោះទទួលពន្លឺបន្ថែមទៀត ហើយពន្លឺនោះភ្លឺកាន់តែខ្លាំងឡើងៗ រហូតដល់ថ្ងៃបានល្អឥតខ្ចោះ» (គ. និង ស. 50:24)។ ■




ក្នុងរង្វង់ដៃរបស់ម៉ារា ដោយ សាញមិន ឌូវី

*«មើលចុះ យើងនឹងមកឯរាស្ត្រយើងដើម្បីបំពេញនូវការណ៍ទាំងអស់ ដែលយើងបានប្រាប់ដល់កូនចៅមនុស្សចាប់តាំងពីកំណើតលោកិយមក ហើយដើម្បីធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា និងព្រះរាជបុត្រា—ព្រះហឫទ័យនៃព្រះវរបិតាពីព្រោះតែយើង ហើយព្រះហឫទ័យនៃព្រះរាជបុត្រាពីព្រោះសាច់របស់យើង។ ហើយមើលចុះ ពេលនោះនៅជិតដែបង្កើយ ហើយយប់នេះទីសម្គាល់នឹងមកហើយ» (នីហ្វៃទី3 1:14)។*



*«ខ្ញុំសូមថ្លែងទីបន្ទាល់ថាព្រះយេស៊ូវដ៏ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រាដ៏ទេវភាពនៃព្រះដែលមានព្រះជន្មរស់» សរសេរដោយអែលឌើរ រ៉ សុល អិម ណិលសុននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់។ «ទ្រង់នឹងស្រឡាញ់អ្នក លើកអ្នកឡើង និងសម្តែងខ្លួនដល់អ្នកប្រសិនបើអ្នកនឹងស្រឡាញ់ទ្រង់ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ (សូមមើល យ៉ូហាន 14:21)។ ពិតណាស់ បុរស និង ស្ត្រីឈ្លាសវៃនៅតែគោរពស្រឡាញ់ទ្រង់»។ សូមមើល «សេចក្តីសុខសាន្ត និងសេចក្តីអំណរមកពីការដឹងពីជីវិតរបស់ព្រះអង្គសង្គ្រោះ» ទំព័រ 18។*

CAMBODIAN
4 02096 92258 5